Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

61694

ធនាគារពិភពលោក

# ប្រទេសកម្ពុជាបង្កើនប្រសិទ្ធភាពចំណាយរបស់រដ្ឋាភិបាល ដើម្បីកំណើនខ្ពស់ និងមានមូលដ្ឋានទូលាយជាងមុន

## ការវាយតំលៃចំរុះលើទំនុកចិត្ត និងការពិនិត្យសើរើឡើងវិញ លើចំណាយសាធារណៈ (IFAPER)












ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១

ផ្នែកកាត់បន្ថយភាពក្រីក្រ និងគ្រប់គ្រងសេដ្ឋកិច្ច
តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក

**ឆ្នាំសារពើពន្ធរបស់រដ្ឋាភិបាល**

ថ្ងៃទី ១ មករា - ៣១ ធ្នូ

**សមមូលជារូបិយប័ណ្ណ**

( អត្រាប្តូរប្រាក់គិតត្រឹមថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១១)

ឯកតារូបិយវត្ថុ : ប្រាក់រៀលកម្ពុជា (CR)

១ ដុល្លារអាមេរិក = ៤.០៧៨ រៀល

**ទម្ងន់ និងរង្វាស់**

ប្រព័ន្ធរង្វាស់ទសភាគ

| | |
|---|---|
| អនុប្រធាន | James W. Adams |
| នាយកប្រចាំប្រទេស | Annette Dixon |
| ប្រធានសេដ្ឋវិទូ និងប្រធានវិស័យ | Vikram Nehru |
| ប្រធានគ្រប់គ្រងប្រចាំប្រទេស | Qimiao Fan |
| សេដ្ឋវិទូចម្បង | Mathew A. Verghis |
| ប្រធានក្រុមការងារ | Ivailo Izvorski/Leah April |

# ពាក្យកាត់ និងអក្សរកាត់

| | |
|---|---|
| **AOPs** | ផែនការប្រតិបត្តិការប្រចាំឆ្នាំ |
| **ASSDP** | ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រវិស័យកសិកម្ម |
| **BCR** | អនុបាតផលចំណេញ-ការខាតបង់ |
| **BSP** | ផែនការយុទ្ធសាស្ត្រថវិកា |
| **CAR** | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| **CDC** | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| **CESSP** | គម្រោងគាំទ្រវិស័យអប់រំកម្ពុជា |
| **CMDG** | គោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្ស |
| **CMS** | ឃ្លាំងឱសថកណ្តាល |
| **COA** | ប្លង់គណនេយ្យ |
| **CSF** | មូលនិធិឃុំ/សង្កាត់ |
| **D&D** | វិមជ្ឈការ និងវិសហមជ្ឈការ |
| **DFID** | នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (អង់គ្លេស) |
| **ECE** | ការអប់រំកុមារតូច |
| **EDB** | ការិយាល័យឱសថសារវន្ត |
| **EMIS** | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងការអប់រំ |
| **ESP** | ផែនការយុទ្ធសាស្ត្រអប់រំ |
| **EFA FTI** | គំនិតផ្តួចផ្តើមបែបរហ័សអំពីការអប់រំសម្រាប់ទាំងអស់គ្នា |
| **FMIS** | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ |
| **FWUCs** | សហគមន៍កសិករប្រើប្រាស់ទឹក |
| **GDP** | ផលិតផលក្នុងស្រុកសរុប (ផសស) |
| **GFATM** | មូលនិធិសាកលសម្រាប់ប្រយុទ្ធនឹងមេរោគអេដស៍ គ្រុនចាញ់ និងរបេង |
| **HEFs** | មូលនិធិសមធម៌សុខភាព |
| **HSP2** | ផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទី ២ |
| **IFAPER** | ការវាយតំលៃចំរុះលើទំនុកចិត្ត និងការពិនិត្យសើរើឡើងវិញលើចំណាយសាធារណៈ |
| **IMF** | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| **MAFF** | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **NER** | អត្រាចុះឈ្មោះចូលរៀនសុទ្ធ |
| **NGOs** | អង្គការមិនមែនរដ្ឋាភិបាល |
| **NIS** | រដ្ឋឧស្សាហកម្មថ្មីថ្មោង |
| **NPF** | តម្លៃបច្ចុប្បន្នសុទ្ធ |
| **NSDP** | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) |
| **O&M** | ប្រតិបត្តិការ និងការថែទាំ |
| **ODA** | ជំនួយសហប្រតិបត្តិការអភិវឌ្ឍន៍ |
| **OECD** | អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| **OOP** | ចំណាយប្រាក់ចេញពីហោប៉ៅផ្ទាល់ខ្លួន |
| **PAP** | ផែនការសកម្មភាពអាទិភាព |
| **PAR** | កំណែទម្រង់រដ្ឋបាលសាធារណៈ |
| **PASEC** | កម្មវិធីសម្រាប់វិភាគប្រព័ន្ធអប់រំ Confemen (ប្រទេសនិយាយភាសាបារាំងនៅទ្វីបអាហ្វ្រិក) |
| **PB** | ការកសាងថវិកាកម្មវិធី |
| **PEFA** | ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ |
| **PETS** | អង្កេតតាមដានចំណាយសាធារណៈ |
| **PFM** | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| **PFMAP** | គម្រោងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណនេយ្យភាព |
| **PFMRP** | កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| **PHDO** | ការិយាល័យមន្ទីរសុខាភិបាលខេត្ត |
| **PISA** | កម្មវិធីវាយតម្លៃនិស្សិតអន្តរជាតិ |
| **PMU** | អង្គភាពអនុវត្តគម្រោង |
| **POC** | ចំណាយប្រតិបត្តិការអាទិភាព |
| **PPP** | ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន |
| **PREAC** | គណៈកម្មាធិការវាយតំលៃបុរេលក្ខណៈសម្បត្តិ និងផ្តល់កិច្ចសន្យា |
| **QIP** | គម្រោងវិនិយោគដែលមានគុណវុឌ្ឍិ |
| **SAW** | យុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹក |
| **SDGs** | កញ្ចប់ថវិកាសម្រាប់ផ្តល់សេវា |

| | |
|---|---|
| **MEF** | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MDG** | គោលដៅអភិវឌ្ឍន៍សហស្សវត្ស |
| **MOEYS** | ក្រសួងអប់រំ យុវជន និងកីឡា |
| **MOH** | ក្រសួងសុខាភិបាល |
| **MOWRM** | ក្រសួងធនធានទឹក និងឧតុនិយម |
| **MRD** | ក្រសួងអភិវឌ្ឍន៍ជនបទ |
| **MTEF** | ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម |
| **NCD** | ជំងឺមិនឆ្លង |
| **SIDA** | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត |
| **SNFL** | ច្បាប់ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ |
| **SOAs** | ទីភ្នាក់ងារប្រតិបត្តិការពិសេស |
| **SOEs** | សហគ្រាសរដ្ឋ |
| **TIMSS** | និន្នាការក្នុងការសិក្សាគណិតសាស្ត្រ និងវិទ្យាសាស្ត្រអន្តរជាតិ |
| **UN** | អង្គការសហប្រជាជាតិ |
| **VAT** | អាករលើតម្លៃបន្ថែម |
| **WHO** | អង្គការសុខភាពពិភពលោក |

# សេចក្ដីថ្លែងអំណរគុណ


ឯកសារស្ដីពីការវាយតំលៃចំរុះលើទំនុកចិត្ត និងការពិនិត្យសើរើឡើងវិញលើចំណាយសាធារណៈ (IFAPER) ត្រូវបានរៀបចំឡើងដោយក្រុមមួយ ដែលដឹកនាំដោយ Ivailo Izvorski ដែលរួមមាន Huot Chea, Sodeth Ly, Paavo Eliste, Timothy Johnston, Emre Ozaltin, Suhas Parandekar, និង Leah April ។ សូមអរគុណជាពន្លឹកចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុដ៏សប្បុរសពី AusAID, DFID, និង SIDA ។

ចំពោះផ្នែករដ្ឋាភិបាលវិញ យើងបានទទួលអត្ថប្រយោជន៍យ៉ាងច្រើនពីការពិគ្រោះយោបល់ជាញឹកញាប់ជាមួយ ឯ.ឧ. បណ្ឌិត ហង់ ជួន ណារ៉ុន, បណ្ឌិត សុខ សារាវុឌ្ឍ បណ្ឌិត យក់ ប៊ុនណា លោក ប៊ុន រ័ត្ន លោក គឹម ផល្លា និងលោក ប៉ែន ធីរុង្គ (នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ឯ.ឧ. បណ្ឌិត វិទ្ធ វុឌ្ឍី (ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) ឯ.ឧ. អ៊ឹម សុធី និងលោក ព្រំ ភាព (ក្រសួងអប់រំ យុវជន និងកីឡា) ឯ.ឧ. ច័ន្ទ តុងអ៊ីវ និងលោក ម៉ុង ឡេង (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ឯ.ឧ. ហ៊ីវ សារឹម (ក្រសួងអភិវឌ្ឍន៍ជនបទ) ឯ.ឧ. វ៉េង សាខុន (ក្រសួងធនធានទឹក និងឧតុនិយម) ឯ.ឧ. សាស្ត្រាចារ្យ កើត មៀច (ក្រសួងសុខាភិបាល) និង ឯ.ឧ. វេជ្ជបណ្ឌិត យក់ សម្បត្តិ (ក្រសួងសុខាភិបាល) ឯ.ឧ. ង៉ោ ហុងលី (ក្រុមប្រឹក្សាកំណែទម្រង់) បណ្ឌិត គុណ ញឹម លោក ផា អេងវេង និងលោក គង់ សុផល្លាគុណ (គយ) ។ យើងសូមថ្លែងនូវកតវេទិតាធមិចំពោះបុគ្គលិកនាយកដ្ឋានថវិកា ហិរញ្ញកិច្ច និងផែនការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសុខាភិបាល និងក្រសួងបរិស្ថាន សូមថ្លែងអំណរគុណចំពោះប្រធាននាយកដ្ឋានផ្សព្វផ្សាយ និងផលិតកម្មដំណាំនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមអរគុណចំពោះប្រធាននាយកដ្ឋានផ្លូវជនបទនៅក្រសួងអភិវឌ្ឍន៍ជនបទ សូមអរគុណចំពោះនាយកដ្ឋានសហប្រតិបត្តិការវិនិយោគ ថវិកា និងគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ សូមអរគុណចំពោះលេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសូមអរគុណចំពោះបុគ្គលិកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ មតិយោបល់ដ៏មានតំលៃត្រូវបានទទួលនៅក្នុងការបង្ហាញជាច្រើនលើកនៃជំពូកនីមួយៗទៅកាន់មន្ត្រីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងបុគ្គលិករបស់ធនាគារពិភពលោក រីឯជំពូកស្ដីពីកសិកម្មក៏បានបង្ហាញដល់និស្សិតនៃមហាវិទ្យាល័យភូមិន្ទកសិកម្មផងដែរ ។

យើងបានទទួលសំណើ យោបល់ និងការណែនាំដ៏មានតម្លៃពី Qimiao Fan, Stephane Guimbert, Robert Taliercio, Mathew Verghis, Luc Christiaensen, Gary Reid, Patrick Labaste, Peter Murphy, និង Jos Verbeek, Simeth Beng, Tsuyoshi Fukao, Frederico Gil Sander, Patrick Grady, Ronald Points, Ahsan Ali, Christopher Robert Fabling, Giovanni Ganelli, Joel Turkewitz, និង Sudhir Chitale ។ លោក Ray Purcell និងសហការីរបស់លោកនៅ Mokoro បានផ្ដល់ឯកសារពាក់ព័ន្ធស្ដីពីកសិកម្ម ។ Timothy Purcell (ក្នុងស៊ុលតង់មិនទាក់ទងនឹង Ray Purcell) ក៏បានផ្ដល់វិភាគទានចំពោះជំពូកស្ដីពីកសិកម្មផងដែរ ។ Diane Northway និង Daniel Whitaker បានរៀបចំសេចក្ដីព្រាងដើមនៃជំពូកស្ដីពីសុខភាព ។ Linna Ky, Sophorn Kith និង Narya Ou បានផ្ដល់ការគាំទ្រផ្នែកផ្គត់ផ្គង់ និងរដ្ឋបាលល្អឥតខ្ចោះ ។ Shane Perkinson, Lynn Gross និង Narya Ou បានជួយរៀបចំទម្រង់ខ្លះនៃឯកសារនេះ ។ Galina Andronova-Vincelette, Sajitha Bashir, Ron Hood, និង Sergiy Zorya គឺជាអ្នកដែលជួយពិនិត្យមើលឡើងវិញនូវឯកសារនេះ ។

# តារាងមាតិកា


**និដ្ឋភាពរួម** ........ i

វិស័យកសិកម្ម ........ iii
វិស័យសុខាភិបាល ........ iii
វិស័យអប់រំ ........ iv
សេចក្តីសន្និដ្ឋាន និងការផ្តល់តម្លៃអនុសាសន៍ ........ iv

**ជំពូក ១. មូលដ្ឋានយុទ្ធសាស្ត្រ៖ ការស្តារ និងការពង្រីកលំហសារពើពន្ធ** ........ ១

ក. សេចក្តីផ្តើម ........ ១
ខ. ការអភិវឌ្ឍសេដ្ឋកិច្ច និងបញ្ហាប្រឈមកន្លងទៅថ្មីៗ ........ ២
គ. ស្ថានភាពសារពើពន្ធ ........ ៦
ឃ. បំណុលរដ្ឋាភិបាល និងចីរភាពនៃបំណុល ........ ១០
ង. លំហសារពើពន្ធ ........ ១០
ច. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ ........ ១៤

**ជំពូក ២. សមាសភាពនៃចំណាយ អាទិភាព និងការអនុវត្តភាពរបស់រដ្ឋាភិបាល** ........ ១៥

ក. សេចក្តីផ្តើម ........ ១៥
ខ. កម្រិតនៃចំណាយសាធារណៈ ........ ១៦
គ. សមាសភាពនៃចំណាយរដ្ឋាភិបាល ........ ១៩
ឃ. ចំណាយឯកជនលើទំនិញសាធារណៈ ........ ២៦
ង. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ ........ ២៨

**ជំពូក ៣. ចំណាយរបស់រដ្ឋាភិបាលលើវិស័យកសិកម្ម** ........ ២៩

ក. សេចក្តីផ្តើម ........ ២៩
ខ. ទិដ្ឋភាពទូទៅនៃវិស័យកសិកម្ម ការស្រោចស្រព និងផ្លូវជនបទ ........ ៣០
គ. កម្រិត និងសមាសភាគនៃចំណាយរបស់រដ្ឋាភិបាលលើវិស័យកសិកម្ម ........ ៣១
ឃ. ដំណើរការថវិកា និងលទ្ធផលអនុវត្ត ........ ៣៤
ង. ប្រសិទ្ធភាព និងប្រសិទ្ធផលនៃចំណាយរបស់រដ្ឋាភិបាលក្នុងវិស័យកសិកម្ម ........ ៣៤
ច. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ ........ ៣៨

**ជំពូក ៤. ការបង្កើនសុខភាពចំពោះការចំណាយប្រាក់** ........ ៤១

ក. សេចក្តីផ្តើម ........ ៤១
ខ. វិស័យសុខាភិបាលនៅកម្ពុជា ........ ៤២
គ. និន្នាការ និងសមាសភាគនៃចំណាយសុខាភិបាល ........ ៤៥
ឃ. ប្រសិទ្ធភាព និងសមធម៌នៃចំណាយសុខាភិបាលនៅកម្ពុជា ........ ៥០
ង. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ ........ ៥៥

**ជំពូក ៥. រចនាសម្ព័ន្ធ និងគុណភាពនៃចំណាយអប់រំ** ........ ៥៨

ក. សេចក្តីផ្តើម ........ ៥៨
ខ. សមិទ្ធផល និងបញ្ហាប្រឈមនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ........ ៥៩
គ. ចំណាយលើវិស័យអប់រំ លំនាំ និងនិន្នាការ ........ ៦២
ឃ. គ្រូបង្រៀន និងប្រាក់កម្រៃគ្រូបង្រៀន ........ ៦៥
ង. ការផ្តល់សៀវភៅសិក្សា ........ ៦៦

ច. ចំណាយគ្រួសារចំពោះការអប់រំមូលដ្ឋាន ........ ៦៧
ឆ. ភាពជាដៃគូរវាងសាធារណៈ និងឯកជននៅឧត្តមសិក្សា ........ ៦៨
ជ. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ ........ ៦៨

**ជំពូក ៦. ការធ្វើឱ្យជំនឿទុកចិត្តចំពោះថវិកាមាននិរន្តរភាព និងការឈានឆ្ពោះទៅកាន់គណនេយ្យភាព ហិរញ្ញវត្ថុកាន់តែធំ ........ ៧០**

ក. សេចក្តីផ្តើម ........ ៧០
ខ. ស្ថានភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ៧១
គ. ការធ្វើកំណែទម្រង់ជ្រាលជ្រៅចំពោះជំហានទីមួយ ពន្លឿនសកម្មភាពជំហានទីពីរ ........ ៧៦
ឃ. ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ : បញ្ហាប្រឈម និងហានិភ័យ ........ ៨១
ង. កំណែទម្រង់រដ្ឋបាលសាធារណៈ និងវិមជ្ឈការ និងវិសហមជ្ឈការ ........ ៨៣
ច. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ ........ ៨៥

**ឧបសម្ព័ន្ធ ........ ៨៧**

**ឯកសារយោង ........ ១០៨**

## រូប

រូបលេខ ១. លទ្ធផលកើនឡើងជាថ្មី បន្ទាប់ពីការធ្លាក់ចុះបណ្តាលមកពីវិបត្តិនៅឆ្នាំ ២០០៩ ........ ៣
រូបលេខ ២. ឱនភាពសារពើពន្ធនៅតែមានទំហំធំ បន្ទាប់ពីការកើនឡើងនៅឆ្នាំ ២០០៩ ........ ៣
រូបលេខ ៣. កំណើន និងអតិផរណាមានកម្រិតខ្ពស់ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ ១៩៩០ ........ ៥
រូបលេខ ៤. អត្រាប្តូរប្រាក់ពិតកំពុងធ្លាក់ចុះ ........ ៥
រូបលេខ ៥. ចំណូលមិនគិតជំនួយឥតសំណងនៅកម្ពុជា ទាបជាងនៅបណ្តាប្រទេសដែលមានចំណូលទាបដទៃទៀត ........ ៨
រូបលេខ ៦. ទឹកប្រាក់លើកលែងមិនយកពន្ធនៅតែមានទំហំធំ ........ ៨
រូបលេខ ៧. ចំណាយទូទៅរបស់រដ្ឋាភិបាលស្របជាមួយចំណាយទូទៅក្នុងបណ្តាប្រទេស ដែលមានចំណូលក្នុងពលរដ្ឋម្នាក់ៗប្រហាក់ប្រហែលគ្នា ........ ១៨
រូបលេខ ៨. ប្រាក់ខែកើនឡើង ប៉ុន្តែចំណាយលើការថែទាំ និងចំណាយប្រតិបត្តិការមាននិន្នាការធ្លាក់ចុះ ........ ១៩
រូបលេខ ៩. ចំណាយប្រាក់ខែបានកើនឡើងយ៉ាងច្រើននៅឆ្នាំ ២០០៩ មួយផ្នែកធំ ដោយសារកំណើនចំណាយប្រាក់ខែកងកម្លាំងយោធា និងសន្តិសុខ ........ ១៩
រូបលេខ ១០. ចំនួនបុគ្គលិកសាធារធាណៈក្រៅពីយោធា និងសន្តិសុខមានទំហំតូច ........ ២០
រូបលេខ ១១. ...ដូចប្រាក់ខែជនស៊ីវិល ........ ២០
រូបលេខ ១២. ចំណែកប្រាក់ខែសម្រាប់វិស័យអប់រំបានធ្លាក់ចុះចាប់តាំងពីឆ្នាំ ២០០៧ ........ ២១
រូបលេខ ១៣. ចំណាយមូលធនមានចំនួនធំជាងបណ្តាប្រទេស ដែលមានកម្រិតនៃប្រាក់ចំណូលក្នុងម្នាក់ៗប្រហែលគ្នា ........ ២១
រូបលេខ ១៤. ចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំមានកម្រិតទាបធៀបនឹងបណ្តាប្រទេសដទៃ ........ ២៤
រូបលេខ ១៥. សាលារៀន និងផ្លូវជនបទ ចំណាយស្មើនឹងពាក់កណ្តាលនៃចំណាយឯកជនលើទំនិញសាធារណៈ ........ ២៥
រូបលេខ ១៦. គណបក្សនយោបាយផ្តល់អំណោយយ៉ាងច្រើន ........ ២៦
រូបលេខ ១៧. ចំណាយសរុបរបស់រដ្ឋាភិបាលលើវិស័យកសិកម្មបានកើនឡើង ........ ៣២
រូបលេខ ១៨. ... ចំណែកឯកការគាំទ្ររបស់ម្ចាស់ជំនួយបានធ្លាក់ចុះ ........ ៣២
រូបលេខ ១៩. ចំណាយចរន្តបានកើនឡើងជាបន្តបន្ទាប់នៅក្នុងក្រសួងទាំងបី ........ ៣៣
រូបលេខ ២០. ចំណាយមូលធនរបស់រដ្ឋាភិបាលបានកើនឡើងជាខ្លាំង ........ ៣៣
រូបលេខ ២១. លទ្ធផលសំខាន់ៗដែលសម្រេចបាន ជាទូទៅមាននិន្នាការឡើង ........ ៣៥
រូបលេខ ២២. ប៉ុន្តែតួលេខចំណាយមានទិដ្ឋភាពចម្រុះ ........ ៣៥
រូបលេខ ២៣. អនុបាតរវាងផលចំណេញ និងចំណាយចំពោះវិស័យកសិកម្ម និងផ្លូវជនបទកំពុងកើនឡើង ........ ៣៦
រូបលេខ ២៤. ... ប៉ុន្តែចំណាយទាំងនេះ នៅតែទាបជាងសក្តានុពល ........ ៣៦

រូបលេខ ២៥. ការស្លាប់របស់ទារក និងកុមារបានធ្លាក់ចុះជាខ្លាំង ប៉ុន្តែការស្លាប់របស់ទារកទើបកើតធ្លាក់ចុះតិចតួចប៉ុណ្ណោះ ......៤៣
រូបលេខ ២៦. កង្វះអាហារូបត្ថម្ភនៅតែមានកម្រិតខ្ពស់ ......៤៣
រូបលេខ ២៧. ចំនួនមន្ទីរសម្ភពបានកើនឡើងយ៉ាងច្រើនជាមួយនឹងកំណើនយឺតចំពោះការបង្ការការមានកូន ......៤៤
រូបលេខ ២៨. អ្នកផ្តល់សេវាឯកជន ត្រូវបានពិគ្រោះជំងឺញឹកញាប់ចំពោះការថែទាំព្យាបាល ......៤៤
រូបលេខ ២៩. ចំណាយរដ្ឋាភិបាលបានកើនឡើងយ៉ាងខ្ពស់លើទឹកប្រាក់ចំណាយជាក់ស្តែង ......៤៦
រូបលេខ ៣០. ... និងកើនឡើងគិតជាភាគរយនៃ ផសស និងចំណាយសរុបរបស់រដ្ឋាភិបាល ......៤៦
រូបលេខ ៣១. ចំណាយលើឱសថ និងបរិក្ខារពេទ្យ មានចំនួនច្រើនជាងពីរដងនៃចំណាយលើប្រាក់កម្រៃ ......៤៦
រូបលេខ ៣២. ថវិកាភាគច្រើន ពុំមែនជាថវិកាកម្មវិធី ......៤៦
រូបលេខ ៣៣. គ្រួសារមានជីវភាពធូរធារចំណាយច្រើនលើការថែទាំសុខភាព - ឆ្នាំ ២០០៧ ......៤៧
រូបលេខ ៣៤. ថ្លៃសេវា គឺជាប្រភពសំខាន់មួយនៃការផ្តល់មូលនិធិ-ឆ្នាំ ២០០៩ ......៤៧
រូបលេខ ៣៥. ថ្លៃសេវាបង្កើតបានជាចំណូលយ៉ាងច្រើន ......៤៨
រូបលេខ ៣៦. ប្រភពផ្តល់មូលនិធិសម្រាប់មន្ទីរពេទ្យជាតិ ឆ្នាំ ២០០៨-២០០៩ ......៤៨
រូបលេខ ៣៧. ចំណាយលើការថែទាំសុខភាពបឋមមានលក្ខណៈអំណោយផលចំពោះពលរដ្ឋក្រីក្រជាជាងចំណាយមន្ទីរពេទ្យ ......៥១
រូបលេខ ៣៨. ពលរដ្ឋក្រីក្រស្ថិតនៅកៀកមណ្ឌលសុខភាពជាងមន្ទីរពេទ្យ ......៥១
រូបលេខ ៣៩. វិភាជន៍ថវិកាមានទំនាក់ទំនងជាមួយចំនួនគ្រែ ប៉ុន្តែមិនទាក់ទងនឹងលទ្ធផលរបស់មន្ទីរពេទ្យឡើយ ......៥២
រូបលេខ ៤០. វិភាជន៍ថវិកានៅថ្នាក់ខេត្តមិនដូចគ្នាឡើយ ......៥២
រូបលេខ ៤១. របាយគ្រូពេទ្យវេជ្ជបណ្ឌិត និងឆ្មបបឋមប្រែប្រួលជាខ្លាំង ......៥៣
រូបលេខ ៤២. នៅតែមានការដាច់ស្តុក ទោះបីជាចំណាយសម្រាប់ទិញឱសថកើនឡើងយ៉ាងឆាប់រហ័សក្តី ......៥៣
រូបលេខ ៤៣. សមត្ថភាពយល់ដឹងរបស់កុមារកម្ពុជាវ័យក្មេងបានធ្លាក់ចុះ ......៦០
រូបលេខ ៤៤. ប្រូបាប៊ីលីតេប៉ាន់ស្មានអំពីការចូលរៀន និងចុះឈ្មោះចូលរៀនជាអនុគមន៍នៃចំណាត់ថ្នាក់ ......៦០
រូបលេខ ៤៥. ចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំបានធ្លាក់ចុះធៀបនឹង ផសស ឆ្នាំ ២០០៣-២០០៩ ......៦៣
រូបលេខ ៤៦. បំណុលកកស្ទះចំពោះការទូទាត់បានធ្លាក់ចុះយ៉ាងលឿន និងត្រូវបានលុបបំបាត់ទាំងស្រុងនៅឆ្នាំ ២០០៧ ......៧២
រូបលេខ ៤៧. ... ខណៈដែលការបើកផ្តល់ថវិកានៅចុងត្រីមាស ត្រូវបានកែលំអយ៉ាងឆាប់រហ័ស ......៧២
រូបលេខ ៤៨. ចំណាយអាទិភាពត្រូវបានលើកកម្ពស់ជាបណ្តើរៗ ទន្ទឹមនឹងកំណើនខ្ពស់នៃចំណាយវិនិយោគ ......៧៣
រូបលេខ ៤៩. ... ហើយការបើកផ្តល់ថវិកាប្រចាំឆ្នាំ ជារួមគិតតាមប្រភេទចំណាយបានកើនឡើងយ៉ាងច្បាស់ ......៧៣
រូបលេខ ៥០. ការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចធ្វើឱ្យប្រាក់ចំណូលធ្លាក់ចុះនៅឆ្នាំ ២០០៩ ......៧៧
រូបលេខ ៥១. ... នៅពេលដែលអត្រាកំណើនពន្ធផ្ទាល់នៅតែប្រែប្រួល ......៧៧
រូបលេខ ៥២. ចំណាយវិស័យអាទិភាពគិតជាភាគរយនៃថវិកាក្នុងស្រុកកំពុងធ្លាក់ចុះ ......៧៨
រូបលេខ ៥៣. សមតុល្យសាច់ប្រាក់គណនីទោលរតនាគារ បាន និងកំពុងធ្លាក់ចុះចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០០៩ ......៧៨


## តារាង


តារាងលេខ ១. សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា ......៤
តារាងលេខ ២. កម្ពុជា គណនីសារពើពន្ធទូទៅរបស់រដ្ឋាភិបាល ឆ្នាំ ២០០០-២០១០ ......៧
តារាងលេខ ៣. រចនាសម្ព័ន្ធនៃចំណូលរបស់រដ្ឋាភិបាល ឆ្នាំ ២០០០-២០០៩ ......៩
តារាងលេខ ៤. ចំណាយទូទៅរបស់រដ្ឋាភិបាលបានកើនឡើងយ៉ាងខ្ពស់នៅឆ្នាំ ២០០៩ ក្រោយពីការកើនឡើងតិចតួច ក្នុងអំឡុងឆ្នាំ ២០០៥-២០០៨ ......១៦
តារាងលេខ ៥. ចំណាយសាធារណៈសរុបនៅកម្ពុជាមានទំហំធំ ......១៨
តារាងលេខ ៦. ប្រាក់ខែមធ្យមសម្រាប់វិស័យអប់រំបានកើនឡើង ប៉ុន្តែកើនយឺតជាងប្រាក់ខែមធ្យមរបស់មន្ត្រីរាជការ ......២២
តារាងលេខ ៧. ចំណាយតាមប្រភេទមុខងារបានកើនឡើង ......២៣
តារាងលេខ ៨. ជំនួយបរទេសផ្តល់ហិរញ្ញប្បទានច្រើនជាងពាក់កណ្តាលនៃចំណាយរបស់រដ្ឋាភិបាល ក្នុងវិស័យដឹកជញ្ជូន កសិកម្ម និងសុខាភិបាល ......២៤
តារាងលេខ ៩. ប្រាក់បង្វែរពីរដ្ឋាភិបាលកណ្តាលទៅថ្នាក់ក្រោមជាតិមានកម្រិតទាប ......២៥

តារាងលេខ ១០. អាទិភាពនានាសម្រាប់អភិវឌ្ឍន៍របស់ឃុំ នៅមិនទាន់បានតម្រឹមជាមួយការគាំទ្ររបស់ម្ចាស់ជំនួយក្នុងស្រុកនៅឡើយ ..... ២៦
តារាងលេខ ១១. គុណភាពនៃលទ្ធផលសាធារណៈមានលក្ខណៈដូចក្នុងបណ្ដាប្រទេសដទៃទៀតដែលមានប្រាក់ចំណូលក្នុងម្នាក់ៗដូចគ្នា ..... ២៧
តារាងលេខ ១២. វិស័យកសិកម្មមានកំណើនខ្ពស់ ..... ៣០
តារាងលេខ ១៣. វិស័យកសិកម្មមានកំណើនខ្ពស់រដ្ឋាភិបាលចំណាយតិច ..... ៣២
តារាងលេខ ១៤. កម្ពុជាកំពុងដើរតាមផ្លូវត្រូវក្នុងការឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សផ្នែកសុខាភិបាលជាច្រើន ..... ៤២
តារាងលេខ ១៥. លទ្ធភាពបានទទួលសេវាអប់រំកម្រិតបឋម និងមធ្យមសិក្សា ..... ៥៩
តារាងលេខ ១៦. ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ ..... ៦១
តារាងលេខ ១៧. ការអភិវឌ្ឍស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពចំពោះបុគ្គលិកអប់រំចំពោះវិមជ្ឈការ ..... ៦២
តារាងលេខ ១៨. ចំណាយលើវិស័យអប់រំនៅកម្ពុជាមានកម្រិតទាបជាងគូប្រៀបធៀប ..... ៦៣
តារាងលេខ ១៩. ចំណាយវិស័យអប់រំ ឆ្នាំ ២០០៩-១៣ ..... ៦៤
តារាងលេខ ២០. ស្ថានភាពគ្រូ និងទំហំប្រាក់កម្រៃរបស់គ្រូ ឆ្នាំ ២០០១/០២ ដល់ ២០០៩/១០ ..... ៦៥
តារាងលេខ ២១. ចំណាយគ្រួសារនៅតាមបញ្ចូភាគមិនដូចគ្នាឡើយ ឆ្នាំ ២០០៩ ..... ៦៧
តារាងលេខ ២២. ចំណាយសរុបនៅឧត្តមសិក្សាគិតតាមប្រភពនៃការផ្ដល់មូលនិធិ ..... ៦៨
តារាងលេខ ២៣. គម្រោងស្នើ ៣+២ : កត្តាជំរុញសំខាន់ ដើម្បីឱ្យមានគណនេយ្យភាពហិរញ្ញវត្ថុ ..... ៨២


## ប្រអប់


ប្រអប់លេខ ១. វិសាលភាព និយមន័យ និងការគណនាទិន្នន័យចំណាយដែលប្រើក្នុងរបាយការណ៍នេះ ..... ១៥
ប្រអប់លេខ ២. ការកត់ត្រាចំណាយនៃគម្រោង និងកម្មវិធីដែលផ្ដល់មូលនិធិដោយម្ចាស់ជំនួយ ..... ២៣
ប្រអប់លេខ ៣. តើប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុចម្រុះធ្វើអ្វី? ..... ៧៤
ប្រអប់លេខ ៤. ចំណាត់ថ្នាក់ថ្មីជំរុញការប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល ..... ៧៥
ប្រអប់លេខ ៥. វិធានការលើកទឹកចិត្តដើម្បីអនុវត្តកម្មវិធីកំណែទម្រង់ ..... ៧៩
ប្រអប់លេខ ៦. បទពិសោធន៍ធនាគារពិភពលោកជាមួយប្រព័ន្ធរតនាគារ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ ..... ៨០


## ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ ១. ចំណុចដៅនានានៃផយអជ ឆ្នាំ ២០០៦-២០១០ និងគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សកម្ពុជា ..... ៨៧
ឧបសម្ព័ន្ធ ២. រដ្ឋាភិបាល ហិរញ្ញប្បទានទូទៅរបស់រដ្ឋាភិបាលតាមចំណាត់ថ្នាក់មុខងារ ..... ៩០
ឧបសម្ព័ន្ធ ៣. រដ្ឋាភិបាលទូទៅតាមចំណាត់ថ្នាក់មុខងារ : ផ្នែកអនុវត្តរតនាគារ ..... ៩១
ឧបសម្ព័ន្ធ ៤. រដ្ឋាភិបាលទូទៅតាមចំណាត់ថ្នាក់មុខងារ ផ្នែកហិរញ្ញប្បទានពីបរទេស ..... ៩២
ឧបសម្ព័ន្ធ ៥. ជំនួយបច្ចេកទេសដែលផ្ដល់ហិរញ្ញប្បទានពីបរទេស និងធនធានផ្ទាល់របស់អង្គការក្រៅរដ្ឋាភិបាល ..... ៩៣
ឧបសម្ព័ន្ធ ៦. ធនធានតម្រូវដោយ ផយអជ និងវិភាជន៍ជាក់ស្ដែង ..... ៩៤
ឧបសម្ព័ន្ធ ៧. កម្មវិធីវិភាជន៍ថវិកាក្រសួងសុខាភិបាល ឆ្នាំ ២០០៩ ..... ៩៥
ឧបសម្ព័ន្ធ ៨. វិភាជន៍ថវិការដ្ឋាភិបាលសម្រាប់វិស័យសុខាភិបាល ឆ្នាំ ២០០០-២០០៩ ..... ៩៥
ឧបសម្ព័ន្ធ ៩. ឱកាសការងារនៅក្រសួងសុខាភិបាល ..... ៩៦
ឧបសម្ព័ន្ធ ១០. ថ្លៃ ciprofloxacine តាមវិក្កយបត្ររបស់ឃ្លាំងឱសថកណ្ដាល ខ្ពស់ជាងថ្លៃឱសថនេះនៅលើទីផ្សារអន្តរជាតិ ..... ៩៧
ឧបសម្ព័ន្ធ ១១. ថ្លៃ ciprofloxacine នៅឱសថស្ថានឯកជនថោកជាងថ្លៃឱសថនេះនៅបរទេស ..... ៩៧
ឧបសម្ព័ន្ធ ១២. សូចនាករអនុវត្ត ឆ្នាំ ២០០៤-២០១០ ..... ៩៨
ឧបសម្ព័ន្ធ ១៣. កម្រិតភ្លើងចរាចរខ្ពស់នៃសូចនាករលទ្ធផលអនុវត្តសម្រាប់ជំហានទីពីរ ..... ១០៤
ឧបសម្ព័ន្ធ ១៤. ការប្រៀបធៀបពិន្ទុចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុប្រចាំតំបន់ ..... ១០៦

# ទិដ្ឋភាពរួម

**ប្រទេសកម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពជាខ្លាំងក្នុងការកសាងសេដ្ឋកិច្ចជាថ្មីឡើងវិញ ចាប់តាំងពីការបោះឆ្នោតនៅឆ្នាំ ១៩៩៣ ដែលបានជួយនាំមកវិញនូវសន្តិភាពដល់ប្រទេសដែលរងវិនាសកម្មដោយសង្គ្រាម។** កំណើនសេដ្ឋកិច្ចជាមធ្យមសម្រាប់រយៈពេលពីរទសវត្សរ៍បន្តបន្ទាប់គ្នាស្មើនឹង ៧ ភាគរយ ក្នុងមួយឆ្នាំ នាំមកនូវចំណូលក្នុងម្នាក់ៗប្រមាណជា ៧៦០ ដុល្លារ នៅឆ្នាំ ២០១០ ទោះបីជាមានវិបត្តិសេដ្ឋកិច្ចពិភពលោកក្តី ។ គេឃើញមានវឌ្ឍនភាពក្នុងការអភិវឌ្ឍរដ្ឋដែលមានប្រសិទ្ធភាព ។ កម្រិត និងប្រសិទ្ធភាពចំណាយរបស់រដ្ឋាភិបាលបានកើនឡើងជាបណ្តើរៗ ហើយការគាំទ្ររបស់ម្ចាស់ជំនួយនៅតែមានចំនួនច្រើន ។ បច្ចុប្បន្ន ការយកចិត្តទុកដាក់ចាំបាច់ត្រូវងាកមកកាត់បន្ថយយ៉ាងឆាប់រហ័សនូវឧបសគ្គនានាចំពោះលទ្ធភាពរបស់រដ្ឋាភិបាល ដើម្បីផ្តល់សេវាសាធារណៈដែលមានយុត្តិធម៌មានប្រសិទ្ធភាព និងចំណាយតិច ប៉ុន្តែបានផលច្រើនដែលគាំទ្រកំណើនប្រកបដោយនិរន្តរភាព និងមានមូលដ្ឋានទូលាយជាងមុន ។ ការពង្រឹងស្ថាប័ន ការបង្កើនតម្លាភាព និងអភិបាលកិច្ច ព្រមទាំងគណនេយ្យភាព គឺជាផ្នែកដ៏សំខាន់ ដើម្បីធ្វើឱ្យប្រាកដថាគោលដៅនៃការលើកកម្ពស់កម្រិតជីវភាពរស់នៅអាចសម្រេចបានដោយគ្មានការផាត់ចេញពីសង្គម (social exclusion) ។

**ភាពប្រុងប្រយ័ត្នផ្នែកសារពើពន្ធ និងការកើនឡើងនូវប្រាក់ចំណូលដោយសារកំណើនខ្ពស់ និងដោយសារការប្រមូលចំណូលបានកាន់តែល្អប្រសើរបានជួយកាត់បន្ថយឱនភាពសារពើពន្ធយ៉ាងច្រើនក្នុងទសវត្សរ៍រហូតដល់ឆ្នាំ ២០០៨។** ជាមួយគ្នានេះ រដ្ឋាភិបាលបានបង្កើនប្រាក់បញ្ញើរបស់ខ្លួនដល់ចំនួន ៧៣២ លានដុល្លារ នៅធនាគារកណ្តាលកើនឡើងជាងម្តេដងចាប់ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៨ ។ ទឹកប្រាក់ដ៏ច្រើននេះជាពិសេសនៅពេលដែលរដ្ឋាភិបាលគ្មានលទ្ធភាពចូលទៅកាន់ទីផ្សារទុន - បានបង្កលក្ខណៈឱ្យរដ្ឋាភិបាលបង្កើនចំណាយក្នុងឆ្នាំ២០០៩ និងជួយកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោក ។

**ចំណាយរបស់រដ្ឋាភិបាលកម្ពុជា មានកម្រិតប្រហាក់ប្រហែលគ្នានឹងចំណាយនៅប្រទេសដទៃ ដែលប្រាក់ចំណូលក្នុងម្នាក់ៗមានកម្រិតអាចប្រៀបធៀបគ្នាបាន ហើយមានលទ្ធផលនៃការអភិវឌ្ឍប្រដំប្រសងគ្នា។** សមាសភាគចំណាយរបស់កម្ពុជា ក៏មានភាពខុសគ្នាតិចតួចធៀបនឹងបណ្តាប្រទេសដែលអាចប្រៀបធៀបគ្នាបាន ។ ទោះជាយ៉ាងណាក៏ដោយ មានបញ្ហាសំខាន់ចំនួនពីរ ។ ទីមួយ ចំណាយមូលធនមានចំណែកយ៉ាងធំនៃចំណាយថវិកាជាចំណែកមួយសមស្របសម្រាប់ប្រទេសមួយ ដែលមានសេចក្តីត្រូវការច្រើនចំពោះការអភិវឌ្ឍ ។ ការធ្វើយ៉ាងណាឱ្យចំណាយទាំងនេះ ត្រូវគ្នាជាមួយវិភាជន៍សម្រាប់ការថែទាំដែលមានលក្ខណៈប្រាកដនិយមមានសារៈសំខាន់ណាស់ ដើម្បីធានាឱ្យប្រាកដថាវិនិយោគទុនទាំងនោះ ត្រូវបានអនុវត្តដោយពេញលេញ និងទ្រទ្រង់កំណើន ។ ទីពីរ ការដំឡើងប្រាក់ខែសម្រាប់វិស័យយោធានៅឆ្នាំ ២០០៩ បានធ្វើឱ្យចំណាយប្រាក់ខែកើនឡើងយ៉ាងច្រើនខ្ពស់ជាងការដំឡើងប្រាក់បៀវត្សចំពោះបុគ្គលិកមិនមែនយោធាជាខ្លាំងចាប់តាំងពីឆ្នាំ ២០០៧ ។ នៅក្នុងវិស័យមួយចំនួន (មិនមែនយោធា) អាចមានលទ្ធភាពបង្កើនប្រាក់ខែបន្ថែម ប្រសិនបើមានលំហសារពើពន្ធ (Fiscal Space) ហើយការប្រាក់ត្រូវបានញែកក្រោមក្របខ័ណ្ឌនៃកំណែទម្រង់បៀវត្សដែលមានប្រសិទ្ធភាព ។

**សមាសភាពនៃចំណាយរបស់រដ្ឋាភិបាលមានលក្ខណៈស្រដៀងគ្នាជាទូទៅជាមួយបណ្តាប្រទេស ដែលមាន ផសស ក្នុងពលរដ្ឋម្នាក់ៗប្រហាក់ប្រហែលគ្នា។** ទោះជាយ៉ាងណាក្តី កម្ពុជានៅមិនទាន់អនុវត្តបាននូវគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សបី ក្នុងចំណោមគោលដៅអភិវឌ្ឍន៍សហស្សវត្សទាំងប្រាំបួននៅឡើយ ។ នៅក្នុងកញ្ចប់ធនធានមានកម្រិតរបស់ប្រទេស គប្បីមានលទ្ធភាពក្នុងការបែងចែកចំណាយជាថ្មីឡើងវិញ ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្ស និងកំណើនកាន់តែខ្ពស់ និងពេញលេញ ។ អនុសាសន៍នៅក្នុងរបាយការណ៍នេះបង្ហាញជំហានជាក់លាក់ ដើម្បីសម្រេចផលប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងវិស័យកសិកម្ម សុខាភិបាល និងអប់រំ ដែលនឹងបង្កលក្ខណៈក្នុងការបញ្ជូនមូលនិធិបន្ថែមទៅកាន់ផ្នែកអាទិភាព ដោយមិនបង្កើនកម្រិតចំណាយរួមធៀបនឹង ផសស ។

**ការគាំទ្ររបស់ម្ចាស់ជំនួយនៅតែមានចំនួនច្រើនក្នុងកម្រិតប្រមាណជាមួយភាគបីនៃចំណាយទូទៅរបស់រដ្ឋាភិបាល ឬប្រហែល ៤០ ភាគរយ នៃចំណាយសាធារណៈសរុបនៅពេលរួមបញ្ចូលការគាំទ្រក្រៅថវិការបស់ម្ចាស់ជំនួយសម្រាប់សហប្រតិបត្តិការ បច្ចេកទេស និងអង្គការមិនមែនរដ្ឋាភិបាលនានាដែលបម្រើការលើផ្នែកទំនិញសាធារណៈ។** ការពឹងផ្អែកលើម្ចាស់ជំនួយនេះ មានន័យថា រដ្ឋាភិបាល និងម្ចាស់ជំនួយចាំបាច់ត្រូវប្រឹងប្រែងធ្វើការបន្ថែមទៀត ដើម្បីធានាដល់ការបន្សុីកាន់តែល្អប្រសើរនូវការកសាងផែនការយុទ្ធសាស្ត្រ ការរៀបចំថវិកា និងការសម្របសម្រួលជំនួយ ។

**វឌ្ឍនភាពក្នុងការលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណនេយ្យភាព ហិរញ្ញវត្ថុមានភាពរឹងមាំ ប៉ុន្តែមហិច្ឆតា និងចំណុចដៅរបស់រដ្ឋាភិបាលនៅមិនទាន់ស៊ីគ្នានៅឡើយ។** ភាពជឿទុកចិត្តនៃថវិកាត្រូវបានបង្កើតឡើងក្នុងល្បឿនមួយរឹងមាំ។ កំណែទម្រង់នានាដែលប្រគល់ការទទួលខុសត្រូវកាន់តែច្រើនលើផ្នែកថវិកាកាន់តែទៅកាន់អ្នកគ្រប់គ្រងកម្មវិធី ដែលគាំទ្រដោយការលើកកម្ពស់យន្តការត្រួតពិនិត្យផ្ទៃក្នុង និងយន្តការគណនេយ្យភាពសព្វថ្ងៃកំពុងមានវឌ្ឍនភាព។ ចាំបាច់ត្រូវពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ឱ្យបានជោគជ័យ។ ហើយប្រមូលផ្តុំតម្រូវការដើម្បីប្តូរទៅអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដែលបានកំណត់។ ការណ៍នេះចាំបាច់ត្រូវបំពេញដោយកិច្ចប្រឹងប្រែងច្បាស់លាស់ដើម្បីបន្សុំគោលដៅយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល អាទិភាពថវិកា និងការគាំទ្ររបស់ម្ចាស់ជំនួយ។

**បច្ចុប្បន្ន ការគាំទ្ររបស់ម្ចាស់ជំនួយពុំមានការសម្របសម្រួលគ្នាគ្រប់គ្រាន់ឡើយ និងជាលទ្ធផល ការគាំទ្រនោះមានប្រសិទ្ធភាពតិចជាងការរំពឹងទុក។** ទីមួយ ត្រូវបង្កើនកិច្ចសហការរវាងម្ចាស់ជំនួយ ដើម្បីជួយធ្វើឱ្យថវិកាមានភាពជឿទុកចិត្ត។ យ៉ាងហោចណាស់ការពិភាក្សាអំពីការរៀបចំរបាយការណ៍ចំណាយចំពោះគម្រោង ដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ ដោយប្រើប្លង់គណនីរបស់រដ្ឋាភិបាល (COA) ត្រូវបានដោះស្រាយ។ អំពីបញ្ហាអាទិភាព ការគាំទ្រទាំងអស់របស់ម្ចាស់ជំនួយចំពោះរដ្ឋាភិបាល ទោះជាចំពោះចំណាយចរន្ត ចំណាយមូលធន ឬជំនួយបច្ចេកទេសក្តី ចាំបាច់ត្រូវដាក់បញ្ចូលទៅតាមថវិកា និងចាត់ថ្នាក់ឱ្យបានត្រឹមត្រូវ។ ការចាត់ថ្នាក់គម្រោងម្ចាស់ជំនួយទាំងអស់ជាចំណាយមូលធន ដូចក្នុងសព្វថ្ងៃ មិនអនុញ្ញាតឱ្យរដ្ឋាភិបាលដឹងច្បាស់លាស់អំពីចំណាយសាធារណៈទាំងអស់ ហើយសំខាន់ជាងនេះទៅទៀតនោះ ត្រូវកសាងផែនការអំពីការថែទាំចាំបាច់ឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ចំពោះចំណាយមូលធនធំដែលអនុវត្តសព្វថ្ងៃ។ ការបង្ហាញថវិកាគ្រប់ជ្រុងជ្រោយ និងចាត់ថ្នាក់បានត្រឹមត្រូវ តម្រូវឱ្យមានភាពដឹកនាំរបស់រដ្ឋាភិបាល និងសហប្រតិបត្តិការពេញលេញជាមួយម្ចាស់ជំនួយ។ ការណ៍នេះនឹងជួយពង្រឹងគណនេយ្យភាព សម្រួលការកសាងផែនការ បន្សុំចំណាយថវិកាជាមួយគោលដៅយុទ្ធសាស្ត្រនានា និងរួមចំណែកក្នុងការផ្តល់ទំនុកចិត្តប្រជាពលរដ្ឋថា ប្រាក់កាសរបស់ពួកគេត្រូវបានចំណាយបានល្អប្រសើរ។

**ការធ្វើសមាហរណកម្មរដ្ឋបាលសាធារណៈ វិមជ្ឈការ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានភាពទាក់ទងគ្នានៅតែជាបញ្ហាប្រឈមចម្បងមួយ។** ការបែងចែកការទទួលខុសត្រូវចំពោះការផ្តល់សេវានិងការគ្រប់គ្រងធនធានមានទំនាក់ទំនងជាមួយការរៀបចំបុគ្គលិក និងមានទំនាក់ទំនងជាមួយវិធីរៀបចំមុខងារសាធារណៈទាំងមូល។ ការអូសបន្លាយកំណែទម្រង់មុខងារសាធារណៈ និងកំណែទម្រង់ស្ថាប័នគ្រប់ជ្រុងជ្រោយ មានឥទ្ធិពលដោយផ្ទាល់ចំពោះវឌ្ឍនភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងធ្វើឱ្យនិរន្តរភាពនៃផលជាច្រើនដែលបានមកដោយលំបាកជួបហានិភ័យ។ ការចាត់ និងប្រគល់មុខងារនឹងតម្រឹមការទទួលខុសត្រូវ និងប្រភពនៃការផ្តល់មូលនិធិបានកាន់តែប្រសើរ និងជួយបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃការផ្តល់សេវា។

**ការប្រព្រឹត្តិទៅនៃដំណើរការនានារបស់កម្ពុជា ដើម្បីគ្រប់គ្រង និងចំណាយប្រាក់សាធារណៈ ចាំបាច់ត្រូវរៀបចំក្នុងបរិបទទូលាយអំពីវិធីដំណើរការនៃវិស័យសាធារណៈទាំងមូល។** កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពចម្បងក្នុងការកសាងមូលដ្ឋានគ្រឹះ ដើម្បីឱ្យក្លាយជារដ្ឋមួយដែលមានប្រសិទ្ធភាពក្រោយពីជម្លោះអស់ជាច្រើនទសវត្សរ៍។ ជាមួយគ្នានេះ បញ្ហាជាច្រើនធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវាសំខាន់ៗ ហើយការសិក្សាទាំងអស់ (all available studies) ចង្អុលបង្ហាញដល់អំពើពុករលួយកម្រិតខ្ពស់ដែលនៅតែកើតមាន។ ការបង្កើតអភិបាលកិច្ចដែលកាន់តែមានប្រសិទ្ធភាព តម្លាភាព និងមានមូលដ្ឋានផ្អែកលើវិធាន នៅតែជាចំណុចសំខាន់នៃបញ្ហាប្រឈមនៃការអភិវឌ្ឍរបស់កម្ពុជា (និងស្ថិតនៅចំចំណុចកណ្តាលនៃការគាំទ្ររបស់ធនាគារពិភពលោកសម្រាប់អនាគតកម្ពុជា)។ សំខាន់ត្រូវទទួលស្គាល់ថាការវិភាគ និងអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍នេះ គប្បីចាត់ទុកថាជាការលើកសរសើរចំពោះការងារដែលកំពុងប្រព្រឹត្តិទៅ ដើម្បីលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការចូលរួម ហើយការលើកកម្ពស់តម្លៃដែលបានមកពីហិរញ្ញវត្ថុសាធារណៈពឹងអាស្រ័យលើវឌ្ឍនភាពក្នុងផ្នែកទាំងពីរ។

**បញ្ហានៃការលើកកម្ពស់ប្រសិទ្ធភាព និងសមធម៌នៃចំណាយរបស់រដ្ឋាភិបាលក្នុងពេលពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការលើកកម្ពស់គណនេយ្យភាព និងអភិបាលកិច្ច ត្រូវបានឆ្លុះបញ្ចាំងក្នុងការវិភាគវិស័យចំនួនបីនៃរបាយការណ៍នេះ។** វិស័យកសិកម្ម សុខាភិបាល និងអប់រំ ត្រូវបានជ្រើសរើស ដោយមានការពិគ្រោះយោបល់យ៉ាងច្រើនជាមួយអាជ្ញាធរនានា។ សេចក្តីសង្ខេបនៃបញ្ហាសំខាន់ៗនៅក្នុងវិស័យនីមួយៗនៃវិស័យទាំងនេះមានដូចតទៅ។

# វិស័យកសិកម្ម

**កសិកម្មជាអាទិភាពមួយរបស់រដ្ឋាភិបាល ព្រោះវិស័យនេះជាប្រភពសំខាន់មួយនៃកំណើនសេដ្ឋកិច្ច និងចំណូលពីការនាំចេញ។** ទោះបីជាចេញពីមូលដ្ឋានទាបក្តី ចំណាយរបស់រដ្ឋាភិបាលលើវិស័យកសិកម្មបានកើនឡើងពី ១,៣ ភាគរយ នៃ ផសស នៅឆ្នាំ២០០៧ដល់ ១,៥ ភាគរយ នៅឆ្នាំ ២០០៩ សំខាន់ គឺកើនឡើងដោយសារការបង្កើនចំណាយលើការស្រោចស្រព និងផ្លូវជនបទ[១]។ អំឡុងពេលនៃការបង្កើនចំណាយសាធារណៈមកលើវិស័យកសិកម្មនេះ កើនឡើងទន្ទឹមគ្នាជាមួយអត្រាកំណើនខ្ពស់ប្រចាំឆ្នាំនៃផលកសិកម្ម។ ទោះបីជាពេលវេលាមិនគ្រប់គ្រាន់បានកន្លងផុតទៅ ដើម្បីប៉ាន់ស្មានប្រកបដោយទំនុកចិត្តថា តើមានទំនាក់ទំនង ហេតុ-ផល រវាងកម្រិតនៃចំណាយ-សាធារណៈ និងកំណើនកសិកម្មនៅកម្ពុជាដែរ ឬយ៉ាងណានោះ ភស្តុតាងបានបង្ហាញថា ចំណាយសាធារណៈ - ស្របជាមួយការលើកកម្ពស់បរិយាកាសគោលនយោបាយ - ពិតជាអាចមានបច្ច័យច្រើនក្នុងការបង្កើន និងធ្វើឱ្យកំណើនកសិកម្មមាននិរន្តរភាព។ ការវិភាគបញ្ជាក់ថាចំណាយរបស់រដ្ឋាភិបាលបានផ្តោតត្រឹមត្រូវលើការផ្តល់ទំនិញ និងសេវាសាធារណៈដែលមានអត្រាផលចំណេញខ្ពស់ ជាជាងលើឧបត្ថម្ភធន។ ទោះជាយ៉ាងណាក្តី គេឃើញមានសក្តានុពលល្អ ដើម្បីទទួលផលពីប្រសិទ្ធភាពបន្ថែមចំពោះធនធានដែលបានចំណាយ។

**ទោះបីជាកម្ពុជាគ្មានគោលនយោបាយ ដែលធ្វើឱ្យសកម្មភាពនានាក្នុងវិស័យកសិកម្មប្រាសចាកពីសភាពធម្មតាក្តី ឧបសគ្គដែលមានលក្ខណៈរចនាសម្ព័ន្ធស្មុគស្មាញមួយផ្នែងបានរាំងស្ទះប្រសិទ្ធផល និងប្រសិទ្ធភាពនៃចំណាយសាធារណៈ។** ទាំងនេះ រួមមានកង្វះភាពស្ថិតស្ថេរនៃការផ្តល់មូលនិធិសាធារណៈ ជាពិសេសចំពោះចំណាយប្រតិបត្តិការ និងថែទាំសម្រាប់ការផ្សព្វផ្សាយ និងការស្រាវជ្រាវកសិកម្ម។ បញ្ហាផ្នែកស្ថាប័នដែលមានលក្ខណៈជ្រាលជ្រៅ ដែលអាចកំណត់ប្រសិទ្ធភាពរយៈពេលវែងនៃចំណាយទាំងនេះ ចាំបាច់ត្រូវដោះស្រាយផងដែរ។ បញ្ហាប្រឈមដទៃទៀត រួមមាន ការផ្តោតការយកចិត្តទុកដាក់ជ្រុលហួសលើការស្តារនីតិសម្បទាហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពមេ ហើយមិនយកចិត្តទុកដាក់ចំពោះប្រព័ន្ធស្រោចស្រពរង និងប្រព័ន្ធជើងក្អែប ការមិនយកចិត្តទុកដាក់ថែទាំប្រព័ន្ធស្រោចស្រព និងផ្លូវជនបទ និងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីចំពោះផ្លូវជនបទដោយល្បឿនយឺត។ ចាំបាច់ត្រូវផ្តល់អាទិភាពចំណាយឱ្យបានកាន់តែប្រសើរ ដើម្បីបង្កើនប្រសិទ្ធភាពផល និងប្រសិទ្ធភាពនៃចំណាយសាធារណៈសម្រាប់វិស័យកសិកម្ម សុខាភិបាល និងអប់រំ។

**រដ្ឋាភិបាលអាចទទួលបានគុណតម្លៃកាន់តែប្រសើរចំពោះប្រាក់ តាមរយៈការវិភាជន៍ចំណាយសាជាថ្មីនៅក្នុងកញ្ចប់ចំណាយស្តីពីកសិកម្ម។** ក្នុងរយៈពេលខ្លី ធនធានបន្ថែមសម្រាប់ការស្រាវជ្រាវកសិកម្ម ការផ្សព្វផ្សាយកសិកម្ម និងប្រឡាយរង ព្រមទាំងវិភាជន៍ធនធានតិចតួចសម្រាប់រៀបចំយុទ្ធសាស្ត្រ និងការកសាងផែនការ គឺជាអនុសាសន៍មួយក្នុងចំណោមអនុសាសន៍នានា ដែលសមត្ថកិច្ចគប្បីពិចារណា។ ការស្រាវជ្រាវអំពីវិធានការកាត់បន្ថយ និងការបន្សាំ នឹងជួយធ្វើឱ្យកម្ពុជាត្រៀមលក្ខណៈចំពោះការប្រែប្រួលអាកាសធាតុ។ ការផ្តល់មូលនិធិក្នុងរង្វង់កញ្ចប់ថវិកាបច្ចុប្បន្ន - ឬវិភាជន៍ ដែលមានទំហំធំមកពីប្រភពធនធានជំនួយឥតសំណងរបស់ម្ចាស់ជំនួយ - ចំពោះប្រឡាយរង និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធមុខជាផ្តល់ផលប្រយោជន៍យ៉ាងច្រើនផងដែរ។ ក្នុងរយៈពេលមធ្យម សមត្ថកិច្ចនានាត្រូវបានស្នើឱ្យពិចារណានូវភាពអាចសម្រេចបានផ្នែកសេដ្ឋកិច្ចនៃបច្ចេកវិទ្យាថ្មីសម្រាប់ស្តារនីតិសម្បទា និងថែទាំផ្លូវថ្នល់ជនបទ។

# វិស័យសុខាភិបាល

**កម្ពុជាសម្រេចបានលទ្ធផលសុខាភិបាលគួរឱ្យកត់សំគាល់ក្នុងទសវត្សរ៍ចុងក្រោយ។** ចំណាយរួមលើវិស័យសុខាភិបាលបានកើនឡើង ប៉ុន្តែប្រាក់ចំណាយចេញពីហោប៉ៅផ្ទាល់ខ្លួននៅតែមានចំនួនច្រើន ជាការដាក់បន្ទុកមកលើពលរដ្ឋក្រីក្រ ហើយធ្វើឱ្យការថែទាំជំងឺធ្ងន់ធ្ងរមានតម្លៃខ្ពស់ហួស សម្រាប់អ្នកមានប្រាក់ចំណូលគ្រប់កម្រិតទោះជាមាន ឬក្រក្តី។

**នៅពេលដែលបង្កើនចំណាយលើប្រភេទនៃការថែទាំសុខភាព អាចជួយបង្កើនឱ្យមានសុខភាពល្អសំខាន់វិភាជន៍បែបនេះ ត្រូវរអមដោយវិធានការផ្សេងៗ ដើម្បីបង្កើនប្រសិទ្ធភាពនៃចំណាយបច្ចុប្បន្ន និងត្រូវផ្តល់មូលនិធិយ៉ាងហោចណាស់ក្នុងរយៈពេលមធ្យម តាមរយៈការសន្សំក្នុងវិស័យ។** ទីមួយ ប្រសិទ្ធភាពនៃការចំណាយលើការថែទាំសុខភាព អាចត្រូវបានលើកកម្ពស់តាមរយៈការទិញដែលកាន់តែមានប្រសិទ្ធភាព ជាពិសេសចំពោះការទិញឱសថ បរិក្ខារពេទ្យ និងសម្ភារៈនានា។ ការសន្សំអាចមានចំនួនលើស ៥០ លានដុល្លារក្នុងមួយឆ្នាំ ឬមួយភាគបីនៃចំណាយសុខាភិបាលរបស់រដ្ឋាភិបាល ដែលស្មើនឹង ០,៤ ភាគរយ នៃផសស។ ទីពីរ វិភាជន៍ថវិកាចំពោះបណ្តានាយកដ្ឋាន មន្ទីរពេទ្យនានា

*១ នៅក្នុងរបាយការណ៍នេះ ការចំណាយលើវិស័យកសិកម្ម រួមមានការចំណាយលើកសិកម្ម ផ្លូវជនបទ និងធនធានទឹក*

នៅថ្នាក់កណ្ដាល និងបណ្ដាខេត្ត គប្បីផ្អែកលើរូបមន្តដែលមានតម្លាភាព និងត្រូវមានលទ្ធផលច្បាស់លាស់តាមការគ្រោងទុក។ ទីបី យន្តការនានាសម្រាប់កសាងថវិកា និងតាមដានចំណាយ គប្បីត្រូវបានពង្រឹងនៅកម្រិតស្រុកប្រតិបត្តិ និងមន្ទីរពេទ្យ។ ទីបួន ការប្ដូរទៅជាការរៀបចំផ្ដល់សេវាពាក់កណ្ដាលស្វយ័តចំពោះមន្ទីរពេទ្យ និងមន្ទីរសុខាភិបាលស្រុកមួយចំនួន គប្បីអមដោយវិធានការនានាដើម្បីដាក់កំណត់ចំពោះកំណើនថ្លៃសេវា និងបង្កើតការរៀបចំការផ្ដល់ហិរញ្ញប្បទានសមស្រប ដើម្បីធ្វើឱ្យប្រាកដថា ពលរដ្ឋក្រីក្រ និងស្ទើរក្រីក្រនៅតែបានទទួលសេវាជាបន្តប្រកបដោយគុណភាព។

# វិស័យអប់រំ

**កម្ពុជាសម្រេចបានវឌ្ឍនភាពជាខ្លាំងក្នុងការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំនៅបឋមសិក្សា និងឧត្តមសិក្សា។** ការផ្ដោតការយកចិត្តទុកដាក់សព្វថ្ងៃ ចាំបាច់ត្រូវលើកកម្ពស់លទ្ធភាពចូលរៀនចំពោះការអប់រំកុមារតូច និងការអប់រំនៅមធ្យមសិក្សា និងការបង្កើនគុណភាពនៃលទ្ធផលសម្រាប់រយៈពេលវែង។ ដូចក្នុងវិស័យដទៃទៀតដែរ វិស័យអប់រំនៅកម្ពុជានៅតែពឹងផ្អែកជាខ្លាំងការគាំទ្ររបស់ម្ចាស់ជំនួយបរទេស។ ទោះជាមានជំនួយបរទេសយ៉ាងច្រើនក្ដី ក៏ចំណាយរួមរបស់រដ្ឋាភិបាលនៅតែមានចំនួនច្រើន ដូចចំណាយគ្រួសារដែរធ្វើឱ្យមានបន្ទុកធ្ងន់មកលើស្រទាប់ប្រជាជន។

**ចំណាយរដ្ឋាភិបាលលើវិស័យអប់រំ ត្រូវបានអនុវត្តស្របតាមផែនការរបស់រដ្ឋាភិបាល ប៉ុន្តែធៀបជាមួយ ផសស ចំណាយនេះទាបជាងបណ្ដាប្រទេសដែលមាន ផសស គិតលើមូលដ្ឋានពលរដ្ឋម្នាក់ៗ ដែលមានកម្រិតប្រហាក់ប្រហែលនឹងកម្ពុជា។** មុនពេលពិចារណាបង្កើនចំណាយរួមលើវិស័យអប់រំ សូមឱ្យអាជ្ញាធរនានាពិចារណាអំពីសក្ដានុពលនៃការសន្សំពីការធ្លាក់ចុះយ៉ាងច្រើនក្នុងការចុះឈ្មោះចូលរៀនរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ។ ការសន្សំបែបនេះនឹងអាចទទួលបាន ប្រសិនបើសមត្ថកិច្ចអាចបែងចែងធនធានជាថ្មីឡើងវិញពីសាលារៀន និងបណ្ដាស្រុក ដែលការចុះឈ្មោះចូលរៀនធ្លាក់ចុះ។ ការសន្សំមួយផ្នែកតូចទាំងនេះ ប្រហែល ០,១ ភាគរយ នៃ ផសស អាចត្រូវបានប្រើប្រាស់ ដើម្បីបែងចែងមូលនិធិគ្រប់គ្រាន់ ដើម្បីបង្កើនចំនួនសៀវភៅសិក្សា។ ការសន្សំទាំងនេះមួយចំនួន ឬការគាំទ្របន្ថែមរបស់ម្ចាស់ជំនួយ អាចផ្ដល់ធនធានបន្ថែមសម្រាប់អាហារូបករណ៍សិស្ស។

**ក្របខ័ណ្ឌនៃការកសាងផែនការ និងកសាងថវិកាក្នុងវិស័យអប់រំ ជាទូទៅដំណើរការបានល្អ។** វិស័យនេះនៅមានឱកាសសម្រាប់លើកកម្ពស់អនុកម្មវិធីនៃថវិកាកម្មវិធី ដើម្បីផ្ដល់ថវិកាប្រតិបត្តិការដល់សាលារៀន។ នៅពេលដែលប្រគល់ការទទួលខុសត្រូវបន្ថែមសមត្ថកិច្ច គប្បីធ្វើយ៉ាងណាឱ្យបញ្ហាអភិបាលកិច្ចត្រូវបានដោះស្រាយឱ្យបានគ្រប់គ្រាន់ ដើម្បីលើកកម្ពស់លទ្ធផល។ សមត្ថភាពធ្វើប្រព្រឹត្តិកម្មទិន្នន័យសម្រាប់សេចក្ដីសម្រេចចិត្តទាក់ទងនឹងគោលនយោបាយ ការកសាងផែនការ និងការអនុវត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ត្រូវពង្រឹងផងដែរ។ ជាពិសេសការតាមដានផែនការយុទ្ធសាស្ត្រអប់រំ ចាំបាច់ត្រូវគិតគូរដល់ឱកាស ដើម្បីកែសម្រួលសកម្មភាពគោលនយោបាយលើមូលដ្ឋាននៃកម្រិតសមិទ្ធផល។ គុណភាពអប់រំដែលវាស់ស្ទង់តាមរយៈការវាយតម្លៃសិស្ស ចាំបាច់ត្រូវបញ្ជ្រាប និងពង្រីកពីអភិក្រមផ្អែកលើគម្រោងបច្ចុប្បន្ន ដើម្បីផ្ដល់រង្វាស់ច្បាស់លាស់លើមូលដ្ឋានដែលត្រូវធ្វើសេចក្ដីសម្រេចចិត្ត និងធ្វើការវាយតម្លៃថា តើធនធានសាធារណៈត្រូវបានចំណាយត្រឹមត្រូវដែរ ឬយ៉ាងណា។

# សេចក្ដីសន្និដ្ឋាន និងការផ្ដល់តម្លៃចំពោះអនុសាសន៍

សរុបមក របាយការណ៍នេះបង្ហាញសារសំខាន់ៗដូចតទៅ :

- **ការបង្កើនលំហសារពើពន្ធតាមរយៈការកាត់បន្ថយការលើកលែងពន្ធ ការរឹតបន្តឹងការប្រមូលពន្ធ និងការកែសម្រួលរចនាសម្ព័ន្ធចំណាយបច្ចុប្បន្ន អាចជួយផ្ដល់ឱកាសសម្រាប់បង្កើនវិភាជន៍ទៅកាន់កន្លែងសំខាន់ៗ ដើម្បីធានាឱ្យមានកំណើនខ្ពស់ និងពេញលេញប្រកបដោយនិរន្តរភាព។** ការណ៍រួមមាន ហេដ្ឋារចនាសម្ព័ន្ធ ការផ្ដល់មូលនិធិគ្រប់គ្រាន់សម្រាប់ស្ដារនីតិ-សម្បទា និងការថែទាំនៃចំណាយបច្ចុប្បន្នមូលធន ការស្រាវជ្រាវ និងផ្សព្វផ្សាយក្នុងវិស័យកសិកម្ម សៀវភៅសិក្សា និងសៀវភៅណែនាំក្នុងវិស័យអប់រំ។
- **ការលើកកម្ពស់គុណភាព ការគ្រប់ដណ្ដប់ និងការចាត់ថ្នាក់មុខចំណាយនៅក្នុងថវិការបស់រដ្ឋាភិបាលមានសារៈសំខាន់សម្រាប់រៀបចំអនុវត្ត និងតាមដានគោលនយោបាយរដ្ឋាភិបាល និងពង្រឹងគណនេយ្យភាព។** អាជ្ញាធរមានសមត្ថកិច្ចគប្បីព្យាយាមធ្វើឱ្យចំណាយទាំងអស់របស់រដ្ឋាភិបាលអនុវត្តទៅក្នុងថវិកា រាប់ទាំងការចំណាយបើកផ្ដល់ចំពោះគម្រោង និងសហប្រតិបត្តិការបច្ចេកទេសដែលផ្ដល់

ហិរញ្ញប្បទានដោយម្ចាស់ជំនួយ និងប្រាក់ឧបត្ថម្ភរបស់ម្ចាស់ជំនួយលើប្រាក់ខែមន្ត្រីរាជការស៊ីវិលផងដែរ ។ ចាំបាច់ត្រូវមានកិច្ចព្រមព្រៀងគ្នាលើរបាយការណ៍ចំណាយចំពោះគម្រោងដែលគាំទ្រដោយម្ចាស់ជំនួយ ដែលរៀបចំដោយប្រើប្លង់គណនីរបស់រដ្ឋាភិបាល ដែលនឹងបង្កលក្ខណៈក្នុងការដាក់បញ្ចូលចំណាយគម្រោងទាំងនោះទៅក្នុងថវិកាបានល្អប្រសើរ ។

- **ចាំបាច់ត្រូវមានការតម្រឹមរវាងថវិកា ការកសាងផែនការយុទ្ធសាស្ត្រ និងការគាំទ្ររបស់ម្ចាស់ជំនួយ។** ចាំបាច់ត្រូវរៀបចំយុទ្ធសាស្ត្រតាមវិស័យ តាមរយៈសហប្រតិបត្តិការពេញលេញរវាងម្ចាស់ជំនួយ និងរដ្ឋាភិបាល ។ ដើម្បីសម្រេចឱ្យបាននូវគោលដៅទាំងនេះ ចាំបាច់ត្រូវលើកកម្ពស់កិច្ចសហការរវាងម្ចាស់ជំនួយ ដើម្បីជំនះកង្វះភាពជាប្រព័ន្ធ និងលើកកម្ពស់ភាពដឹកនាំរបស់រដ្ឋាភិបាល ។

- **ការជំរុញកំណែទម្រង់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានសារៈសំខាន់ក្នុងការធ្វើឱ្យប្រាកដថា ប្រាក់សាធារណៈត្រូវបានចំណាយប្រកបដោយប្រសិទ្ធភាព ចំណែកឯថវិកា ការទទួលខុសត្រូវ និងរង្វាន់ ត្រូវបានបន្សុីគ្នាបានកាន់តែល្អប្រសើរ។**

- **កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាំបាច់ត្រូវដាក់បញ្ចូលជាមួយកំណែទម្រង់រដ្ឋបាលសាធារណៈ និងវិមជ្ឈការ និងវិសហមជ្ឈការ។** ការបែងចែកការទទួលខុសត្រូវចំពោះការផ្តល់សេវា និងការគ្រប់គ្រងធនធានមានទំនាក់ទំនងជាមួយកម្រិតប្រាក់ខែ ការរៀបចំបុគ្គលិក និងការចាត់ចែងផ្នែកអន្តរជាតិរបស់រដ្ឋាភិបាល ។

- **ការប្រព្រឹត្តិទៅនៃដំណើរការធានាររបស់កម្ពុជាដើម្បីគ្រប់គ្រង និងចំណាយប្រាក់សាធារណៈ ចាំបាច់ត្រូវរៀបចំក្នុងបរិបទទូលាយអំពីវិធីដែលវិស័យសាធារណៈទាំងមូលដំណើរការ។** វឌ្ឍនភាពជាខ្លាំងត្រូវបានសម្រេចក្នុងការអភិវឌ្ឍមូលដ្ឋានគ្រឹះនានា ដើម្បីឱ្យរដ្ឋមានប្រសិទ្ធភាព ។ ប៉ុន្តែមានបញ្ហាជាច្រើនដែលធ្វើឱ្យរាំងស្ទះដល់លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវាសំខាន់ៗ ហើយការសិក្សានានាបានលើកឡើងអំពីអំពើពុករលួយកម្រិតខ្ពស់ដែលតែងតែកើតមាន ។

- **ការបង្កើតអភិបាលកិច្ចដែលកាន់តែមានប្រសិទ្ធភាព តម្លាភាព និងមានមូលដ្ឋានផ្អែកលើវិធាននៅតែជាចំណុចសំខាន់នៃបញ្ហាប្រឈមនៃការអភិវឌ្ឍរបស់កម្ពុជា (និងជាចំណុចសំខាន់នៃការគាំទ្ររបស់ធនាគារពិភពលោកសម្រាប់អនាគតរបស់កម្ពុជា)។** វឌ្ឍនភាពក្នុងការលើកកម្ពស់ហិរញ្ញវត្ថុសាធារណៈ ពឹងផ្អែកសំខាន់លើវឌ្ឍនភាពក្នុងការបង្កើនតម្លាភាព គណនេយ្យភាព និងការចូលរួម ។

**ការវិភាគនៅក្នុងរបាយការណ៍នេះ គឺជាមូលដ្ឋានជាសំណើចំពោះសមត្ថកិច្ចនានាក្នុងការពិចារណាទាក់ទងនឹងកម្រិត និងសមាសភាពនៃចំណាយរបស់រដ្ឋាភិបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងពិសេសជាងនេះទៅទៀតនោះ គឺសម្រាប់វិស័យកសិកម្ម សុខាភិបាល និងអប់រំ។** អនុសាសន៍ទាំងអស់នេះមានបច្ច័យលើផ្អែកសារពើពន្ធ ។ អនុសាសន៍សំខាន់ៗបំផុត ត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោមនេះ ។

### អនុសាសន៍របស់ IFAPER: សេចក្ដីសង្ខេបអំពីបច្ច័យនៃចំណូល និងចំណាយ

| អនុសាសន៍ | បច្ច័យសារពើពន្ធក្នុងមួយឆ្នាំ | សំគាល់ |
|---|---|---|
| **កាត់បន្ថយការលើកលែងពន្ធ** | សន្សំ ០,៦% នៃ ផសស | ទំហំនៃការសន្សំអាចស្មើ ៦-៧% នៃ ផសស |
| **កសិកម្ម** | **ជារួម : គ្មានបច្ច័យជាទូទៅ** | អនុសាសន៍ស្នើឱ្យបែងចែកចំណាយជាថ្មីក្នុងរង្វង់កញ្ចប់ថវិកាបច្ចុប្បន្ន |
| **សុខាភិបាល** | **ជារួម : កាត់បន្ថយចំណាយ** | ស្មើនឹងមួយភាគបីនៃចំណាយសុខាភិបាល |
| បង្កើនប្រសិទ្ធភាពនៃចំណាយផ្គត់ផ្គង់ឱសថ បរិក្ខារ និងចំណាយសម្ភារៈពេទ្យ | សន្សំ ០,៤% នៃ ផសស | |
| បង្កើនចំណាយលើមូលនិធិ សមធម៌សុខភាព | ចំណាយ ០,០១-០,០៥% នៃ ផសស | |
| **អប់រំ** | **ជារួម : ជាទូទៅគ្មានបច្ច័យ** | |
| កន្លែងទំនេរពីការធ្លាក់ចុះ ១២,៥% ក្នុងការចុះឈ្មោះចូលរៀននៅបឋមសិក្សា | សន្សំ ០,០២% នៃ ផសស | |
| ចំណាយបន្ថែមលើអាហារូបករណ៍ និងសៀវភៅសិក្សាសម្រាប់សិស្ស | ចំណាយ ០,០៥% នៃ ផសស | |

*សំគាល់ :* ចំពោះព័ត៌មានលម្អិត សូមពិនិត្យមើលបញ្ជីអនុសាសន៍នៅចុងជំពូក ១-៦។

# ១

# មូលដ្ឋានយុទ្ធសាស្រ្ត ៖ ការស្តារ និងការពង្រីកលំហសារពើពន្ធ

## ក. សេចក្តីផ្តើម

**កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សំគាល់ចាប់តាំងពីការបោះឆ្នោត ដែលគាំទ្រដោយអង្គការសហប្រជាជាតិនៅឆ្នាំ ១៩៩៣។** កម្ពុជាមានសន្តិភាពពេញលេញនៅឆ្នាំ ១៩៩៨ ដែលទ្រទ្រង់ដោយស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្កលក្ខណៈឱ្យសមត្ថកិច្ចនានាជំរុញកំណែទម្រង់រចនាសម្ព័ន្ធផ្សេងៗ ចំណែកឯម្ចាស់ជំនួយវិញបង្កើនការគាំទ្រហិរញ្ញវត្ថុ។ កិច្ចអភិវឌ្ឍទាំងនេះ អនុញ្ញាតឱ្យកម្ពុជាទាញយកឧត្តមភាពពេញលេញអំពីទីតាំងរបស់ខ្លួននៅក្នុងតំបន់ពោរពេញដោយថាមភាពនៅលើពិភពលោក។ ជាមធ្យម ផសស ពិតបានកើនឡើង ៧,៤ ភាគរយ ក្នុងមួយឆ្នាំ ក្នុងអំឡុងទសវត្សរ៍ ១៩៩០ មុនពេលកើនឡើងយ៉ាងឆាប់រហ័សដល់ ៩,៧ ភាគរយ ក្នុងមួយឆ្នាំក្នុងអំឡុងទសវត្សរ៍ឆ្នាំ ២000 ដែលជាកម្រិតកើនឡើងឆាប់រហ័សបំផុតនៅអាស៊ីបូព៌ាបន្ទាប់ពីប្រទេសចិន។ កំណើនឆាប់រហ័សបានជួយបង្កើនចំណូលក្នុងពលរដ្ឋម្នាក់ៗច្រើនជាងបីដងចាប់តាំងពីដើមទសវត្សរ៍ ១៩៩0 ដល់ ៧៦0 ដុល្លារ នៅឆ្នាំ ២0១0 និងកាត់បន្ថយអត្រាភាពក្រីក្រពី ៤៧ ភាគរយ នៅឆ្នាំ ១៩៩៣-១៩៩៤ ដល់ ២១ ភាគរយ នៅឆ្នាំ ២00៨ [២]។ តារាងតុល្យការរបស់រដ្ឋាភិបាលរីកចម្រើនយ៉ាងច្រើន វិនិយោគបរទេសបានកើនឡើងគួរឱ្យកត់សំគាល់ ហើយកំណើនយ៉ាងរហ័សនៃផលិតកម្មវាយនភណ្ឌធ្វើឱ្យកម្ពុជាដើរតាមផ្លូវត្រូវក្លាយទៅជាប្រទេសមួយស្ថិតនៅក្នុងបណ្តាញផលិតកម្មក្នុងតំបន់ និងនៅលើពិភពលោក។

**វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកឆ្នាំ ២00៨-២00៩ បានបញ្ឈប់កំណើនខ្ពស់ដែលមានរយៈពេលពីរទសវត្សរ៍មកហើយ ប៉ុន្តែសេដ្ឋកិច្ចកម្ពុជាបានដោះស្រាយសម្ពាធនៃវិបត្តិនេះបានល្អ។** កំណើន ផសស ពិត (Real GDP is estimated to have declined to 0.1 percent) ធ្លាក់ចុះដល់ 0,១ ភាគរយ នៅឆ្នាំ ២00៩ ខណៈដែលការនាំចេញសម្លៀកបំពាក់ និងការមកដល់នៃភ្ញៀវទេសចរណ៍បានធ្លាក់ចុះ ហើយលទ្ធផលនៃវិស័យសំណង់បានធ្លាក់ចុះ។ ផ្អែកលើប្រាក់តម្កល់យ៉ាងច្រើនដែលកម្ពុជារកបានពីពេលមុន រដ្ឋាភិបាលបានបង្កើនចំណាយ ដើម្បីកាត់បន្ថយវិបត្តិទាំងនេះមកលើតម្រូវការក្នុងស្រុក។ ជាលទ្ធផល ធ្វើឱ្យឱនភាពសារពើពន្ធមានទំហំច្រើនជាងទ្វេដងរហូតដល់ ៨,១ ភាគរយ នៃ ផសស នៅឆ្នាំ ២00៩។ ជាមួយនឹងកំណើនដែលបានងើបឡើងវិញនៅឆ្នាំ ២0១0 និងក្នុងរយៈពេលមធ្យម រដ្ឋាភិបាលនានាព្យាយាមកាត់បន្ថយឱនភាពសារពើពន្ធ និងបង្កើនប្រាក់តម្កល់របស់រដ្ឋាភិបាលជាថ្មីសម្រាប់ធានាការចំណាយក្នុងពេលមានវិបត្តិនាពេលអនាគត។ ជាមួយគ្នានេះ រដ្ឋាភិបាលនានាកំពុងពិនិត្យជម្រើសផ្សេងៗ ដើម្បីបង្កើនលំហសារពើពន្ធ និងបង្កើនលទ្ធភាពប្រើប្រាស់លំហសារពើពន្ធនោះ។ រដ្ឋាភិបាលកំពុងបំពេញបន្ថែមកិច្ចពិភាក្សាទាំងនេះ តាមរយៈកិច្ចប្រឹងប្រែងនានាដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃចំណាយសាធារណៈ។

**ឯកសារស្តីពីការវាយតំលៃចំរុះលើទំនុកចិត្ត និងការពិនិត្យសើរើឡើងវិញលើចំណាយសាធារណៈ (IFAPER) នេះ វិភាគរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃចំណាយរបស់រដ្ឋាភិបាលនៅកម្ពុជា ដោយផ្តោតការយកចិត្តទុកដាក់លើវិស័យកសិកម្ម អប់រំ និងសុខាភិបាល។** ការវិភាគនេះត្រូវបានបំពេញបន្ថែម ដោយការពិនិត្យឡើងវិញនូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ គោលបំណងសំខាន់បំផុតនៃអនុសាសន៍ដែលបានបង្ហាញទាំងនេះ និងការលើកទឹកចិត្តសំខាន់នៃឯកសារ IFAPER គឺដើម្បីគាំទ្រកំណើនខ្ពស់ចំពោះលទ្ធផល និងការងារឱ្យមានចីរភាពជួយកាត់បន្ថយភាពក្រីក្រ និងដើម្បីធ្វើឱ្យប្រាកដថាកម្ពុជាមាននិរន្តរភាពសារពើពន្ធ។

**របាយការណ៍នេះត្រូវបានរៀបចំដូចតទៅ។ ជំពូក ១** បង្ហាញសាវតារពាក់ព័ន្ធដែលមានចរិតយុទ្ធសាស្រ្ត រួមមាន ការអភិវឌ្ឍម៉ាក្រូសេដកិច្ច និងសារពើពន្ធ។ ជំពូកនេះសង្ខេបដោយបង្ហាញជម្រើសនានាសម្រាប់ស្តារ និងពង្រីកលំហសារពើពន្ធរបស់រដ្ឋាភិបាល។ **ជំពូក ២** ពិភាក្សាអំពីកម្រិត និងសមាសភាពនៃចំណាយសាធារណៈ។ ចំណាយរដ្ឋាភិបាលធៀបនឹង ផសស ជាទូទៅស្របជាមួយកម្រិតចំណាយក្នុងបណ្តាប្រទេសដែលមានចំណូលក្នុងពលរដ្ឋម្នាក់ៗ និងលទ្ធផលនៃចំណាយនេះប្រហាក់ប្រហែលគ្នា។ ទោះជាយ៉ាងណាក្តី

---

*២ តួលេខមធ្យមភាគអំពីភាពក្រីក្រនៅឆ្នាំ ២00៩ មានកម្រិតល្មៀងស្តង់ដារធំជាងកម្រិតល្មៀងស្តង់ដារកាលពីមុន ដោយសារមានទំហំសំណាកតូច (៣.៥៤៨ គ្រួសារ) និងការកើនឡើងថ្លៃស្បៀងអាហារ និងថ្លៃឥន្ធនៈនាឆ្នាំនោះ។ អង្កេតគ្រួសារដែលមានទ្រង់ទ្រាយធំ ត្រូវបានធ្វើនៅឆ្នាំ ២00៩ ហើយនៅពេលដែលមានទិន្នន័យទាំងនេះ នោះនឹងមានទិដ្ឋភាពច្បាស់លាស់បន្ថែមទៀតអំពីទម្រង់នៃភាពក្រីក្រនៅកម្ពុជា។*

ដើម្បីឱ្យសេដ្ឋកិច្ចបន្តរីកចម្រើនរឹងមាំ រដ្ឋាភិបាលនានាបានដាក់ចេញនូវគោលដៅដែលមានមហិច្ឆតាខ្ពស់ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយឆាប់រហ័ស។ អនុសាសន៍ដែលបង្ហាញនៅក្នុងជំពូកនេះ ត្រូវបានរៀបចំក្នុងគោលដៅនេះ។

**ជំពូក ៣-៤ និង ៥ ពិភាក្សាអំពីកម្រិតសមាសភាព និងប្រសិទ្ធភាពចំណាយរបស់រដ្ឋាភិបាលលើវិស័យកសិកម្ម សុខាភិបាល និងអប់រំតាមលំដាប់ជំពូក។** ការវិភាគបង្ហាញថា ចំណាយរបស់រដ្ឋាភិបាលក្នុងផ្នែកទាំងនេះធៀបនឹង ផសស មានកម្រិតទាបជាងនៅបណ្ដាប្រទេសដែលមានកម្រិតនៃប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់ៗប្រហាក់ប្រហែលគ្នា។ ទោះជាយ៉ាងណាក្ដី លទ្ធផលនៃចំណាយមានសង្គតិភាពជាមួយចំណាត់ថ្នាក់ប្រាក់ចំណូល។ ការវិភាគសន្និដ្ឋានថា ខណៈពេលដែលការបន្ថែមមូលនិធិទៅកាន់ផ្នែកជាក់លាក់ អាចជួយបង្កើនលទ្ធផលមួយចំនួន វិភាជន៍ថវិកាដែលមានទំហំកាន់តែធំ នឹងអាចប្រព្រឹត្តិទៅបាន ប្រសិនបើគេរកឃើញលំហសារពើពន្ធបន្ថែម និងប្រសិនបើប្រសិទ្ធភាពចំណាយរបស់រដ្ឋាភិបាល និងគុណភាពនៃការផ្ដល់សេវាត្រូវបានលើកកម្ពស់។

**ជំពូក ៦ ពិភាក្សាអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានារបស់កម្ពុជា ក្នុងការកែទម្រង់គោលនយោបាយចំណាយសាធារណៈ និងហិរញ្ញប្បទានសាធារណៈ។** ការលើកកម្ពស់សមិទ្ធផលចំពោះភាពជឿទុកចិត្តនៃថវិកានៅក្នុងជំហានទីមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានលក្ខណៈគួរឱ្យកត់សំគាល់ ប៉ុន្តែការធ្វើឱ្យវឌ្ឍនភាពមាននិរន្តរភាពនៅតែជាបញ្ហាប្រឈមចម្បងមួយ។ ជំហានទីពីរជាជំហានពង្រីកកំណែទម្រង់នានា និងមានគោលបំណងប្រគល់ការទទួលខុសត្រូវផ្នែកថវិកាកាន់តែធំ ទៅកាន់អ្នកគ្រប់គ្រងកម្មវិធីតាមរយៈការលើកកម្ពស់យន្តការត្រួតពិនិត្យផ្ទៃក្នុង និងយន្តការគណនេយ្យភាព។ ជំពូកនេះគូសបញ្ជាក់ផ្នែកសំខាន់ៗ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែម ដើម្បីជួយពន្លឿនរបៀបវារៈកំណែទម្រង់។ ទាំងនេះរួមមាន ការលើកកម្ពស់កិច្ចសហការជាមួយម្ចាស់ជំនួយ ការពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការតម្រឹមតម្រង់កំណែទម្រង់វិស័យសាធារណៈទាំងអស់ និងតម្រូវឱ្យកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ប្រាក់ឧបត្ថម្ភ លើកកម្ពស់ប្រសិទ្ធភាព (improve government effi ciency) និងពង្រឹងគុណភាពនៃសេវាសាធារណៈ។

## ២. ការអភិវឌ្ឍសេដ្ឋកិច្ច និងបញ្ហាប្រឈមកន្លងទៅថ្មីៗ

**កំណើនខ្ពស់បានវិលមកវិញក្រោយពីការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ចបណ្ដាលមកពីវិបត្តិនៅឆ្នាំ ២០០៩។** ការយកចិត្តទុកដាក់របស់សមត្ថកិច្ចបានប្ដូរពីការឆ្លើយតបនឹងវិបត្តិទៅកាន់គោលនយោបាយដែលចាំបាច់ ដើម្បីធានាដល់ការពង្រីកសេដ្ឋកិច្ចរឹងមាំ និងពេញលេញក្នុងរយៈពេលវែង និងអន្តរកាលទៅកាន់ឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យម។

### លទ្ធផល ការងារ និងអតិផរណា

**រចនាសម្ព័ន្ធនាំចេញដែលមានលក្ខណៈប្រមូលផ្ដុំរបស់កម្ពុជា ភាពពឹងផ្អែកយ៉ាងច្រើនលើវិនិយោគបរទេស និងជំនួយបរទេស និងទីផ្សារក្នុងស្រុកដែលមានទំហំតូច បានរួមចំណែកចំពោះការធ្លាក់ចុះនៃសេដ្ឋកិច្ច** (contraction of output) **នៅឆ្នាំ ២០០៩។** ផសស ពិត ត្រូវបានគណនា (Real GDP is estimated to have declined) ធ្លាក់ចុះដល់ 0,១ ភាគរយ នៅឆ្នាំ ២០០៩ បន្ទាប់ពីការកើនឡើងជាមធ្យមចំនួន ៩,៧ ភាគរយ ចន្លោះឆ្នាំ ១៩៩៩ និង ២០០៨។ ការធ្លាក់ចុះលទ្ធផលបានឆ្លុះបញ្ចាំងនូវការធ្លាក់ចុះក្នុងការផលិតសម្លៀកបំពាក់ និងការនាំចេញ និងការធ្លាក់ចុះនៃវិស័យសំណង់ និងទេសចរណ៍ ទោះបីជាផលិតកម្មកសិកម្មមានកំណើនរឹងមាំក្ដី។ កម្ពុជាបានក្លាយខ្លួនជាប្រទេសនាំចេញសម្លៀកបំពាក់នៅពាក់កណ្ដាលទសវត្សរ៍ ១៩៩០ ហើយសម្លៀកបំពាក់បានកើនឡើងឆាប់រហ័សពីឧស្សាហកម្មនាំចេញចំនួន ២៧ លានដុល្លារ នៅឆ្នាំ ១៩៩៥ ដល់ ៣ ពាន់លានដុល្លារ នៅឆ្នាំ ២០១០។ សព្វថ្ងៃឧស្សាហកម្មនេះ គឺជាវិស័យដែលនាំមកនូវរូបិយប័ណ្ណបរទេសច្រើនជាងគេនៅកម្ពុជា ពោល គឺត្រូវជា ៦០ ភាគរយ នៃចំណូលនាំចេញរបស់កម្ពុជា និងស្រូបយកការងារជិតស្មើមួយភាគបួននៃការងារផ្នែកឧស្សាហកម្ម។ វិស័យទេសចរណ៍ក៏បានកើនឡើងយ៉ាងឆាប់រហ័សផងដែរ ដែលចំណូលទេសចរណ៍កើនឡើងដប់ដងក្នុងទសវត្សរ៍ចុងក្រោយដល់ ១,៨ ពាន់លានដុល្លារ នៅឆ្នាំ ២០១០។

**សេដ្ឋកិច្ចបានហក់ចេញឆ្ងាយពីវិបត្តិ។** ការកើនឡើងសាជាថ្មីចំពោះការមកដល់នៃភ្ញៀវទេសចរណ៍ និងការនាំចេញសម្លៀកបំពាក់ហាក់ដូចជាបានជួយ ផសស ពិត ឱ្យកើនឡើង ៦,0 ភាគរយ នៅឆ្នាំ ២០១០ ប្រហែលជាស្មើឆ្នាំ ២០១១។ វិធានការជំរុញសារពើពន្ធឆ្នាំ ២០០៩ ក៏បានជួយដល់សភាពការណ៍នេះផងដែរ (រូបលេខ ២)។ ការនាំចេញសម្លៀកបំពាក់បានកើនឡើង ២៤ ភាគរយ នៅឆ្នាំ ២០១០ ដែលឆ្លុះឱ្យឃើញការងើបឡើងវិញនៃការលក់រាយនៅសហរដ្ឋអាមេរិក ដែលជាទីផ្សារសំខាន់បំផុតសម្រាប់កម្ពុជា។ ការមកដល់នៃភ្ញៀវទេសចរណ៍កំពុងស្ថិតលើនិន្នាការងើបឡើង ហើយទំនងជាបានកើនឡើងប្រមាណជា ១៦ ភាគរយ មកហើយក្នុង

**រូបលេខ ១. លទ្ធផលកើនឡើងជាថ្មីបន្ទាប់ពីការធ្លាក់ចុះបណ្តាលមកពីវិបត្តិនៅឆ្នាំ ២០០៩**
(គិតជា ភាគរយ)




*ប្រភព* : វិទ្យាស្ថានជាតិស្ថិតិ និងធនាគារពិភពលោក

**រូបលេខ ២. ឱនភាពសារពើពន្ធនៅតែមានទំហំធំបន្ទាប់ពីការកើនឡើងនៅឆ្នាំ ២០០៩**
(គិតជា ភាគរយនៃផសស)




*ប្រភព* : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មូលនិធិរូបិយវត្ថុអន្តរជាតិ និងការប៉ាន់ស្មានរបស់ធនាគារពិភពលោក

ឆ្នាំ ២០១១ ជាមធ្យមមានល្បឿនដូចគ្នាក្នុងអំឡុងឆ្នាំ ២០០៥-២០១០។ កសិកម្មនៅតែមានលទ្ធភាពរីកចម្រើនខ្ពស់ខណៈដែលផលិតកម្មស្រូវកើនឡើងជាមធ្យម ១៣ ភាគរយក្នុងមួយឆ្នាំ ចាប់តាំងពីឆ្នាំ ២០០៥ មក។ ដោយសារការប្រមូលផលបានច្រើន ថ្លៃស្រូវជាទូទៅមិនប្រែប្រួលក្នុងអំឡុងឆ្នាំ ២០១០ ជាឆ្នាំមួយដែលប្រទេសជាច្រើននៅក្នុងតំបន់រងគ្រោះពីការកើនឡើងនូវថ្លៃស្បៀងអាហារទាក់ទងនឹងបញ្ហាធាតុអាកាស។ ប្រមាណជា ៧០ ភាគរយនៃកម្លាំងពលកម្ម មានការងារធ្វើនៅក្នុងវិស័យកសិកម្មភាគច្រើនដើម្បីចិញ្ចឹមក្រពះ ហើយវិស័យនេះមានភាគរយពលរដ្ឋក្រីក្រខ្ពស់បំផុតនៅក្នុងប្រទេសចំនួនប្រហែល ៧៩[៣]។

**អតិផរណាទូទៅបានធ្លាក់ចុះដល់ ៣,១ ភាគរយ នៅឆ្នាំ ២០១០ ពី ៥,៣ ភាគរយ នៅឆ្នាំ ២០០៩។** ក្នុងស្ថានភាពនៃដុល្លាររូបនីយកម្មនៃសេដ្ឋកិច្ច និងទំនាក់ទំនងស្អិតរមួតរវាងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកមានហានិភ័យ ដែលថាការកើនឡើងនូវថ្លៃស្បៀងអាហារ និងប្រេងឥន្ធនៈអន្តរជាតិ ថាអាចមានឥទ្ធិពលអវិជ្ជមានមកលើថ្លៃក្នុងស្រុក។ ទោះជាយ៉ាងណាក្តី ការប្រមូលផលបានល្អ និងសន្និធិគ្រប់គ្រាន់កន្លងមក បានកាត់បន្ថយផលប៉ះពាល់។

## ជញ្ជីងទូទាត់

**ការងើបឡើងវិញក្នុងផ្នែកវិនិយោគក្នុងស្រុក និងការប្រើប្រាស់ទំនងជាបានបង្កើនឱនភាពគណនីចរន្តជាថ្មីនៅឆ្នាំ ២០១០។** ឱនភាពពីបរទេសហាក់ដូចជាបានកើនដល់ ៧,១ ភាគរយ នៃ ផសស នៅឆ្នាំ ២០១០ ពីកម្រិត ៥,៤ ភាគរយ នៅឆ្នាំ ២០០៩ និង ២,៨ ភាគរយ ជាមធ្យមក្នុងអំឡុងឆ្នាំ ២០០០ ដល់ ២០០៨។ ឱនភាពនេះ មួយផ្នែកធំបណ្តាលមកពីឱនភាពជញ្ជីងពាណិជ្ជកម្មដោយសារការនាំចូល និងនាំចេញបានងើបឡើងវិញជាខ្លាំង។

**លំហូរមូលធនសុទ្ធចូលមកក្នុងប្រទេសបានកើនឡើងក្នុងឆ្នាំ ២០១០ សម្រាប់ធ្វើហិរញ្ញប្បទានឱនភាពពីបរទេស និងបង្កើនប្រាក់បម្រុងរូបិយប័ណ្ណបរទេស។** ក្នុងឆ្នាំ ២០១០ លំហូរមូលធនចូលមកក្នុងប្រទេសបានកើនឡើងប្រមាណជា ២៥ ភាគរយ ស្មើនឹង ១,៣ ពាន់លានដុល្លារ (នៅឆ្នាំ ២០០៩ លំហូរទុនសុទ្ធចូលមកក្នុងប្រទេសមានចំនួនជិតស្មើនឹង ០,៣ ពាន់លានដុល្លារ) សឱ្យឃើញការកើនឡើងនូវវិនិយោគផ្ទាល់ពីបរទេស (FDI) និងប្រាក់កម្ចីយ៉ាងច្រើនពីធនាគារបរទេស។ ប្រាក់បម្រុងរូបិយប័ណ្ណបរទេសបានកើនឡើងដល់ ២,៧ ពាន់លានដុល្លារ នៅចុងឆ្នាំ ២០១០ សមមូលនឹងទឹកប្រាក់សម្រាប់នាំចូលប្រមាណជាចំនួនបួនខែ ដែលជាកម្រិតមួយខ្ពស់បំផុតក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក។ ហើយសញ្ញាសេដ្ឋកិច្ចល្អប្រសើររបស់កម្ពុជាធ្វើឱ្យលំហូរវិនិយោគផ្ទាល់ពីបរទេស (FDI) កើនឡើងវិញនៅឆ្នាំ ២០១០-២០១១ បន្ទាប់ពីធ្លាក់ចុះនៅឆ្នាំ ២០០៩។ គេរំពឹងថា ការហូរចូលវិនិយោគផ្ទាល់ពីបរទេសនឹងកើនពី ៦,៧ ភាគរយ នៃ ផសស នៅឆ្នាំ ២០១០ ដល់ ៧,១ ភាគរយ នៅឆ្នាំ ២០១១។

៣ *ធនាគារពិភពលោក ឆ្នាំ ២០០៥ "Cambodia Rural Sector Strategy Note: Towards a Strategy for Rural Growth and Poverty Reduction", ខែមិថុនា*

## គោលនយោបាយរូបិយវត្ថុ និងការអភិវឌ្ឍធនាគារ

**សេដ្ឋកិច្ចកម្ពុជាជាសេដ្ឋកិច្ចចាយប្រាក់ដុល្លារ ធ្វើឱ្យជម្រើសរបស់អ្នកធ្វើគោលនយោបាយរូបិយវត្ថុមានតិចតួច។** មុខងារនៃរូបិយវត្ថុក្នុងស្រុកបានធ្លាក់ចុះទៅតាមពេលវេលា ហើយនៅចុងឆ្នាំ ២០១០ ប្រាក់បញ្ញើជាប្រាក់រៀលមានចំនួនត្រឹមតែ ៣,១ ភាគរយ នៃប្រាក់បញ្ញើធនាគារសរុបប៉ុណ្ណោះ។ ដុល្លារូនីយកម្មទូទៅ គឺជាកត្តាសំខាន់ក្នុងការដឹកនាំធនាគារកណ្ដាលក្នុងការរក្សាប្រាក់រៀលឱ្យមានទំនាក់ទំនងជិតស្និទ្ធជាមួយប្រាក់ដុល្លារអាមេរិក ដោយរក្សាកម្រិតប្រែប្រួលត្រឹម ± ១ ភាគរយ។ សូម្បីតែជាមួយមធ្យោបាយរឹតបន្តឹងបែបនេះក្តី ធនាគារកណ្ដាលបានបន្ធូរស្ថានភាពរូបិយវត្ថុនៅឆ្នាំ ២០០៩ ដោយកាត់បន្ថយអនុបាតប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាពី ១៦ ភាគរយ នៃប្រាក់បញ្ញើដុលមកត្រឹម ១២ ភាគរយ និងដោយលុបបំបាត់ការដាក់កំហិតលើការឱ្យខ្ចីចងការចំពោះផ្នែកអចលនទ្រព្យ។

**តារាងលេខ ១. សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា**

| | ២០០១ ... | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០e | ២០១១f |
|---|---|---|---|---|---|---|---|
| **លទ្ធផល ការងារ និងថ្លៃ** | (អត្រាភាគរយប្រែប្រួលប្រចាំឆ្នាំ វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ) | | | | | | |
| ផសស ពិត | ១០,៧ | ១០,៨ | ១០,២ | ៦,៧ | ០,១ | ៦,០ | ៦,០ |
| ផលិតកម្មឧស្សាហកម្ម | ១១,២ | ១៨,៣ | ៨,៤ | ៤,០ | -៩,៥ | ១៣,៥ | ១០,៥ |
| ថ្លៃទំនិញប្រើប្រាស់ | ០,៧ | ៤,២ | ១៤,០ | ១២,៥ | ៥,៣ | ៣,១ | ៧,៥ |
| **ពាណិជ្ជកម្មក្រៅប្រទេស ជញ្ជីងពាណិជ្ជកម្ម និងបំណុលបរទេស** | (គិតជាលានដុល្លារអាមេរិក វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ) | | | | | | |
| សមតុល្យគណនីចរន្ត (មិនគិតបង្វែរផ្លូវការ) | -៣៤៧ | -៥២២ | -៧០៥ | -១២៨០ | -១.២០៣ | -១.៥៧០ | -១.៦៣១ |
| (% ផសស) | -៨,៧ | -៧,១ | -៨,១ | -១២,៤ | -១១,៦ | -១៣,៥ | -១៣,០ |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរផ្លូវការ) | -៤៥ | -៤៧ | -២៩៦ | -៧០០ | -៥៦២ | -៨២៨ | -១.១៧៩ |
| (% ផសស) | -១,១ | -០,៦ | -៣,៤ | -៦,៨ | -៥,៤ | -៧,១ | -៩,៤ |
| ជញ្ជីងពាណិជ្ជកម្ម | -៥២៣ | -១.០៧៨ | -១.៣៤៣ | -១.៨០១ | -១.៦៣៤ | -១.៦៩៨ | -១.៨៥៩ |
| ការនាំចេញទំនិញ | ១.៥៧១ | ៣.៦៩៣ | ៤.០៨៩ | ៤.៧០៨ | ៤.១៩៦ | ៤.៦៨៧ | ៥.៤៨៣ |
| ការនាំចូលទំនិញ | ២.០៩៤ | ៤.៧៧១ | ៥.៤៣២ | ៦.៥០៩ | ៥.៨៣១ | ៦.៣៨៤ | ៧.៣៤២ |
| វិនិយោគផ្ទាល់ពីបរទេស | ១៥០ | ៤៧៥ | ៨៦៦ | ៧៩៥ | ៥២០ | ៧៧៤ | ៨៩០ |
| បំណុលបរទេស | ១.៣២១ | ២.២៤៥ | ២.៥៥៥ | ២.៨០៨ | ៣.០៩៤ | ៣.៥១៤ | ៣.៨១៣ |
| (% ផសស) | ៣៣ | ៣១ | ២៩ | ២៧ | ៣០ | ៣០ | ៣០ |
| បំណុលរយៈពេលខ្លី | ២២៤ | ២០៩ | ២១៨ | ២១៨ | ២១៨ | ២១៨ | ២១៨ |
| អនុបាតសេវាបំណុល (%) ការនាំចេញទំនិញ និងសេវាកម្ម | ២,៩ | ១,៤ | ១,០ | ១,០ | ១,២ | ១,០ | ១,០ |
| ប្រាក់បម្រុងបរទេស | ៥៤៨ | ១.០៩៧ | ១.៦១៦ | ២.១៦៤ | ២.៣៦៧ | ២.៦៥៣ | ៣.២៣៧ |
| (ចំនួនខែនៃការនាំចូលទំនិញ និងសេវាកម្ម) | ២,៧ | ២,៤ | ៣,១ | ៣,៤ | ៤,១ | ៤,៣ | ៤,៤ |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | | | | |
| ឥណទានក្នុងស្រុក (% ប្រែប្រួលប្រចាំឆ្នាំ) | -៤,១ | ៣៥,៧ | ៧០,៧ | ៥១,១ | ១៩,៩ | ៣៥,៣ | ៣៥,០ |
| អត្រាប្តូរប្រាក់ (រៀល, ដុល្លារអាមេរិក-ចុងគ្រា) | ៣.៩០០ | ៤.០៦១ | ៤.០០៣ | ៤.០៨១ | ៤.១៦៩ | ៤.០៥៣ | ៤.១០០ |
| អត្រាប្តូរប្រាក់ពិត (២០០០ = ១០០) | ៩៩,៧ | ៩២,៤ | ៩៥,១ | ១១១,៧ | ១១១,៣ | ១០៨,០ | .. |
| (% ប្រែប្រួលប្រចាំឆ្នាំ) | -០,៣ | ២,១ | ៣,០ | ១៧,៤ | -០,៤ | -២,៩ | .. |
| កំណត់ចំណាំ : ផសស ជាក់ស្តែង (លាន US$) | ៤.០០៤ | ៧.៣៥០ | ៨.៧៥៤ | ១០.២៨៤ | ១០.៣២៨ | ១១.៦០៨ | ១២.៥២៩ |

*ប្រភព :* មូលនិធិរូបិយវត្ថុអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**កំណើនឥណទានចំពោះផ្នែកឯកជនបានកើនឡើងជាថ្មីនៅឆ្នាំ ២០១០ ក្រោយពីធ្លាក់ចុះជាខ្លាំងនៅឆ្នាំ ២០០៩។** សាច់ប្រាក់ងាយស្រួលធនាគារបានកើនឡើង ប្រាក់បញ្ញើបានកើនឡើងដល់កម្រិតខ្ពស់ស្មើនឹង ៤,៣ ពាន់លានដុល្លារ នៅចុងឆ្នាំ ២០១០។ អនុបាតនៃប្រាក់កម្ចីធៀបនឹងប្រាក់បញ្ញើ ជាទូទៅមិនប្រែប្រួលស្មើនឹង ៧៤ ភាគរយ។ ការឱ្យខ្ចីចងការភាគច្រើនក្នុងឆ្នាំកន្លងទៅ ត្រូវបានផ្តល់ឱ្យពាណិជ្ជកម្មក្នុងស្រុក សកម្មភាពទាក់ទងនឹងទេសចរណ៍ និងកម្មន្តសាលមួយចំនួន។ ការពង្រឹងការគ្រប់គ្រងធនាគារភាគច្រើនផ្តោតលើការអនុវត្តបង្លំគណនេយ្យស្តង់ដារ និងប្រតិបត្តិការដែលមានការធានា ក៏បានជួយបង្កើនទំនុកចិត្តលើប្រព័ន្ធធនាគារផងដែរ។

**រូបលេខ ៣. កំណើន និងអតិផរណាមានកម្រិតខ្ពស់ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ ១៩៩០**
(គិតជា ភាគរយ)




*ប្រភព :* វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់បុគ្គលិក

**រូបលេខ ៤. អត្រាប្តូរប្រាក់ពិតកំពុងធ្លាក់ចុះ**
(ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក)




*ប្រភព :* ធនាគារជាតិនៃកម្ពុជា និងមូលនិធិរូបិយវត្ថុអន្តរជាតិ។

## ភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្ស

**ការកាត់បន្ថយភាពក្រីក្រ និងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សកម្ពុជា** (CMDG) **គឺជាអាទិភាពសំខាន់ៗ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ[៤] របស់រដ្ឋាភិបាល។** អាទិភាពសេដ្ឋកិច្ចសង្គមដទៃទៀត ដែលបានកំណត់នៅក្នុងផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSGC) គឺកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត អភិវឌ្ឍន៍ផ្នែកឯកជន សុខាភិបាល និងអប់រំ។ ដើម្បីសម្រេចគោលដៅទាំងនេះ និងដើម្បីជំរុញការអភិវឌ្ឍស្របតាមអាទិភាពទាំងនេះ រដ្ឋាភិបាលបានប្រកាន់ខ្ជាប់នូវការអនុវត្តការចំណាយដោយប្រុងប្រយ័ត្ន ក្នុងន័យធានាការវិភាជន៍ធនធានសាធារណៈឱ្យបានត្រឹមត្រូវទៅតាមគោលដៅអាទិភាពនីមួយៗ។ តាមធម្មតា វិស័យសុខាភិបាល អប់រំ និងដឹកជញ្ជូន ត្រូវបានផ្តល់មូលនិធិគ្រប់គ្រាន់ទៅតាម ផយអជ រីឯការផ្តល់មូលនិធិសម្រាប់អភិវឌ្ឍន៍ជនបទ និងកសិកម្មវិញ នៅមានកម្រិតទាបដោយសារគម្រោងស្ពារ និងអភិវឌ្ឍន៍ជាច្រើនក្នុងវិស័យនេះ ត្រូវបានទ្រទ្រង់ដោយមូលនិធិពីដៃគូអភិវឌ្ឍន៍ (ឧបសម្ព័ន្ធលេខ ៦)។

**របាយការណ៍របស់អង្គការសហប្រជាជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្ស** (MDG) **បានលើកសរសើរកម្ពុជាចំពោះការធ្វើឱ្យមានវឌ្ឍនភាពជាជំហានៗ ឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្ស ជាពិសេសចំពោះគោលដៅកាត់បន្ថយភាពក្រីក្រមកត្រឹម ១៩,៥ ភាគរយ នៅឆ្នាំ ២០១៥[៥]។** ជាមួយនឹងភាពជឿនលឿនរឹងមាំទាំងនេះ របាយការណ៍នេះបានកត់សំគាល់អំពីវឌ្ឍនភាពយឺតរបស់កម្ពុជាក្នុងការកាត់បន្ថយអត្រាស្លាប់កុមារអាយុតិចជាង ៥ ឆ្នាំ និងអត្រាស្លាប់របស់មាតា ព្រមទាំងការសម្រេចឱ្យបាននូវការអប់រំបឋមសិក្សាទូទៅ (ឧបសម្ព័ន្ធលេខ ១)។

---

៤ *គោលនយោបាយសេដ្ឋកិច្ចត្រូវបានដឹកនាំដោយផែនការប្រាំឆ្នាំចាប់តាំងពីឆ្នាំ ១៩៩៦ មក។ ផែនការទាំងនោះផ្តោតលើស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនខ្ពស់ និងការកាត់បន្ថយភាពក្រីក្រ។ ក្នុងអំឡុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទីមួយ (១៩៩៦-២០០០) កំណើន ផសស ពិតមានកម្រិតមធ្យមស្មើនឹង ៧,៥ ភាគរយ។ កំណើននេះបានកើនឡើងយ៉ាងខ្ពស់នៅក្នុងអំឡុងផែនការលើកទីពីរ (២០០១-២០០៥) ក្រោយមកហៅថាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ដែលកំណើនផលិតផលស្មើនឹង ៩,២ ភាគរយ ក្នុងមួយឆ្នាំ។ ទោះបីជាមានវិបត្តិសេដ្ឋកិច្ចពិភពលោកក្តី កំណើនក្នុងពេលមាន ផយអជ (២០០៦-២០១០) នៅតែមានកម្រិតខ្ពស់ស្មើនឹង ៦,៧ ភាគរយ ក្នុងមួយឆ្នាំ ជាទូទៅអនុវត្តបានតាមផែនការ។ ផយអជ បច្ចុប្បន្នកម្មកំណត់កំណើនសេដ្ឋកិច្ច ៦ ភាគរយក្នុងមួយឆ្នាំ និងកំណត់ប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់ៗស្មើនឹង ១.០០០ ដុល្លារ នៅឆ្នាំ ២០១៣។*

៥ *របាយការណ៍រួមរបស់ UNDP ADB និង UNESCAP; "Paths to 2015: MDG Priorities in Asia and the Pacific" 2010/11*

# គ. ស្ថានភាពសារពើពន្ធ

**ការប្រុងប្រយ័ត្នផ្នែកសារពើពន្ធ និងការកើនឡើងប្រាក់ចំណូល ដោយសារកំណើនខ្ពស់ និងការប្រមូលពន្ធបានច្រើនបានជួយកាត់បន្ថយឱនភាពសារពើពន្ធយ៉ាងច្រើនក្នុងទសវត្សរ៍រហូតដល់ឆ្នាំ ២០០៨។** ទោះជាយ៉ាងណាក្តី ចំណាយរដ្ឋាភិបាលបានចាប់ផ្តើមកើនឡើងនៅឆ្នាំ ២០០៦ ពីកម្រិតទាប កើនឡើងជិត ១៥ ភាគរយ នៃផសស នៅឆ្នាំ ២០០៨។ ជាមួយគ្នានេះ រដ្ឋាភិបាលបានបង្កើនប្រាក់បញ្ញើនៅធនាគារកណ្តាលច្រើនជាងម្តេដងដល់ចំនួន ៧៣២ លានដុល្លារ ចាប់ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៨។ ប្រាក់បញ្ញើដ៏ច្រើននេះបានបង្កលក្ខណៈឱ្យរដ្ឋាភិបាលបង្កើនចំណាយខ្ពស់បំផុតនៅឆ្នាំ ២០០៩ ក្នុងការជួយកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោក ។

## តុល្យភាពសារពើពន្ធក្នុង និងក្រោយពេលមានវិបត្តិ

**ការធ្លាក់ចុះជាខ្លាំងនៃសកម្មភាពសេដ្ឋកិច្ច ក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ចពិភពលោក ធ្វើឱ្យរដ្ឋាភិបាលបង្កើនឱនភាពសារពើពន្ធមួយចំណែកដើម្បីសម្រាលផលប៉ះពាល់នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចចំពោះតម្រូវការក្នុងស្រុក។** នេះ គឺជាការសម្រេចចិត្តច្បាស់លាស់ និងសមស្រប ទោះបីជាមានការលើកឡើងនូវកង្វល់នានាអំពីការធ្វើឱ្យកើនឡើងយ៉ាងច្រើនចំពោះបញ្ជីប្រាក់ខែក្តី ។ តុល្យភាពសារពើពន្ធបានប្តូរពីអតិរេកស្មើនឹង ០,៣ ភាគរយ នៃ ផសស ទៅជាមានឱនភាព ៤ ភាគរយ នៅឆ្នាំ ២០០៩ (តារាងលេខ ២) រាប់ទាំងជំនួយឥតសំណងនៅឆ្នាំ ២០០៨ ផងដែរ ។ ការបាត់តុល្យភាពស្ទើរតែទាំងអស់ បានឆ្លុះបញ្ចាំងនូវការចំណាយច្រើនជាងមុន ធ្វើឱ្យការកើនឡើងនូវចំណាយវិនិយោគស្ទើរតែមានកម្រិតស្មើគ្នា និងកំណើនបៀវត្សសាធារណៈ ។ ចំណូលពន្ធបានជួយសម្រាលសភាពការណ៍បានតិចតួច ទោះបីជាចំណូលពន្ធបានធ្លាក់ចុះក្តី ព្រោះថាវិស័យដែលរងគ្រោះខ្លាំងបំផុត ដោយវិបត្តិនេះ - រួមមានសម្លៀកបំពាក់ផងដែរ - ធ្លាប់ត្រូវបានផ្តល់ការលើកលែងពន្ធច្រើនកាលពីមុន មានន័យថា ទោះជាយ៉ាងណាក៏ដោយការបង់ពន្ធពីវិស័យកាត់ដេរមានកម្រិតទាប ។

**គោលនយោបាយសារពើពន្ធ គឺជាឧបករណ៍ចម្បងសម្រាប់គ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ក្នុងពេលដែលដុល្លាវូបនីយកម្មកើតមានជាទូទៅ និងការចងប្រាក់រៀលជាមួយដុល្លារ។** ខណៈពេលដែលសេដ្ឋកិច្ចងើបចេញពីវិបត្តិ រដ្ឋាភិបាលប្រឹងប្រែងដកចេញនូវការបន្ធូរបន្ថយសារពើពន្ធនៅឆ្នាំ ២០០៩។ ការណ៍នេះអាចធានាឱ្យមាននិរន្តរភាពសារពើពន្ធ និងការពិចារណារយៈពេលខ្លី ដែលចង្អុលបង្ហាញគោលនយោបាយសារពើពន្ធក្នុងអំឡុងពេលមានវិបត្តិ អមដោយគោលដៅនៃគោលនយោបាយរយៈពេលវែងដូចបានបញ្ជាក់នៅក្នុង ផយអជ ។ ជាងនេះទៅទៀត កំហិតនៃគោលនយោបាយសារពើពន្ធសម្រាប់រយៈពេលខ្លី ត្រូវបានគេដឹងច្បាស់លាស់ ។ ទាំងនេះរួមមាន ភាពយឺតយ៉ាវជាខ្លាំងក្នុងការអនុវត្ត និងភាពមិនប្រាកដប្រជាផ្នែករដ្ឋបាល ។

**នៅឆ្នាំ ២០១០ ឱនភាពសារពើពន្ធហាក់ដូចជាមានកម្រិតទាប ស្មើនឹង ២,២ ភាគរយ នៃ ផសស មួយផ្នែកធំ គឺដោយសារការកើនឡើងនូវប្រាក់ចំណូល។** ចំណូលកើនឡើងដោយសារសេដ្ឋកិច្ចរឹងមាំ ការលើកកម្ពស់ការអនុវត្តពន្ធនាំចូល និងពន្ធគយ ព្រមទាំងការបង្កើនពន្ធផ្លូវទ្វេដងចំពោះយានយន្ត[៦] ។ ចំពោះផ្នែកចំណាយវិញ រដ្ឋាភិបាលបានកាត់បន្ថយការដំឡើងឋានៈមន្ត្រីរាជការ និងការជ្រើសរើសបុគ្គលិកព្រមទាំងកាត់បន្ថយចំណាយឆន្ទានុសិទ្ធិដទៃទៀត ។

*៦ ចាប់ពីឆ្នាំ ២០១០ មក រដ្ឋាភិបាលបានដាក់ឱ្យអនុវត្តការយកពន្ធលើអចលនទ្រព្យ (ដី និងអាគារ ទាំងសំណង់ដែលបានសង់រួចរាល់ និងសំណង់ដែលកំពុងសាងសង់) ក្នុងអត្រា ០,១ ភាគរយក្នុងមួយឆ្នាំ ចំពោះអចលនទ្រព្យដែលមានតម្លៃសមមូល ឬច្រើនជាង ១០០ លានរៀល (ប្រហែល ២៥.០០០ ដុល្លារ) ។*

## តារាងលេខ ២. កម្ពុជា : គណនីសារពើពន្ធទូទៅរបស់រដ្ឋាភិបាល ឆ្នាំ២០០០-២០១០

(គិតជា ភាគរយ នៃផសស)

| | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០e |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុបចំណូល និងជំនួយឥតសំណង | ១៣,០ | ១២,៥ | ១៣,២ | ១១,៨ | ១២,០ | ១២,៤ | ១៤,០ | ១៤,១ | ១៥,១ | ១៥,៦ | ១៧,៩ |
| ចំណូល | ១០,២ | ១០,០ | ១០,៥ | ៩,៦ | ១០,៣ | ១០,៣ | ១១,៥ | ១១,៩ | ១២,០ | ១១,៥ | ១៣,១ |
| ពន្ធ | ៧,៥ | ៧,២ | ៧,៤ | ៦,៦ | ៧,៧ | ៧,៦ | ៧,៩ | ៩,៥ | ៩,៩ | ៩,៤ | ១០,៦ |
| មិនមែនពន្ធ (រាប់ទាំងចំណូលមូលធន) | ២,៧ | ២,៨ | ៣,១ | ៣,០ | ២,៦ | ២,៧ | ៣,៥ | ២,៣ | ២,១ | ២,១ | ២,៤ |
| ជំនួយឥតសំណង | ២,៧ | ២,៥ | ២,៧ | ២,២ | ១,៧ | ២,១ | ២,៦ | ២,២ | ៣,១ | ៤,១ | ៤,៨ |
| សរុបចំណាយ និងការឱ្យខ្ចីសុទ្ធ | ១៥,០ | ១៥,២ | ១៦,៨ | ១៥,៥ | ១៤,៨ | ១២,៨ | ១៤,២ | ១៤,៧ | ១៤,៨ | ១៩,៦ | ២០,១ |
| ចំណាយចរន្ត | ៨,៧ | ៨,៩ | ៩,៤ | ៩,៩ | ៨,៩ | ៧,៩ | ៨,៥ | ៨,៧ | ៩,០ | ១១,២ | ១១,០ |
| ចំណាយមូលធន | ៦,៤ | ៦,២ | ៧,៤ | ៦,៥ | ៦,០ | ៤,៩ | ៥,៨ | ៦,១ | ៥,៨ | ៨,៤ | ៩,៤ |
| កែតម្រូវសាច់ប្រាក់ | .. | .. | .. | ០,៩ | .. | .. | .. | .. | .. | .. | ០,៣ |
| សមតុល្យសរុប (គិតទាំងជំនួយឥតសំណង) | -២,១ | -២,៦ | -៣,៦ | -៣,៧ | -២,៩ | -០,៤ | -០,២ | -០,៧ | ០,៣ | -៤,០ | -២,២ |
| សមតុល្យសរុប (មិនគិតជំនួយឥតសំណង) | -៤,៨ | -៥,២ | -៦,៣ | -៥,៩ | -៤,៥ | -២,៥ | -២,៧ | -២,៩ | -២,៨ | -៨,១ | -៧,០ |
| ការផ្តល់ហិរញ្ញប្បទាន | ២,១ | ២,៦ | ៣,៥ | ៣,៧ | ២,៩ | ០,៤ | ០,២ | ០,៧ | -០,៣ | ៤,០ | ២,២ |
| ពីបរទេស | ២,៣ | ២,៤ | ៣,៩ | ៣,៥ | ៣,១ | ៣,០ | ២,៤ | ៣,២ | ២,៥ | ២,៥ | ២,៤ |
| ពីឥណទាយកផ្លូវការ | ២,៣ | ២,៤ | ៣,៩ | ៣,៥ | ៣,១ | ៣,០ | ២,៤ | ៣,២ | ២,៥ | ២,៥ | ២,៤ |
| ពីក្នុងស្រុក | -០,២ | ០,៣ | -០,៤ | ០,៥ | -០,២ | -២,៤ | -២,០ | -២,២ | -២,៥ | ១,៨ | ០,២ |
| ពីការរំលោះកាត់ទុកបំណុល | ០,០ | ០,០ | ០,០ | -០,៣ | -០,១ | -០,១ | -០,២ | -០,៣ | -០,២ | -០,៣ | -០,៣ |
| *មិនទាន់សម្រេចចំណុចផ្សេងទៀត :* | | | | | | | | | | | |
| ជំនួយឥតសំណង | ២,៧ | ២,៥ | ២,៧ | ២,២ | ១,៧ | ២,១ | ២,៦ | ២,២ | ៣,១ | ៤,១ | ៤,៨ |
| ប្រាក់កម្ចី | ២,៣ | ២,៤ | ៣,៩ | ៣,៥ | ៣,១ | ៣,០ | ២,៤ | ៣,២ | ២,៥ | ២,៥ | ២,៤ |
| ការឧបត្ថម្ភគាំទ្របច្ចេកទេស ១/ | ៧,៩ | ៦,៩ | ៥,៩ | ៥,៨ | ៥,៥ | ៤,៧ | ៤,៨ | ៣,៧ | ៣,៨ | ៣,៣ | ៣,៣ |
| **សរុប** | **១៣,០** | **១១,៨** | **១២,៤** | **១១,៥** | **១០,៣** | **៩,៧** | **៩,៧** | **៩,០** | **៩,៣** | **៩,៩** | **១០,៥** |

*ប្រភព :* មូលនិធិរូបិយវត្ថុអន្តរជាតិ តារាងប្រតិបត្តិការហិរញ្ញវត្ថុ និងសេដ្ឋកិច្ច រៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

១/ ការឧបត្ថម្ភគាំទ្របច្ចេកទេស និងការគាំទ្រផ្ទាល់ដទៃទៀតចំពោះអង្គការសង្គមស៊ីវិល (មិនបញ្ជូនតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

## ចំណូលរបស់រដ្ឋាភិបាល

**ចំណូលមិនគិតជំនួយឥតសំណងពីបរទេស បានកើនឡើង ១,៣ ភាគរយ នៃផសស ចាប់ពីឆ្នាំ ២០០០ ដល់ ២០០៩ ជាកំណើនដែលទាបជាងកំណើននៅក្នុងឆ្នាំ ២០១០។** ការកើនឡើងនៅឆ្នាំ ២០១០ សឱ្យឃើញតែការពង្រីកមូលដ្ឋានគិតពន្ធ ការធ្វើឱ្យប្រព័ន្ធពន្ធដារមានលក្ខណៈសាមញ្ញ និងការលើកកម្ពស់អនុលោមភាពប៉ុណ្ណោះ។ ទោះជាក្នុងកម្រិតកំណើនឆ្នាំ ២០១០ ក្តី ក៏ប្រាក់ចំណូលនៅកម្ពុជាធៀបនឹងផសស មានកម្រិតទាបជាងប្រាក់ចំណូលមធ្យមនៃបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប (រូបលេខ ៥)។ តម្លៃនៃការលើកលែង (The value of exemptions) មានការធ្លាក់ចុះ ប៉ុន្តែនៅតែមានទំហំធំប្រមាណជា ៤,៥ ភាគរយ នៃ ផសស (រូបលេខ ៦)។

---

*៧ មធ្យមភាគដោយរាប់បញ្ចូលសាធារណៈរដ្ឋ Kyrgyz ជាមួយនឹងមរតកពីសម័យ USSR ដែលមានអត្រាពន្ធខ្ពស់។ ប្រសិនបើមិនគិតបញ្ចូលសាធារណៈរដ្ឋនេះទេនោះ មធ្យមភាគនៃចំណូលធ្លាក់ចុះមកត្រឹម ១៣,៥ ភាគរយ។*

**ចំណូលពន្ធដ៏ច្រើនបានមកពីពន្ធប្រយោលជាពន្ធមានមូលដ្ឋានលើការប្រើប្រាស់។** ការផ្តោតការយកចិត្តទុកដាក់លើពន្ធប្រយោល ជាពិសេស អាករលើតម្លៃបន្ថែម គឺជាការសមស្របខណៈដែលសេដ្ឋកិច្ចក្រៅប្រព័ន្ធមានទំហំធំ ការធ្លាក់ចុះនៃចំណែកអត្រា ពន្ធអន្តរជាតិ និងសក្តានុពលសម្រាប់ការគេចពន្ធ (តារាងលេខ ៣)។ ទោះជាយ៉ាងណាក្តី មួយភាគបីនៃប្រាក់ចំណូលទាំងអស់បានមកពីអាករលើតម្លៃបន្ថែម - ហើយ ៦០ ភាគរយ នៃអាករទាំងនេះបានមកពីទំនិញនាំចូល - ដែលធ្វើឱ្យថវិកាប្រឈមមុខដោយផ្ទាល់ទៅនឹងកលិយុគពីបរទេស។ ចំណូលពីពន្ធលើប្រាក់ចំណេញរបស់ក្រុមហ៊ុនមានចំនួនតិច មួយផ្នែកធំ គឺដោយសារការលើកលែងពន្ធ និងទាបជាងប្រទេសឡាវ និងវៀតណាមជាខ្លាំង ដែលប្រទេសទាំងពីរប្រមូលពន្ធលើប្រាក់ចំណេញក្រុមហ៊ុនប្រមាណជាមួយភាគបីនៃការប្រមូលប្រាក់ពន្ធ។

**រូបលេខ ៥. ចំណូល មិនគិតជំនួយឥតសំណងនៅកម្ពុជា ទាបជាងនៅបណ្តាប្រទេស ដែលមានចំណូលទាបដទៃទៀត**
(គិតជា ភាគរយនៃ ផសស នៅឆ្នាំ ២០០៨)




*ប្រភព :* សូចនាកររបស់ World Development, ធនាគារពិភពលោក

**រូបលេខ ៦. ទឹកប្រាក់លើកលែងមិនយកពន្ធនៅតែមានទំហំធំ**
(គិតជា ភាគរយនៃ ផសស)




*ប្រភព :* អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## ហិរញ្ញប្បទានថវិកា

**រដ្ឋាភិបាលបានដកប្រាក់បញ្ញើរបស់ខ្លួននៅធនាគារកណ្តាល ដើម្បីធ្វើហិរញ្ញប្បទានចំពោះឱនភាពដ៏ធំនៅឆ្នាំ ២០០៩។** ផ្ទុយមកវិញ រហូតដល់ឆ្នាំ ២០០៨ ជំនួយឥតសំណង និងកម្ចីសម្បទានពីបរទេស បានផ្តល់ហិរញ្ញប្បទានឱនភាពសារពើពន្ធស្ទើរតែទាំងអស់ ដោយសារមិនសូវមានជម្រើសផ្សេងពីនេះ។ ការខ្ចីប្រាក់ដោយគ្មានសម្បទានត្រូវបានហាមឃាត់ដោយច្បាប់ថវិកា រដ្ឋាភិបាលមិនអាចខ្ចីពីក្នុងស្រុក ឬពីផ្សារទុនអន្តរជាតិ ចំណែកឯចំណូលពីឯកជនភាវូបនីយកម្មមានចំនួនតិចតួចណាស់។

**ប្រាក់បញ្ញើរបស់រដ្ឋាភិបាលនៅធនាគារកណ្តាលបានធ្លាក់ចុះពី ៧៣២ លានដុល្លារ ឬ ៧,១ ភាគរយ នៃ ផសស នៅចុងឆ្នាំ ២០០៨ មកត្រឹម ៥៤០ លានដុល្លារ (ប្រហែល ៥ ភាគរយ នៃ ផសស) នៅចុងឆ្នាំ ២០០៩។** នៅពេលដែលសេដ្ឋកិច្ចងើបឡើងវិញ រដ្ឋាភិបាលចាំបាច់ត្រូវបង្កើនឡើងវិញនូវប្រាក់បម្រុងទាំងនេះ ដើម្បីស្តារសភាពការណ៍។

**ជំនួយបរទេសបានកើនឡើងជាខ្លាំងក្នុងអំឡុងទសវត្សរ៍ឆ្នាំ ២០០០ ប៉ុន្តែហាក់ដូចជាធ្លាក់ចុះមកវិញ។** ជំនួយដល់ប្រទេសកម្ពុជាគិតក្នុងពលរដ្ឋម្នាក់ៗបានកើនឡើងពី ៣១ ដុល្លារ នៅឆ្នាំ ២០០០ ដល់ ៥១ ដុល្លារ នៅឆ្នាំ ២០០៨ ហើយចាប់ពីពេលនោះមកមានការប្រែប្រួលតិចតួច។ បន្ថែមលើជំនួយបរទេសដែលបានបញ្ជូនតាមរយៈថវិកា ម្ចាស់ជំនួយបរទេសផ្តល់ជំនួយបច្ចេកទេសច្រើនដល់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។ (ព័ត៌មានបន្ថែម សូមអានជំពូក ២)

**ខណៈពេលដែលការតម្រឹមតម្រង់ និងការសម្របសម្រួលជំនួយជាមួយម្ចាស់ជំនួយបានល្អប្រសើរនៅមានកិច្ចការជាច្រើនបន្ថែមទៀត ដែលត្រូវធ្វើដើម្បីតម្រឹមតម្រង់ការគាំទ្រ ការកសាងផែនការយុទ្ធសាស្ត្រ និងថវិកាប្រចាំឆ្នាំរបស់ម្ចាស់ជំនួយ។** បញ្ហាសំខាន់ៗ រួមមាន :

- ម្ចាស់ជំនួយបានគាំទ្រមួយផ្នែកធំចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធចម្បង និងគម្រោងមូលធន (ដូចជា ការសាងផ្លូវថ្នល់ ស្ពាន និងប្រឡាយស្រោចស្រពសំខាន់ៗ) ហើយទុកលទ្ធភាពឱ្យថវិកាជាតិផ្តល់ហិរញ្ញប្បទានចំពោះហេដ្ឋារចនាសម្ព័ន្ធបន្ទាប់បន្សំ

និងតូចតាច និងការថែទាំនាពេលបន្ទាប់ ។ ក្នុងស្ថានភាពដែលថវិកាជាតិមានតិចតួច ការផ្តល់មូលនិធិគ្រប់គ្រាន់សម្រាប់ថែទាំនាពេលបន្ទាប់មិនអាចធានាបានឡើយ ។

- ជំនួយបរទេសមួយចំនួនធំ ត្រូវបានបញ្ជូនតាមរយៈសហប្រតិបត្តិការបច្ចេកទេស និងអង្គការក្រៅរដ្ឋាភិបាល ។ ជាអាទិភាពទីមួយនៅពេលរៀបចំថវិកាប្រចាំឆ្នាំ រដ្ឋាភិបាលចាំបាច់ត្រូវគិតដល់ជំនួយបរទេស ដែលបានផ្តល់ឱ្យអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តមុខងារដូចរដ្ឋាភិបាល ។
- អាទិភាពរយៈពេលមធ្យម ម្ចាស់ជំនួយ និងរដ្ឋាភិបាល គប្បីពិចារណាអំពីវិធីកៀរគរការគាំទ្ររបស់ម្ចាស់ជំនួយភាគច្រើនឱ្យគាំទ្រថវិកា ។ ការណ៍នេះនឹងតម្រូវឱ្យចាកចេញឆ្ងាយពីអង្គភាពគ្រប់គ្រងគម្រោង ឬអង្គភាពសមមូល ដើម្បីបង្កើតប្រព័ន្ធនានារបស់រដ្ឋាភិបាល ដែលមានការសម្របសម្រួលការគាំទ្រពីម្ចាស់ជំនួយផ្សេងគ្នាបានកាន់តែប្រសើរ និងមានមុខងារដឹកនាំកាន់តែធំពីរដ្ឋាភិបាលក្នុងការរៀបចំស្នើសុំការគាំទ្របែបនេះ ។

**តារាងលេខ ៣. រចនាសម្ព័ន្ធនៃចំណូលរបស់រដ្ឋាភិបាល ឆ្នាំ២០០០-២០០៩**

(គិតជា ភាគរយនៃតួលេខសរុប)

| | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩e |
|---|---|---|---|---|---|---|---|---|---|---|
| ចំណូល | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ចំណូលពន្ធ | | | | | | | | | | |
| ពន្ធលើប្រាក់ចំណូល និងលើប្រាក់ចំណេញ | ៨,៩ | ៨,៤ | ៦,៩ | ៧,៤ | ៦,៦ | ៧,៨ | ៩,១ | ១០,៩ | ១១,៣ | ១៣,៤ |
| ពន្ធអចលនទ្រព្យ (ថ្លៃជួល) | ០,៥ | ០,៥ | ០,៥ | ១,០ | ០,៥ | ០,៥ | ០,៦ | ០,៦ | ០,៧ | ០,៨ |
| ពន្ធលើការប្រើប្រាស់ | ៣៣,៦ | ៣៥,៧ | ៣៦,៣ | ៣៤,៣ | ៤០,០ | ៣៩,៨ | ៣៦,៦ | ៤១,១ | ៤៦,៧ | ៤៣,៨ |
| ក្នុងនោះ អាករលើតម្លៃបន្ថែម | ២៥,៧ | ២៥,៨ | ២៤,៣ | ២៣,១ | ២៦,២ | ២៥,៥ | ២៤,៤ | ២៦,២ | ២៨,៣ | ២៧,៧ |
| ក្នុងនោះ អាករពិសេស | ៧,៨ | ៩,៩ | ១១,៩ | ១១,២ | ១៣,៨ | ១៤,៣ | ១២,២ | ១៤,៨ | ១៨,៤ | ១៦,១ |
| ពន្ធលើទុនបង្វិល | ០,៩ | ០,៦ | ០,៤ | ០,៦ | ០,៣ | ០,៤ | ០,៤ | ០,៤ | ០,៣ | ០,៣ |
| ពន្ធលើពាណិជ្ជកម្មអន្តរជាតិ | ២៧,០ | ២៤០ | ២៤,០ | ២២,១ | ២៣,១ | ២១,៥ | ១៨,៧ | ២១,៧ | ១៩,៨ | ២០,១ |
| ក្នុងនោះ ពន្ធគយ | ២៥,៩ | ២៣,៣ | ២៣,១ | ២១,១ | ២២,២ | ២០,៨ | ១៨,០ | ២០,៩ | ១៩,៤ | ១៨,៧ |
| ពន្ធផ្សេងទៀត | ២,៤ | ២,៩ | ២,៥ | ៣,២ | ៣,៩ | ៣,៣ | ៣,៨ | ៥,៦ | ៣,៦ | ៥,២ |
| ចំណូលមិនមែនពន្ធ | | | | | | | | | | |
| ទេសចរណ៍ (គិតទាំងថ្លៃទិដ្ឋាការ) | ១,៨ | ២,៧ | ៣,៤ | ៣,៥ | ៤,១ | ៤,៩ | ៤,៥ | ៤,៨ | ៣,៩ | ៣,៨ |
| ក្រៅពីនេះ | ២២,៩ | ២៤,៥ | ២៥,០ | ២៦,១ | ២០,៥ | ១៦,៩ | ១៥,៣ | ១២,១ | ១០,១ | ១០,៤ |
| ចំណូលមូលធន | ២,១ | ០,៦ | ០,៩ | ១,៧ | ០,៩ | ៤,៨ | ១១,០ | ២,៨ | ៣,៧ | ២,២ |

*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តារាង TOFE. e= ប៉ាន់ស្មាន

## ឃ. បំណុលរដ្ឋាភិបាល និងចីរភាពនៃបំណុល

**នៅចុងឆ្នាំ ២០០៩ បំណុលបរទេសរបស់កម្ពុជា (បំណុលបរទេសស្ទើរតែទាំងអស់ កើតឡើងដោយកាតព្វកិច្ចសាធារណៈ និងកាតព្វកិច្ចធានាជាសាធារណៈ) មានចំនួនស្មើនឹង ២៨ ភាគរយ នៃ ផសស គិតជាតួលេខជាក់ស្តែង និង ២៦ ភាគរយ គិតជាតម្លៃបច្ចុប្បន្នសុទ្ធ (NPV)។** ទោះជាយ៉ាងណាក្តី សន្និធិបំណុលបានកើនឡើងជិត ៣០ ភាគរយ នៃផសស នៅចុងឆ្នាំ ២០១០ សឱ្យឃើញការកើនឡើងនូវការឧបត្ថម្ភគាំទ្រពីម្ចាស់ជំនួយក្នុងពេលប្រឈមនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក។ ទំហំនៃបំណុលសាធារណៈក្នុងស្រុកក្នុងពេលបច្ចុប្បន្នមានទំហំតូចប្រមាណជា ១ ភាគរយ នៃ ផសស។ លើមូលដ្ឋាននៃការកាត់កង ប្រសិនបើដកចេញនូវសន្និធិប្រាក់បញ្ញើរបស់រដ្ឋាភិបាល បំណុលក្នុងស្រុកជាតួលេខអវិជ្ជមានធៀបនឹង ផសស។ រដ្ឋាភិបាលក៏បានធ្វើការធានាចំពោះក្រុមហ៊ុនរបស់រដ្ឋ ដែលរដ្ឋាភិបាលជាម្ចាស់ទាំងស្រុង។ ការធានាទាំងនេះគ្របដណ្តប់កិច្ចសន្យាជាច្រើនរវាងក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនឯកជន។ ឧទាហរណ៍ ក្រុមហ៊ុនរដ្ឋមួយបានចុះកិច្ចព្រមព្រៀងទិញថាមពល (PPA) ក្នុងនោះ ក្រុមហ៊ុនបានយល់ព្រមទិញអគ្គិសនី ទោះបីជាមាន ឬគ្មានតម្រូវការអគ្គិសនីក្តី។ រដ្ឋាភិបាលធានាការទិញថាមពលអគ្គិសនី ក្នុងករណីដែលក្រុមហ៊ុនរដ្ឋមិនអាចទូទាត់ការទិញអគ្គិសនីបាន។

**ការវិភាគ និរន្តរភាពបំណុលកាលពីពេលថ្មីៗបង្ហាញថា កម្ពុជាមានហានិភ័យតិចតួចអំពីភាពតានតឹងនៃបំណុល[៨]។** ហានិភ័យដែលមានសក្តានុពលអាចកើតឡើង ដោយសាររដ្ឋាភិបាលបានបង្កើនទ្វេដងនូវពិតាននៃការខ្ចីប្រាក់ស្របច្បាប់របស់ខ្លួន ដោយអនុម័តវិធានសម្រាប់ឆ្នាំ ២០១១ និងតទៅអនាគត ដើម្បីផ្តល់ហិរញ្ញប្បទានបន្ថែមចំពោះគម្រោងមូលធន។ ការខ្ចីប្រាក់ដែលពុំសូវមានលក្ខណៈសម្បទាន ក៏អាចបន្ថែមហានិភ័យផងដែរ ដូចគ្នានឹងបំណុលពីកាតព្វកិច្ចយថាភាពទាក់ទងនឹងរោងចក្រវារីអគ្គិសនីនានា និងវិនិយោគហេដ្ឋារចនា-សម្ព័ន្ធសាធារណៈដទៃទៀត។ អាស្រ័យហេតុនេះរាល់ការបង្កើនពិតានប្រាក់កម្ចី គប្បីពិនិត្យពិចារណាដោយប្រុងប្រយ័ត្ន ព្រោះថាវាអាចបន្ថយលទ្ធភាពយ៉ាងច្រើនរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះវិបត្តិណាមួយនាពេលអនាគត។

**សមត្ថភាពខ្ពស់ក្នុងការគ្រប់គ្រងបំណុលគឺជាបុរេលក្ខខណ្ឌសំខាន់មួយ សម្រាប់ប្រើប្រាស់កម្ចីបរទេសដោយប្រុងប្រយ័ត្ន រាប់ទាំងកម្ចីដែលពុំសូវមានលក្ខណៈសម្បទានផងដែរ។** សមត្ថភាពបែបនេះនឹងកាន់តែមានសារៈសំខាន់ថែមទៀត នៅពេលកម្ពុជាចាប់ផ្តើមពិចារណាអំពីទីផ្សារសញ្ញាប័ណ្ណរបស់រដ្ឋាភិបាលនៅក្នុងប្រទេស។ ជាមួយនឹងទីផ្សារមូលបត្រកម្មសិទ្ធិដែលកំពុងដំណើរការសមត្ថកិច្ចនានា ចាំបាច់ត្រូវពិចារណាដោយប្រុងប្រយ័ត្នអំពីចំណាយ និងផលចំណេញនៃការខ្ចីក្នុងស្រុកពីសំណាក់រដ្ឋាភិបាល (សូមមើលខាងក្រោម)។

## ខ. លំហសារពើពន្ធ

**លំហសារពើពន្ធ សំដៅដល់អត្ថិភាពនៃធនធានថវិកា ដែលមិនធ្វើឱ្យប៉ះពាល់ដល់និរន្តរភាពនៃស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ឬមិនធ្វើឱ្យប៉ះពាល់ដល់ស្ថេរភាពនៃសេដ្ឋកិច្ច[៩]។** រដ្ឋាភិបាលនានាអាចបង្កើតលំហសារពើពន្ធ ដោយបង្កើនចំណូលពន្ធ និងមិនមែនពន្ធតាមរយៈការធានាឱ្យមានបន្ថែមនូវជំនួយឥតសំណង ដោយកាត់បន្ថយចំណាយដែលមិនសូវមានអាទិភាព ឬដោយការខ្ចីក្នុងស្រុក ឬពីបរទេស។

### ការកាត់បន្ថយឱនភាពសារពើពន្ធ និងការបង្កើនប្រាក់បញ្ញើជាថ្មីឡើងវិញ

**អាទិភាពទីមួយសម្រាប់រដ្ឋាភិបាលទាក់ទងនឹងលំហសារពើពន្ធ គឺកាត់បន្ថយឱនភាពសារពើពន្ធ និងបង្កើនសន្និធិប្រាក់បញ្ញើជាថ្មីឡើងវិញរបស់រដ្ឋាភិបាល។** ចាំបាច់ត្រូវកាត់បន្ថយបន្ថែមនូវឱនភាពសារពើពន្ធសម្រាប់រយៈពេលមធ្យម ហើយចាំបាច់ត្រូវបង្កើនឡើងវិញនូវប្រាក់បញ្ញើរបស់រដ្ឋាភិបាល យ៉ាងហោចណាស់រហូតដល់កម្រិតមុនពេលមានវិបត្តិក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដូចជានៅឆ្នាំ ២០១៥ ជាដើម។ ក្នុងពេលគ្មានលទ្ធភាពចូលទៅកាន់ទីផ្សារទុន កម្ពុជានឹងបន្តពឹងផ្អែកលើប្រាក់បញ្ញើទាំងនេះរបស់រដ្ឋាភិបាល (សមតុល្យសាច់ប្រាក់នៅធនាគារកណ្តាល) ធ្វើជាប្រាក់បម្រុងសម្រាប់កាត់បន្ថយបច្ច័យអវិជ្ជមាន ដោយសារកលិយុគពីបរទេស។ នៅពេលសមស្រប សមត្ថកិច្ចនានានឹងចាប់ផ្តើមពិចារណាជម្រើសនានា ដើម្បីចូលទៅកាន់ទីផ្សារទុនក្នុងពេលអនាគត។ ជម្រើសបែបនេះអាចជួយដាក់កម្រិតសេចក្តីត្រូវការក្នុងការរក្សាប្រាក់បម្រុងច្រើន មិនផ្តល់លាភការ (កំណត់ដោយច្បាប់) នៅធនាគារកណ្តាល។

---

*៨ ការវិភាគរួមគ្នារវាងមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក (ដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី) ខែតុលា ឆ្នាំ២០១០ វ៉ាស៊ីនតោនឌីស៊ី។*

*៩ Heller, Peter (2005) and World Bank (2009).*

**មានអំណះអំណាងច្បាស់លាស់ក្នុងការគាំទ្រការបង្កើតលំហសារពើពន្ធ បន្ថែមលើប្រាក់បម្រុងសម្រាប់កាត់បន្ថយវិបត្តិក្នុងពេលអនាគត។** វិនិយោគលើអចលកម្មរបស់កម្ពុជា - ទាំងរដ្ឋាភិបាល និងផ្នែកឯកជន - មានចំនួន ១៩ ភាគរយ នៃ ផសស នៅឆ្នាំ ២០០៧-២០០៩ ក្រោម ២៥ ភាគរយ ដែលជាកម្រិតមធ្យមភាគក្នុងចំណោមប្រទេសទាំង ១៣ ដែលប្រឹងប្រែងឱ្យកើនឡើងយ៉ាងហោចណាស់ ៧ ភាគរយក្នុងមួយឆ្នាំ សម្រាប់រយៈពេល ៣០ ឆ្នាំ យោងតាមរបាយការណ៍របស់គណៈកម្មការកំណើន[១០]។ ក្នុងស្ថានភាពដែលផ្នែកឯកជននៅកម្ពុជាមានសមត្ថភាពតិចតួច ហើយកម្ពុជាពឹងផ្អែកច្រើនរួចទៅហើយលើសញ្ញ័យបរទេស ដែលបង្កើតបាននូវលទ្ធភាពលំហសារពើពន្ធបន្ថែមសម្រាប់វិនិយោគសាធារណៈដែលមានទំហំកាន់តែធំ និងសម្រាប់បង្កើនការថែទាំមានសារៈសំខាន់ណាស់។ ពិសេសបំផុតចាំបាច់ត្រូវមានលំហសារពើពន្ធ ដើម្បីធ្វើឱ្យចំណាយក្រៅថវិកា និងចំណាយឯកជនមួយចំនួនលើទំនិញសាធារណៈស្មើនឹងតួលេខថវិកា។ ការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយបច្ចុប្បន្នចំពោះសកម្មភាពបែបនេះ ទំនងជាធ្លាក់ចុះទៅតាមកាលវេលា ឬត្រូវបានប្តូរទៅកាន់ថវិកាប្រសិនបើការបង្វែរប្រព្រឹត្តិទៅដោយតម្លាភាព។

## ការបង្កើនលំហសារពើពន្ធ ៖ មុខងារនៃចំណូល

**វិធានការនានាដើម្បីបង្កើនចំណូល ចាំបាច់ត្រូវថ្លឹងថ្លែងជាមួយកង្វល់ផ្សេងៗអំពីថា តើវិធានការទាំងនោះនឹងធ្វើឱ្យរាំងស្ទះដល់កំណើនសេដ្ឋកិច្ចច្រើនជាងជួយដល់ចំណាយរដ្ឋាភិបាលលើទំនិញសាធារណៈដែរ ឬយ៉ាងណា។** របកគំហើញរបស់យើងដែលថា កម្ពុជាមានអនុបាតចំណូលធៀបនឹង ផសស ទាបជាងបណ្តាប្រទេសដែលមានកម្រិតប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់ៗប្រហាក់ប្រហែលគ្នាបង្ហាញថា មានលទ្ធភាពបង្កើនប្រាក់ចំណូល ដោយមិនធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានចំពោះកំណើនឡើយ។

**មានលទ្ធភាពសម្រាប់កំណែទម្រង់បន្ថែម ដើម្បីធ្វើឱ្យក្រុមហ៊ុននានាមានឱកាសដូចៗគ្នា និងបង្កើនការប្រមូលចំណូល។** រដ្ឋាភិបាលអាចពិចារណាអំពីការរៀបចំកំណត់ត្រាគណនេយ្យមានលក្ខណៈស្តង់ដារចំពោះធុរកិច្ចក្នុងស្រុក ការពង្រឹងសមត្ថភាពរបស់រដ្ឋបាលពន្ធ និងដាក់ឱ្យដំណើរការនូវប្រព័ន្ធប៉ាន់ស្មានពន្ធ ដើម្បីកាត់បន្ថយឱកាសឆន្ទានុសិទ្ធិ។ សំខាន់ត្រូវពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារឱ្យបានកាន់តែទូលំទូលាយក្នុងចំណោមប្រជាជន (ដូចបានប្រកាសកាលពីឆ្នាំ ២០០៥ ដូច្នោះដែរ) ដើម្បីប្រមូលពន្ធ។ កិច្ចប្រឹងប្រែងដើម្បីលើកកម្ពស់ការប្រមូលពន្ធ និងការបង្ក្រាបអំពើរត់ពន្ធឈើមូល និងឈើអារ ទំនងជាបង្កើនចំណូល ហើយគប្បីពិចារណាអំពីវិធានការដូចគ្នានេះនៅក្នុងវិស័យដទៃទៀតនៃសេដ្ឋកិច្ច។

**ការកាត់បន្ថយ ការគេចពន្ធនឹងនាំមកនូវប្រាក់ចំណូលយ៉ាងច្រើន ព្រមទាំងធ្វើឱ្យក្រុមហ៊ុនក្នុងស្រុក និងបរទេសត្រូវបានធ្វើប្រព្រឹត្តិកម្មប្រកបដោយសមធម៌បន្ថែមទៀត។** នៅឆ្នាំ ២០០៦ ក្រសួងទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភា និងអធិការកិច្ចបានឱ្យដឹងថា ក្រុមហ៊ុនជិត ៥០០ នៅជំពាក់ប្រាក់ពន្ធរាប់លាន[១១]។ ការសិក្សាមួយទៀតបានរកឃើញថា នៅឆ្នាំ ២០០៥ ប្រាក់ពន្ធត្រឹមតែមួយភាគបួននៃពន្ធដែលត្រូវបង់ប៉ុណ្ណោះដែលបានប្រមូល[១២]។ ក្រៅពីភាពកម្សោយក្នុងការអនុវត្តមូលហេតុមួយទៀតចំពោះការប្រមូលចំណូលទាបនេះ គឺវិស័យក្រៅប្រព័ន្ធនៅក្នុងសេដ្ឋកិច្ចមានទំហំធំ។ អាជីវកម្មជាច្រើនកំពុងដំណើរការក្រៅប្រព័ន្ធហិរញ្ញវត្ថុ និងមិនបានចុះបញ្ជីជាមួយរដ្ឋាភិបាល។ អវត្តមាននៃកំណត់ត្រាគណនេយ្យ ដែលមានលក្ខណៈស្តង់ដារចំពោះអាជីវកម្មក៏ជាកត្តាមួយផងដែរ។ ការសម្រួលការចុះបញ្ជីការដាក់ឱ្យប្រើនូវកាតព្វកិច្ចកត់ត្រាប្រតិបត្តិការអាជីវកម្ម និងការពង្រឹងរដ្ឋបាលពន្ធ គប្បីបន្តអនុវត្តគ្រប់មុខព្រួញ។ ចំណាត់ការចំពោះការគេចពន្ធ និងការរត់ពន្ធ គឺជារបៀបវារៈសំខាន់បំផុតរបស់រដ្ឋាភិបាល ប៉ុន្តែគប្បីផ្តោតការយកចិត្តទុកដាក់លើការពិនិត្យឡើងវិញនូវសារពើភណ្ឌសាធារណៈ និងការចុះបញ្ជីទ្រព្យរដ្ឋ (ពិសេស គឺការចុះបញ្ជីដីរដ្ឋ) ដើម្បីរកឱ្យឃើញនូវការជួល និងថ្លៃជួលដែលមិនបានចុះបញ្ជី និងមិនបានបង់ពន្ធទៅឱ្យផ្នែកឯកជន។ អនុវត្តហ្មត់ចត់នូវច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយដែលទើបអនុម័តកាលពីពេលកន្លងទៅថ្មីៗ មុខជាកាត់បន្ថយការគេចពន្ធផងដែរ។

**ការគិតឡើងវិញអំពីទំហំនៃការលើកទឹកចិត្តផ្នែកពន្ធ ដែលបានផ្តល់ឱ្យក្រុមហ៊ុនក្នុងពេលបច្ចុប្បន្ននេះ ក៏មានសារៈសំខាន់ផងដែរ។** ការពិចារណាឡើងវិញបែបនេះ គប្បីដាក់បញ្ចូលនូវការផ្លាស់ប្តូរវិធីផ្តល់ការលើកទឹកចិត្តផ្នែកពន្ធ ដោយលះបង់ការលើកលែងពន្ធឆ្ពោះទៅកាន់ការឧបត្ថម្ភលើការវិនិយោគ ឥណទានពន្ធ និងការរំលោះដោយបង្ខំ។ គេបានប៉ាន់ស្មានថាការលើកលែងពីការបង់ពន្ធគយ និងអាករពិសេសធ្វើឱ្យខាតបង់ ៤ ភាគរយ នៃ ផសស ក្នុងមួយឆ្នាំៗ។ ការលើកទឹកចិត្តដទៃទៀតដែលពិបាកគណនាទំហំ ទំនងជាមានចំនួនប្រមាណជា

---

*១០ យុទ្ធសាស្ត្រដើម្បីឱ្យកំណើន និងការអភិវឌ្ឍពេញលេញមាននិរន្តរភាព ឆ្នាំ ២០០៨ គណៈកម្មការកំណើន - www.growthcommission.org*
*១១ កាសែតខាំបូឌាដេយលី ថ្ងៃ ទី ១៥-១៧ ខែ កក្កដា ឆ្នាំ ២០០៦*
*១២ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០០៦ "ការប៉ាន់ស្មានអំពើពុករលួយនៅក្នុងវិស័យឯកជននៅកម្ពុជា"*

២ ទៅ ៣ ភាគរយ នៃ ផសស និងរាប់ទាំងរយៈពេលអនុគ្រោះពន្ធលើប្រាក់ចំណេញរហូតដល់ ៩ ឆ្នាំ សម្រាប់គម្រោងវិនិយោគដែលមានគុណវុឌ្ឍិ (QIP) ដែលយល់ព្រមដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (កអក)។ ជាលទ្ធផល ចំណាយសរុបចំពោះការលើកលែងទាំងនេះលើស ផសស ៦-៧ ក្នុងមួយឆ្នាំៗ។

**ការលើកលែងទាំងនេះមួយចំនួន គប្បីពិនិត្យមើលឡើងវិញ និងកាត់បន្ថយ ដើម្បីជួយបង្កើនលំហសារពើពន្ធ។** នៅពេលដែលការលើកលែងពន្ធជួយវិនិយោគិនក្នុងការជំនះចំណុចចាញ់ប្រៀបរបស់ពួកគេធៀបនឹង - អ្នកធ្វើសកម្មភាពមុនគេ - ចូលទៅក្នុងទីផ្សារដោយរក្សាទុកពួកគេក្នុងរយៈពេលវែង នឹងបានទទួលផលសេដ្ឋកិច្ចតិចតួច។ អត្រាពន្ធទាប - អនុវត្តសម្រាប់វិនិយោគិនទាំងអស់ - ជាអ្វីដែលគប្បីអនុវត្ត។ បន្ថែមពីលើនេះ ការលើកទឹកចិត្តផ្នែកពន្ធកម្រជាកត្តាសំខាន់សំខាន់បំផុត ដែលវិនិយោគិនពិចារណានៅពេលជ្រើសរើសទីតាំងដែលជាកន្លែងមានស្ថេរភាពនយោបាយ មានហេដ្ឋារចនាសម្ព័ន្ធសមរម្យ ថ្លៃអគ្គិសនីសមរម្យ និងចំណាយលើប្រាក់ខែមិនខុសពីផលិតភាពការងារ។

**ការលើកកម្ពស់ការគ្រប់គ្រងសាធារណៈនៃធនធានឧស្សាហកម្មនិស្សារណកម្ម នឹងជួយបង្កើនលំហសារពើពន្ធបន្ថែមទៀត ព្រមទាំងបង្កើនកម្រិតជីវភាពរស់នៅ។** កម្ពុជាផ្តល់ទីលានមួយនៃទីលានកម្រដែលមិនទាន់ធ្វើអាជីវកម្មនៅលើពិភពលោក។ហើយអាស្រ័យលើរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការប្រែក្លាយសម្បត្តិក្រោមដីឱ្យទៅជាធនធាន ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ច និងវិបុលភាព។ គោលនយោបាយសារពើពន្ធមានមុខងារសំខាន់ក្នុងការធ្វើឱ្យប្រាកដថា ធនធានធម្មជាតិពុំមែនជាបណ្តាសា និងត្រូវបានប្រើប្រាស់ដោយប្រុងប្រយ័ត្ន។ ក្របខ័ណ្ឌសារពើពន្ធដែលមានតម្លាភាព និងការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋាភិបាល ក៏ជាធាតុដែលមានសារៈសំខាន់ចំពោះការគ្រប់គ្រងធនធានធម្មជាតិផងដែរ។ បញ្ហាស្រដៀងគ្នាកើតឡើងជាមួយនឹងការបែងចែកដីធ្លីសម្រាប់សម្បទានសេដ្ឋកិច្ច។ ការធានាឱ្យថ្លៃមានភាពយុត្តិធម៌ ដើម្បីបានទទួលសម្បទាន មិនត្រឹមតែរួមចំណែកក្នុងការបង្កើនចំណូលសារពើពន្ធ និងធានាឱ្យដីធ្លីត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែនេះ គឺជាចំណុចគោលមួយនៃកិច្ចប្រឹងប្រែងក្នុងការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋាភិបាល (សូមមើលជំពូកទី ៦ ផងដែរ)។

## ការបង្កើនលំហសារពើពន្ធ : មុខងារនៃជំនួយបរទេស

**កម្ពុជានៅពឹងផ្អែកលើជំនួយនៅឡើយ។** ខណៈពេលដែលរដ្ឋាភិបាលផ្តល់នូវភាពដឹកនាំរឹងមាំក្នុងការដឹកនាំប្រសិទ្ធភាពជំនួយ បរិយាកាស ជំនួយពោរពេញទៅដោយម្ចាស់ជំនួយជាច្រើនជាមួយនឹងគម្រោងនានា ដែលគ្មានការសម្របសម្រួល និងដាច់ដោយឡែកពីគ្នា។ ខណៈពេលដែលជំនួយរបស់ម្ចាស់ជំនួយជារួមមានសារៈសំខាន់សម្រាប់ការស្តារប្រទេស គេកាន់តែមានការពិបាកខ្លាំងក្នុងការធ្វើឱ្យប្រាកដថាជំនួយដែលមានកម្រិតប្រមាណជា ០,៩ ពាន់លានដុល្លារក្នុងមួយឆ្នាំ នាំមកនូវលទ្ធផលអភិវឌ្ឍន៍ចាំបាច់ក្នុងការអនុវត្តជាក់ស្តែង - ដោយហេតុថា "ប្រាក់ជំនួយងាយរកត្រូវបានគេយកអស់ទៅហើយ"។

**ជម្រើសគោលនយោបាយបច្ចុប្បន្នរបស់រដ្ឋាភិបាល ដែលគាំទ្រដោយម្ចាស់ជំនួយ គឺដើម្បីធ្វើឱ្យប្រាកដថាមានការបែងចែកភារកិច្ចបំពេញបន្ថែមក្នុងចំណោមម្ចាស់ជំនួយ ការតម្រឹមតម្រង់ និងសុខដុមភាវូបនីយកម្មជំនួយ។** ការតម្រឹមតម្រង់រវាងការគាំទ្ររបស់ម្ចាស់ជំនួយ ការរៀបចំយុទ្ធសាស្ត្រអាទិភាពក្រោម ផយអជ និងថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល ត្រូវតែបន្សុីគ្នាឱ្យបានពេញលេញ។ ការគាំទ្ររបស់ម្ចាស់ជំនួយចំពោះរដ្ឋាភិបាល - រួមមានជំនួយសម្រាប់ចំណាយក្រៅថវិកា ដែលផ្តល់ហិរញ្ញប្បទានដោយសហប្រតិបត្តិការបច្ចេកទេស - និងផ្តល់ឱ្យអង្គការក្រៅរដ្ឋាភិបាលនានា ចាំបាច់ត្រូវស្ថិតនៅក្រោមទិដ្ឋភាពរួមរបស់រដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រាកដថាកិច្ចប្រឹងប្រែងមិនត្រួតជាន់គ្នា។ ជាអាទិភាពមួយចំណាយក្រៅថវិកា ដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយចាំបាច់ត្រូវដាក់បញ្ចូលក្នុងថវិកាផងដែរ។

**ជាមួយគ្នានេះ ក៏ចាំបាច់ត្រូវធ្វើសុខដុមភាវូបនីយកម្ម និងតម្រឹមតម្រង់ប្រព័ន្ធ និងនីតិវិធីនានាផងដែរ។** ដូចនៅបណ្តាប្រទេសដទៃ ការចាត់ចែងចំពោះកិច្ចតម្រូវ និងទម្រង់នានារបស់ម្ចាស់ជំនួយផ្សេងគ្នា (ដូចជាចំពោះការរៀបចំ ការរាយការណ៍ ការតាមដាន និងវាយតម្លៃឬសវនកម្មជាដើម) ធ្វើឱ្យមានចំណាយប្រតិបត្តិការច្រើន ទាំងខាងរដ្ឋាភិបាល និងម្ចាស់ជំនួយ។ ការឆ្លើយតបរបស់រដ្ឋាភិបាល គឺជំរុញឱ្យមានសុខដុមភាវូបនីយកម្មនៃប្រព័ន្ធនានានៅកម្រិតផ្សេងៗ។ ទាំងនេះរួមមាន ប្រតិភូកម្មការរៀបចំកិច្ចសហប្រតិបត្តិការ មូលនិធិបរិបាលកិច្ចពហុម្ចាស់ជំនួយ និងទម្រង់ដទៃទៀតនៃការផ្តល់ហិរញ្ញប្បទានរួមគ្នា និងក្នុងករណីមួយចំនួនមានសៀវភៅណែនាំរួមសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម។ នៅពេលដែលប្រព័ន្ធនានារបស់រដ្ឋាភិបាលខ្សោយ ការណ៍នេះនឹងជួយប្រព័ន្ធទាំងនោះទៅតាមកម្រិតនានារបស់ម្ចាស់ជំនួយដែលអាចទទួលយកបាន។ បញ្ហាសំខាន់មួយដែលនៅមិនទាន់ដោះស្រាយ គឺអត្ថិភាពនៃផ្នែកអនុវត្តគម្រោងជាច្រើនដែលម្ចាស់ជំនួយបានបង្កើតឡើង។

**ភាពមិនអាចព្យាករណ៍បានអំពីជំនួយ ធ្វើឱ្យមានការលំបាកក្នុងការធ្វើសមាហរណកម្មជំនួយទៅក្នុងដំណើរការនានារបស់រដ្ឋាភិបាល។** ភាពមិនអាចព្យាករណ៍បាននេះ ក្តោបទាំងភាពខុសគ្នារវាងទឹកប្រាក់សន្យា និងទឹកប្រាក់បើកផ្តល់ និងនិន្នាការចំពោះម្ចាស់ជំនួយជាច្រើនឱ្យសន្យាត្រឹមតែមួយឆ្នាំមុនប៉ុណ្ណោះ ដែលធ្វើឱ្យការរៀបចំកម្មវិធីជំនួយរបស់រដ្ឋាភិបាលនៅក្នុងយុទ្ធសាស្ត្រសារពើពន្ធ និងយុទ្ធសាស្ត្រវិស័យជារួមជួបការលំបាកជាខ្លាំង ។

**ការមានទិន្នន័យតិចតួចអំពីជំនួយ ធ្វើឱ្យពិបាកតាមដាន និងបង្កើនប្រសិទ្ធភាពជំនួយ។** រហូតមកដល់សព្វថ្ងៃ ម្ចាស់ជំនួយមិនបានផ្តល់ទិន្នន័យគ្រប់គ្រាន់ មិនអាចប្រៀបធៀបគ្នាបាន និងមិនបានទាន់ពេលវេលាមកកាន់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឡើយ ធ្វើឱ្យលំបាកក្នុងការតម្រឹមតម្រង់ជំនួយអភិវឌ្ឍន៍ជាមួយអាទិភាពនានារបស់រដ្ឋាភិបាល ។

## ការបង្កើនលំហសារពើពន្ធដោយធ្វើវិចារណកម្មចំណាយបច្ចុប្បន្ន

**ទោះបីជាចំណាយរបស់រដ្ឋាភិបាលមានកម្រិតទាបក្តី គេឃើញមានលទ្ធភាពក្នុងការធ្វើវិចារណកម្មចំណាយសាធារណៈ។** ជំពូក ២ ផ្តោតលើជម្រើសជាក់លាក់ ដែលបំពេញបន្ថែមដោយការវិភាគនៅក្នុងជំពូក ៣-៥ ។

## ការបង្កើនលំហសារពើពន្ធ ដោយធានាឱ្យរដ្ឋាភិបាលមានលទ្ធភាពចូលទៅកាន់ផ្សារទុន

**ច្បាប់សារពើពន្ធរបស់កម្ពុជាចែងបានត្រឹមត្រូវ ដោយមិនអនុញ្ញាតឱ្យរដ្ឋាភិបាលខ្ចីប្រាក់ដែលគ្មានសម្បទាន ហើយក៏មិនអនុញ្ញាតឱ្យបោះផ្សាយសញ្ញាប័ណ្ណរដ្ឋាភិបាលដែរ។** ទោះជាយ៉ាងណាក្តី នៅឆ្នាំ ២០១១ ច្បាប់ថវិកាបានអនុញ្ញាតឱ្យបោះផ្សាយប័ណ្ណរតនាគារ ដែលមានទឹកប្រាក់ ២៥ លានដុល្លារ ក្នុងករណីត្រូវការសាច់ប្រាក់បន្ទាន់ ប៉ុន្តែត្រូវមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ។ ជាងនេះទៅទៀត ខណៈពេលដែលច្បាប់ហាមឃាត់រដ្ឋាភិបាលមិនឱ្យខ្ចីពីធនាគារកណ្តាល ច្បាប់អនុញ្ញាតឱ្យធនាគារផ្តល់ឥណទានបណ្តោះអាសន្នទៅរតនាគារជាតិដែលមានឥណប្រតិទានរហូតដល់បីខែ[១៣] ។ ចំនួនទឹកប្រាក់ឥណទានផ្តល់ឱ្យរដ្ឋាភិបាលមិនអាចលើស ១០ ភាគរយ នៃចំណូលថវិកាក្នុងស្រុកធម្មតា (លើកលែងតែជំនួយឥតសំណង និងចំណូលពីការលក់ទ្រព្យសម្បត្តិ) សម្រាប់ឆ្នាំហិរញ្ញកិច្ចពីមុន។ អស់រយៈកាលជាងមួយទសវត្សរ៍មកហើយរដ្ឋាភិបាលមិនបានអនុវត្តជម្រើសនេះឡើយ ។

**ក្នុងស្ថានភាពដែលសេដ្ឋកិច្ចមានដុល្លារូបនីយកម្មខ្ពស់ និងខណៈដែលគ្មានតម្រូវការមូលបត្រដែលកំណត់ថ្លៃជារូបិយវត្ថុក្នុងស្រុក រដ្ឋាភិបាលមិនអាចធ្វើហិរញ្ញប្បទានឱនភាព ឬគ្រប់គ្រងសាច់ប្រាក់ពីប្រភពទីផ្សារក្នុងស្រុកបានឡើយ។** ទោះជាយ៉ាងណាក្តី រដ្ឋាភិបាលកំពុងពិចារណាអំពីលទ្ធភាពរកប្រាក់ពីទីផ្សារទុនក្នុងស្រុកនាពេលអនាគត ។ ផ្សារហ៊ុនកម្ពុជាដែលកំពុងរៀបចំបង្កើតទំនងជាមានដំណើរការនៅចុងឆ្នាំនេះ ហើយនេះអាចបើកឱកាស ដើម្បីពិចារណាអំពីការបង្កើតទីផ្សារសញ្ញាប័ណ្ណក្នុងស្រុកនាពេលអនាគត ។ ទោះជាយ៉ាងណាក្តី ដើម្បីសម្រេចឱ្យបាននូវគោលដៅបែបនេះ តម្រូវឱ្យមានកិច្ចប្រឹងប្រែងជាច្រើនក្នុងការលើកកម្ពស់សមត្ថភាពរបស់រដ្ឋាភិបាល ។

**ការវាយតម្លៃលទ្ធផលគ្រប់គ្រងបំណុលកាលពីពេលកន្លងទៅថ្មីៗ (DeMPA) បានឱ្យដឹងថា កម្ពុជាបំពេញបាននូវលក្ខខណ្ឌអប្បបរមាចំនួនប្រាំនៃសូចនាករអំពីលទ្ធផលគ្រប់គ្រងបំណុលចំនួន ១៥ [១៤]។** ទាំងនេះរួមមាន សូចនាករស្តីពីក្របខ័ណ្ឌគតិយុត្ត រចនាសម្ព័ន្ធគ្រប់គ្រង ការសម្របសម្រួលដោយគោលនយោបាយរូបិយវត្ថុ និងតួលេខបំណុល និងការគ្រប់គ្រងបំណុល ។ សូចនាករស្តីពីការខ្ចីប្រាក់ពីទីផ្សារក្នុងស្រុកមិនត្រូវបានពិចារណាឡើយ ដោយសារកម្ពុជាមិនបោះផ្សាយមូលបត្ររដ្ឋាភិបាលនៅក្នុងទីផ្សារក្នុងស្រុក។ ការវាយតម្លៃនេះបានកំណត់ផ្នែកខាងក្រោមដែលតម្រូវឱ្យកែលំអ និងអាចត្រូវបានចាត់ទុកថាជាអាទិភាពសម្រាប់ការកសាងសមត្ថភាព និងកែទម្រង់ : (i) រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុល និងវាយតម្លៃប្រតិបត្តិការគ្រប់គ្រងបំណុល (ii) សវនកម្មសកម្មភាពគ្រប់គ្រងបំណុលគោល-នយោបាយ និងប្រតិបត្តិការ (iii) ការបង្កើនសមត្ថភាពដើម្បីរៀបចំការវាយតម្លៃ និរន្តរភាពនៃបំណុល (iv) ចែករំលែកព័ត៌មានដែលកាន់តែមានលក្ខណៈជាប្រព័ន្ធជាមួយធនាគារជាតិនៃកម្ពុជា និងនៅក្នុង និងជាមួយនាយកដ្ឋានពាក់ព័ន្ធរបស់រដ្ឋាភិបាល (v) ប្រកាន់យកមុខងារឱ្យកាន់តែសកម្មគិតគូរដល់ការប្រៀបធៀប និងចរចាលក្ខខណ្ឌឥណទានដែលបានផ្តល់ (vi) រៀបចំនីតិវិធីនានាសម្រាប់ឱ្យខ្ចីបន្ត (vii) កែលំអការគ្រប់គ្រងសមតុល្យសាច់ប្រាក់ (viii) លើកកម្ពស់ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ និង (ix) រៀបចំ និងបោះផ្សាយព្រឹត្តិបត្រស្ថិតិបំណុលទៀងទាត់ និងពេញលេញ។ ផ្នែកគ្រប់គ្រងបំណុលបរទេសរបស់សមត្ថកិច្ចត្រូវបានដាក់ឱ្យដំណើរការចាប់តាំងពីឆ្នាំ ១៩៩៧ និងមានបុគ្គលិកគ្រប់គ្រាន់ ប៉ុន្តែមិនបានរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលផ្លូវការឡើយ[១៥] ហើយក៏មិនបានបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងបំណុលរយៈពេលមធ្យមអំពីសមាសភាពរូបិយវត្ថុដែរ បុនហិរញ្ញប្បទាន និងហានិភ័យអត្រាការប្រាក់ដែរ ។

---

*១៤ DeMPA ខែ វិច្ឆិកា ឆ្នាំ ២០០៩-ការវាយតម្លៃរួមគ្នារបស់ធនាគារពិភពលោក និង UNCTAD*

*១៥ យុទ្ធសាស្ត្រគ្រប់គ្រងបំណុលកំពុងត្រូវបានកសាងបញ្ចប់*

## ច. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ

**ការស្តារឡើងវិញ និងការបង្កើនលំហសារពើពន្ធ ត្រូវតែជាអាទិភាពមួយខ្ពស់សម្រាប់រដ្ឋាភិបាលក្នុងរយៈពេលខ្លី។** ជំពូកនេះផ្តល់អនុសាសន៍ដូចខាងក្រោម ៖

- **នៅពេលដែលសេដ្ឋកិច្ចងើបឡើងវិញ សំខាន់ត្រូវបង្កើនឡើងវិញនូវសន្តិធិប្រាក់បញ្ញើរបស់រដ្ឋាភិបាល យ៉ាងហោចណាស់ត្រឹមកម្រិតមុនពេលមានវិបត្តិ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិក្នុងពេលអនាគត។** តាមកាលវេលាជាក់ស្តែង រដ្ឋាភិបាលចាំបាច់ត្រូវពិចារណាជ្រើសយកក្របខ័ណ្ឌមួយសម្រាប់ប្រើប្រាស់ប្រាក់បញ្ញើទាំងនេះឱ្យមានតម្លាភាព។

- **អាទិភាពមួយទៀតទាក់ទងនឹងលំហសារពើពន្ធ គឺបំពេញឱនភាពសារពើពន្ធសម្រាប់រយៈពេលមធ្យម។**

- **មានលទ្ធភាពសម្រាប់កំណែទម្រង់បន្ថែមទៀត ដើម្បីបង្កើនការប្រមូលចំណូល។** វិធានការនានាដើម្បីបង្កើនបណ្តាញពន្ធ រួមមានការបន្ថយកម្រិតពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ការបង្កើនពន្ធលើថ្នាំជក់ និងគ្រឿងស្រវឹង ការអនុវត្តពន្ធលើអចលនទ្រព្យ ពន្ធលើផលចំណេញមូលធន រៀបចំកំណត់ត្រាគណនេយ្យនៃអាជីវកម្មក្នុងស្រុកឱ្យមានលក្ខណៈស្តង់ដារ ការពង្រឹងសមត្ថភាពរដ្ឋបាលពន្ធ និងបង្កើតប្រព័ន្ធប៉ាន់ស្មានពន្ធ ដើម្បីកាត់បន្ថយឱកាសឆន្ទានុសិទ្ធិ។ ការគ្រប់គ្រងធនធានធិស្សារណកម្ម និងគ្រប់គ្រងដីបានកាន់តែប្រសើរ មុខជាផ្តល់ឱកាសបង្កើនចំណូល និងគណនេយ្យភាពរបស់រដ្ឋាភិបាលកាន់តែខ្ពស់។

- **ជាមួយគ្នានេះ ក៏ត្រូវគិតគូរឡើងវិញអំពីការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ឧស្សាហកម្មជាក់លាក់។** លុបបំបាត់ការលើកលែងពន្ធទាំងនេះដែលសរុបមកត្រូវបានប៉ាន់ស្មានថាមានចំនួន ៦-៧ ភាគរយ នៃផសស ក្នុងមួយឆ្នាំ - នឹងអនុញ្ញាតឱ្យសមត្ថកិច្ចដាក់ឱ្យអនុវត្តអត្រាពន្ធទាបសម្រាប់វិនិយោគិនគ្រប់ៗគ្នា។

- **ចាំបាច់ត្រូវអនុវត្តឱ្យបានល្អនូវវិធាន និងបទប្បញ្ញត្តិដែលកំពុងមានសព្វថ្ងៃ។** ការអនុវត្តហ្មត់ចត់កាលពីពេលថ្មីៗ កន្លងទៅនេះចំពោះសកម្មភាពកាប់ឈើ និងអារឈើ គប្បីយកទៅអនុវត្តចំពោះវិស័យដទៃទៀត ដើម្បីកាត់បន្ថយអំពើរត់ពន្ធដែលជាប្រភពសំខាន់នៃការបាត់បង់ចំណូល។ ដូចគ្នាដែរ សកម្មភាពលទ្ធកម្មផ្នែកលើវិធានតឹងតែង គប្បីត្រូវបានលើកកម្ពស់ដោយសារកិច្ចសន្យាជាង ៦០ ភាគរយ នៃកម្រិតដេញថ្លៃដែលមានលក្ខណៈប្រកួតប្រជែងមិនបានដេញថ្លៃ ដោយប្រកួតប្រជែងឡើយ ដោយសារភាពខ្វះចន្លោះនៃបទប្បញ្ញត្តិ[១៦]។

១៦ IMF, 2010, Cambodia Article IV Consultations Report, Washington DC

# សមាសភាពនៃចំណាយ អាទិភាព និង កាលានុវត្តភាពរបស់រដ្ឋាភិបាល

# ២

## ក. សេចក្តីផ្តើម

**កម្រិតនៃចំណាយរបស់រដ្ឋាភិបាលកម្ពុជាមានលក្ខណៈស្រដៀងគ្នាទៅនឹងកម្រិតនៃចំណាយនៅប្រទេសនានាដទៃ ដែលមានកម្រិតប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់ៗ និងលទ្ធផលនៃការអភិវឌ្ឍប្រហាក់ប្រហែលគ្នា។** ភាពខុសគ្នាអំពីសមាសភាពនៃចំណាយរបស់កម្ពុជា ធៀបនឹងប្រទេសប្រៀបធៀបពាក់ព័ន្ធភាគច្រើនក៏មានកម្រិតតិចតួច ។ មានបញ្ហាសំខាន់ពីរទាក់ទងនឹងសមាសភាពនៃចំណាយដែលរដ្ឋាភិបាល ត្រូវយកចិត្តទុកដាក់ជាបន្ទាន់ ។ ទីមួយ ត្រូវធ្វើយ៉ាងណាឱ្យចំណាយមូលធនដែលមានចំនួនច្រើន ត្រូវបានបន្សុីត្ថាដោយវិភាជន៍សមស្របសម្រាប់ការថែទាំមានសារៈសំខាន់ ដើម្បីឱ្យមានកំណើនខ្ពស់ និងមាននិរន្តរភាព ។ ការគាំទ្ររបស់ម្ចាស់ជំនួយមុខជាមានសារៈសំខាន់ណាស់ ដើម្បីឱ្យកិច្ចការនេះក្លាយជាការពិត ។ រដ្ឋាភិបាលក៏ចាំបាច់ត្រូវធ្វើការជាមួយម្ចាស់ជំនួយ ដើម្បីធ្វើឱ្យប្រាកដថាមានការចាត់ថ្នាក់សមស្របនូវគម្រោងវិនិយោគ ដែលទទួលការគាំទ្រពីម្ចាស់ជំនួយស្ថិតនៅក្នុងគណនីសារពើពន្ធ ។ ទីពីរ ការបង្កើនប្រាក់ខែសម្រាប់យោធានៅឆ្នាំ ២០០៩ បានបង្កើនចំណាយប្រាក់ខែយ៉ាងច្រើនខ្ពស់ជាងការបង្កើនប្រាក់បៀវត្សចំពោះបុគ្គលិកស៊ីវិលជាខ្លាំងចាប់តាំងពីឆ្នាំ ២០០៧ មក ។ គេអាចមានលទ្ធភាពដំឡើងប្រាក់ខែចំពោះវិស័យមិនមែនយោធា ប្រសិនបើមានលំហសារពើពន្ធ និងកាំប្រាក់ ត្រូវបានប្តូរទៅកាន់សភាពដើមក្រោមក្របខ័ណ្ឌនៃកំណែទម្រង់ប្រាក់ខែដែលមានប្រសិទ្ធភាព ។

**ការគាំទ្ររបស់ម្ចាស់ជំនួយនៅមានចំនួនច្រើនប្រមាណជាមួយភាគបីនៃចំណាយទូទៅរបស់រដ្ឋាភិបាល ឬប្រហែល៤០ ភាគរយនៃចំណាយសាធារណៈសរុបរួម នៅពេលដែលការគាំទ្រក្រៅថវិការបស់ម្ចាស់ជំនួយសម្រាប់សហប្រតិបត្តិការបច្ចេកទេស និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលធ្វើការលើផ្នែកទំនិញសាធារណៈត្រូវបានរាប់បញ្ចូល។** ភាពពឹងផ្អែកដ៏ច្រើនលើម្ចាស់ជំនួយបែបនេះមានន័យថា រដ្ឋាភិបាល និងម្ចាស់ជំនួយ ចាំបាច់ត្រូវសម្របសម្រួលឱ្យបានប្រសើរជាងមុន ដើម្បីធ្វើឱ្យប្រាកដថា ការកសាងផែនការយុទ្ធសាស្ត្រ ការរៀបចំថវិកា និងការសម្របសម្រួលជំនួយ ត្រូវបានតម្រឹមតម្រង់បានពេញលេញ ។

**កំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ ព្រមជាមួយការកើនឡើងនូវចំណូលជាក់ស្តែង ធ្វើឱ្យគេអាចបែងចែកធនធានបានច្រើនជាងផែនការ ដែលបានគ្រោងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៅឆ្នាំ ២០០៨។** ទោះជាយ៉ាងណាក្តី ការចំណាយប្រាក់បន្ថែម ពុំមែនសុទ្ធតែមានន័យថាបានទទួលវឌ្ឍនភាពដូចការព្យាករណ៍នោះទេ ។ កម្ពុជានៅមិនទាន់អនុវត្តបាននូវគោលដៅបី ក្នុងចំណោមគោលដៅទាំងប្រាំបួននៃគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្ស ។ ក្នុងក្របខ័ណ្ឌនៃកញ្ចប់ធនធានមានកម្រិតរបស់កម្ពុជា គប្បីស្វះស្វែងបែងចែកចំណាយជាថ្មីឡើងវិញ ដើម្បីអនុវត្តគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សឱ្យបាន និងដើម្បីគាំទ្រកំណើន ។ អនុសាសន៍នានានៅក្នុងជំពូកនេះ បង្ហាញនូវជំហានមួយចំនួនដែលត្រូវប្រកាន់យកក្នុងទិសដៅនេះ រាប់ទាំងការបង្កើនចំណែកធនធានសម្រាប់ការថែទាំ ការបង្កើនប្រាក់ខែក្នុងករណីដែលពិនិត្យឃើញថា បង្កើនប្រសិទ្ធភាពប៉ុណ្ណោះ និងប្រសិនបើកំណែទម្រង់នៃប្រព័ន្ធប្រាក់ខែបច្ចុប្បន្នផ្លាស់ប្តូរការលើកទឹកចិត្ត និងបង្កើនវិភាជន៍ធនធានទៅកាន់វិស័យសំខាន់ៗដែលបានកំណត់នៅក្នុង ផយអជ ។

### ប្រអប់លេខ ១. វិសាលភាព និយមន័យ និងការគណនាទិន្នន័យចំណាយដែលប្រើក្នុងរបាយការណ៍នេះ

**វិសាលភាព :** ពាក្យថា "ចំណាយទូទៅរបស់រដ្ឋាភិបាល" ដែលប្រើនៅក្នុងរបាយការណ៍នេះ រួមមាន ចំណាយរបស់រដ្ឋាភិបាលថ្នាក់កណ្តាល និងអាជ្ញាធរមូលដ្ឋាន (ថ្នាក់ខេត្ត) ដែលទាំងពីរនេះទទួលហិរញ្ញប្បទានក្នុងស្រុក និងបរទេស លើកលែងចំណុចដូចតទៅ : សហប្រតិបត្តិការបច្ចេកទេស ដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយ-ចំណាយរបស់អង្គការក្រៅរដ្ឋាភិបាលទោះបីជាផ្តល់មូលនិធិពីធនធានផ្ទាល់ក្តី-និងចំណាយឯកជនលើអ្វីដែលជាទំនិញសាធារណៈ ។

**ការប្រមូលទិន្នន័យ :** ទិន្នន័យស្តីពីចំណាយដែលផ្តល់ហិរញ្ញប្បទានពីក្នុងស្រុក រួមមាន ចំណូលថ្នាក់ខេត្ត ហើយទិន្នន័យចំណាយបានទទួលពីរបាយការណ៍ TOFE ប្រចាំឆ្នាំ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ទិន្នន័យចំណាយដែលផ្តល់ហិរញ្ញប្បទានពីបរទេស ត្រូវបានប្រមូលដោយទិន្នន័យបើកផ្តល់ហិរញ្ញប្បទានសហ-ប្រតិបត្តិការអភិវឌ្ឍន៍ (របាយការណ៍ដោយ កអក) ។ ទិន្នន័យទាំងពីរត្រូវបានផ្គុំគ្នាដើម្បីបានតួលេខចំណាយទូទៅរបស់រដ្ឋាភិបាល ។

ខណៈពេលដែលមានទិន្នន័យទាំងនេះ កង្វះការបូកបញ្ចូលគ្នាធ្វើឱ្យការតាមដាន និងការរៀបចំផែនការជួបការលំបាក ។

**ការវិភាគដែលបានបង្ហាញនៅក្នុងជំពូកនេះ មានមូលដ្ឋានលើទិន្នន័យសម្រាប់ចំណាយទូទៅរបស់រដ្ឋាភិបាល ដែលក្រុមនេះបានប្រមូលពីព័ត៌មានដែលផ្តល់ដោយនាយកដ្ឋាននានារបស់រដ្ឋាភិបាល និងម្ចាស់ជំនួយ។** បន្ថែមលើចំណាយទូទៅរបស់រដ្ឋាភិបាល មានចំណាយលើទំនិញសាធារណៈរបស់អង្គភាពក្រៅរដ្ឋាភិបាល អាចអនុវត្តដោយរដ្ឋាភិបាលក្រោមកាលៈទេសៈផ្សេងគ្នា ឬនៅប្រទេសខុសគ្នា។ ចំណាយបែបនេះរួមមាន ចំណាយរបស់អង្គការក្រៅរដ្ឋាភិបាលនានាលើវិស័យសុខាភិបាល និងអប់រំ ដែលភាគច្រើនបានមូលនិធិមកពីបរទេស និងចំណាយដោយគណបក្សនយោបាយ និងចំណាយដោយអ្នកដទៃទៀត។ ទិដ្ឋភាពសង្ខេបខ្លីមួយត្រូវបានបង្ហាញនៅក្នុងប្រអប់លេខ ១។

**ផ្នែកផ្សេងទៀតនៃជំពូក ត្រូវបានរៀបចំដូចតទៅ។** ផ្នែក ខ វិភាគ កម្រិតនៃចំណាយរបស់រដ្ឋាភិបាល និងផ្នែក គ ពិភាក្សាសមាសភាពនៃចំណាយរបស់រដ្ឋាភិបាល។ ផ្នែក ឃ បង្ហាញ និងវិភាគលទ្ធផលនៃអង្កេតមួយកាលពីពេលកន្លងទៅថ្មីៗ អំពីចំណាយឯកជនចំពោះទំនិញសាធារណៈនៅកម្រិតឃុំ។ ផ្នែក ង សន្និដ្ឋានអមដោយអនុសាសន៍ ដើម្បីជួយកែលំអគោលនយោបាយរបស់រដ្ឋាភិបាល។

## ខ. កម្រិតនៃចំណាយសាធារណៈ

**បន្ទាប់ពីការកើនឡើងខ្លះក្នុងអំឡុងឆ្នាំ ២០០៦ ដល់ ២០០៨ ចំណាយរបស់រដ្ឋាភិបាលបានកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ ២០០៩ ដោយសារវិធានការជំរុញសារពើពន្ធយ៉ាងធំ និងការដំឡើងយ៉ាងខ្ពស់នូវបៀវត្សសាធារណៈមួយចំនួន។** បន្ទាប់ពីការកែតម្រូវសារពើពន្ធដែលបានចាប់ផ្តើមនៅឆ្នាំ ២០០៤ ចំណាយរបស់រដ្ឋាភិបាលជិតស្មើ ១៥ ភាគរយ នៃ ផសស នៅឆ្នាំ ២០០៨ ប៉ុន្តែកម្រិតនេះបានផ្លាស់ប្តូរតិចតួចចាប់តាំងពីដើមទសវត្សរ៍នេះ (តារាងលេខ ៤)។ ទោះជាយ៉ាងណាក្តី នៅឆ្នាំ ២០០៩ ចំណាយបានកើនឡើងយ៉ាងខ្ពស់ស្មើនឹង ៥ ភាគរយ នៃ ផសស ក្នុងនោះ ០,៧ ភាគរយ ឆ្លុះបញ្ចាំងការធ្លាក់ចុះតួលេខជាក់ស្តែងនៃ ផសស ដោយសារវិបត្តិសេដ្ឋកិច្ច ហើយ ១,៥ ភាគរយ ដោយសារការដំឡើងប្រាក់ខែ ពិសេសចំពោះយោធា។ ក្រៅពីនេះឆ្លុះបញ្ចាំងការជំរុញសារពើពន្ធកាន់តែទូលាយ។

**តារាងលេខ ៤. ចំណាយទូទៅរបស់រដ្ឋាភិបាលបានកើនឡើងយ៉ាងខ្ពស់នៅឆ្នាំ ២០០៩ ក្រោយពីការកើនឡើងតិចតួចក្នុងអំឡុងឆ្នាំ ២០០៥-២០០៨** (គិតជា ភាគរយនៃ ផសស)

| | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩e |
|---|---|---|---|---|---|---|---|---|---|
| សរុបចំណាយ និងការឱ្យខ្ចី | ១៥,២ | ១៦,៧ | ១៥,៥ | ១៤,៨ | ១២,៨ | ១៤,២ | ១៤,៧ | ១៤,៨ | ១៩,៦ |
| ចំណាយចរន្ត | ៨,៩ | ៩,៤ | ៩,៩ | ៨,៩ | ៧,៩ | ៨,៥ | ៨,៧ | ៩,០ | ១១,២ |
| ប្រាក់ខែ | ៣,១ | ៣,៥ | ៣,៣ | ៣,៥ | ៣,២ | ៣,៣ | ៣,០ | ៣,២ | ៤,៦ |
| ក្នុងនោះ រដ្ឋបាលស៊ីវិល | ១,៤ | ១,៨ | ១,៨ | ១,៦ | ១,៦ | ១,៧ | ២,២ | ២,១ | ២,៥ |
| ចំណាយចរន្តដទៃទៀត | ៥,៥ | ៥,៨ | ៦,២ | ៤,៨ | ៤,១ | ៤,៦ | ៥,០ | ៥,១ | ៥,៩ |
| ក្នុងនោះ : ការប្រាក់ | ០,១ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ |
| ចំណាយថ្នាក់ខេត្ត | ០,២ | ០,១ | ០,៥ | ០,៥ | ០,៥ | ០,៦ | ០,៦ | ០,៨ | ០,៧ |
| ចំណាយមូលធន | ៦,២ | ៧,៤ | ៦,៥ | ៦,០ | ៤,៩ | ៥,៨ | ៦,១ | ៥,៨ | ៨,៤ |
| ផ្តល់ហិរញ្ញប្បទានពីក្នុងស្រុក | ១,៧ | ២,០ | ១,៨ | ១,៤ | ១,២ | ១,៣ | ១,២ | ១,៥ | ២,៣ |
| ផ្តល់ហិរញ្ញប្បទានពីបរទេស | ៤,៦ | ៥,៤ | ៤,៧ | ៤,៦ | ៣,៧ | ៤,៥ | ៤,៨ | ៤,៣ | ៦,១ |
| **ចំណុចផ្សេងទៀត :** | | | | | | | | | |
| **ចំណាយកែតម្រូវ** | | | | | | | | | |
| ***ចំណាយចរន្តដែលបានកែតម្រូវ*** | ១០,១ | ១០,៧ | ១១,៣ | ៩,៩ | ៨,៨ | ៩,៥ | ៩,៧ | ៩,៩ | ១២,៤ |
| ចំណាយចរន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៨,៩ | ៩,៤ | ៩,៩ | ៨,៩ | ៧,៩ | ៨,៥ | ៨,៧ | ៩,០ | ១១,២ |
| ការកែតម្រូវចំពោះចំណាយដែលផ្តល់ហិរញ្ញប្បទានពីបរទេស | ១,២ | ១,៣ | ១,៤ | ១,០ | ០,៩ | ១,០ | ១,០ | ០,៩ | ១,២ |
| ***ចំណាយមូលធនដែលបានកែតម្រូវ*** | ៥,០ | ៦,១ | ៥,១ | ៥,០ | ៤,១ | ៤,៧ | ៥,០ | ៤,៩ | ៧,៣ |
| ចំណាយមូលធនដែលផ្តល់ហិរញ្ញប្បទានពីក្នុងស្រុក | ១,៧ | ២,០ | ១,៨ | ១,៤ | ១,២ | ១,៣ | ១,២ | ១,៥ | ២,៣ |
| ចំណាយមូលធនដែលផ្តល់ហិរញ្ញប្បទានពីបរទេសដែលបានកែតម្រូវ | ៣,៣ | ៤,១ | ៣,៣ | ៣,៦ | ២,៩ | ៣,៤ | ៣,៨ | ៣,៣ | ៥,០ |

*ប្រភព :* មូលនិធិរូបិយវត្ថុអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**មានចំណាយលើទំនិញសាធារណៈមួយចំនួន ដែលមិនបានដាក់បញ្ចូលទៅក្នុងតួលេខចំណាយទូទៅរបស់រដ្ឋាភិបាល ហើយចាំបាច់ត្រូវពិចារណាអំពីតួលេខទាំងនេះ។** ចំណាយទាំងនេះត្រូវបានបង្ហាញលម្អិតនៅក្នុងតារាងលេខ ៥ និងរួមមាន :

- **សហប្រតិបត្តិការបច្ចេកទេស :** ទាំងនេះ គឺជាចំណាយ ដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយទាំងស្រុងផ្តោតលើការពង្រឹងជំនាញបច្ចេកទេសរបស់មន្ត្រីរដ្ឋាភិបាល និងផ្តោតលើការកសាងស្ថាប័ន។ បរិមាណទឹកប្រាក់ចំណាយទាំងនេះ ស្មើនឹង ៣ ភាគរយ នៃ ផសស ឬស្មើនឹងមួយភាគបីនៃជំនួយឧបត្ថម្ភគាំទ្រសរុបពីបរទេស។ នៅបណ្តាប្រទេសភាគច្រើនដទៃទៀត មុខចំណាយនេះត្រូវបានចាត់ជាចំណាយទូទៅរបស់រដ្ឋាភិបាល។ នៅកម្ពុជា មុខចំណាយនេះមិនត្រូវបានបង្ហាញដូច្នេះឡើយ សឱ្យឃើញនូវការគ្រប់គ្រងមានកម្រិតរបស់រដ្ឋាភិបាលអំពីរបៀបប្រើមុខចំណាយនោះ និងសឱ្យឃើញអវត្តមាននៃសហហិរញ្ញប្បទាន ឬការសន្យាផ្តល់ក្នុងពេលអនាគតរបស់រដ្ឋាភិបាល។ ជាផ្នែកមួយនៃអនុសាសន៍របស់យើង ៗស្នើឱ្យរដ្ឋាភិបាល និងម្ចាស់ជំនួយធ្វើការជិតស្និទ្ធជាមួយគ្នា ដើម្បីឯកភាពលើវិសាលភាពនៃសកម្មភាពទាំងនេះ និងដើម្បីសរុបចំណាយបែបនេះទាំងអស់នៅក្រោមថវិកាទូទៅរបស់រដ្ឋាភិបាល។

- **ចំណាយរបស់អង្គការក្រៅរដ្ឋាភិបាល :** ចំណាយទាំងនេះមានទំហំធំលើទំនិញសាធារណៈ រួមមាន ចំណាយលើវិស័យអប់រំ និងសុខាភិបាល ដែលផ្តល់ហិរញ្ញប្បទានដោយអង្គការក្រៅរដ្ឋាភិបាលនានា (ពីធនធានផ្ទាល់របស់ខ្លួន)។ អង្គការក្រៅរដ្ឋាភិបាលដដែលទាំងនេះ ក៏ច្រើនជួយអនុវត្តកម្មវិធីរបស់រដ្ឋាភិបាលដែលស្ថិតនៅក្នុងផ្នែកដូចគ្នា និងដែលមាននៅក្នុងថវិកា។ នៅពេលដែលអង្គការក្រៅរដ្ឋាភិបាលអនុវត្តចំណាយលើទំនិញសាធារណៈដែលនៅប្រទេសដទៃ ឬនៅក្នុងកាលៈទេសៈផ្សេងទៀត រដ្ឋាភិបាលជាអ្នកអនុវត្តសំខាន់ អាជ្ញាធរត្រូវពិចារណាអំពីទំហំ និងផ្នែកនានាចំពោះការចំណាយទាំងនេះក្នុងការរៀបចំថវិកា។ គេមិនអាចព្យាករណ៍ការគាំទ្ររបស់ម្ចាស់ជំនួយចំពោះអង្គការក្រៅរដ្ឋាភិបាលសម្រាប់រយៈពេលវែងតទៅទៀតបានឡើយ ដូចការគាំទ្ររបស់ពួកគេចំពោះរដ្ឋាភិបាលនោះទេ ប្រការនេះអាចបង្កឱ្យមានទ្វេគ្រោះ និងការប្រាសចាកពីសភាពដើម។

- **ចំណាយឯកជនលើទំនិញសាធារណៈ :** ម្ចាស់ជំនួយឯកជន - ជាអាទិ៍ គឺគណបក្សនយោបាយ - ផ្តល់ហិរញ្ញប្បទានលើចំណាយរបស់អាជ្ញាធរមូលដ្ឋាន លើសាលារៀន មន្ទីរពេទ្យ និងផ្លូវថ្នល់ (សូមមើលផ្នែក ឃ ខាងក្រោម)។

**ចំណាយទូទៅរបស់រដ្ឋាភិបាល និងចំណាយលើទំនិញសាធារណៈរបស់ស្ថាប័នមិនមែនរដ្ឋាភិបាលមានចំនួនប្រហែល ២០ ភាគរយ នៃ ផសស នៅឆ្នាំ ២០០៧-២០០៨ និង ២៤ ភាគរយ នៅឆ្នាំ ២០០៩។** តួលេខទាំងនេះមិនខ្ពស់ខ្លាំងនោះទេ ប៉ុន្តែមានកម្រិតក្បែរកម្រិតខ្ពស់សម្រាប់បណ្តាប្រទេសដែលមានកម្រិតនៃ ផសស ប្រហាក់ប្រហែលគ្នាចំពោះពលរដ្ឋម្នាក់ៗ។ ការឆ្លុះបញ្ចាំងចំណាយទាំងនេះសមស្របនៅក្នុងថវិកា ត្រូវមានអាទិភាពរយៈពេលមធ្យម ប៉ុន្តែត្រូវលើកយកចំណុចនេះមកពិចារណានៅពេលរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយថវិកាត្រូវតែជាកង្វល់ចំពោះមុខ។ ប្រការនេះអាចអមដោយកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយក្នុងភាពជាដៃគូ ដើម្បីតម្រឹមតម្រង់ការគាំទ្ររបស់ម្ចាស់ជំនួយឱ្យបានជិតស្និទ្ធជាមួយផែនការយុទ្ធសាស្ត្រ និងថវិកា។

**តារាងលេខ ៥. ចំណាយសាធារណៈសរុបនៅកម្ពុជាមានទំហំធំ**
(គិតជា ភាគរយនៃផសស ឆ្នាំ២០០៩)

| សរុប | ២៤,០ |
|---|---|
| ចំណាយទូទៅរបស់រដ្ឋាភិបាល | ១៩,៦ |
| ហិរញ្ញប្បទានពីក្នុងស្រុក | ១៤,០ |
| ហិរញ្ញប្បទានពីបរទេស (ជំនួយឥតសំណង និងកម្ចី) | ៥,៦ |
| សហប្រតិបត្តិការបច្ចេកទេស១/ | ២,៩ |
| អង្គការក្រៅរដ្ឋាភិបាលទទួលហិរញ្ញប្បទានពីម្ចាស់ជំនួយក្នុងស្រុក | ១,០ |
| ចំណាយឯកជនលើទំនិញសាធារណៈ២/ | ០,៥ |

*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*សំគាល់ :* ១/ ផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយបរទេស ចំណែកឯរដ្ឋាភិបាលជាអ្នកអនុវត្ត។
២/ លើមូលដ្ឋាននៃការអង្កេតថ្នាក់ឃុំ (មើលខាងក្រោម)

**រូបលេខ ៧. ចំណាយទូទៅរបស់រដ្ឋាភិបាលស្របជាមួយចំណាយទូទៅក្នុងបណ្តាប្រទេស ដែលមានចំណូលក្នុងពលរដ្ឋម្នាក់ៗប្រហាក់ប្រហែលគ្នា**
(គិតជា ភាគរយនៃ ផសស ឆ្នាំ២០០៨ និង២០០៩)




*ប្រភព :* សូចនាករអភិវឌ្ឍន៍ពិភពលោក
*សំគាល់ :* ១/ ចំណាយសាធារណៈសរុបសម្រាប់ឆ្នាំ ២០០៩ មានបង្ហាញនៅក្នុងតារាងលេខ ៥

**សរុបចំណាយរបស់រដ្ឋាភិបាល និងចំណាយឯកជនលើទំនិញសាធារណៈខាងលើបង្ហាញនូវការយល់ដឹងដែលមានសារប្រយោជន៍ចំពោះចំណែកនៃការបែងចែកធនធានសាឡើងវិញនៅក្នុងសេដ្ឋកិច្ច។** ជាញឹកញាប់ គេមិនអាចរកបាននូវទិន្នន័យដែលអនុញ្ញាតឱ្យគណនាបែបនេះសម្រាប់បណ្តាប្រទេសដែលមានកម្រិតប្រាក់ចំណូលប្រហាក់ប្រហែលគ្នាបានឡើយ។ អាស្រ័យហេតុនេះ ការវិភាគតទៅនេះ - ជាពិសេសនៅពេលដែលយើងប្រៀបធៀបកម្ពុជាជាមួយប្រទេសជិតខាង ឬជាមួយបណ្តាប្រទេសដែលមានប្រាក់ចំណូលប្រហាក់ប្រហែលគ្នា - នឹងផ្តោតលើថវិកាទូទៅរបស់រដ្ឋាភិបាល។

**រហូតដល់ឆ្នាំ ២០០៨ ចំណាយទូទៅរបស់រដ្ឋាភិបាលកម្ពុជាធៀបនឹង ផសស មានកម្រិតដូចគ្នាទៅនឹងបណ្តាប្រទេសនានាដែលមានកម្រិតចំណូលក្នុងពលរដ្ឋម្នាក់ៗប្រហាក់ប្រហែលគ្នា** (រូបលេខ ៧)។ ទោះជាយ៉ាងណាក្តី មានប្រទេសតិចតួចដែលពលរដ្ឋម្នាក់ៗមានកម្រិតប្រាក់ចំណូលប្រហែលពលរដ្ឋម្នាក់ៗនៅកម្ពុជា បានប្រើប្រាស់វិធានការជំរុញសារពើពន្ធដែលកម្ពុជាបានអនុវត្តនៅឆ្នាំ ២០០៩ តាមរយៈការពឹងផ្អែកលើប្រាក់បញ្ញើរបស់រដ្ឋាភិបាល។ ជាលទ្ធផល ការចំណាយធៀបនឹង ផសស នៅកម្ពុជានៅឆ្នាំ ២០០៩ ប្រហែលជាមានកម្រិតចំណាយខ្ពស់បើធៀបជាមួយប្រទេស ដែលមានប្រាក់ចំណូលប្រហាក់ប្រហែលគ្នា។ នោះ គឺជាការសម្រេចចិត្តដាច់ណាត់ និងអនុវត្តបានទាន់ពេលវេលា។ នៅពេលវិធានការនេះត្រូវបានបញ្ឈប់ រដ្ឋាភិបាលទំនងជារក្សាទុកនូវការចំណាយខ្ពស់ ដើម្បីជួយលើកកម្ពស់ការផ្តល់សេវាសាធារណៈដែលមានតម្រូវការច្រើន ស្របជាមួយការកើនឡើងនូវប្រាក់ចំណូល និងកិច្ចប្រឹងប្រែងដែលកំពុងអនុវត្តជាបន្តក្នុងការកាត់បន្ថយការលើកលែងពន្ធ និងការគេចពន្ធ។ ខណៈពេលដែលកញ្ចប់ប្រាក់ចំណូលកើនឡើងនឹងជួយកាត់បន្ថយឧបសគ្គចម្បងៗ រួមមាន ហេដ្ឋារចនាសម្ព័ន្ធ-ពិសេស គឺវិស័យថាមពល - រដ្ឋាភិបាលចាំបាច់ត្រូវធ្វើយ៉ាងណាឱ្យមូលនិធិបន្ថែមត្រូវបានចំណាយបានត្រឹមត្រូវ មានប្រសិទ្ធភាព និងប្រសិទ្ធផល។

**ម្ចាស់ជំនួយបរទេសផ្តល់ហិរញ្ញប្បទានប្រមាណជាមួយភាគបីនៃចំណាយទូទៅរបស់រដ្ឋាភិបាល តាមរយៈជំនួយឥតសំណង និងកម្ចី។** ការគាំទ្ររបស់ម្ចាស់ជំនួយត្រូវបានបង្កើនយ៉ាងឆាប់រហ័សជាប្រាក់ដុល្លារ ប៉ុន្តែបានធ្លាក់ចុះធៀបនឹង ផសស រហូតដល់ពេលចាប់ផ្តើមមានវិបត្តិ។ ជាមួយនឹងសហប្រតិបត្តិការបច្ចេកទេស ជំនួយឥតសំណងសម្រាប់ការកសាងសមត្ថភាព និងការកសាងស្ថាប័ន និងការផ្តល់ហិរញ្ញប្បទានដល់អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយបរទេសផ្តល់ហិរញ្ញប្បទានប្រហែល ៤០ ភាគរយ នៃចំណាយសាធារណៈសរុប។ ការគាំទ្ររបស់ម្ចាស់ជំនួយនឹងវិវត្តទៅតាមពេលវេលាទៅតាមកត្តាផ្សេងៗ រួមមានសមត្ថភាព និងចេតនារបស់រដ្ឋាភិបាលក្នុងការបង្កើនប្រាក់ចំណូលប្រាក់ចំណូលបន្ថែមឱ្យបានច្រើនដោយខ្លួនឯង តម្រូវការចំណាយខ្ពស់របស់រដ្ឋាភិបាលក្នុងកម្រិតនៃប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់ៗ និងក្នុងកម្រិតសមត្ថភាពអនុវត្តរបស់ខ្លួន។ ជាមួយគ្នានេះ រដ្ឋាភិបាល និងម្ចាស់ជំនួយត្រូវបង្កើនវឌ្ឍនភាពបន្ថែមទៀតលើការតម្រឹមតម្រង់ការគាំទ្ររបស់ម្ចាស់ជំនួយជាមួយទិសដៅយុទ្ធសាស្ត្រចំពោះសេដ្ឋកិច្ច និងថវិកា។ ការដាក់បញ្ចូលការគាំទ្ររបស់ម្ចាស់ជំនួយជាផ្លូវការទៅក្នុងថវិកា ក៏នឹងជួយរដ្ឋាភិបាលក្នុងការកសាងផែនការ និងតាមដានការអនុវត្តគោលនយោបាយសារពើពន្ធផងដែរ។

## គ. សមាសភាគនៃចំណាយរដ្ឋាភិបាល

**សមាសភាគនៃចំណាយរដ្ឋាភិបាលមានការប្រែប្រួលតិចតួចរហូតដល់ឆ្នាំ ២០០៨។** ទោះជាយ៉ាងណាក្តី វិធានការជំរុញសារពើពន្ធនៅឆ្នាំ ២០០៩ និងការដំឡើងប្រាក់ខែ - ពិសេសសម្រាប់កងកម្លាំងការពារ និងសន្តិសុខជាតិ - ធ្វើឱ្យទំហំចំណាយកើនឡើងយ៉ាងច្រើន ។ ខណៈពេលដែលផ្នែកភាគច្រើននៃវិធានការជំរុញសារពើពន្ធ ត្រូវបានបញ្ឈប់ប្រាក់ខែនៅតែមានកំណើនដដែល ។

### ចំណាត់ថ្នាក់បែបសេដ្ឋកិច្ច

**ការចាត់ថ្នាក់នៃវិភាជន៍ថវិការបស់យើងនៅក្នុងផ្នែកនេះ មានសង្គតិភាពជាទូទៅជាមួយគោលដៅរបស់រដ្ឋាភិបាល ដែលបានបង្ហាញនៅក្នុងផយអជ។** ទោះជាយ៉ាងណាក្តី ការកើនឡើងយ៉ាងច្រើននូវប្រាក់ខែយោធា និងការពារជាតិនៅឆ្នាំ ២០០៩ ធ្វើឱ្យប៉ះពាល់ដល់ចំណាយសម្រាប់ការថែទាំ ដែលមានសារៈសំខាន់ក្នុងការរក្សាសន្និធិមូលធនឱ្យមានទម្រង់សមរម្យ[១៧] ។

<u>**បញ្ជីប្រាក់ខែ**</u>

**បន្ទាប់ពីការផ្លាស់ប្តូរខ្លះៗកាលពីមុន ប្រាក់ខែសរុបបានកើនឡើងយ៉ាងច្រើននៅឆ្នាំ ២០០៨ និង ២០០៩ គិតជាភាគរយនៃ ផសស** បន្ថែមលើការដំឡើងប្រាក់ខែចំពោះបុគ្គលិកការពារជាតិ និងសន្តិសុខជាតិ ចំណាយប្រាក់ខែសម្រាប់បុគ្គលិកស៊ីវិលបានកើនឡើងជាបណ្តើរៗចាប់តាំងពីឆ្នាំ ២០០៧ មក (រូបលេខ ៨-រូបលេខ ៩) ។ លក្ខណៈលេចធ្លោមួយចំនួនផ្សេងទៀតនៃប្រាក់ខែសរុប និងការងារសាធារណៈរួមមាន :

- **ទំហំប្រាក់ខែសរុបមិនខ្ពស់ជាងនៅបណ្តាប្រទេសដែលមាន ផសស ក្នុងម្នាក់ៗប្រហាក់ប្រហែលគ្នាឡើយ។**
- **ការងារសាធារណៈក្រៅពីវិស័យការពារ និងសន្តិសុខ - ប្រហែល ១,៥ ភាគរយ នៃប្រជាជន - តិចជាងនៅប្រទេសដទៃដែលមានចំនួនប្រជាជនប្រហាក់ប្រហែលគ្នា** (រូបលេខ ១០) ។ ទោះជាយ៉ាងណាក្តី ភាពខុសគ្នាមានទំហំតិចតួចនៅពេលប្រៀបធៀបកម្ពុជាជាមួយប្រទេសដែលមានកម្រិតប្រាក់ចំណូលប្រហែលគ្នា និងជាពិសេសជាមួយប្រទេសសឹង្ហបុរី ។

**រូបលេខ ៨. ប្រាក់ខែកើនឡើង ប៉ុន្តែចំណាយលើការថែទាំ និងចំណាយប្រតិបត្តិការមាននិន្នាការធ្លាក់ចុះ**
(គិតជា ភាគរយ នៃចំណាយចរន្ត)




*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**រូបលេខ ៩. ចំណាយប្រាក់ខែបានកើនឡើងយ៉ាងច្រើននៅឆ្នាំ២០០៩ មួយផ្នែកធំដោយសារកំណើនចំណាយប្រាក់ខែកងកម្លាំងយោធា និងសន្តិសុខ** (គិតជា ភាគរយ នៃផសស)




*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

*១៧ អាជ្ញាធរនានានៅកម្ពុជាចាត់ថ្នាក់ចំណាយប្រាក់ខែរួមជាពីរផ្នែក : (i) ការពារ និងសន្តិសុខ និង (ii) រដ្ឋបាលស៊ីវិល ។ សម្រាប់រដ្ឋបាលស៊ីវិល រួមមាន ប្រាក់ខែសម្រាប់គ្រូបង្រៀន និងគ្រូពេទ្យផងដែរ ។*

- **ក្នុងកម្រិតស្ថានភាពនៃទំហំការងារនៅកម្ពុជា និងទំហំថវិកាចំណាយប្រាក់ខែសម្រាប់បុគ្គលិកក្នុងផ្នែកមិនមែនយោធា និងសន្តិសុខ ក៏មានចំនួនតិចដូចនៅប្រទេសដទៃទៀតនានាដែលមានកម្រិតនៃ ផសស ក្នុងពលរដ្ឋម្នាក់ៗប្រហាក់ប្រហែលគ្នាដែរ** (រូបលេខ ១១)។
- **ចំណែកប្រាក់ខែនៃវិស័យយោធា និងសន្តិសុខមានទំហំធំជាងចំណែកប្រាក់ខែសរុបនៃផ្នែកសាធារណៈ។** ការដំឡើងប្រាក់ខែកាលពីពេលកន្លងទៅថ្មីៗ ទោះបីជាបានមកពីការកាត់បន្ថយចំណែកមួយនៃចំណាយសរុបចាប់តាំងពីដើមឆ្នាំ ២000 ក្តី ក៏មានលទ្ធភាពតិចតួចក្នុងការដំឡើងប្រាក់ខែសម្រាប់បុគ្គលិកស៊ីវិលដែរ។

**រូបលេខ ១០. ចំនួនបុគ្គលិកសាធារណៈក្រៅពីយោធា និងសន្តិសុខមានទំហំតូច...**
(បុគ្គលិកស៊ីវិល គិតជាភាគរយនៃប្រជាជន ឆ្នាំ ២០០៨)




*ប្រភព* : ការវិភាគរបស់ធនាគារពិភពលោក

**រូបលេខ ១១. ...ដូចប្រាក់ខែជនស៊ីវិល**
(គិតជា ភាគរយនៃ ផសស ឆ្នាំ ២០០៨ ឬជាតួលេខចុងក្រោយ)




*ប្រភព* : ការវិភាគរបស់ធនាគារពិភពលោក

- **ចំណែកប្រាក់ខែសម្រាប់វិស័យអប់រំនៅក្នុងប្រាក់ខែសរុបបានធ្លាក់ចុះចាប់តាំងពី ២០០៧ មក** (រូបលេខ ១២)។ ប្រាក់ខែវិស័យអប់រំបានថយចុះ ៤៥ ភាគរយ នៃចំណាយប្រាក់ខែ ប៉ុន្តែបុគ្គលិកក្នុងវិស័យអប់រំបានកើនឡើងដល់ ៥៩ ភាគរយ នៃចំនួនមន្ត្រីរាជការស៊ីវិលសរុប (ឆ្នាំ ២០០៩)។ ប្រការនេះមានន័យថា ប្រាក់ខែមធ្យមរបស់បុគ្គលិកអប់រំមានកម្រិតទាបជាងប្រាក់ខែមធ្យមរបស់មន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិ។ បញ្ហានេះចោទជាសំណួរថា តើប្រាក់ឧបត្ថម្ភរបស់គ្រូបង្រៀនត្រូវបានផ្តល់អាទិភាពត្រឹមត្រូវ ដែរឬយ៉ាងណា (តារាងលេខ ៦)។
- **រចនាសម្ព័ន្ធប្រាក់ខែមានលក្ខណៈចង្អៀត។** អនុបាតមធ្យមនៃប្រាក់ខែមន្ត្រីរាជការពីខ្ពស់បំផុតដល់ទាបបំផុត (compression ration) ស្មើនឹង ៣,៥ នៅកម្ពុជា ផ្ទុយទៅវិញ អនុបាតនេះស្មើ ៥ ឬ ៦ នៅបណ្តាប្រទេសដែលមានចំណូលទាបទៅមធ្យមនៅអឺរ៉ុបខាងកើត និងស្មើប្រមាណជា ១០ នៅបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន[១៨]។ នៅក្នុងរចនាសម្ព័ន្ធប្រាក់ខែអាចនៅមានលទ្ធភាពខ្លះ ដើម្បីពង្រឹងការលើកទឹកចិត្តចំពោះលទ្ធផលអនុវត្តល្អ ដែលនេះ គឺជាប្រធានបទមួយដែលយើងនឹងវិលត្រឡប់មកពិភាក្សានៅខាងក្រោម។ ទោះជាយ៉ាងណាក្តី នៅបណ្តាប្រទេសដែលមានកម្រិតនៃការអភិវឌ្ឍដូចប្រទេសកម្ពុជា ការបំបែកបង្ហំប្រាក់ខែសមស្របមិនងាយនឹងសម្រេចបានទេ។ ហើយនៅក្នុងការដំឡើងកម្រិតប្រាក់ខែយោធាកាលពីពេលថ្មីៗកន្លងទៅ ធ្វើឱ្យចំណែកនៃប្រាក់ខែ និងទំហំប្រាក់ខែកើនកាន់តែធំ ដែលធ្វើឱ្យមានឱកាសតិចតួចសម្រាប់កែសម្រួលប្រាក់ខែនៃផ្នែកមិនមែនយោធា។

*១៨ compression ratio សម្រាប់ប្រភេទមួយ គឺជាប្រាក់ខែមធ្យមក្នុងប្រភេទនោះ ធៀបជាមួយប្រាក់ខែមធ្យមនៃប្រភេទទាបបំផុត។ សូមអានឯកសាររបស់ Nunberg, Barbara (ឆ្នាំ ១៩៩៥) និង De Tommaso (១៩៩៧) សម្រាប់ការពិភាក្សាលម្អិត។*

- ចំណាយប្រាក់ខែភាគច្រើន គឺប្រាក់ឧបត្ថម្ភ គឺជាផ្នែកដែលមិនជាប់ទាក់ទងទៅនឹងកិច្ចតម្រូវឱ្យមានជំនាញ និងការទទួលខុសត្រូវចំពោះមុខតំណែងរបស់អ្នកដែលទទួលលាភការនោះ ហើយដែលត្រូវបានផ្តល់តាមរយៈនីតិវិធីគ្មានតម្លាភាព ដែលធ្វើឱ្យមានការអាក់អន់ចិត្តក្នុងចំណោមបុគ្គលិកជាច្រើននាក់។ ប្រាក់ខែមូលដ្ឋានមានចំនួនត្រឹមតែ ៤៤ ភាគរយ នៃលាភការសរុបរបស់មន្ត្រីរាជការធៀបនឹងចំនួនរហូតដល់ ៩០ ភាគរយ នៅបណ្តាប្រទេសរីកចម្រើន។

**រូបលេខ ១២. ចំណែកប្រាក់ខែសម្រាប់វិស័យអប់រំបានធ្លាក់ចុះចាប់តាំងពីឆ្នាំ ២០០៧**
(គិតជា ភាគរយនៃប្រាក់ខែសរុប)




*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**រូបលេខ ១៣. ចំណាយមូលធនមានចំនួនធំជាងបណ្តាប្រទេសដែលមានកម្រិតនៃប្រាក់ចំណូលក្នុងម្នាក់ៗប្រហែលគ្នា**
(គិតជា ភាគរយនៃ ផសស)




*ប្រភព :* សូចនាកររបស់ *World Development* ឆ្នាំចុងក្រោយដែលមាន
សំគាល់ : ចំណាយមូលធនកែតម្រូវដូចបានពិភាក្សាក្នុងអត្ថបទ

- **ការបង្កើនលាភការសរុបចំពោះមុខងារមិនអាចជឿជាក់គ្រប់គ្រាន់ថា មានទំនាក់ទំនងទៅនឹងលទ្ធផលអនុវត្តធៀបនឹងការងារផ្លូវការរបស់បុគ្គលនោះបានទេ** (Increases in total remuneration over one's career are not enough linked to performance relative to one's formal job)។
- **មានការពឹងផ្អែកច្រើនលើការផ្តល់ហិរញ្ញប្បទានពីសំណាក់ម្ចាស់ជំនួយ ដើម្បីរ៉ាប់រងលើចំណាយប្រាក់ខែសរុបចំពោះមុខតំណែងមួយក្រុម** (There is significant reliance on donor financing to cover wage bill costs for a subset of public administration positions) **នៃរដ្ឋបាលសាធារណៈដែលចាំបាច់ត្រូវបញ្ឈប់ជាបណ្តើរៗ។**

**ការឧបត្ថម្ភលើបៀវត្សពីសំណាក់ម្ចាស់ជំនួយ ភាគច្រើនមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទិន្នន័យផ្លូវការឡើយ។** នៅចុងឆ្នាំ ២០០៩ រដ្ឋាភិបាលបានបញ្ឈប់ការផ្តល់ប្រាក់ឧបត្ថម្ភលើបៀវត្សដែលផ្អែកលើលទ្ធផលការងារ (the Merit-based Pay Initiative) ដោយសារកង្វល់ដែលថាការណ៍នេះជំរុញឱ្យមានការផ្តល់ប្រាក់ខែមិនស្មើគ្នាចំពោះការងារស្មើគ្នា។ គម្រោងក្រៅថវិកានេះ ត្រូវបានផ្តល់ហិរញ្ញប្បទានរួមគ្នាដោយម្ចាស់ជំនួយ និងរដ្ឋាភិបាលចំពោះមន្ត្រីរាជការអចិន្ត្រៃយ៍ត្រឹមតែ ២ ភាគរយប៉ុណ្ណោះ នៅពេលបញ្ឈប់ការផ្តល់នេះ។ គម្រោងនោះ ត្រូវបានជំនួសដោយអ្វីដែលហៅថាចំណាយប្រតិបត្តិការអាទិភាព (POC) ដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយសុទ្ធសាធ។ ទោះបីជាការផ្តល់ប្រាក់បន្ថែមនៅក្នុងគម្រោងថ្មីនេះមានកម្រិតទាបជាងកាលពីមុនក្តី រដ្ឋាភិបាលមិនចូលរួមក្នុងការផ្តល់មូលនិធិនេះឡើយ បញ្ហាវិសមភាពនៅតែមាន។ ជាលទ្ធផល នេះគ្រាន់តែជាដំណោះស្រាយរយៈពេលខ្លីតែប៉ុណ្ណោះ ចំណែកឯបញ្ហានៅតែត្រូវការឱ្យមានដំណោះស្រាយអចិន្ត្រៃយ៍ ដើម្បីធ្វើឱ្យប្រាកដថាការងារស្មើគ្នាបានទទួលប្រាក់ស្មើគ្នា ដែលគាំទ្រដោយរបៀបវារៈកំណែទម្រង់នៃរដ្ឋបាលសាធារណៈ។

---

*១៩ គម្រោង MBPI បានផ្តល់ប្រាក់ឧបត្ថម្ភជាមធ្យមលើបៀវត្សចំនួន ៣០០ ដុល្លារក្នុងមួយខែ ចំពោះបុគ្គលិកធម្មតា ប៉ុន្តែខ្ពស់រហូតដល់រាប់ពាន់ដុល្លារក្នុងមួយខែ ចំពោះអ្នកទទួលដែលមានជំនាញខ្ពស់ (កម្រិតបណ្ឌិត)។*

**តារាងលេខ ៦. ប្រាក់ខែមធ្យមសម្រាប់វិស័យអប់រំបានកើនឡើង ប៉ុន្តែកើនយឺតជាងប្រាក់ខែមធ្យមរបស់មន្ត្រីរាជការ**
(គិតជា ពាន់រៀលក្នុងមួយខែ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ)

| | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|---|
| ប្រាក់ខែវិស័យអប់រំ | ១៧២ | ១៧០ | ១៧៧ | ២០៤ | ៣០០ | ៣២០ | ៣២៣ |
| ប្រាក់ខែសរុប | ១៤៥ | ១៤៧ | ១៦៧ | ១៨៩ | ២៤៦ | ៣២៥ | ៤៣៣ |
| ប្រាក់ខែមន្ត្រីរាជការស៊ីវិល | ១៦១ | ១៦២ | ១៧៩ | ២០៩ | ៣៣១ | ៣៩៤ | ៤២១ |
| ចំណែកនៃវិស័យអប់រំនៅក្នុងចំនួនសរុបនៃមន្ត្រីរាជការស៊ីវិល (គិតជាភាគរយ) | ៥០ | ៥១ | ៥២ | ៥៣ | ៥៦ | ៥៦ | ៥៩ |
| ចំណែកនៃវិស័យអប់រំនៅក្នុងប្រាក់ខែសរុបនៃប្រាក់ខែមន្ត្រីរាជការស៊ីវិល (គិតជាភាគរយ) | ៥៣ | ៥៤ | ៥១ | ៥២ | ៥០ | ៤៥ | ៤៥ |

*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**ការអនុវត្តកំណែទម្រង់បៀវត្ស និងការងារជាការចាំបាច់ ដើម្បីលើកកម្ពស់គណនេយ្យភាព និងលើកកម្ពស់ការផ្តល់សេវាសាធារណៈ។** ជម្រើសដែលអាចអនុវត្តបានគឺការពិនិត្យមើលលទ្ធភាពអនុវត្តសាកល្បងនូវការបំបែករចនាសម្ព័ន្ធប្រាក់ខែ ដើម្បីកាត់បន្ថយគម្លាតរវាងប្រាក់ខែវិស័យសាធារណៈ និងផ្នែកឯកជនចំពោះគុណវុឌ្ឍិ ការទទួលខុសត្រូវ ប្រសិទ្ធភាព និងលទ្ធផលដូចគ្នា។ ការណ៍អាចអនុវត្តដោយធ្វើសមាហរណកម្មចំណាយបៀវត្សដែលឧបត្ថម្ភដោយម្ចាស់ជំនួយ (បច្ចុប្បន្នប្រហែល ២០ លាន ដុល្លារ ក្នុងមួយឆ្នាំ) និងចំណាយបៀវត្សក្រោមហិរញ្ញប្បទានរបស់រដ្ឋាភិបាល ហើយប្រើប្រាស់ប្រាក់សន្សំជាបណ្តើរៗមកពីផ្នែកដទៃ ដើម្បីកាត់បន្ថយជាបណ្តើរៗនូវហិរញ្ញប្បទានម្ចាស់ជំនួយ និងដាក់បញ្ចូលចំណាយទាំងនេះទៅក្នុងថវិកា។ កំណែទម្រង់ ចាំបាច់ត្រូវរួមបញ្ចូលកំណើនបៀវត្សមូលដ្ឋានយ៉ាងច្រើនជាភាគរយនៃបៀវត្សសរុប (ពោល គឺកំណើនលើផ្នែកនៃបៀវត្សដែលមានទំនាក់ទំនងជាមួយកិច្ចតម្រូវផ្នែកជំនាញ និងការទទួលខុសត្រូវនៃឋានៈរបស់អ្នកទទួលលាភការ) និងផ្សារភ្ជាប់ការកើនឡើងនូវបៀវត្សទៅតាមពេលវេលា និងលទ្ធផលអនុវត្ត។

**ដោយមានធនធានមនុស្សដែលត្រូវបានគ្រប់គ្រងបានល្អគ្រប់គ្រាន់ ការបង្រួញគម្លាតរវាងប្រាក់ខែសាធារណៈ និងប្រាក់ខែឯកជនកន្លងមកបានបង្ហាញថាទទួលជោគជ័យរួចហើយ។** ស្ថាប័នសាធារណៈ ស្វយ័ត និងពាក់កណ្តាលស្វយ័ត រាប់ទាំងស្ថាប័នដែលស្ថិតនៅក្រោមការរៀបចំជាទីភ្នាក់ងារប្រតិបត្តិការពិសេស ពោល គឺរដ្ឋាករទឹកភ្នំពេញ អគ្គិសនីកម្ពុជា ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថាន ឧត្តមសិក្សាសាធារណៈ និងមណ្ឌលសុខភាព ព្រមទាំងមន្ទីរពេទ្យជាច្រើន គឺជាស្ថាប័ន និងគ្រឹះស្ថានដែលបានបង្កើនលទ្ធផលអនុវត្តច្បាស់លាស់។ សូមអានជំពូក ៤ និង ៥ ចំពោះកំណែទម្រង់គំនិតផ្តួចផ្តើមជាក់លាក់ឆ្ពោះទៅរកការលើកកម្ពស់សេវាមូលដ្ឋាន។

<u>**ចំណាយមូលធន**</u>

ដោយសារវិធានការជំរុញសារពើពន្ធ **ចំណាយមូលធនទូទៅរបស់រដ្ឋាភិបាលបានកើនឡើង ៧,៣ ភាគរយ នៃផសស នៅឆ្នាំ ២០០៩ គឺកើនឡើងពី ៤,៩ ភាគរយ នៅឆ្នាំ ២០០៨**[២០]**។** កំណើននៃការបើកផ្តល់ប្រាក់ចំពោះការវិនិយោគ ដែលគាំទ្រដោយម្ចាស់ជំនួយមានចំនួនស្មើនឹងពីរភាគបីនៃកំណើន។ សូម្បីតែមុនការកើនឡើងនូវចំណាយមូលធននៅឆ្នាំ ២០០៩ ដោយសារវិធានការជំរុញសារពើពន្ធ ចំណាយមូលធនរបស់រដ្ឋាភិបាលនៅកម្ពុជា - រាប់ទាំងចំណាយផ្តល់ហិរញ្ញប្បទានដោយការគាំទ្រសប្បុរសរបស់ម្ចាស់ជំនួយ - មានទំហំធំជាងនៅបណ្តាប្រទេស ដែលមានកម្រិតនៃប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់ៗប្រហាក់ប្រហែល កម្ពុជា (រូបលេខ ១៣)។ តួលេខនេះខ្ពស់ជាងបន្តិច - ប្រហែល ០,៣ ភាគរយ នៃផសស - ប្រសិនបើរាប់បញ្ចូលនូវចំណាយឯកជនលើទំនិញសាធារណៈ (សូមអានផ្នែកបន្តបន្ទាប់)។

**ការចាត់ថ្នាក់ត្រឹមត្រូវចំពោះគម្រោងវិនិយោគដែលគាំទ្រដោយម្ចាស់ជំនួយចូលទៅក្នុងចំណាយចរន្ត និងចំណាយមូលធន មានសារៈសំខាន់ជាសារវន្ត។** បច្ចុប្បន្ន គម្រោងវិនិយោគដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ ត្រូវបានចាត់ពេញលេញជាចំណាយមូលធន ទោះបីជា

*២០ ទិន្នន័យទាំងនេះអំពីចំណាយមូលធនរបស់រដ្ឋាភិបាលត្រូវបានកែតម្រូវ។ ការកែតម្រូវនេះដកចេញពី "គម្រោងដែលផ្តល់ហិរញ្ញប្បទានពីបរទេស" នូវចំណែកដែលប៉ាន់ស្មានថាត្រូវចាត់ជាចំណាយចរន្ត។ សូមពិនិត្យមើលប្រអប់លេខ ២ ចំពោះព័ត៌មានលម្អិត។*

គម្រោងទាំងនោះមានផ្នែកចំណាយចរន្តដែលមានទំហំធំក្តី។ ការកែសម្រួលចំណុចនេះនឹងធ្វើឱ្យប្រាកដថា រដ្ឋាភិបាលមានទិដ្ឋភាពច្បាស់លាស់ អំពីទំហំនៃចំណាយមូលធន និងបរិមាណទឹកប្រាក់ចាំបាច់សម្រាប់ការថែទាំ។

**ប្រអប់លេខ ២. ការកត់ត្រាចំណាយនៃគម្រោង និងកម្មវិធីដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយ**

តារាងចំណាយទូទៅរបស់រដ្ឋាភិបាលបង្ហាញតួលេខចំណាយចំពោះគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ ប៉ុន្តែកត់ត្រារាល់ចំណាយជា "ចំណាយមូលធនដែលហិរញ្ញប្បទានពីបរទេស"។ ការវិភាគមួយនៃគម្រោងដែលផ្តល់ហិរញ្ញប្បទាន ដោយម្ចាស់ជំនួយង្ហាញថា ចំណាយមូលធនសុទ្ធសាធមានពីប្រមាណជា ៩៥ ភាគរយ ជាចំណាយលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ រហូតដល់ប្រមាណជាមួយភាគបីជាចំណាយលើគម្រោងអប់រំ និងសុខភាព។ លើមូលដ្ឋាននេះគេប៉ាន់ស្មានថា មានតែ ៧០ ទៅ ៨០ ភាគរយប៉ុណ្ណោះ នៃគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ គប្បីចាត់ទុកជាចំណាយមូលធន។ ជាលទ្ធផល ចំណាយមូលធនរបស់រដ្ឋាភិបាលត្រូវបានកែតម្រូវដោយកាត់បន្ថយពីមធ្យមភាគ ៦,៣ ភាគរយ នៃ ផសស ក្នុងការបង្ហាញរបស់រដ្ឋាភិបាលមកត្រឹម ៥,៣ ភាគរយប៉ុណ្ណោះ (តារាងលេខ ៤)។

## ចំណាយតាមចំណាត់ថ្នាក់មុខងារ

**ការឆ្លុះបញ្ចាំងអាទិភាពនានារបស់រដ្ឋាភិបាល ការចំណាយបានកើនឡើងមិនស្មើគ្នាចំពោះប្រភេទមុខងារផ្សេងៗនៅក្នុងទសវត្សរ៍ ឆ្នាំ ២០០០។** លក្ខណៈជាក់ច្បាស់នៃចំណាយរដ្ឋាភិបាលតាមចំណាត់ថ្នាក់មុខងារ គឺ ៖

**តារាងលេខ ៧. ចំណាយតាមប្រភេទមុខងារបានកើនឡើង**
(គិតជា ភាគរយនៃ ផសស)

| មុខងារសង្ខេប | ២០០១ | ២០០២ | ២០០៥ | ២០០៧ | ២០០៨ | ២០០៩e |
|---|---|---|---|---|---|---|
| រដ្ឋាភិបាលស្នូល | ៥,៤ | ៥,៤ | ៣,២ | ៤,១ | ៤,០ | ៧,៤ |
| សេវាសេដ្ឋកិច្ច | ២,៤ | ៣,៣ | ២,៩ | ៣,១ | ៣,៨ | ៤,៧ |
| ក្នុងនោះកសិកម្ម | ០,៥ | ០,៥ | ០,២ | ០,៤ | ០,៤ | ០,៦ |
| ដឹកជញ្ជូន | ១,៦ | ១,៨ | ១,៤ | ១,៥ | ១,៨ | ២,៤ |
| អភិវឌ្ឍន៍ជនបទ | ១,១ | ០,៧ | ០,៥ | ០,៧ | ០,៦ | ០,៦ |
| សេវាសង្គម | ៥,៧ | ៥,៧ | ៤,៥ | ៤,៨ | ៤,១ | ៤,៧ |
| ក្នុងនោះ សុខាភិបាល | ១,៥ | ១,៥ | ២,២ | ២,១ | ២,០ | ២,៥ |
| អប់រំ | ១,៦ | ២,៤ | ១,៧ | ១,៩ | ១,៦ | ២,១ |
| ក្រៅពីនេះ | ៣,០ | ៣,២ | ២,៣ | ២,៣ | ៣,៩ | ២,១ |
| សរុប | ១៧,៧ | ១៨,៣ | ១៣,៤ | ១៤,៩ | ១៦,៣ | ១៩,៦ |

*ប្រភព ៖* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- វិភាជន៍ទៅកាន់ "រដ្ឋាភិបាលកណ្តាល" (រដ្ឋាភិបាលទូទៅ និងតុលាការ មុខងារការពារនិងសន្តិសុខជាតិ) បានកើនឡើងខ្ពស់ជាងចំណាយតាមប្រភេទមុខងារធៀបនឹងចំណាយតាមប្រភេទមុខងារដទៃ រវាងឆ្នាំ ២០០១ និង ២០០៩ (តារាង លេខ ៧ និងតារាងលេខ ៨)[២១]។ នៅឆ្នាំ ២០០៩ កំណើនមានកម្រិតខ្ពស់ខ្លាំង សឱ្យឃើញការដំឡើងប្រាក់ខែចំពោះកងកម្លាំងការពារ និងសន្តិសុខជាតិ។ ជាលទ្ធផល ចំណាយចំពោះមុខងារស្នូលរបស់រដ្ឋាភិបាលស្មើនឹង ៣៨ ភាគរយ នៃចំណាយទូទៅរបស់រដ្ឋាភិបាលនៅឆ្នាំ ២០០៩ កើនឡើងពី ២៥ ភាគរយ ពីបណ្តាឆ្នាំមុនៗ។

*២១ សម្រាប់កម្ពុជា មុខងារស្នូលរបស់រដ្ឋាភិបាល រួមមាន ព្រះរាជវាំង រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាធម្មនុញ្ញ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរជាតិសវនកម្ម ក្រសួងយុត្តិធម៌ ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ។*

- ផ្ទុយនឹងវិស័យមុខងារដទៃទៀតភាគច្រើន រដ្ឋាភិបាលស្នូលបានទទួលហិរញ្ញប្បទានពេញលេញពីធនធានក្នុងស្រុក ។ ការគាំទ្ររបស់ម្ចាស់ជំនួយបានផ្តល់ហិរញ្ញប្បទាន ៦ ភាគរយ ឬតិចជាងនេះ នៃវិភាជន៏សរុបនៅក្នុងផ្នែកនេះជារៀងរាល់ឆ្នាំក្នុងទសវត្សរ៍កន្លងទៅ ។

- ចំណាយលើការដឹកជញ្ជូនបានកើនឡើង ០,៨ ភាគរយ នៃ ផសស ចាប់ពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០០៩ ដោយសារការគាំទ្រពីបរទេសគិតជាប្រាក់ដុល្លារកើនឡើងបីដង ។ ជាលទ្ធផល ដង់ស៊ីតេនៃបណ្តាញដឹកជញ្ជូនបានកើនឡើងក្នុងអំឡុងឆ្នាំ ២០០០ ហើយគុណភាពនៃការដឹកជញ្ជូនបានរីកចម្រើនជាខ្លាំង ។

- ចំណាយទូទៅរបស់រដ្ឋាភិបាលលើវិស័យសុខភិបាលបានកើនឡើង ១ ភាគរយ នៃ ផសស នៅដើមទសវត្សរ៍រហូតដល់ ២,៥ ភាគរយ នៅឆ្នាំ ២០០៩ ។ ចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាលប្រហែលពាក់កណ្តាល ត្រូវបានផ្តល់មូលនិធិដោយម្ចាស់ជំនួយ ។ ទោះជាយ៉ាងណាក្តី ចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាលមានចំនួនត្រឹមតែមួយភាគបីនៃចំណាយសុខភាពសរុបក្នុងប្រទេសប៉ុណ្ណោះ ទុកឱ្យគ្រួសារនានារ៉ាប់រងដោយខ្លួនឯងលើចំណាយពីរភាគបីទៀត ( ជំពូក ៤) ។

- ចំណាយអប់រំសាធារណៈបានកើនឡើង ០,៥ ភាគរយ នៃ ផសស ចាប់តាំងពីដើមទសវត្សរ៍នេះ គឺកើនឡើងជាប្រាក់ដុល្លារចំនួនបីដង ដោយសារវិភាជន៏ក្នុងស្រុកមានទំហំច្រើនជាងមុន ដែលបច្ចុប្បន្នគ្របដណ្តប់ច្រើនជាង ៨០ ភាគរយ នៃតួលេខសរុប ។ វិស័យអប់រំមានលំដាប់ទីពីរ បន្ទាប់ពីរដ្ឋាភិបាលស្នូលបើនិយាយអំពីចំណាយដែលផ្តល់ហិរញ្ញប្បទានពីចំណូលផ្ទាល់របស់រដ្ឋាភិបាល ។ ទោះជាយ៉ាងណាក្តី ចំណាយលើវិស័យអប់រំធៀបនឹង ផសស មានកម្រិតទាបជាងនៅបណ្តាប្រទេសដទៃទៀត រាប់ទាំងប្រទេសដែលមានកម្រិតនៃចំណូលក្នុងពលរដ្ឋម្នាក់ៗប្រហាក់ប្រហែលនឹងកម្ពុជាផងដែរ ( រូបលេខ ១៤) ។

**តារាងលេខ ៨. ជំនួយបរទេសផ្តល់ហិរញ្ញប្បទានច្រើនជាងពាក់កណ្តាលនៃចំណាយរបស់រដ្ឋាភិបាលក្នុងវិស័យដឹកជញ្ជូន កសិកម្ម និងសុខាភិបាល**
( គិតជា ភាគរយ និងភាគរយនៃ ផសស)

| | ការប្រែប្រួល ២០០១-២០០៩ គិតជាភាគរយនៃ | | ហិរញ្ញប្បទានមធ្យមភាគ ២០០៨-០៩ ជាភាគរយនៃហិរ. សរុប | |
|---|---|---|---|---|
| | ផសស | ចំណាយរដ្ឋាភិបាល | ពីបរទេស | ក្នុងស្រុក |
| ចំណាយស្នូលរបស់រដ្ឋាភិបាល | ២,០ | ៧,២ | ៦,១ | ៩៣,៩ |
| ដឹកជញ្ជូន | ០,៨ | ៣,៣ | ៦៩,៥ | ៣០,៥ |
| សុខាភិបាល | ១,០ | ៤,៤ | ៥១,៦ | ៤៨,៤ |
| អប់រំ | ០,៥ | ១,៧ | ២០,១ | ៧៩,៩ |
| កសិកម្ម | ០,១ | ០,២ | ៦៧,២ | ៣២,៨ |
| អភិវឌ្ឍន៍ជនបទ | -០,៦ | -៣,២ | ៤៣,១ | ៥៦,៩ |
| បរិស្ថាន | | | ២៦,៧ | ៧៣,៣ |

*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-កអក-និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**រូបលេខ ១៤. ចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំមានកម្រិតទាបធៀបនឹងបណ្តាប្រទេសដទៃ**
( គិតជា ភាគរយនៃ ផសស)




*ប្រភព :* ២០១០ WDI, សូចនាករ ADB និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

- វិភាជន៍សម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ បានកើនឡើងតិចតួចរវាងឆ្នាំ ២០០៧ និង ២០០៩។ មួយផ្នែកធំនៃវិភាជន៍ដែលមាននិន្នាការធ្លាក់ចុះទាំងនេះ ជាវិភាជន៍ដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយបរទេស ពិសេសសម្រាប់គម្រោងមូលធនលើផ្នែកស្រោចស្រព។ រដ្ឋាភិបាលចំណាយតិចលើវិស័យកសិកម្មជាងនៅបណ្តាប្រទេសដទៃ ដែលមានកម្រិតប្រាក់ចំណូលប្រហែលគ្នា (សូមមើលជំពូក ៣)។

**គេឃើញមានវឌ្ឍនភាពចំពោះការងារវិមជ្ឈការ និងវិសហមជ្ឈការ។** ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ (D&D) បានចាប់ផ្តើមនៅឆ្នាំ ២០០២ នៅពេលដែលរដ្ឋាភិបាលកណ្តាល និងម្ចាស់ជំនួយបានចាប់ផ្តើមផ្ទេរមូលនិធិឱ្យឃុំ និងសង្កាត់[២២]។ ច្បាប់អង្គការស្តីពីវិមជ្ឈការ និងវិសហមជ្ឈការត្រូវបានអនុម័តនៅឆ្នាំ ២០០៨ ដែលត្រួសត្រាយផ្លូវសម្រាប់បង្កើតរដ្ឋបាលថ្នាក់ក្រោមជាតិបន្ថែមនៅថ្នាក់ស្រុក និងថ្នាក់ខេត្តផងដែរ។ ខណៈដែលរដ្ឋាភិបាលកណ្តាលមិនទាន់បានផ្ទេរមូលនិធិទៅឱ្យថ្នាក់ក្រោមជាតិដទៃទាំងនេះ ផ្ទុយទៅវិញ ម្ចាស់ជំនួយ គឺជាអ្នកផ្តល់ការគាំទ្រដោយផ្ទាល់ដល់ពួកគេទៅវិញ។

**វិភាជន៍សរុបទៅកាន់ឃុំ សង្កាត់ និងថ្នាក់ស្រុក និងថ្នាក់ខេត្ត មានចំនួនត្រឹមតែ ៣ ភាគរយប៉ុណ្ណោះ នៃចំណាយទូទៅរបស់រដ្ឋាភិបាល។** ការបង្វែរទៅកាន់ឃុំ និងសង្កាត់ ពីធនធានផ្ទាល់របស់រដ្ឋាភិបាលកណ្តាលតាមរយៈមូលនិធិឃុំ និងសង្កាត់ (CSF) របស់ខ្លួនមានចំនួនប្រហែល ២ ភាគរយ នៃប្រាក់ចំណូលក្នុងស្រុក និងដោយសារសមត្ថភាពស្រូបយកមានកម្រិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះ រដ្ឋាភិបាលបានស្នើដាក់កម្រិតអតិបរមានៃវិភាជន៍នេះត្រឹម ៤ ភាគរយ (តារាងលេខ ៩)។

**តារាងលេខ ៩. ប្រាក់បង្វែរពីរដ្ឋាភិបាលកណ្តាលទៅថ្នាក់ក្រោមជាតិមានកម្រិតទាប**
(គិតជា ភាគរយនៃចំណាយទូទៅរបស់រដ្ឋាភិបាល)

| | ការបង្វែរមូលនិធិ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|
| ឃុំ | មូលនិធិឃុំ/សង្កាត់តាមរយៈរតនាគារ | ១,៧ | ១,៤ | ១,៣ |
| | ម្ចាស់ជំនួយ | ០,៥ | ០,៨ | ០,៧ |
| ស្រុក | រដ្ឋាភិបាល | - | - | - |
| | ម្ចាស់ជំនួយ | ០,៣ | ០,៣ | ០,៣ |
| ខេត្ត | រដ្ឋាភិបាល | - | - | - |
| | ម្ចាស់ជំនួយ | ០,៧ | ០,៩ | ០,៦ |
| សរុប | | ៣,២ | ៣,៤ | ៣,០ |

*ប្រភព :* NCDD និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**រូបលេខ ១៥. សាលារៀន និងផ្លូវជនបទចំណាយស្មើនឹងពាក់កណ្តាលនៃចំណាយឯកជនលើទំនិញសាធារណៈ**
(គិតជា លានដុល្លារអាមេរិក មធ្យមភាគប្រចាំឆ្នាំ ២០០៥-២០០៩)




*ប្រភព :* អង្កេតចំណាយឯកជនលើទំនិញសាធារណៈសម្រាប់របាយការណ៍នេះប្រព្រឹត្តិទៅនៅខែ កក្កដា និងសីហា ឆ្នាំ ២០១០

*២២ ក្រុង និងទីរួមខេត្តនានា ត្រូវបានចែកជាសង្កាត់*

# ឃ. ចំណាយឯកជនលើទំនិញសាធារណៈ

**ចំណាយឯកជនលើទំនិញសាធារណៈមានមុខងារចម្បងនៅថ្នាក់ឃុំនៅកម្ពុជា។** អង្កេតមួយកាលពីពេលថ្មីៗអំពីចំណាយនៅថ្នាក់ឃុំ ដែលធ្វើឡើងសម្រាប់របាយការណ៍នេះបង្ហាញថា គណបក្សនយោបាយ ក្រុមហ៊ុនក្នុងស្រុក និងបុគ្គលឯកជន ផ្តល់ជំនួយឥតសំណង ប្រហែល ៣០ លានដុល្លារ (០,៣ ភាគរយ នៃ ផសស) សម្រាប់កម្មវិធីនានានៅថ្នាក់ឃុំ ភាគច្រើន គឺផ្លូវថ្នល់ សាលារៀន និងប្រព័ន្ធស្រោចស្រព (រូបលេខ ១៥) ។ ជំនួយឥតសំណងទាំងនេះត្រូវបានបំពេញបន្ថែមដោយការគាំទ្រពីម្ចាស់ជំនួយដដែលទៅឱ្យឃុំ ដែលមានចំនួនស្មើនឹង ២៥ លានដុល្លារក្នុងមួយឆ្នាំ សម្រាប់ស្តារឡើងវិញ ឬសម្រាប់កសាងវត្តអារាម ។ ទោះបីជាចំនួនទឹកប្រាក់ចំណាយឯកជនលើទំនិញសាធារណៈ ជារួម មានទំហំតិចតួចក្តី ឃុំភាគច្រើនចាត់ទុកថាមូលនិធិនេះមានសារៈសំខាន់ណាស់ ព្រោះថាយ៉ាងហោចណាស់ចំណាយនេះ ជាញយដង មានចំនួនស្មើនឹងពាក់កណ្តាលនៃបរិមាណបង្វែរសរុបពីរដ្ឋាភិបាលកណ្តាល តាមរយៈមូលនិធិឃុំ/សង្កាត់ ។ ទោះជាយ៉ាងណាក្តី មន្ត្រីឃុំភាគច្រើនដែលបានផ្តល់កិច្ចសម្ភាសន៍ដល់អង្កេតនោះបានឱ្យដឹងថា ការអនុវត្តចំណាយឯកជន ពុំមានប្រសិទ្ធភាពដូចចំណាយដែលផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលឡើយ ។

**គណបក្សនយោបាយផ្តល់ជិតពីភាគបីនៃចំណាយឯកជនលើទំនិញសាធារណៈនៅថ្នាក់ឃុំ** (រូបលេខ ១៦) ។ ការគាំទ្រនេះនៅតែហាក់ដូចជាឆ្លុះបញ្ចាំងសកម្មភាពរបស់បុគ្គល និងសមាជិកក្រុមការងារគណបក្ស ដែលបានចាត់ឱ្យទៅកាន់មណ្ឌលនីមួយៗ ។

**ចំណាយឯកជនលើទំនិញសាធារណៈប្រែប្រួលជាខ្លាំងរវាងឃុំនានា ហើយមិនប្រាកដថាឆ្លើយតបនឹងអាទិភាពនានានៃផែនការអភិវឌ្ឍន៍ឃុំ ឬកម្មវិធីវិនិយោគឃុំឡើយ** (តារាងលេខ ១០) ។ ការរកវិធីមួយ ដើម្បីឱ្យឃុំសម្របសម្រួលឱ្យបានកាន់តែប្រសើរជាមួយម្ចាស់ជំនួយឯកជន ឆ្លុះឱ្យឃើញនូវការលំបាកដែលរដ្ឋាភិបាលកណ្តាលប្រឈមជាមួយម្ចាស់ជំនួយអន្តរជាតិ - គេត្រូវធ្វើការបន្ថែមទៀត ដើម្បីធ្វើឱ្យប្រាកដថាផែនការយុទ្ធសាស្ត្រ ថវិកា និងការគាំទ្ររបស់ម្ចាស់ជំនួយ ត្រូវបានតម្រឹមតម្រង់នៅគ្រប់កម្រិត ។

**រូបលេខ ១៦. គណបក្សនយោបាយផ្តល់អំណោយយ៉ាងច្រើន**
(គិតជា លានដុល្លារអាមេរិកមធ្យមភាគ
ឆ្នាំ ២០០៥-២០០៩)




*ប្រភព :* អង្កេតចំណាយឯកជនលើទំនិញសាធារណៈសម្រាប់របាយការណ៍នេះប្រព្រឹត្តិទៅនៅខែកក្កដា និងសីហា ឆ្នាំ ២០១០

**តារាងលេខ ១០. អាទិភាពនានាសម្រាប់អភិវឌ្ឍន៍របស់ឃុំនៅមិនទាន់បានតម្រឹមជាមួយការគាំទ្ររបស់ម្ចាស់ជំនួយក្នុងស្រុកនៅឡើយ**
(ចាត់ថ្នាក់ផ្អែកលើអង្កេត)

| អភិវឌ្ឍន៍តាមផ្នែក | ការចាត់ថ្នាក់អាទិភាព (ពិន្ទុមធ្យម ១-៤) |
|---|---|
| ជួសជុលផ្លូវថ្នល់ | ៣,៨ |
| ប្រព័ន្ធស្រោចស្រព | ៣,៥ |
| សេវាផ្សព្វផ្សាយកសិកម្ម | ៣,៤ |
| អនាម័យ និងទឹកស្អាត | ៣,២ |
| អភិវឌ្ឍន៍មណ្ឌលសុខភាព | ៣,១ |
| អភិវឌ្ឍន៍សាលារៀន | ៣,១ |
| ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី | ២,៩ |
| អភិវឌ្ឍន៍វត្តអារាម | ២,២ |

*ប្រភព :* អង្កេតចំណាយឯកជនលើទំនិញសាធារណៈសម្រាប់របាយការណ៍នេះប្រព្រឹត្តិទៅនៅខែកក្កដា និងសីហា ឆ្នាំ ២០១០

## គុណភាពនៃលទ្ធផលចំណាយរបស់រដ្ឋាភិបាល

**គុណភាពនៃលទ្ធផលដែលអនុវត្តដោយចំណាយសាធារណៈនៅកម្ពុជាមានលក្ខណៈស្របគ្នាជាមួយគុណភាពនៃលទ្ធផល ដែលអនុវត្តនៅប្រទេសដទៃនានា ដែលមានកម្រិតនៃចំណូលក្នុងពលរដ្ឋម្នាក់ៗប្រហែលគ្នា។** យើងឈានដល់ការប៉ាន់ស្មាននេះ ដោយធ្វើការប្រៀបធៀបសូចនាករមួយចំនួន រួមមាន អាយុមធ្យម មរណភាពកុមារ អត្រាបញ្ចប់បឋមសិក្សា និងអត្រាសិស្សស្រី ធៀបសិស្សប្រុសនៅបឋមសិក្សា និងមធ្យមសិក្សានៅកម្ពុជាជាមួយបណ្តាប្រទេសដទៃដែលមានកម្រិតនៃចំណូលក្នុងម្នាក់ៗ ប្រហែលគ្នា (តារាងលេខ ១១) ។ ទោះជាយ៉ាងណាក្តី កម្ពុជាប្រាថ្នាចង់បានឋានៈជាប្រទេសដែលមានប្រាក់ចំណូលមធ្យម ដែលមានន័យថា កម្ពុជាចាំបាច់ត្រូវការពិនិត្យឡើងវិញនូវគោលនយោបាយផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភរបស់ខ្លួន ដើម្បីធ្វើឱ្យប្រាកដថា ប្រាក់លើកទឹកចិត្តចំពោះលទ្ធផលការងារមានភាពសមស្រប ។

តារាងលេខ ១១. គុណភាពនៃលទ្ធផលសាធារណៈមានលក្ខណៈដូចក្នុងបណ្តាប្រទេសដទៃទៀត ដែលមានប្រាក់ចំណូលក្នុងម្នាក់ៗដូចគ្នា

| | អាយុមធ្យមចាប់ពីកំណើត តួលេខសរុប (ឆ្នាំ) | | | អត្រាស្លាប់អាយុក្រោម ៥ ឆ្នាំ (ក្នុង ១.០០០ នាក់) | | | អត្រាបញ្ចប់បឋមសិក្សាសរុប (%នៃក្រុមអាយុពាក់ព័ន្ធ) | | | អត្រាសិស្សស្រីធៀបនឹងសិស្សប្រុសនៅបឋមសិក្សា និងមធ្យមសិក្សា (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០០០ | ២០០៨ | ប្រែប្រួល | ២០០០ | ២០០៨ | ប្រែប្រួល | ២០០០ | ២០០៨ | ប្រែប្រួល | ២០០០ | ២០០៨ | ប្រែប្រួល |
| **កម្ពុជា** | **៥៦,៩** | **៦១,០** | **៤,១** | **១០៦,៤** | **៨៩,៥** | **១៦,៩** | **៤៧,២** | **៨៥,០** | **៣៧,៨** | **៨១,៧** | **៨៩,,៧** | **៧,៩** |
| នេប៉ាល់ | ៦១,៧ | ៦៦,៧ | ៥,០ | ៨៥,៤ | ៥១,៤ | ៣៤,០ | ៦៥,៨ | -- | -- | ៧៧,១ | -- | -- |
| អ៊ូហ្គង់ដា | ៤៦,២ | ៥២,៧ | ៦,៤ | ១៥៧,៨ | ១៣៤,៩ | ២២,៩ | -- | ៥៦,១ | -- | ៩២,៨ | ៩៨,៩ | ៦,២ |
| បង់ក្លាដែស | ៦១,៣ | ៦៦,១ | ៤,៨ | ៩១,៣ | ៥៤,៤ | ៣៦,៩ | ៥៩,៥ | ៥៧,៥ | -១,៩ | -- | ១០៦,១ | -- |
| តូហ្គោ | ៥៩,៧ | ៦២,៥ | ២,៨ | ១២១,៧ | ៩៧,៥ | ២៤,២ | ៦៣,២ | ៦១,៣ | -១,៩ | | | -- |
| ឡាវ | ៦១,០ | ៦៥,០ | ៤,០ | ៨៦,៣ | ៦១,៣ | ២៥,១ | ៦៩,៣ | ៧៤,៧ | ៥,៤ | ៨១,៣ | ៨៧,២ | ៥,៩ |
| កេនយ៉ា | ៥២,៨ | ៥៤,២ | ១,៤ | ១២៧,៧ | ១២៦,៦ | ១,១ | -- | ៧៩,៥ | -- | ៩៧,៦ | ៩៥,៩ | -១,៧ |
| វៀតណាម | ៧១,៩ | ៧៤,៤ | ២,៤ | ៣០,០ | ១៣,៦ | ១៦,៤ | ៩៦,៤ | -- | -- | ៩៣,១ | -- | -- |
| ឥណ្ឌា | ៦១,៣ | ៦៣,៧ | ២,៤ | ៩៣,៥ | ៦៨,៨ | ២៤,៨ | ៧២,៤ | ៩៣,៦ | ២១,២ | ៧៨,៩ | ៩២,២ | ១៣,៣ |
| អេត្យូពី | ៥១,៤ | ៥៥,២ | ៣,៨ | ១៤៨,០ | ១០៨,៥ | ៣៩,៥ | ២៣,០ | ៥២,១ | ២៩,១ | ៦៥,១ | ៨៥,២ | ២០,១ |

*ប្រភព :* សូចនាកររបស់ World Development

# ខ. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ

**ជំពូកនេះបានវិភាគកម្រិត និងសមាសភាគនៃចំណាយរបស់រដ្ឋាភិបាល និងការការតម្រឹមជាមួយការគាំទ្ររបស់ម្ចាស់ជំនួយ និងទិសដៅយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។** ក្នុងរយៈពេលខ្លី រដ្ឋាភិបាលត្រូវបានលើកទឹកចិត្តក្នុងការពិចារណាអនុសាសន៍ខាងក្រោម ៖

- **ដាក់បញ្ចូលចំណាយទាំងអស់របស់រដ្ឋាភិបាលទៅក្នុងថវិការាប់ទាំងគម្រោងវិនិយោគ ដែលផ្តល់ហិរញ្ញប្បទានពីបរទេសសហប្រតិបត្តិការបច្ចេកទេស និងប្រាក់ឧបត្ថម្ភបន្ថែមលើប្រាក់ខែរបស់មន្ត្រីរាជការ។**

- **លើកកម្ពស់គុណភាព និងពង្រីកវិសាលភាពនៃស្ថិតិហិរញ្ញវត្ថុរបស់រដ្ឋាភិបាល រួមមាន ការកត់ត្រាចំណាយទាំងអស់របស់រដ្ឋាភិបាលទាំងហិរញ្ញប្បទានពីក្នុងស្រុក និងពីបរទេសនៅក្នុងកម្រងទិន្នន័យ និងឯកសារថវិការបស់រដ្ឋាភិបាល។** បច្ចុប្បន្ន ឯកសារថវិកាមានត្រឹមតែតួលេខប៉ាន់ស្មាននៃចំណាយដែលផ្តល់ហិរញ្ញប្បទានពីបរទេស ដែលបានមកពីទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈប៉ុណ្ណោះ ។

- **ចាត់ថ្នាក់ឱ្យបានសមស្របនូវចំណាយចរន្ត និងចំណាយមូលធន ព្រមទាំងការផ្តល់ហិរញ្ញប្បទាន ដោយចាប់ផ្តើមពីការចាត់ថ្នាក់គម្រោងវិនិយោគដែលផ្តល់ហិរញ្ញប្បទានពីបរទេស ដែលក្នុងពេលបច្ចុប្បន្នមានចំណាយចរន្តច្រើន។** ដើម្បីឱ្យថវិកាទូទៅរបស់រដ្ឋាភិបាលមានលក្ខណៈសមាហរណកម្ម និងពេញលេញ ចំណាយដែលផ្តល់ដោយហិរញ្ញប្បទានពីបរទេស ចាំបាច់ត្រូវចាត់ថ្នាក់ពេញលេញ និងត្រឹមត្រូវ ដោយប្រើប្លង់គណនីរបស់រដ្ឋាភិបាល (សូមមើលជំពូក ៦ បន្ថែម) ។

សមត្ថកិច្ចនានាក៏សូមចាប់ផ្តើមធ្វើការងារលើវិធានការផ្សេងៗ ដែលនឹងនាំមកនូវលទ្ធផលរយៈកាលមធ្យម ៖

- **ធ្វើយ៉ាងណាឱ្យចំណាយប្រតិបត្តិការ និងចំណាយថែទាំ ត្រូវបានដាក់បញ្ចូលគ្រប់គ្រាន់ទៅក្នុងថវិកាអនាគតចំពោះរាល់គម្រោងមូលធនដែលកំពុងអនុវត្តដោយគ្មានបច្ច័យអវិជ្ជមានមកលើនិរន្តរភាពសារពើពន្ធ។** ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ផែនការយុទ្ធសាស្ត្រ (BSP) គឺជាចំណុចសមស្របដែលត្រូវចាប់ផ្តើមការងារនេះ ។ ផយអជ និងច្បាប់ថវិកាប្រចាំឆ្នាំ ក៏គប្បីឆ្លុះបញ្ចាំងកិច្ចតម្រូវនេះផងដែរ ។

- **ធ្វើវិចារណកម្មសកម្មភាពសហប្រតិបត្តិការបច្ចេកទេស ដោយងាកឆ្ពោះទៅកាន់អភិក្រមទូទាំងវិស័យ និងការរៀបចំកម្មវិធីរួមគ្នារវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ។** ជំហានដំបូង គប្បីមានការបូកបញ្ចូលគ្នានូវចំនួនអង្គភាពគ្រប់គ្រងគម្រោងឯករាជ្យ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផល ។

# ចំណាយរបស់រដ្ឋាភិបាលលើវិស័យកសិកម្ម ៣

## ក. សេចក្តីផ្តើម

**កសិកម្ម គឺជាអាទិភាពខ្ពស់មួយសម្រាប់រដ្ឋាភិបាលកម្ពុជា ព្រោះកសិកម្មគឺជាប្រភពចម្បងមួយនៃកំណើនសេដ្ឋកិច្ច និងការទទួលបានចំណូលពីការនាំចេញ។** ចាប់ផ្តើមពីកម្រិតមួយទាប ចំណាយរបស់រដ្ឋាភិបាលលើវិស័យកសិកម្មបានកើនឡើង ១,៣ ភាគរយ នៃ ផសស នៅឆ្នាំ ២០០៧ និង ១,៥ ភាគរយ នៅឆ្នាំ ២០០៩ សំខាន់ គឺតាមរយៈការកើនឡើងនូវចំណាយយ៉ាងច្រើនលើការស្រោចស្រព និងផ្លូវជនបទ។ ក្នុងអំឡុងពេលនៃការបង្កើនចំណាយសាធារណៈលើវិស័យកសិកម្មបានកើតឡើង ទន្ទឹមគ្នានឹងកំណើនលទ្ធផលកសិកម្មប្រចាំឆ្នាំខ្ពស់។ ទោះបីជាពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីប៉ាន់ស្មានប្រកបដោយទំនុកចិត្តថា តើមានទំនាក់ទំនងហេតុផលដែល ឬទេ រវាងកម្រិតនៃចំណាយសាធារណៈ និងកំណើនកសិកម្មនៅកម្ពុជា។ ភស្តុតាងដែលបានបង្ហាញនៅក្នុងជំពូកនេះ បង្ហាញថាចំណាយសាធារណៈពិតជាអាចធ្វើឱ្យមានឥទ្ធិពលក្នុងការបង្កើន និងធានានិរន្តរភាពនៃកំណើនកសិកម្មជាមួយនឹងបរិយាកាសគោលនយោបាយល្អប្រសើរ។ ការវិភាគ បញ្ជាក់ថាចំណាយថវិការដ្ឋាភិបាល ជាទូទៅ ច្រើនចំណាយលើទំនិញ និងសេវាសាធារណៈ ដែលនាំមកនូវផលចំណេញខ្ពស់ពីការវិនិយោគ។ ទោះជាយ៉ាងណាក្តី ការវិភាគនេះក៏បង្ហាញផងដែរថា មានសក្តានុពលល្អសម្រាប់ទទួលបានប្រសិទ្ធភាពបន្ថែមចំពោះធនធានដែលបានចំណាយ។

**ជំពូកនេះផ្តោតលើផ្នែកដែលមានសក្តានុពលប្រសិទ្ធភាពខ្ពស់បំផុតក្នុងការបង្កើនតម្លៃប្រាក់ពីវិនិយោគលើទំនិញសាធារណៈ និងសេវាសំខាន់ៗ ដូចជា ការផ្សព្វផ្សាយកសិកម្ម ការស្រោចស្រព និងផ្លូវជនបទ។** នេះ គឺជាកិច្ចប្រឹងប្រែងលើកដំបូងក្នុងការការវិភាគបែបនេះនៅកម្ពុជា ហើយក៏ជាលើកដំបូងនៅក្នុងមហាអនុតំបន់មេគង្គផងដែរ។ ផ្អែកលើការប្រមូលទិន្នន័យ និងអង្កេតជាច្រើន ជំពូកនេះវិភាគប្រសិទ្ធភាព និងប្រសិទ្ធផលចំណាយក្នុងវិស័យកសិកម្មនៅកម្ពុជា និងវាយតម្លៃជម្រើសនានា សម្រាប់បង្កើនឥទ្ធិពលនៃចំណាយរដ្ឋាភិបាលមកលើកំណើនកសិកម្ម។ បញ្ហាប្រឈមដទៃទៀត រួមមាន ការផ្តោតការយកចិត្តទុកដាក់ច្រើនហួសលើការស្តារនីតិសម្បទាហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពមេ និងមិនបានយកចិត្តទុកដាក់ចំពោះប្រព័ន្ធប្រឡាយរង និងប្រព័ន្ធប្រឡាយជើងក្អែប កង្វះការថែទាំប្រព័ន្ធស្រោចស្រព និងផ្លូវជនបទ ព្រមទាំងភាពវិវត្តយឺតនៃការអនុវត្តបច្ចេកវិទ្យា ដើម្បីកាត់បន្ថយចំណាយថែទាំក្នុងពេលអនាគត។ ជាមួយគ្នានេះផងដែរ ចាំបាច់ត្រូវផ្តល់អាទិភាពដល់ចំណាយហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងចំណាយពាក់ព័ន្ធ ទាំងចំណាយតាមប្រភេទ និងចំណាយតាមទីតាំងភូមិសាស្ត្រ ដើម្បីបង្កើនបច្ច័យជាអតិបរមាចំពោះកំណើន។

**ផ្នែកផ្សេងទៀតនៃជំពូកនេះ ត្រូវបានរៀបចំដូចតទៅ។** ផ្នែក ខ ពិភាក្សាកិច្ចអភិវឌ្ឍកាលពីពេលថ្មីៗក្នុងវិស័យកសិកម្មនៅកម្ពុជា។ ផ្នែក គ បង្ហាញទិដ្ឋភាពទូទៅនៃចំណាយរបស់រដ្ឋាភិបាលក្នុងអំឡុងទសវត្សរ៍ឆ្នាំ ២០០០។ ដំណើរការថវិកា និងទំនាក់ទំនងថវិកាជាមួយយុទ្ធសាស្ត្រអភិវឌ្ឍតាមវិស័យ ត្រូវបានពិភាក្សានៅក្នុងផ្នែក ឃ។ ផ្នែក ង បង្ហាញការវិភាគរបស់យើងអំពីប្រសិទ្ធភាព និងប្រសិទ្ធផលនៃចំណាយរបស់រដ្ឋាភិបាល ដោយប្រើការវិភាគចំណាយ និងផលចំណេញនៃវិនិយោគសាធារណៈមួយចំនួន។ ផ្នែក ច បង្ហាញនូវសេចក្តីសន្និដ្ឋាន និងអនុសាសន៍គោលនយោបាយរបស់យើង។

## ខ. និន្នាការទូទៅនៃវិស័យកសិកម្ម ការស្រោចស្រព និងផ្លូវជនបទ

**កសិកម្មនៅតែជាវិស័យសំខាន់នៃសេដ្ឋកិច្ចកម្ពុជា ហើយកាលពីពេលថ្មីៗនេះកសិកម្មបានក្លាយជាប្រភពកំណើនចម្បង។ វិស័យនេះបានរីកចម្រើន ៤,៤ ភាគរយក្នុងមួយឆ្នាំ ជាមធ្យមក្នុងទសវត្សរ៍ចន្លោះឆ្នាំ ១៩៩៨ និង ២០០៨ និង ៥,៤ ភាគរយ នៅឆ្នាំ ២០០៩** (តារាងលេខ ១២) ។ទោះបីជាមានកំណើនទាបជាងអត្រាកំណើន ផសស សរុបក្តី ល្បឿននៃការរីកចម្រើននេះមានកម្រិតខ្ពស់ជាងអត្រាកំណើនមធ្យម ៣,៨ ភាគរយ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីបូព៌ាដែរ ។

**ស្រូវ គឺជាដំណាំដែលគេនិយមដាំភាគច្រើន ហើយផលិតកម្មស្រូវស្មើនឹងមួយភាគបួននៃ ផសស កសិកម្ម និងពាក់កណ្តាលនៃតម្លៃបន្ថែមនៃដំណាំកសិផល។** ស្រូវត្រូវបានគេដាំដុះលើផ្ទៃដី ៨៤ ភាគរយ នៃផ្ទៃដីដាំចុះសរុបនៅកម្ពុជា ហើយប្រមាណជាពលរដ្ឋជនបទប្រមាណជា ៨៥ ភាគរយ ជាអ្នកធ្វើស្រែ ។ ទោះបីភាគច្រើនជាដំណាំស្រូវក្តី គេបានធ្វើពិធកម្មយ៉ាងច្រើនកាលពីទសវត្សរ៍កន្លងទៅ ។ ផលិតកម្មដំណាំស្បៀង និងដំណាំឧស្សាហកម្មដែលពុំមែនជាដំណាំប្រពៃណី ដូចជា ពោត ដំឡូងមី និងសណ្តែកសៀង បានកើនឡើងយ៉ាងឆាប់រហ័ស មួយចំណែក គឺជាការឆ្លើយតបនឹងតម្រូវការរបស់អ្នកចិញ្ចឹមសត្វ ។ ដំណាំដទៃទៀតដែលបានកើនឡើងយ៉ាងឆាប់រហ័សរួមមាន ថ្នាំជក់ សណ្តែកដី ល្ង និងកៅស៊ូ ។

**តារាងលេខ ១២. វិស័យកសិកម្មមានកំណើនខ្ពស់**
(ការប្រែប្រួលគិតជា ភាគរយ-ថ្លៃស្ថេរ)

| | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|---|---|---|---|
| កសិកម្ម | ៤,៤ | ១,៧ | -២,៥ | ១០,៥ | -០,៩ | ១៥,៧ | ៥,៥ | ៥,០ | ៥,៧ | ៥,៤ |
| ដំណាំ | ៨,៦ | ១២,១ | ៣,០ | -៤,៨ | ២១,៩ | -២,៣ | ២៧,៦ | ៨,២ | ៦,៦ | ៥,៨ |
| ចិញ្ចឹមសត្វ | -១,១ | ១,០ | -១,១ | ៥,៧ | ៣,៩ | ៥,៦ | ៨,២ | ៣,៧ | ៣,៨ | ៥,០ |
| ជលផល | ៥,០ | ៥,៩ | ០,៦ | ១,៧ | -១,៧ | ៥,៦ | ៣,៨ | ០,៨ | ៦,៥ | ៦,០ |
| រុក្ខាប្រមាញ់ និងកាប់ឈើ | -១៣,០ | -១៣,៨ | -៤,៣ | -៣,០ | ០,៨ | ៥,១ | ៧,០ | ១,១ | ០,៩ | ១,១ |
| ឧស្សាហកម្ម | ៣១,២ | ១១,២ | ១៧,១ | ១២,០ | ១៦,៦ | ១២,៧ | ១៨,៣ | ៨,៤ | ៤,០ | -៩,៥ |
| សេវាកម្ម | ៨,៩ | ១១,១ | ៧,៧ | ៥,៩ | ១៣,២ | ១៣,១ | ១០,១ | ១០,១ | ៩,០ | ២,៣ |
| ផសស | ១០,៧ | ៧,៤ | ៦,៦ | ៨,៥ | ១០,៣ | ១៣,៣ | ១០,៨ | ១០,២ | ៦,៧ | ០,១ |

*ប្រភព :* វិទ្យាស្ថានជាតិកម្ពុជា (កក្កដា ២០១១)

**វិស័យកសិកម្មមានសក្តានុពលច្រើនក្នុងការរួមចំណែកជំរុញឱ្យមានកំណើនសេដ្ឋកិច្ច និងការនាំចេញខណៈដែលកម្ពុជាមានបរិយាកាសល្អមានផ្ទៃដីធំធេង និងមានទឹកនៅលើដី។** ជាមួយនឹងការគាំទ្របច្ចេកទេស និងស្ថាប័នសមស្របពីវិស័យសាធារណៈ គេឃើញមានសក្តានុពលជាច្រើនក្នុងការផលិតកំណើនទិន្នផលដំណាំ ដែលមាននិរន្តរភាពដោយបង្កើនកត្តាផលិតកម្ម លើកកម្ពស់បច្ចេកទេសដាំដុះ និងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ។

**បញ្ហាប្រឈមចំពោះកម្ពុជាគឺការចាប់យកឱកាសក្នុងវិស័យកសិកម្ម។** ចាំបាច់ត្រូវដោះស្រាយឧបសគ្គចំពោះការអភិវឌ្ឍកសិកម្ម ប្រសិនបើចង់ឱ្យវិស័យនេះដឹកនាំកំណើនកាន់តែខ្ពស់ និងជួយកាត់បន្ថយភាពក្រីក្រ ។ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទមានកម្រិតទាបដែលមិនបង្កលក្ខណៈងាយស្រួលចំពោះការអភិវឌ្ឍកសិកម្ម ដែលមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ ។ កម្ពុជាមានបណ្តាញផ្លូវថ្នល់តិចជាងគេបង្អស់នៅក្នុងតំបន់ និងមានភាគរយផ្លូវថ្នល់ក្រាលកៅស៊ូតិចជាងគេបង្អស់ ។ ជាង ៧០ ភាគរយ នៃផ្លូវជនបទនៅកម្ពុជាមិនក្រាលកៅស៊ូ ជាផ្លូវពិបាកធ្វើដំណើរ ឬមិនអាចធ្វើដំណើរបាននៅរដូវភ្លៀង ដែលធ្វើផ្នែកមួយចំនួននៃប្រទេសត្រូវបានកាត់ផ្តាច់ និង

មិនអាចធ្វើពាណិជ្ជកម្មកសិកម្មក្នុងស្រុក និងក្រៅប្រទេសបានឡើយ។ ទោះបីជាមានការកើនឡើងនូវផលិតភាពកសិកម្ម ខណៈពេលដែលលទ្ធភាពមានទឹកប្រើប្រាស់ត្រូវបានធានាក្តី ការស្រោចស្រពនៅតែមានចំនួនតិចតួចលើតំបន់គ្របដណ្តប់ដែលមានប្រសិទ្ធភាព។ ថ្មីៗនេះ នៅកម្ពុជាមានគម្រោងប្រព័ន្ធស្រោចស្រពចំនួន ២.៤០០ គ្របដណ្តប់លើផ្ទៃដីដាំដុះ ១,០៤៦ លានហិកតា (៥៨២.០៨៥ ហិកតាស្រោចស្រពនៅរដូវវស្សា និង ២៨៥.២៨៨ ហិកតា ស្រោចស្រពនៅរដូវប្រាំង)។ យោងតាមប្រភពព័ត៌មានពីក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ត្រូវជា ៤០ ភាគរយ យ៉ាងតិចនៃដីសរុបដែលអាចដាំដំណាំបាន។ សមត្ថភាពកសិកម្មដែលនៅពុំទាន់ទាញផល អាចបណ្តាលមកពីដំណើរប្រែប្រួលនៃការធ្លាក់ភ្លៀង គួបផ្សំជាមួយហានិភ័យខ្ពស់នៃការប្រើប្រាស់សម្ភារៈកសិកម្ម ដែលកសិករខ្នាតតូចទិញ និងការធ្លាក់ចុះនូវសមត្ថភាពនៃការដាំដុះនៅរដូវប្រាំង។

## គ. កម្រិត និងសមាសភាគនៃចំណាយរបស់រដ្ឋាភិបាលលើវិស័យកសិកម្ម

**ក្រសួងបីរបស់រដ្ឋាភិបាលផ្តោតលើកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធជនបទនៅកម្ពុជា។** ក្រសួងទាំងនោះ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) និងក្រសួងអភិវឌ្ឍន៍ជនបទ (MRD)។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវចំពោះការគាំទ្រកសិកម្មដីគោក ដំណាំដីខ្ពង់រាប និងដីទំនាប ការផលិត និងការរកទីផ្សារស្រូវ និងចំពោះសេវាគាំទ្រកសិកម្មទាក់ទងនឹងការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការអប់រំកសិករ។ ក្រសួងកសិកម្ម ក៏ទទួលខុសត្រូវចំពោះមុខងារទាក់ទងនឹងធនធានទឹកសម្រាប់ស្រោចស្រពកសិកម្ម អភិវឌ្ឍជលផល និងកម្មវិធីព្រៃឈើ និងផ្ទៃរងទឹកភ្លៀងផងដែរ។ ក្រសួងនេះត្រូវបានរៀបចំជាបួនផ្នែក ៖ កសិកម្មទូទៅ ការអភិវឌ្ឍដំណាំកៅស៊ូ ព្រៃឈើ និងជលផល។ ក្រសួងធនធានទឹក និងឧតុនិយម ទទួលខុសត្រូវចំពោះការអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹកទាំងអស់។ ក្រសួងមាននាយកដ្ឋានបច្ចេកទេសចំនួនពីរ។ នាយកដ្ឋានវិស្វកម្ម ទទួលខុសត្រូវចំពោះការស្តារនីតិសម្បទា ឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ធនធានទឹក ក៏ដូចជាការដាក់ឱ្យដំណើរការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធទាំងនោះផងដែរ។ នាយកដ្ឋានកសិកម្មស្រោចស្រព ចាត់ចែងជាមួយបញ្ហាផ្នែកស្ថាប័នទាក់ទងនឹងការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក (FWUCs)។ អាណត្តិរបស់ក្រសួងអភិវឌ្ឍន៍ជនបទគ្របដណ្តប់លើហេដ្ឋារចនាសម្ព័ន្ធជនបទដទៃទៀត រាប់ទាំងផ្លូវជនបទ ការផ្គត់ផ្គង់ទឹក និងអនាម័យ ការអភិវឌ្ឍជាតិពន្ធ អភិវឌ្ឍន៍សហគមន៍ អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ។

**ចំណាយសរុបរបស់រដ្ឋាភិបាលលើវិស័យកសិកម្ម - ទាំងចំណាយចរន្ត និងចំណាយមូលធន និងចំណាយដែលផ្តល់ហិរញ្ញប្បទានពីធនធានរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយ - មានចំនួន ១,៥ ភាគរយ នៃ ផសស នៅឆ្នាំ ២០០៩ ដែលមានចំនួនខ្ពស់ជាងឆ្នាំ ២០០៧។** ចំណាយចរន្តមានទំហំមួយភាគធំនៃចំណាយសរុប ទោះបីជាចំណែកនៃចំណាយមូលធនបាន និងកំពុងកើនឡើងក្តី (តារាងលេខ ១៣)។ ការគាំទ្ររបស់ម្ចាស់ជំនួយបរទេសចំពោះវិស័យកសិកម្មបានធ្លាក់ចុះប្រហែលពី ៤២ ភាគរយ នៃចំណាយសរុបរបស់រដ្ឋាភិបាលលើវិស័យកសិកម្មក្នុងឆ្នាំ ២០០៧ មកត្រឹមប្រមាណជាមួយភាគបីនៅឆ្នាំ ២០០៩ (រូបលេខ ១៨)។

**ចំណាយសាធារណៈរបស់កម្ពុជាលើវិស័យកសិកម្មមានកម្រិតទាប នៅពេលប្រៀបធៀបជាមួយបណ្តាប្រទេសដែលមានកម្រិត ផសស ក្នុងម្នាក់ៗប្រហាក់ប្រហែលគ្នា។** ក្នុងចំណោមដប់ប្រទេសមានតែបួនប៉ុណ្ណោះ ដែលមានអត្រាចំណាយសាធារណៈរបស់រដ្ឋាភិបាលស្មើ ឬទាបជាងអត្រាធៀបនឹងតម្លៃបន្ថែមរបស់កសិកម្ម។ ចំណាយសាធារណៈលើការស្រាវជ្រាវ និងអភិវឌ្ឍន៍នៅកម្ពុជាមានកម្រិតទាបស្មើនឹង ០,១ ភាគរយ នៃ ផសស កសិកម្មដែលចំណាយនេះស្មើចាប់ពី ០,២ ដល់ ០,៦ ភាគរយ នៅប្រទេសដទៃនៅអាស៊ី។ ចំណុចនេះបង្ហាញថា គុណភាពនៃចំណាយសាធារណៈ យ៉ាងហោចណាស់ក៏មានសារៈសំខាន់ដូចកម្រិតនៃចំណាយដែរ។ ប្រាកដណាស់ដែលថា ខណៈដែលចំណាយសាធារណៈបានរួមចំណែកធ្វើឱ្យកសិកម្មនៅកម្ពុជា និងបង់ក្លាដែសមានកំណើនខ្ពស់ ប្រទេសទាំងពីរក៏មានភាពដូចគ្នាអំពីបរិយាកាសគោលនយោបាយអំណោយផល និងគ្មានការប៉ះទង្គិចដល់គោលនយោបាយ ហើយបានរួមចំណែកធ្វើឱ្យចំណាយសាធារណៈមានប្រសិទ្ធភាព និងបានលើកទឹកចិត្តដល់ការចូលរួមរបស់ផ្នែកឯកជនចំពោះលទ្ធផលអនុវត្តរបស់វិស័យ។

### តារាងលេខ ១៣. វិស័យកសិកម្មមានកំណើនខ្ពស់ រដ្ឋាភិបាលចំណាយតិច

| | ចំណាយរដ្ឋាភិបាលលើវិស័យកសិកម្ម ឆ្នាំ ២០០៤ គិតជា ភាគរយ នៃ | | ស្រាវជ្រាវ និងអភិវឌ្ឍន៍សាធារណៈ ជាភាគរយ នៃ ផសស ឆ្នាំ ២០០០ | កំណើន ផសស កសិកម្ម គិតជា ភាគរយ ឆ្នាំ ១៩៩០-២០០៥ | តម្លៃបន្ថែមកសិកម្ម គិតជា ភាគរយ នៃ ផសស ឆ្នាំ ២០០៣-២០០៥ |
|---|---|---|---|---|---|
| | ធៀបនឹង ផសស | ... ផសស | | | |
| បង់ក្លាដែស | ១ | ១,៧ | ០,៤៤ | ៣,២ | ២០,០ |
| ចិន | ៦ | ១១,៣ | ០,៤៣ | ៣,៧ | ១២,៨ |
| ឥណ្ឌា | ១ | ១១,៧ | ០,៣៤ | ២,៥ | ១៧,៦ |
| ឥណ្ឌូនេស៊ី | ១ | ៣,១ | ០,២១ | ២,៣ | ១៥ |
| ហ្វីលីពីន | ៣ | ៥,១ | ០,៤១ | ២,៤ | ១៤,៩ |
| ស្រីលង្កា | ៣ | ៥,៣ | ០,៦៤ | ១,៤ | ១៥,៩ |
| ថៃឡង់ដ៏ | ៣ | ១១,៧ | គ្មាន | ១,៨ | ១០,១ |
| កេនយ៉ា | ២ | ៤,១ | ២,៦៨ | ២,៦ | ២៥,៩ |
| អ៊ូហ្គង់ដា | ៥ | ៤,១ | ០,៥ | ៣,៩ | ២៥,៦ |
| បូលីវី | ២ | ៦,៨ | គ្មាន | ២,៩ | ១២,៩ |
| **កម្ពុជា** | **១,៥** | **២,៩** | **០,១** | **៥,៣ (២០០៨)** | **៣២,៤** |

*ប្រភព :* ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោកចំពោះកម្ពុជា និងសូចនាកររបស់ World Development សូចនាករសម្រាប់ប្រទេសដទៃ។

**ចំណាយចរន្តបាន និងកំពុងកើនឡើងលឿនជាង ផសស។** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឋានៈជាអ្នកផ្តល់សេវាមានថវិកាចរន្តធំបំផុត (៧៨ ពាន់លានរៀល នៅឆ្នាំ ២០០៩) បន្ទាប់មក គឺក្រសួងអភិវឌ្ឍន៍ជនបទ (៥៤,៦ ពាន់លានរៀល) និងបន្ទាប់មក គឺក្រសួងធនធានទឹក និងឧតុនិយម (៣១,៤ ពាន់លានរៀល)។ អត្រាកំណើនចំណាយចរន្តប្រចាំឆ្នាំរវាងឆ្នាំ ២០០០ និង ២០០៨ ចំពោះក្រសួងអភិវឌ្ឍន៍ជនបទ (២១,៤ ភាគរយ) និងក្រសួងធនធានទឹក និងឧតុនិយម (១៥,១ ភាគរយ) ខ្ពស់ជាងអត្រាកំណើននៃអត្រាថវិកាចរន្តសរុបបន្ទាប់ពីបានកាត់កងអត្រាអតិផរណា ចំណែកឯក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិញ ចំណាយចរន្តបានកើនឡើង ៩,២ ភាគរយ (រូបលេខ ១៩)។

### រូបលេខ ១៧. ចំណាយសរុបរបស់រដ្ឋាភិបាលលើវិស័យកសិកម្មបានកើនឡើង...
(គិតជា ភាគរយនៃ ផសស ឆ្នាំ ២០០៧-២០០៩)




*ប្រភព :* តារាង TOFE របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### រូបលេខ ១៨. ...ចំណែកឯកការគាំទ្ររបស់ម្ចាស់ជំនួយបានធ្លាក់ចុះ
(គិតជា ភាគរយ នៃចំណាយរដ្ឋាភិបាលលើវិស័យកសិកម្ម)




*ប្រភព :* កម្រងទិន្នន័យរបស់ CDC និង DIC

**នៅក្នុងថវិកាចរន្ត ចំណែកប្បៀវត្ស និងប្រាក់កម្រៃ មានកម្រិតទាបនៅក្នុងក្រសួងទាំងបី។** ប្រាក់កម្រៃស្មើនឹងមួយភាគបីនៃថវិកាចរន្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១៧ ភាគរយ នៃថវិកាចរន្តរបស់ក្រសួងធនធានទឹក និងឧតុនិយម និង ១៥ ភាគរយ នៃថវិកាចរន្តរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ ចំណាយប្រតិបត្តិការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួនខ្ពស់ជាខ្លាំង ចំណែកឯនៅក្រសួងធនធានទឹក និងឧតុនិយម និងនៅក្រសួងអភិវឌ្ឍន៍ជនបទ ថវិកាប្រតិបត្តិការត្រូវបានប្រើជាចម្បងសម្រាប់ការថែទាំ។ បញ្ហាសំខាន់ពីរកើតឡើង។ ទីមួយ វិភាជន៍សម្រាប់ការថែទាំ មិនគ្រប់គ្រាន់ក្នុងកម្រិតចំណាយមូលធនលើការស្រោចស្រព និងផ្លូវជនបទ។ ទីពីរ ចំណែកទាបនៃប្រាក់ឈ្នួល គឺជាកង្វល់។ ការជ្រើសរើសបុគ្គលិក ការរក្សាទុក បុគ្គលិក និងការជំរុញទឹកចិត្តបុគ្គិកបានក្លាយជាបញ្ហាចម្បង ធ្វើឱ្យគេមិនអាចអនុវត្តកម្មវិធីការងារដែលបានគ្រោងទុក និងមិនអាចផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលបានឡើយ។

**រូបលេខ ១៩. ចំណាយចរន្តបានកើនឡើងជាបន្តបន្ទាប់នៅក្នុងក្រសួងទាំងបី**
(គិតជា ពាន់លានរៀល)




*ប្រភព :* តារាង TOFE របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**រូបលេខ ២០. ចំណាយមូលធនរបស់រដ្ឋាភិបាលបានកើនឡើងជាខ្លាំង**
(គិតជា លានរៀល និងគិតជាភាគរយនៃចំណាយរបស់រដ្ឋាភិបាល)




*ប្រភព :* តារាង TOFE របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ការស្រោចស្រព និងផ្លូវជនបទ ត្រូវបានផ្តល់អាទិភាពនៅក្នុងថវិកាមូលធនតិចតួច ប៉ុន្តែកំពុងកើនឡើងដែលផ្តល់ហិរញ្ញប្បទានដោយប្រាក់ចំណូលផ្ទាល់។** ចំណាយមូលធននៅក្នុងក្រសួងធនធានទឹក និងឧតុនិយម មានចំនួនច្រើនជាងពាក់កណ្តាលនៃចំណាយមូលធនសរុបលើវិស័យកសិកម្ម រីឯចំណែកផ្សេងពីនេះ ត្រូវបានចំណាយនៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ។ ថវិកាមូលធន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួនតិចតួចណាស់ចាប់តាំងពីឆ្នាំ ២០០៤ មក។

**មានតែ ៣ ភាគរយ នៃថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប៉ុណ្ណោះ ដែលត្រូវបានវិភាជន៍ទៅឱ្យការផ្សព្វផ្សាយ ហើយមានតែ ៥ ភាគរយប៉ុណ្ណោះ ដែលទុកសម្រាប់ការស្រាវជ្រាវកសិកម្ម។** កង្វះថវិកាប្រតិបត្តិការក្នុងស្រុកសម្រាប់ការផ្សព្វផ្សាយ និងការស្រាវជ្រាវ ត្រូវបានបំពេញដោយម្ចាស់ជំនួយដែលបែងចែងប្រមាណជា ៣១ ភាគរយ នៃការផ្តល់មូលនិធិរបស់ខ្លួនទៅកាន់ផ្នែកទាំងនេះ។ ទាំងនេះក៏ជាផ្នែកដែលភាពពឹងផ្អែកលើម្ចាស់ជំនួយមានកម្រិតខ្ពស់បំផុតនៅក្នុងវិស័យកសិកម្ម។ ក្នុងអំឡុងឆ្នាំ ២០០៧-២០០៩ ចំណែកនៃការផ្តល់មូលនិធិរបស់រដ្ឋាភិបាលក្នុងមូលនិធិសរុបសម្រាប់ការផ្សព្វផ្សាយមានត្រឹមតែ ៣,៥ ភាគរយប៉ុណ្ណោះ និង ៤១ ភាគរយ សម្រាប់ការស្រាវជ្រាវកសិកម្ម។ មូលនិធិដែលផ្តល់ដោយម្ចាស់ជំនួយមានចំនួនតិចជាខ្លាំងចំពោះការវិនិយោគលើផ្លូវជនបទ និងការស្រោចស្រព ដែលមូលនិធិនោះប្រមូលផ្តុំជាចម្បងលើហេដ្ឋារចនាសម្ព័ន្ធថ្មី ឬទីតិសម្បទា។

**ជាសរុបម្ចាស់ជំនួយបរទេសផ្តល់ហិរញ្ញប្បទានប្រហែល៩៧ ភាគរយ នៃចំណាយសាធារណៈលើវិស័យកសិកម្ម ក្នុងអំឡុងឆ្នាំ ២០០៧-២០០៩។** ភាពពឹងផ្អែកយ៉ាងធ្ងន់មកលើមូលនិធិរបស់ម្ចាស់ជំនួយក្នុងវិស័យកសិកម្មនេះ ជាទូទៅបានបង្កើតបញ្ហាមួយចំនួន។ ទីមួយ តើការផ្តល់មូលនិធិមាននិរន្តរភាពផ្អែកសារពើពន្ធដែរឬទេ ទីពីរ ការរីកដុះដាលស្ទេកស្ទះនូវអង្គភាពអនុវត្តគម្រោង បានទាក់ទាញអ្នកមានជំនាញ និងបុគ្គលិកសំខាន់ៗពីរដ្ឋាភិបាលឱ្យទៅធ្វើការក្នុងគម្រោងរបស់ម្ចាស់ជំនួយ។ ក្នុងពេលនោះ ក្រសួងនានាប្រមូលផ្តុំលើគម្រោងជាជាងលើគោលនយោបាយ និងយុទ្ធសាស្ត្រថវិកា រីឯអាទិភាពនានារបស់ម្ចាស់ជំនួយ ជានិច្ចកាលមិនបានតម្រឹមតម្រង់ជាមួយគោលដៅអភិវឌ្ឍន៍ជាតិនោះទេ។

## ឃ. ដំណើរការថវិកា និងលទ្ធផលអនុវត្ត

**ដំណើរការថវិកានៅក្នុងក្រសួងទាំងបីដំណើរការថវិកា ត្រូវបានគ្រប់គ្រងដោយប្រព័ន្ធដែលបំពាក់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)។** ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមបីឆ្នាំរំកិល (MTEF) ព្យាករណ៍ និងវិភាជន៍លំហូរធនធានទៅកាន់វិស័យអាទិភាពនៅក្នុងរដ្ឋាភិបាល ដោយផ្អែកលើអាទិភាពនានា ដែលបានកំណត់ក្នុងឯកសារផែនការកម្រិតខ្ពស់ ដូចជា ផយអជ និងយុទ្ធសាស្ត្រតាមវិស័យជាដើម ។

**ផែនការយុទ្ធសាស្ត្រថវិកា (BSPs) ត្រូវបានដាក់ឱ្យប្រើនៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) នៅឆ្នាំ ២០០៧ គឺជាគោលនយោបាយសំខាន់ និងជាឧបករណ៍កសាងផែនការថវិកាសម្រាប់ក្រសួងនានា។** ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ផ្តោតលើលទ្ធផលអនុវត្ត ដែលប្រើប្រាស់ដោយក្រសួងពាក់ព័ន្ធនានាសម្រាប់រៀបចំថវិការយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំ និងថវិកាកម្មវិធីរបស់ខ្លួន ។ ទោះបីជាមានវឌ្ឍនភាពមួយចំនួនក្តី ចំណងទាក់ទងរវាង ផយអជ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំនៅតែខ្សោយ ។ ថវិកាចរន្ត ថវិកាមូលធន និងថវិកាម្ចាស់ជំនួយ នៅមិនទាន់បានធ្វើសមាហរណកម្មទាំងស្រុងនៅឡើយ (ចំណាយដែលផ្តល់ហិរញ្ញប្បទានពីបរទេស មានតែមួយចំណែកប៉ុណ្ណោះដែលមាននៅក្នុងថវិការបស់រដ្ឋាភិបាល និងមិនត្រូវបានចាត់ថ្នាក់ដោយប្រើប្លង់គណនីរបស់រដ្ឋាភិបាលឡើយ) ។

**ផែនការយុទ្ធសាស្ត្រថវិកា គប្បីក្លាយជាឧបករណ៍កសាងផែនការស្នូល ដើម្បីអនុវត្តយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក (SAW) និងគប្បីគ្របដណ្តប់ទាំងស្រុងនូវចំណាយដែលផ្តល់ហិរញ្ញប្បទានទាំងក្នុងស្រុក និងពីម្ចាស់ជំនួយ។** បច្ចុប្បន្ន ប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រថវិកាជួបការលំបាកដោយកង្វះសមត្ថភាព និងដោយភាពជាន់គ្នាជាមួយអង្គភាពអនុវត្តគម្រោង (PMUs) ។ ម្ចាស់ជំនួយយល់ដឹងបានច្បាស់អំពីចេតនាក្នុងការបោះបង់គម្រោងទៅកាន់អភិក្រម ដែលមានចរិតសមាហរណកម្ម និងកម្មវិធី ។

**ឧបសគ្គចំពោះការកែលំអការកសាងថវិកាមានចរិតជាប្រព័ន្ធ ហើយក្នុងកម្រិតណាមួយនោះ ហួសពីការគ្រប់គ្រងរបស់ក្រសួងពាក់ព័ន្ធ។** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងប្រឹងប្រែងកែលំអប្រព័ន្ធនេះ ទោះបីជាកាលវិភាគនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈច្រើនឆ្នាំទទួលស្គាល់ថា កំណែទម្រង់ទាំងនេះ ត្រូវការពេលវេលាមួយចំនួនដើម្បីអនុវត្តក្តី ។

**ផលិតភាពកសិកម្ម ការស្រោចស្រព និងផ្លូវជនបទ ស្ថិតក្នុងចំណោមអាទិភាពខ្ពស់បំផុតសម្រាប់យុទ្ធសាស្ត្រជាតិ និងយុទ្ធសាស្ត្រតាមវិស័យ។** ផយអជ កំណត់សកម្មភាពសំខាន់ពីរ ពោល គឺការបង្កើនវិនិយោគសាធារណៈក្នុងវិស័យកសិកម្ម និងការបង្កើនទិន្នផលតាមរយៈសេវាផ្សព្វផ្សាយកសិកម្ម ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (ASSDP) សង្កត់ធ្ងន់អំពីសារៈសំខាន់នៃការធ្វើពាណិជ្ជកម្មកសិកម្ម ។ យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ដែលបានជំនួសផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មផ្តល់ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់អនុវត្ត ផយអជ ។

**ចំណាយរដ្ឋាភិបាលលើវិស័យកសិកម្ម និងលើការស្រោចស្រព មានចំនួនខុសពីការគណនាចំណាយដែលបានព្យាករណ៍នៅក្នុងឯកសារយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។** រដ្ឋាភិបាលបានចំណាយលើការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្ម តិចជាងចំណាយដែលបានព្យាករណ៍នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងនៅក្នុងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក និងចំណាយច្រើនលើរុក្ខាប្រមាញ់ ក៏ដូចជាការធានាឱ្យផលិតផលកសិកម្មអាចចូលទីផ្សារបាន និងចំណាយលើការស្រោចស្រព ។ ទឹកប្រាក់ជាក់ស្តែងដែលបានចំណាយលើក្របខ័ណ្ឌស្ថាប័ន និងកំណែទម្រង់ព្រៃឈើ មានលក្ខណៈស្របគ្នាជាមួយការព្យាករណ៍របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ។ ការវិនិយោគរបស់រដ្ឋាភិបាលលើការស្រោចស្រពមានទំហំខ្ពស់ជាងជាខ្លាំងធៀបនឹងការព្យាករណ៍នៅឆ្នាំ ២០០៥ ។

## ង. ប្រសិទ្ធភាព និងប្រសិទ្ធផលនៃចំណាយរបស់រដ្ឋាភិបាលក្នុងវិស័យកសិកម្ម

**នៅក្នុងផ្នែកនេះ ការអនុវត្តរបស់រដ្ឋាភិបាលក្នុងការសម្រេចគោលបំណងរបស់ខ្លួនត្រូវបានវាស់វែងដោយលទ្ធផល កំណើនប្រាក់ចំណូលសម្រាប់អ្នកទទួលផលផ្ទាល់នៃចំណាយសាធារណៈ និងការកាត់បន្ថយចំណាយដោយអ្នកទទួលផលដដែល។** គោលបំណងភាគច្រើនរបស់យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ចំពោះការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការស្រោចស្រព មានគោលដៅបង្កើនប្រាក់ចំណូលរបស់អ្នកទទួលផលជាកសិករ ។ ក្នុងករណីផ្លូវជនបទ គោលបំណងចំពោះមុខនៃយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក គឺដើម្បីបង្កើន

ប្រាក់ចំណូលរបស់កសិករ និងដើម្បីកាត់បន្ថយថ្លៃ និងចំណាយនៃការដឹកជញ្ជូន។ ជាមួយគ្នានេះ ក៏រួមបញ្ចូលផងដែរនូវគោលបំណងទូលាយអំពីការលើកកម្ពស់កំណើន និងការកាត់បន្ថយភាពក្រីក្រ។

**កម្រិតនៃលទ្ធផលពីចំណាយសាធារណៈមាននិរន្តរភាពចាប់តាំងពីឆ្នាំ ២០០២ រីឯចំណាយមួយឯកតាលទ្ធផលមានការប្រែប្រួល។** យោងតាមទិន្នន័យរបស់រដ្ឋាភិបាល លទ្ធផលអំពីការស្រោចស្រព និងផ្លូវជនបទមានការកើនឡើងខណៈដែលចំណែកនៃគម្រោងស្រោចស្រព និងផ្លូវជនបទដែលបានស្តារបានកើនឡើងច្រើនជាង ៥ ភាគរយ នៃគម្រោងសរុប។ គេឃើញតួលេខស្តីពីចំណាយមួយឯកតាប្រចាំឆ្នាំខុសគ្នាយ៉ាងច្រើន ប៉ុន្តែជាទូទៅចំណាយក្នុងមួយឯកតាតាមថ្លៃស្មេរ ភាគច្រើននៅតែមិនប្រែប្រួលចំពោះការផ្សព្វផ្សាយកសិកម្មបានកើនឡើងចំពោះការស្រោចស្រព និងបានធ្លាក់ចុះចំពោះផ្លូវជនបទ។ កត្តានានាដែលមានឥទ្ធិពលចំពោះចំណាយក្នុងមួយឯកតា រួមមាន ការរាយការណ៍មិនបានល្អ អាចមានកំហុសក្នុងការកត់ត្រាការថែទាំផ្លូវថ្នល់ជនបទ និងការដំឡើងថ្លៃ និងប្រាក់ចំណេញលើដំណាំ។ ការបូកសរុបសាមញ្ញបំផុតនៃទិន្នន័យចំពោះសំណង់ធារាសាស្ត្រមួយចំនួនធំ ក៏អាចបន្ថែមបញ្ហាមួយចំនួនធំរួចទៅហើយ។ ភស្តុតាងអន្តរជាតិដែលមានតិចតួចបង្ហាញថា ចំណាយក្នុងមួយឯកតានៅកម្ពុជាចំពោះការផ្សព្វផ្សាយ និងសម្រាប់ផ្លូវជនបទមានកម្រិតខ្ពស់ និងទាបចំពោះការស្រោចស្រព (រូបលេខ ២១ និងរូបលេខ ២២)។

**រូបលេខ ២១. លទ្ធផលសំខាន់ៗដែលសម្រេចបានជាទូទៅមាននិន្នាការឡើង**

(គិតជា រៀល និងជាភាគរយនៃ ផសស ឆ្នាំ ២០០២-២០០៩)




*ប្រភព* : ការគណនារបស់បុគ្គលិកធនាគារពិភពលោក

**រូបលេខ ២២. ប៉ុន្តែតួលេខចំណាយមានទិដ្ឋភាពចម្រុះ**

(បន្ទាត់ជាក់ស្តែង និងបន្ទាត់និន្នាការ-ថ្លៃស្មេរ ឆ្នាំ ២០០៩)




*ប្រភព* : ការគណនារបស់បុគ្គលិកធនាគារពិភពលោក

**ការវិភាគអំពីផលសេដ្ឋកិច្ចចំពោះចំណាយសាធារណៈមានមូលដ្ឋានផ្អែកលើអនុបាតរវាងផលចំណេញ និងចំណាយ (BCRs)។** BCR គឺជាអនុបាតតម្លៃបច្ចុប្បន្នសុទ្ធ (NPV) នៃផលចំណេញ ធៀបនឹងតម្លៃបច្ចុប្បន្ននៃចំណាយដែលនឹងត្រូវបានគណនា ប្រសិនបើមានការវាយតម្លៃផ្នែកសេដ្ឋកិច្ចកាលពីទសវត្សរ៍កន្លងទៅ។ BCRs មានកម្រិតទាប (ជិតស្មើ ១) នៅឆ្នាំ ២០០៧ ប៉ុន្តែបានកើនឡើងខ្ពស់ជាង ២ បន្ទាប់ពីថ្លៃទំនិញកើនឡើងចាប់តាំងពីឆ្នាំ ២០០៧ ហើយទោះបីជាការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយមិនទៀងទាត់ និងការសម្របសម្រួលជាមួយការស្រាវជ្រាវមិនល្អក្តី (រូបលេខ ២៣ និង ២៤)។

**រូបលេខ ២៣. អនុបាតរវាងផលចំណេញ និងចំណាយ ចំពោះវិស័យកសិកម្ម និងផ្លូវជនបទកំពុងកើនឡើង...**




**រូបលេខ ២៤. ...ប៉ុន្តែចំណាយទាំងនេះ នៅតែទាបជាងសក្តានុពល**




*សំគាល់ :* BCRs ត្រូវបានគណនាជាផលចំណេញសុទ្ធពិតដែលបានទទួលពីចំណាយមួយឯកតា ដែលរួមមានទាំងចំណាយចរន្ត និងចំណាយមូលធន។ ការណ៍នេះអាចធ្វើឱ្យគេប្រៀបធៀបវិស័យហេដ្ឋារចនាសម្ព័ន្ធនានា ដូចជា ផ្លូវជនបទធៀបជាមួយការផ្តល់សេវាសាធារណៈ ដូចជា ការផ្សព្វផ្សាយកសិកម្ម ជាដើម។ BCRs ត្រូវបានគណនាសម្រាប់ឆ្នាំនីមួយៗ លើមូលដ្ឋាននៃនិន្នាការជាក់ស្តែងនៃចំណាយក្នុងមួយឯកតាក្នុងមួយឆ្នាំ និងលំហូរផលចំណេញរំពឹងទុកតាមតម្លៃទីផ្សារ។ ក្រាហ្វិកសរសរប្រៀបធៀប BCRs ក្នុងឆ្នាំនីមួយៗ ធៀបជាមួយ BCRs សក្តានុពលដែលអាចទទួលបានតាមទ្រឹស្តី ប្រសិនបើចំណាយសាធារណៈបានអនុវត្តតាមផែនការដែលបានកំណត់ ឬប្រសិនបើមានតុល្យភាពរវាងចំណាយស្តារនីតិសម្បទា និងចំណាយថែទាំ។ ឧទាហរណ៍ BCR សម្រាប់ការផ្សព្វផ្សាយកសិកម្ម ត្រូវបានគណនាដោយសន្មតថា មន្ត្រីផ្សព្វផ្សាយម្នាក់ចុះពិនិត្យកសិករ ៣ នាក់ ក្នុងមួយលើក ដែលជាផែនការកំណត់ដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ចាប់តាំងពីឆ្នាំ ២០០៧ មក ចំណាយសាធារណៈលើការផ្សព្វផ្សាយកសិកម្មបាននាំមកនូវផលចំណូលខ្ពស់ ចំណែកឯផលចំណូលចំពោះការវិនិយោគលើប្រព័ន្ធស្រោចស្រពវិញនៅតែមានកម្រិតទាប ទោះបីជាមានការដំឡើងថ្លៃចាប់តាំងពីឆ្នាំ ២០០៧ ក្តី។** មួយផ្នែកធំ ដោយសារវិសមាមាត្រចំណាយដែលបានវិភាជន៍ចំពោះគម្រោងនីតិសម្បទាប្រព័ន្ធស្រោចស្រព ដែលមានប្រតិបត្តិការថែទាំតិចតួច ឬគ្មានទសោះតែម្តង។ ជាមួយនឹងការកំណត់គោលដៅកាន់តែប្រសើរក្នុងការប្រើប្រាស់មូលនិធិសាធារណៈ គេអាចបង្កើនផលចំណូលពីចំណាយសាធារណៈលើប្រព័ន្ធស្រោចស្រពចំនួនពីរដង។ ចំណាយសាធារណៈលើផ្លូវជនបទទទួលបានផលចំណូលដែលអាចទទួលយកបាន និងកើនឡើងជាបណ្តើរៗក្នុងទសវត្សរ៍ចុងក្រោយ។ ប្រសិនបើគោលដៅលទ្ធផលមានស្ថេរភាព និងសម្រេចបាន ការចំណាយលើការផ្សព្វផ្សាយកសិកម្ម និងផ្លូវជនបទ អាចនឹងផ្តល់ផលចំណូលខ្ពស់បំផុតនៃចំណាយរបស់រដ្ឋាភិបាលលើវិស័យកសិកម្ម។

## កសិកម្ម

**BCRs បានកើនឡើងចាប់តាំងពីឆ្នាំ ២០០៧ បន្ទាប់ពីមានកម្រិតប្រហែលមួយឯកតារហូតដល់ឆ្នាំ ២០០៦ មួយផ្នែកសឱ្យឃើញការកើនឡើងនូវផលចំណេញស្របជាមួយកណើនថ្លៃកសិកម្ម។** ការណ៍នេះធ្វើឱ្យផលចំណូលធៀបជាមួយនឹងការវិនិយោគលើការផ្សព្វផ្សាយកសិកម្មមានលក្ខណៈទាក់ទាញដូចវិនិយោគលើផ្លូវថ្នល់ដែរ ដែល BCR ឡើងខ្ពស់បំផុតរហូតស្មើ ៣ នៅឆ្នាំ ២០០៨។ ចំណែកឯចំណាយមធ្យមក្នុងកសិករម្នាក់ ដែលមន្ត្រីផ្សព្វផ្សាយកសិកម្មបានទំនាក់ទំនងជាមួយនៅកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងនិយាមអន្តរជាតិ គេឃើញមានភាពខុសគ្នាច្រើនក្នុងចំណាយក្នុងមួយឯកតារវាងសេវាផ្សព្វផ្សាយរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ដែលថ្លៃសេវាផ្សព្វផ្សាយរបស់អង្គការក្រៅរដ្ឋាភិបាលមានកម្រិតខ្ពស់ជាងច្រើន នៅពេលគិតបញ្ចូលនូវចំណាយប្រតិបត្តិការក្នុងស្រុក និងក្រៅស្រុក។ លទ្ធផលនៃអង្កេតអ្នកទទួលផលដែលបានអនុវត្តជាផ្នែកមួយនៃការវិភាគពិនិត្យឡើងវិញ នូវចំណាយសាធារណៈ បង្ហាញថា ជាទូទៅកសិករយល់ថា បុគ្គលិកនៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) មានគុណភាព និងចំណេះដឹងបច្ចេកទេសល្អ ហើយបានបញ្ជាក់អំពីការពេញចិត្តជាមួយសេវាផ្សព្វផ្សាយកសិកម្មរបស់ពួកគេ។ ប៉ុន្តែប្រសិទ្ធភាពនៃចំណាយផ្សព្វផ្សាយសាធារណៈមានកម្រិតទាប នៅពេលប្រៀបធៀបអត្រាចុះផ្សព្វផ្សាយដែលបានរាយការណ៍ និងអត្រាសក្តានុពលនៃការចុះផ្សព្វផ្សាយ ការប្រៀបធៀបជាមួយអត្រាខាងក្រោយនេះ គេឃើញមានគម្លាតយ៉ាងច្រើនរវាង BCR ជាក់ស្តែង និង BCR សក្តានុពល (៣ ទល់នឹង ៥)។

**ចំណាយសាធារណៈលើការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា មានសក្តានុពលក្នុងការបន្តទទួលអត្រាផលចំណូលខ្ពស់។** គំរូបច្ចុប្បន្នរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ដែលមន្ត្រីផ្សព្វផ្សាយបណ្តុះបណ្តាកសិករឈានមុខ រួចបន្ទាប់មកកសិករនេះបន្តបណ្តុះបណ្តាលក្រុមកសិកររបស់ពួកគាត់ហាក់មានដំណើរការល្អបង្គួរ។ ទោះជាយ៉ាងនេះក្តី នៅមានលទ្ធភាពយ៉ាងច្រើនក្នុងការបង្កើនកម្រិតផលិតភាព ជាពិសេសផលិតភាពសម្រាប់ស្រូវរដូវវស្សា ដែលបង្ហាញថាសកម្មភាពផ្សព្វផ្សាយអាចអនុវត្តបន្ត ដើម្បីផ្តល់ផលប្រយោជន៍យ៉ាងច្រើនក្នុងរយៈពេលមធ្យមទៅរយៈពេលវែង។ ខណៈដែលការកាត់ចំណាយពិតជាមានឥទ្ធិពលវិជ្ជមានមកលើ BCRs អថេរសំខាន់ដែលមានឥទ្ធិពលលើលទ្ធផលការងារនៃចំណាយផ្សព្វផ្សាយ គឺអត្រាទទួលយកទៅអនុវត្តក្នុងបុគ្គលិកម្នាក់ និងកំណើនអត្រាចុះផ្សព្វផ្សាយក៏ដូចជាការប្រើប្រាស់ច្រើននូវបច្ចេកវិទ្យាថ្មីៗដោយកសិករ។ ឧទាហរណ៍ ការវិភាគចំណាយសាធារណៈបង្ហាញថា ដើម្បីឈានដល់គោលដៅប្រសិទ្ធភាពចំនួន ១.៥០០ ដុល្លារក្នុងមួយឆ្នាំ ក្នុងការបង្កើនតម្លៃបន្ថែមជាបន្តបន្ទាប់ក្នុងបុគ្គលិកផ្សព្វផ្សាយម្នាក់ៗ តម្រូវឱ្យមានកំណើនជាបន្តបន្ទាប់នូវអ្នកអនុវត្តថ្មីចំនួន ១០០ នាក់ សម្រាប់បុគ្គលិកផ្សព្វផ្សាយម្នាក់ក្នុងមួយឆ្នាំ កើនឡើងពីកម្រិតមធ្យមក្នុងពេលបច្ចុប្បន្នចំនួនកសិករ ៥០ នាក់ និងកំណើនតម្លៃបន្ថែមពាក់ព័ន្ធប្រមាណជា ១០ ភាគរយ លើកម្រិតគោល (ពោល គឺសារនានាអំពីផលិតកម្មយថាផល)។ គេអាចសម្រេចបានលទ្ធផលដូចគ្នា ដោយបង្កើនអ្នកអនុវត្តថ្មីតែចំនួន ២០ នាក់ ក្នុងមួយឆ្នាំក្នុងបុគ្គលិកផ្សព្វផ្សាយម្នាក់ ប្រសិនបើកសិករអនុវត្តកញ្ចប់បច្ចេកវិទ្យាដាំដុះពេញលេញ (ពោល គឺការគួបផ្សំរវាងការកែលំអគ្រាប់ពូជ និងសម្ភារៈកសិកម្ម និងបច្ចេកទេសដាំដុះល្អ) ដែលត្រូវបានប៉ាន់ស្មាន ដើម្បីបង្កើនតម្លៃបន្ថែមកសិកម្មប្រហែល ៥០ ភាគរយ លើសកម្រិតសព្វថ្ងៃ (ពោល គឺសារនានាអំពីផលិតកម្មអតិផល)។

**ការបង្កើនលទ្ធផលអនុវត្តរយៈពេលវែងនៃសកម្មភាពផ្សព្វផ្សាយកសិកម្មសាធារណៈ ត្រូវឱ្យលើកកម្ពស់មុខងារស្ថាប័នផ្សព្វផ្សាយ។** បញ្ហាចម្បងទាក់ទងនឹងលទ្ធផលសេវាផ្សព្វផ្សាយក្នុងពេលបច្ចុប្បន្ននៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម គឺថវិកាប្រតិបត្តិការមិនគ្រប់គ្រាន់ដែលធ្វើការការចុះផ្សព្វផ្សាយ កសិករមិនអាចប្រព្រឹត្តិទៅតាមការគ្រោងទុក និងមិនបានញឹកញាប់ ដើម្បីបង្កើនចំណេះដឹង និងជំរុញការអនុវត្តបច្ចេកវិទ្យាថ្មីៗបន្ថែមទៀត ប៉ុន្តែក៏មានបញ្ហាផ្នែកស្ថាប័នទូទៅផងដែរ។ ការសម្រេចបាននូវតុល្យភាពបានកាន់តែល្អប្រសើររវាងចំណាយប្រតិបត្តិការ និងចំណាយចរន្ត គួបផ្សំជាមួយការផ្លាស់ប្តូរទូទៅផ្នែកស្ថាប័នដែលប្រគល់ធនធានថវិកា និងបុគ្គលិកបន្ថែមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ត្រូវធ្វើដំណើរវែងឆ្ងាយ ដើម្បីផ្តល់សារផ្សព្វផ្សាយជាមួយនឹងផលចំណេញខ្ពស់ តាមរយៈការផ្សព្វផ្សាយទៅដល់កសិករច្រើននាក់។ សុខុដុម-ភាវូបនីយកម្មនៃសាស្ត្រីពីការផ្សព្វផ្សាយ និងអភិក្រមធ្វើការផ្សព្វផ្សាយរវាងអ្នកផ្តល់សេវានានា (រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន) និងការលុបបំបាត់សារដែលផ្តល់ព័ត៌មានមិនស៊ីសង្វាក់គ្នា ក៏អាចបង្កើនតម្លៃប្រាក់ចំពោះចំណាយផ្សព្វផ្សាយពីភាគីគ្រប់គ្នាផងដែរ។ ជាចុងក្រោយ សមាហរណកម្មបានល្អប្រសើររវាងមុខងារស្រាវជ្រាវកសិកម្ម និងមុខងារធ្វើការផ្សព្វផ្សាយកសិកម្ម នឹងធ្វើឱ្យប្រាកដថាចំណាយសាធារណៈលើការអភិវឌ្ឍប្រភេទដំណាំថ្មី និងព័ត៌មានស្តីពីសាកល្បងការស្រាវជ្រាវអំពីបច្ចេកទេសគ្រប់គ្រងដី និងដីសម្រាប់ស្ថានភាពកសិ-បរិស្ថានជាក់លាក់ នឹងបានទៅដល់កសិករបានឆាប់រហ័ស និងក្នុងទម្រង់ដែលងាយទទួលបាន ផ្តល់បានជាមូលដ្ឋានចម្បងមួយសម្រាប់បង្កើនផ្សព្វផ្សាយសាស្ត្រីពីការផ្សព្វផ្សាយកសិកម្ម។

## ការស្រោចស្រព

**BCRs ចំពោះការស្រោចស្រពនៅតែជិតស្មើ ១ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ២០០០ ដែលបង្ហាញថាប្រព័ន្ធស្រោចស្រពកំពុងដំណើរការទាបជាងសក្តានុពលនៃប្រព័ន្ធនេះជាខ្លាំង។** ចាប់តាំងពីឆ្នាំ ២០០៧ មក នៅពេលដែលស្រូវអង្ករឡើងថ្លៃ BCRs ចំពោះប្រព័ន្ធស្រោចស្រពមិនប្រែប្រួលឡើយ ដោយសារការកើនឡើងនូវចំណាយក្នុងមួយឯកតា (ទោះបីជាអនុបាតទាំងនោះ មានកម្រិតប្រហាក់ប្រហែលនឹងនិយាមអន្តរជាតិក្តី)។ នេះ គឺជាកង្វល់ចម្បង ហើយក្រសួងធនធានទឹក និងឧតុនិយម ចាំបាច់ត្រូវផ្តល់ការយកចិត្តទុកដាក់បន្ថែមទៀតចំពោះការផ្តល់អាទិភាពលើសកម្មភាពវិនិយោគរបស់ខ្លួន។ ភាពខុសគ្នាច្រើននៃអនុបាត BCRs រវាងគម្រោងនានាបង្ហាញថាការវិនិយោគលើប្រព័ន្ធស្រោចស្រពអាចមានលក្ខណៈប្រកួតប្រជែងគ្នាបាន សូម្បីតែចំពោះចំណាយក្នុងមួយឯកតាបច្ចុប្បន្នមានកម្រិតខ្ពស់ក្តី ប្រសិនបើការវិនិយោគលើប្រព័ន្ធស្រោចស្រពទាំងនោះត្រូវបានជ្រើសរើស និងរៀបចំបានល្អ អនុវត្តដោយពេញលេញ និងរក្សាទុកឱ្យបានត្រឹមត្រូវ។

**អនុបាត BCRs ជាក់ស្តែងពីការវិនិយោគលើប្រព័ន្ធស្រោចស្រពមានទំហំតូចជាងពាក់កណ្តាលនៃសក្តានុពលនៃផលចំណូលពីការវិនិយោគទាំងនេះ។** មូលហេតុចម្បងចំពោះបញ្ហានេះ គឺដោយសារការស្តារនីតិសម្បទាមិនពេញលេញ និងការថែទាំមិនគ្រប់គ្រាន់។ គេបានប៉ាន់ស្មានថា នៅកម្ពុជា មានត្រឹមតែ ៧០ ភាគរយប៉ុណ្ណោះ នៃតំបន់ជុំវិញប្រព័ន្ធធារាសាស្ត្រអាចទទួលការស្រោចស្រព សំខាន់ គឺដោយសារខ្វះ

ការស្តារនីតិសម្បទា។ នេះ គឺជាលទ្ធផលនៃការចំណាយមូលនិធិសាធារណៈលើប្រឡាយមេ ខណៈដែលប្រឡាយរង និងប្រឡាយជើងក្អែបមិនត្រូវបានវិនិយោគ ទោះបីជាមានការទទួលស្គាល់ច្រើនឡើងនៅក្រសួងធនធានទឹក និងឧតុនិយមអំពីតម្រូវការក្នុងការដាក់បញ្ចូលនូវការយកចិត្តទុកដាក់លើប្រឡាយរង និងប្រឡាយជើងក្អែប ជាផ្នែកសំខាន់នៃការវិនិយោគលើសំណង់ធារាសាស្ត្រក្តី។

**ការផ្តល់មូលនិធិតិចតួចចំពោះការថែទាំ គឺជាមូលហេតុចម្បងមួយទៀតចំពោះប្រសិទ្ធភាពតិចតួចនៃវិស័យធារាសាស្ត្រនៅកម្ពុជា។** អាចជាលទ្ធភាព ដែលថាកង្វះការថែទាំសមស្របធ្វើឱ្យផលចំណេញធ្លាក់ចុះរហូតដល់ ១០ ភាគរយ ក្នុងមួយឆ្នាំ។ អាស្រ័យហេតុនេះ យើងផ្តល់អនុសាសន៍ថា ប្រមាណជា ៥ ភាគរយ នៃចំណាយស្តារនីតិសម្បទាបច្ចុប្បន្ន គប្បីបែងចែកដល់ការថែទាំក្នុងឆ្នាំនីមួយៗជាបន្តបន្ទាប់។ ការណ៍នេះមានន័យថា ប្រមាណជាមួយភាគបីនៃចំណាយសរុបលើប្រព័ន្ធស្រោចស្រព គប្បីទុកសម្រាប់ការថែទាំ។ ជាមួយគ្នានេះក៏មានលទ្ធភាពផងដែរថា តាមរយៈការប្រើបច្ចេកវិទ្យាថ្មីក្នុងការវិនិយោគលើប្រព័ន្ធស្រោចស្រព ដែលនឹងកាត់បន្ថយតម្រូវការចំពោះការថែទាំដែលត្រូវចំណាយខ្ពស់ក្នុងពេលអនាគត។ រដ្ឋាភិបាលត្រូវបានលើកទឹកចិត្តឱ្យបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក (FWUCs) ឱ្យធ្វើការថែទាំនៅមូលដ្ឋាន។ ជាគោលការណ៍ ខណៈដែលចំណុចនេះអាចអនុវត្តទៅរួច គេអាចចំណាយពេលវេលាច្រើនមុនពេលដែលសហគមន៍កសិករប្រើប្រាស់ទឹកអាចមានលទ្ធភាពអនុវត្តចំណាយហិរញ្ញវត្ថុបែបនេះ។ អាស្រ័យហេតុនេះ ការបណ្តោយឱ្យសហគមន៍កសិករប្រើប្រាស់ទឹកទទួលខុសត្រូវទាំងស្រុងចំពោះការថែទាំ គ្មានលក្ខណៈប្រាកដនិយមឡើយ មានន័យថា ចំណែកមូលនិធិសាធារណៈល្អបំផុត ដែលត្រូវផ្តល់ឱ្យថែទាំមានចំនួនប្រហែលមួយភាគបី។

### ផ្លូវជនបទ

**ចំណាយលើផ្លូវជនបទបានទទួលផលយ៉ាងច្រើនក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗ ដែលអនុបាត BCRs មានទំហំធំជាង ២ ចាប់តាំងពីឆ្នាំ ២០០៥ និងឡើងដល់ ៣ នៅឆ្នាំ ២០០៨ និង ២០០៩។** ផ្លូវជនបទប្រវែងពី ១០០ ទៅ ៦០០ គ.ម ត្រូវបានស្តារនីតិសម្បទា (ជាមធ្យមប្រហែល ១ ភាគរយក្នុងមួយឆ្នាំ) និង ៣០០ ទៅ ១.០០០ គ.ម. បានទទួលការថែទាំជាទៀងទាត់ ឬជាប្រចាំ (ជាមធ្យមប្រហែល ២,៣ ភាគរយក្នុងមួយឆ្នាំ)។ អនុបាត BCRs ចំពោះផ្លូវជនបទ ពឹងផ្អែកយ៉ាងច្រើនលើកម្រិតនៃកិច្ចប្រឹងប្រែងថែទាំ។ ការបង្កើនចំណាយលើការថែទាំកាលពីពេលថ្មីៗ នឹងបង្កើនប្រសិទ្ធភាពនៃការវិនិយោគទាំងនេះ ទោះបីជាចំណែកនៃថវិកាសម្រាប់ការថែទាំនៅមានកម្រិតទាបជាងកម្រិតល្អបំផុតប្រមាណជា ៤៥ ភាគរយ នៃចំណាយផ្លូវថ្នល់សរុបក្តី។ ចំណាយនៃការកសាង និងថែទាំផ្លូវជនបទកំពុងកើនឡើង ហើយគ្រួសក្រហមក៏ខ្វះខាតកាន់តែច្រើនឡើងផងដែរ។ ចាំបាច់ត្រូវរក និងសាកល្បងសម្ភារៈ និងបច្ចេកទេសថ្មីៗ ដូចជា បេតុង ឬស៊ី វិធីសាស្ត្រកែច្នៃដី ប្រសិនបើចង់ឱ្យវឌ្ឍនភាពក្នុងការបង្កើនលទ្ធភាពទៅទីជនបទមាននិរន្តរភាព ប៉ុន្តែប្រការនេះនឹងតម្រូវឱ្យមានជាមុននូវការចំណាយមូលធន និងការកសាងសមត្ថភាពបន្ថែមច្រើនជាងនេះ។

**ការកែលំអហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទអាចកាត់បន្ថយភាពក្រីក្របានយ៉ាងច្រើន។** ប្រព័ន្ធផ្លូវថ្នល់មិនគ្រប់គ្រាន់ គឺជាឧបសគ្គចម្បងចំពោះការអភិវឌ្ឍសេដ្ឋកិច្ច។ ការវិនិយោគលើផ្លូវជនបទនាំមកនូវផលប្រយោជន៍ច្រើនក្នុងការកាត់បន្ថយភាពក្រីក្រ នៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ហើយចំណុចនេះត្រូវបានបង្ហាញថា ពិតដូច្នោះមែននៅកម្ពុជាផងដែរ។ គេបានប៉ាន់ស្មានថា ការស្តារនីតិសម្បទាផ្លូវថ្នល់អាចកាត់បន្ថយចំណាយ ៣០ ភាគរយ ដល់កសិករក្នុងការដឹកជញ្ជូនផលិតផលរបស់ពួកគេទៅកាន់ទីផ្សារ និងអាចបង្កើនថ្លៃនៅកសិដ្ឋានចំពោះកសិករ ដែលមិនដឹកជញ្ជូនផលិតផលរបស់ពួកគេទៅកាន់ទីផ្សារដោយខ្លួនឯង។ ការកែលំអផ្លូវជនបទជួយប្រជាជនជនបទឱ្យមានលទ្ធភាពទទួលបានសេវាសំខាន់ៗ និងបង្កើនឱកាសរបស់ពួកគេក្នុងការរកប្រាក់ចំណូលក្រៅពីការងារកសិកម្ម។

# ច. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ

**នៅកម្ពុជា ប្រសិទ្ធភាពនៃចំណាយសាធារណៈចំពោះវិស័យកសិកម្មអាចនឹងកើនឡើងច្រើន។** បញ្ហាប្រឈមនានា ដែលបានកំណត់នៅក្នុងជំពូកនេះ រួមមាន កង្វះនិរន្តរភាពនៃការផ្តល់មូលនិធិសាធារណៈ ជាពិសេសចំពោះចំណាយប្រតិបត្តិការ និងថែទាំសម្រាប់ការផ្សព្វផ្សាយ និងស្រាវជ្រាវកសិកម្ម ហើយចាំបាច់ត្រូវដោះស្រាយបញ្ហាជ្រាលជ្រៅផ្នែកស្ថាប័ន ដែលអាចកាត់បន្ថយប្រសិទ្ធភាពរយៈពេលវែងនៃចំណាយទាំងនេះ។ បញ្ហាប្រឈមដទៃទៀត រួមមាន ការយកចិត្តទុកដាក់ច្រើនហួសចំពោះការស្តារនីតិសម្បទាហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពមេ និងមិនបានយកចិត្តទុកដាក់ចំពោះប្រព័ន្ធប្រឡាយរង និងជើងក្អែប ការមិនយកចិត្តទុកដាក់ចំពោះការថែទាំប្រព័ន្ធស្រោចស្រព និងផ្លូវជនបទ និងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីដោយល្បឿនយឺតចំពោះផ្លូវជនបទ ដោយសារការធ្លាក់ចុះនូវការផ្គត់ផ្គង់គ្រួសក្រហម។ ចាំបាច់ត្រូវផ្តល់អាទិភាពចំណាយ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃចំណាយសាធារណៈសម្រាប់វិស័យទាំងបី។

**ការកើនឡើងនូវថ្លៃនៃផលិតផលកសិកម្មកាលពីពេលថ្មីៗកន្លងទៅ ធ្វើឱ្យអនុបាត BCRs កើនឡើងយ៉ាងខ្ពស់។** ខណៈដែល ជាទូទៅគេចង់បង្កើនចំណាយលើទំនិញសាធារណៈ និងសេវានានា យើងជឿថាមានលទ្ធភាពតិចតួចប៉ុណ្ណោះក្នុងការធ្វើបែបនេះធៀបនឹង ផសស ក្នុងកញ្ចប់ថវិកាដែលមានស្រាប់ក្នុងរយៈពេលខ្លី វៀរលែងតែមានការកាត់បន្ថយនូវការកាត់កងក្នុងផ្នែកដទៃទៀត។ ប្រសិនបើមានលទ្ធភាពបែបនេះ បេក្ខភាពសំខាន់សម្រាប់បង្កើនវិភាជន៍ គឺការផ្សព្វផ្សាយកសិកម្ម និងផ្លូវជនបទ។ អាស្រ័យហេតុនេះ អនុសាសន៍នៅក្នុងជំពូកនេះនឹងផ្តោតជាចម្បងលើការលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលរួមនៃកម្រិតចំណាយកសិកម្មបច្ចុប្បន្ន។

លើមូលដ្ឋាននៃការវិភាគនៃជំពូកនេះ យើងផ្តល់អនុសាសន៍ដូចខាងក្រោម ដើម្បីកែលំអលទ្ធផលអនុវត្តន៍នៃចំណាយសាធារណៈលើវិស័យកសិកម្ម ប្រព័ន្ធស្រោចស្រព និងផ្លូវជនបទ :

- **បែងចែងសាឡើងវិញ ដោយផ្តល់ធនធានថវិកាបន្ថែមលើការផ្សព្វផ្សាយកសិកម្ម។** ការផ្តល់មូលនិធិរបស់រដ្ឋាភិបាលសម្រាប់ការផ្សព្វផ្សាយកសិកម្មមានកម្រិតទាបធៀបនឹងចំណែកនៃថវិកាកសិកម្ម និងជាលទ្ធផល សេវាទាំងនេះពឹងផ្អែកលើការគាំទ្ររបស់ម្ចាស់ជំនួយ។ ការផ្សព្វផ្សាយកសិកម្មជាសាធារណៈមានសក្តានុពលសម្រាប់ផ្តល់ផលចំណូលខ្ពស់នៅកម្ពុជា។ គេមានឱកាសសម្រាប់បង្កើនចំណាយថវិកាយ៉ាងច្រើនរបស់រដ្ឋាភិបាល តាមរយៈការវិភាជន៍សាឡើងវិញពីផ្នែកដែលការចំណាយថវិកាមិនសូវមានប្រសិទ្ធភាព។ ទោះជាយ៉ាងណាក្តី រាល់ការបង្កើនចំណាយពីសំណាក់រដ្ឋាភិបាល និងពីម្ចាស់ជំនួយ គប្បីអមដោយការកែលំអមុខងារផ្នែកស្ថាប័ននៃប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតប្រព័ន្ធតាមដាន ដើម្បីវាស់ស្ទង់ប្រសិទ្ធភាពនៃចំណាយលើមុខងារទាំងនេះ។ ការធ្វើសុខុដុមភាវូបនីយកម្មបានកាន់តែប្រសើរនៃស្តង់ដារផ្តល់សេវារវាងអ្នកផ្តល់សេវាផ្សព្វផ្សាយនានា (រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន) និងការលុបបំបាត់សារនានាដែលធ្វើឱ្យយល់ខុសគ្នា ក៏ប្រាកដជាលើកកម្ពស់ប្រសិទ្ធភាពនៃចំណាយផ្សព្វផ្សាយសម្រាប់ទាំងអស់គ្នាផងដែរ។

- **មិនត្រូវបំភ្លេចការផ្តល់មូលនិធិចំពោះការស្រាវជ្រាវកសិកម្មឡើយ។** ការវិភាគប្រសិទ្ធភាពនៃការចំណាយលើស្រាវជ្រាវកសិកម្មនៅកម្ពុជា ជួបការលំបាកដោយសារកំហិតផ្នែកទិន្នន័យ ប៉ុន្តែភស្តុតាងអន្តរជាតិបង្ហាញថា ការស្រាវជ្រាវកសិកម្មអាចនាំមកនូវអត្រាផលចំណូលខ្ពស់ជាខ្លាំង។ ខណៈដែលការបង្កើនចំណាយសាធារណៈសម្រាប់ការស្រាវជ្រាវកសិកម្មមានហេតុផលត្រឹមត្រូវ នោះត្រូវមានការផ្លាស់ប្តូរផ្នែកស្ថាប័ន ដែលបញ្ជាក់មុខងារជាក់លាក់របស់ស្ថាប័នស្រាវជ្រាវនានារបស់ប្រទេស និងតាមរយៈការផ្តុំសមត្ថភាពមន្ទីរពិសោធន៍នៅតាមអង្គភាពនានារបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយការធ្វើការជាន់គ្នា និងខ្ជះខ្ជាយធនធាន។ គេអាចធ្វើដូច្នេះបាន ដោយបង្កើតប្រព័ន្ធកសាងផែនការ និងវាយតម្លៃរួមគ្នារវាងរដ្ឋាភិបាល ម្ចាស់ជំនួយ និងផ្នែកឯកជន ដើម្បីកំណត់តម្រូវការនៃការស្រាវជ្រាវ និងតម្រូវការធនធាន។ ជំនាញបច្ចេកទេសរបស់ម្ចាស់ជំនួយអាចមានមុខងារសំខាន់ក្នុងការកសាងសមត្ថភាពស្រាវជ្រាវនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ ការធ្វើសមាហរណកម្មកាន់តែប្រសើររវាងស្ថាប័នស្រាវជ្រាវកសិកម្មជាតិជាមួយសេវាផ្សព្វផ្សាយ អាចបង្កើនប្រសិទ្ធភាពចំណាយសាធារណៈបន្ថែមទៀតលើការស្រាវជ្រាវ ក៏ដូចជាលើការផ្សព្វផ្សាយកសិកម្ម។

- **ត្រៀមលក្ខណៈសម្រាប់ការប្រែប្រួលអាកាសធាតុ។** ទាក់ទងនឹងអនុសាសាន៍ពីរខាងលើ ប្រសិទ្ធភាពរយៈពេលវែងនៃចំណាយសាធារណៈចំពោះការផ្សព្វផ្សាយ និងការស្រាវជ្រាវ អាចត្រូវបានលើកកម្ពស់បន្ថែម ដោយផ្តោតការយកចិត្តទុកដាក់កិច្ចប្រឹងប្រែងស្រាវជ្រាវបន្ថែមអំពីការអភិវឌ្ឍពូជដំណាំថ្មីៗ និងការផ្សព្វផ្សាយចំណេះដឹងអំពីការកែលំអការស្តុកទឹក និងការរក្សាសំណើមនៅកម្រិតកសិដ្ឋាន - ពោល គឺការវិនិយោគ។ "ដែលមានការសោកស្តាយតិចតួច" ដែលគួបផ្សំការបង្កើនផលិតភាពកសិកម្មជាមួយការបន្សាំនឹងអាកាសធាតុ និងការកាត់បន្ថយឥទ្ធិពលអវិជ្ជមានពីការចុះថយរដូវដាំដុះដែលប្រែប្រួលកាន់តែខ្លាំង។

- **បង្កើនប្រសិទ្ធភាពនៃការវិនិយោគលើការស្រោចស្រព។** ការផ្តល់មូលនិធិសាធារណៈចំពោះគម្រោងស្រោចស្រពថ្មី និងគម្រោងស្រោចស្រពដែលធ្វើនីតិសម្បទា ចាំបាច់ត្រូវពង្រីកដល់ប្រឡាយរង និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ។ ការស្តារនីតិសម្បទាប្រឡាយជើងក្អែប ដោយប្រើមូលនិធិសាធារណៈក៏មានហេតុផលត្រឹមត្រូវផងដែរ ប្រសិនបើការធ្វើបែបនេះដាក់បញ្ចូលនូវការចាត់ចែងចំណាយប្រតិបត្តិការ និងថែទាំ ដោយយកថ្លៃពីអ្នកប្រើប្រាស់។ ជាមួយគ្នានេះផងដែរ ក៏ត្រូវមានភាពជ្រើសរើសបន្ថែមក្នុងការផ្តល់មូលនិធិចំពោះគម្រោងធារាសាស្ត្រនានា។

- **បង្កើនចំណែកថវិកាសម្រាប់ថែទាំប្រព័ន្ធស្រោចស្រព និងផ្លូវជនបទ។** ចំពោះករណីនៃប្រព័ន្ធស្រោចស្រពកម្រិតល្អបំផុតនៃចំណាយថែទាំ គប្បីស្មើ ៣៣ ភាគរយ នៃវិនិយោគសរុប ហើយនៅក្នុងវិស័យផ្លូវជនបទជាមធ្យមត្រូវការ ៤៥ ភាគរយ សម្រាប់ការថែទាំទៀងទាត់ និងជាប្រចាំរួមបញ្ចូលគ្នា។ កម្រិតនៃការថែទាំ គប្បីធ្វើយ៉ាងណាកុំឱ្យការស្តារនីតិសម្បទាធំៗលើកក្រោយត្រូវធ្វើមុនរយៈពេល ១០ ឆ្នាំ។

- **វិធានការរយៈពេលវែងមួយ ដើម្បីបង្កើនប្រសិទ្ធភាពនៃចំណាយលើផ្លូវជនបទ តម្រូវឱ្យមានការស្រាវជ្រាវពិនិត្យមើលលទ្ធភាពអនុវត្តដែលនាំមកនូវផលសេដ្ឋកិច្ចចំពោះការស្តារនីតិសម្បទាផ្លូវថ្នល់ និងបច្ចេកវិទ្យាថែទាំ។** បច្ចេកវិទ្យាថ្មីៗដែលត្រូវពិចារណា រួមមានការប្រើប្រាស់បេតុងឆ្អឹងឬស្សី (ចំពោះផ្លូវថ្នល់មមាញឹក) និងដីដែលបានកែច្នៃ។ រដ្ឋាភិបាលអាចវិនិយោគលើ ឬបង្កើតការលើកទឹកចិត្តចំពោះអ្នកឯទៀត ឱ្យវិនិយោគក្នុងការទាក់ទាញជំនាញក្នុងបច្ចេកវិទ្យាទាំងនេះ។

ចំណុចខ្សោយចម្បងមួយនៃចំណាយសាធារណៈនៅក្នុងក្រសួងពាក់ព័ន្ធទាំងបី គឺអវត្តមាននៃការសម្របសម្រួលរវាងគោល-នយោបាយ កម្មវិធី និងដំណើរការថវិកា។ ចំណុចខ្សោយនេះកាន់តែមានសភាពធ្ងន់ធ្ងរដោយសារមានកម្មវិធីត្រួតជាន់គ្នា និងការប៉ាន់ស្មានថវិកាដែលគ្មានលក្ខណៈប្រាកដនិយម ដោយមិនបានបញ្ជាក់អំពីប្រភពនានានៃការផ្តល់មូលនិធិ។

យើងរៀបចំអនុសាសន៍ខាងក្រោម ដើម្បីកែលំអការកសាងផែនការចំណាយ និងការគ្រប់គ្រងចំណាយរបស់រដ្ឋាភិបាល :

- **ប្រើផែនការយុទ្ធសាស្រ្តថវិកានានានៅក្នុងក្រសួងនីមួយៗ ធ្វើជាឧបករណ៍គោលនយោបាយ និងការកសាងថវិកាគន្លឹះសម្រាប់វិភាជន៍ និងគ្រប់គ្រងធនធានទាំងអស់ទៅកាន់វិស័យទាំងនេះ។** រដ្ឋាភិបាលគប្បីពិចារណាប្រើប្រាស់ផែនការយុទ្ធសាស្រ្តថវិកា ធ្វើជាស្នូលនៃឧបករណ៍កសាងផែនការសម្រាប់អនុវត្តយុទ្ធសាស្រ្តកសិកម្ម និងទឹក (SAW) ហើយអនុវត្តយុទ្ធសាស្រ្តផែនការថវិកាទាំងនោះសម្រាប់វិភាជន៍ថវិកា ដែលផ្តល់ហិរញ្ញប្បទានពីប្រភពក្នុងស្រុក និងវិភាជន៍ពីម្ចាស់ជំនួយ។

- **ពង្រឹងដំណើរការថវិកាប្រចាំឆ្នាំ ដោយតម្រូវឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទដើម្បីបែងចែកថវិកា "រឹង" និងអាចអនុវត្តបានទៅកាន់នាយកដ្ឋាននីមួយៗ តាមរយៈផែនការយុទ្ធសាស្រ្តថវិកានានា។** ប្រព័ន្ធថវិកាតាមកម្មវិធីមួយផ្នែកបច្ចុប្បន្ននេះ គប្បីដាក់បញ្ចូលទៅក្នុងអភិក្រមគ្រប់ជ្រុងជ្រោយនេះ។

- **ប្រើប្រព័ន្ធរតនាគារដើម្បីកត់ត្រាចំណាយលើមូលដ្ឋាននាយកដ្ឋាន។** ការណ៍នេះតម្រូវឱ្យមានការរាយការណ៍ហិរញ្ញវត្ថុ ដែលកាន់តែមានលក្ខណៈពេញលេញ (បច្ចុប្បន្នហៅថាទម្រង់ពង្រីកនៃ TOFE) និងការធ្វើប្រតិភូកម្មការទទួលខុសត្រូវកាន់តែច្រើនចំពោះចំណាយផ្សេងៗទៅឱ្យអង្គភាពថវិកា។

- **ណែនាំឱ្យធ្វើការពិនិត្យឡើងវិញប្រចាំឆ្នាំ និងណែនាំអំពីដំណើរការថវិកាចំពោះថវិកាប្រចាំឆ្នាំ និងរយៈពេលមធ្យម រាប់ទាំងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលចាត់ផែនការយុទ្ធសាស្រ្តថវិកាជាស្នូលនៃដំណើរការនេះ ហើយដាក់បញ្ចូលយុទ្ធសាស្រ្តកសិកម្ម និងទឹកទៅក្នុងការកសាងផែនការរបស់រដ្ឋាភិបាល។** ចំពោះចំណុចចុងក្រោយនេះនឹងតម្រូវឱ្យមានការសម្របសម្រួល និងសមាហរណកម្មរវាល់ឧបករណ៍កសាងផែនការថវិកា និងគ្រប់គ្រងថវិកា ដែលរដ្ឋាភិបាលបានបង្កើតក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល ម្ចាស់ជំនួយកំពុងរៀបចំដំណើរការឆ្ពោះទៅមុខ ហើយចំណុចនេះគប្បីអនុវត្តជាសកម្មភាពរួមគ្នារវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ។ គំនិតផ្តួចផ្តើមនៃយុទ្ធសាស្រ្តកសិកម្ម និងទឹក គឺជាឱកាស ដើម្បីបង្កើតប្រព័ន្ធវាយតម្លៃទៀងទាត់ និងផ្តល់ព័ត៌មាន តាមដាននិងវាយតម្លៃចំណាយ និងដើម្បីដាក់បញ្ចូលចំណុចទាំងនេះទៅក្នុងសេចក្តីសម្រេចចិត្តនៃការកសាងថវិកានាពេលអនាគត។

# ការបង្កើនសុខភាពចំពោះការចំណាយប្រាក់ ៤

## ក. សេចក្តីផ្តើម

**ក្នុងទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានធ្វើឱ្យប្រសើរឡើងនូវសុខភាពប្រជាជនគួរឱ្យកត់សំគាល់។** ទោះជាយ៉ាងណាក្តី ការឈានទៅសម្រេចបាននូវគោលដៅរបស់រដ្ឋាភិបាលអំពីការគ្របដណ្តប់សុខភាពសាកល តម្រូវឱ្យមានបង្កើនវិភាជន៍ចំណាយសុខាភិបាលទៅឱ្យផ្នែកមួយចំនួន។ ខណៈពេលដែលមានការលំបាកជារួមចំពោះកញ្ចប់សារពើពន្ធ ការបង្កើនចំណាយបែបនេះចាំបាច់ត្រូវអមដោយការធ្វើវិភាជន៍សាជាថ្មីក្នុងថវិកាសុខាភិបាលបច្ចុប្បន្នកែលំអ (Given overall constraints to the fiscal envelope, such increases need to be accommodated predominantly by reallocation within the existing health) ដោយយកចិត្តទុកដាក់លើប្រសិទ្ធភាព និងការលើកកម្ពស់គុណភាពនៃការចំណាយលើផ្នែកសុខាភិបាល។ ចាប់តាំងពីឆ្នាំ ២000 មក ចំណាយសរុបលើវិស័យសុខាភិបាលបានកើនឡើង ប៉ុន្តែប្រាក់ចំណាយពីហោប៉ៅផ្ទាល់ខ្លួននៅតែមានចំនួនច្រើន។ ចំណាយថែទាំសុខភាពអាចមានតំលៃខ្ពស់ជាខ្លាំង ដែលប្រការនេះជាបន្ទុកសម្រាប់ប្រជាជន ទោះមានប្រាក់ចំណូលតិច ឬច្រើនក្តី។ ចំណាយចរន្តរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាលក៏កើនឡើងផងដែរ បើគិតជាភាគរយនៃចំណាយសាធារណៈសរុប ប៉ុន្តែការវិភាជន៍ធនធានបន្ថែមណាមួយ រាប់ទាំងការបង្កើនប្រាក់ឈ្នួលផងដែរ នឹងអាស្រ័យលើលំហសារពើពន្ធដែលមាន។ ការបង្កើន និងការសម្រេចយកពន្ធថែទាំសុខភាពលើប្រាក់បៀវត្ស នឹងធ្វើឱ្យសកម្មភាពនៃវិស័យក្នុងប្រព័ន្ធចុះថយ ហេតុនេះការធ្វើបែបនេះពុំមែនជាជម្រើសសម្រាប់ផ្តល់អនុសាសន៍ ដើម្បីកៀរគរធនធានបន្ថែមនោះទេ។

**ការវិនិយោគលើសុខភាព និងអាហារូបត្ថម្ភមានសារៈសំខាន់សម្រាប់ពង្រឹងមូលធនមនុស្ស។** ដូចដែលបានពិភាក្សានៅក្នុងរបាយការណ៍នេះ ការបង្កើនលើតួលេខផែនការលើប្រភេទមួយចំនួននៃវិភាជន៍សុខាភិបាលអាចប្រព្រឹត្តិទៅបាន ប៉ុន្តែត្រូវអមដោយការលើកកម្ពស់ប្រសិទ្ធភាពនៃការចំណាយបច្ចុប្បន្ន ហើយយ៉ាងហោចណាស់ទទួលបានហិរញ្ញប្បទានរយៈពេលខ្លី ដល់រយៈពេលមធ្យមពីការសន្សំសំចៃដែលទទួលបាននៅក្នុងវិស័យនេះ។ ទីមួយ ប្រសិទ្ធភាពនៃចំណាយអាចត្រូវបានលើកកម្ពស់តាមរយៈការទិញបានកាន់តែល្អប្រសើរពិសេស គឺឱសថ បរិក្ខារពេទ្យ និងសម្ភារៈផ្សេងៗ។ ទីពីរ វិភាជន៍ថវិកាចំពោះនាយកដ្ឋាន មន្ទីរពេទ្យនានានៅថ្នាក់កណ្តាល និងចំពោះបណ្តាខេត្តនានា គប្បីផ្អែកលើរូបមន្តដែលមានតម្លាភាព និងផ្អែកលើលទ្ធផលដែលបានឯកភាពគ្នាច្បាស់លាស់ ព្រមទាំងគប្បីពង្រឹងយន្តការនានាសម្រាប់រៀបចំថវិកា និងការតាមដានចំណាយនៅស្រុកប្រតិបត្តិ និងនៅតាមមន្ទីរពេទ្យនានា។ ទីបី គំនិតផ្តួចផ្តើមអំពីហិរញ្ញប្បទានបច្ចុប្បន្ន រួមមាន មូលនិធិសមធមិសុខភាព ការចុះកិច្ចសន្យាលើមូលដ្ឋាននៃលទ្ធផលអនុវត្តសម្រាប់ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យ និងការលើកទឹកចិត្តឆ្មប គប្បីបង្កើនដាក់បញ្ចូលទៅក្នុងស្ថាប័នជាតិនិងថវិកាជាតិ។ ទីបួន ការប្តូរទៅកាន់ការរៀបចំផ្តល់សេវាពាក់កណ្តាលស្វយ័តសម្រាប់មន្ទីរពេទ្យ និងស្រុកប្រតិបត្តិមួយចំនួន ត្រូវមានវិធានការដាក់កំហិតចំពោះការបង្កើនថ្លៃសេវា និងបង្កើតកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន ដើម្បីធានាឱ្យមានគុណភាព និងធ្វើឱ្យពលរដ្ឋក្រីក្រ និងពលរដ្ឋដែលមានជីវភាពស្ទើរក្រីក្រអាចទទួលបានសេវាជាបន្ត។ ទីប្រាំ ចាំបាច់ត្រូវពង្រឹងការគ្រប់គ្រង និងការតាមដានលទ្ធផលអនុវត្តន៍។ ចុងបញ្ចប់ ខណៈពេលដែលផ្នែកឯកជនមាន និងគ្មានអាជ្ញាបណ្ណ នៅតែជាប្រភពសំខាន់នៃការថែទាំសុខភាព រដ្ឋាភិបាលគប្បីពង្រឹងការគ្រប់គ្រងលើការពិនិត្យព្យាបាលឯកជន និងលើឱសថស្ថាននានា និងដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិសមស្របចំពោះការផ្តល់សេវាទាំងពីរប្រភេទនេះ។

**ផ្នែកផ្សេងទៀតនៃជំពូកនេះត្រូវបានរៀបចំដូចតទៅ។** ផ្នែក ខ ពិភាក្សាត្រួសៗអំពីវិស័យសុខាភិបាលនៅកម្ពុជា។ ផ្នែក គ ពិនិត្យឡើងវិញអំពីនិន្នាការ និងសមាសភាពនៃចំណាយសុខាភិបាល។ ផ្នែក ឃ ពិភាក្សាអំពីប្រសិទ្ធភាព និងសមធមិនៃចំណាយសុខាភិបាលនៅកម្ពុជា។ ផ្នែក ង ផ្តល់អនុសាសន៍។

# ២. វិស័យសុខាភិបាលនៅកម្ពុជា

**សុខាភិបាល គឺជាវិស័យអាទិភាពមួយសម្រាប់រដ្ឋាភិបាល ដូចមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ។** អន្តរាគមន៍នានាដែលទ្រទ្រង់យុទ្ធសាស្ត្រនេះ រួមមាន ការកសាងមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ព្រមទាំងការផ្តល់ការថែទាំសុខភាពដោយមិនយកប្រាក់ចំពោះពលរដ្ឋក្រីក្រ និងបន្តកម្មវិធីបង្ការ និងព្យាបាលជំងឺឆ្លងនានា។ អន្តរាគមន៍ដទៃទៀត រួមមាន លើកកម្ពស់សុខភាពមាតា និងកុមារ ព្រមទាំងអនុម័ត និងអនុវត្តច្បាប់ និងបទប្បញ្ញត្តិសុខាភិបាលនានា ដើម្បីធានាគុណភាព និងសុវត្ថិភាពនៃសេវាសុខាភិបាល ឱសថ និងម្ហូបអាហារ។ សេចក្តីប្រកាសគោលនយោបាយនៃយុទ្ធសាស្ត្រនេះ មានចែងលម្អិតនៅក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទីពីរ (HSP2) ពីឆ្នាំ ២០០៨-២០១៥។ ផែនការនេះផ្តោតលើការអភិវឌ្ឍប្រព័ន្ធសុខាភិបាល ដើម្បីលើកកម្ពស់លទ្ធផលសុខាភិបាល និងបានបង្កើតយុទ្ធសាស្ត្រទូទាំងវិស័យចំនួនប្រាំ ដើម្បីសម្រេចគោលដៅទាំងនេះ ៖ (១) ការផ្តល់សេវាសុខភាព (២) ការផ្តល់ហិរញ្ញប្បទានសុខាភិបាល (៣) ធនធានមនុស្សសម្រាប់សុខាភិបាល (៤) ប្រព័ន្ធព័ត៌មានសុខាភិបាល និងទី (៥) អភិបាលកិច្ចប្រព័ន្ធសុខាភិបាល។ យុទ្ធសាស្ត្រ និងគោលនយោបាយជាតិស្តីពីហិរញ្ញប្បទានសុខាភិបាល មានបញ្ជាក់បន្ថែមនៅក្នុងធម្មនុញ្ញជាតិស្តីពីហិរញ្ញប្បទានសុខាភិបាល (១៩៩៦) និងក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ហិរញ្ញប្បទានសុខាភិបាល (២០០៨-២០១៥)។

**កម្ពុជាកំពុងអនុវត្តត្រឹមត្រូវក្នុងការឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្ស ប៉ុន្តែនៅមានបញ្ហាប្រឈមអំពីអាហារូបត្ថម្ភកុមារ និងការស្លាប់ទារកទើបកើត។** អាយុមធ្យមជារួមបានកើនពី ៥២ ឆ្នាំ ទៅ ៦៣ ឆ្នាំ នៅឆ្នាំ ២០០៨ សម្រាប់បុរស និងកើនពី ៥៦ ឆ្នាំ ដល់ ៦៧ ឆ្នាំ សម្រាប់ស្ត្រីក្នុងរយៈពេលដូចគ្នា (តារាង ១៤)។ ទាំងការស្លាប់របស់ទារក និងកុមារអាយុក្រោម ៥ ឆ្នាំ បានធ្លាក់ចុះចាប់តាំងពីឆ្នាំ ២០០៥ មួយផ្នែកធំ គឺដោយសារស្ថានភាពសង្គមសេដ្ឋកិច្ចត្រូវបានលើកកម្ពស់ ការចាក់ថ្នាំបង្ការមានវិសាលភាពកាន់តែធំ និងមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការថែទាំព្យាបាល (រូបលេខ ២៥)។ ទោះជាយ៉ាងណាក្តី វឌ្ឍនភាពទូទៅនេះបិតបាំងភាពខុសគ្នាជាខ្លាំងរវាងប្រជាជន និងប្រជាជន។ ឧទាហរណ៍ ការស្លាប់របស់កុមារនៅឆ្នាំ ២០០៥ មានចំនួនបីដងខ្ពស់ជាងចំពោះប្រជាជនកម្ពុជា ដែលមកពីបញ្ចូភាគអ្នកមានទ្រព្យសម្បត្តិតិចបំផុត អ្នកដែលមានធនធានច្រើនបំផុត (CDHS ២០០៥)។

**តារាងលេខ ១៤ ៖ កម្ពុជាកំពុងដើរតាមផ្លូវត្រូវក្នុងការឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សផ្នែកសុខាភិបាលជាច្រើន**

| គោលដៅ | ការវាស់ស្ទង់ | ២០០០ DHS | ២០០៥ DHS | ២០១៥ target | ២០១០ target | ទិន្នន័យថ្មីៗ | ការវាយតម្លៃ |
|---|---|---|---|---|---|---|---|
| កាត់បន្ថយការស្លាប់របស់កុមារ | អត្រាស្លាប់របស់កុមារអាយុតិចជាង ៥ ឆ្នាំ ក្នុង ១.០០០ កំណើតរស់ | ១២៤ | ៨៣ | ៦៥ | ៨៥ | ៥៤ (២០១០) | ដើរតាមផ្លូវត្រូវ |
| | កុមារអាយុតិចជាង ១ ឆ្នាំ បានចាក់ថ្នាំការពារកញ្ជ្រឹល | ៤១ | ៧០ | ៩០ | ៨៥ | ៩១ (២០០៨) | ដើរតាមផ្លូវត្រូវ |
| លើកកម្ពស់សុខភាពមាតា | អត្រាស្លាប់មាតា ក្នុង ១០០.០០០ កំណើតរស់ | ៤៣៧ | ៤៧២ | ២៥០ (ផយអជ បច្ចុប្បន្នកម្ម) | ៣៥០ (ផយអជ បច្ចុប្បន្នកម្ម) | ២០៦ (CDHS ២០១០) | ដើរតាមផ្លូវត្រូវ |
| ប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺដទៃទៀត | ប្រេវ៉ាឡង់បេកាវិជ្ជមានក្នុងទឹកមាត់ក្នុងប្រជាជន ១០០.០០០ នាក់ | - | - | ១៣៥ | ២១៤ | ៦៩៣ (២០០៩) | ដើរខុសផ្លូវ |
| | អ្នកផ្ទុកមេរោគអេដស៍ដែលមានអាយុចាប់ពី ១៥-៤៩ ឆ្នាំ | - | ០,៦ ភាគរយ | ១,៨០ ភាគរយ | ២,០០ ភាគរយ | ០,៧ ភាគរយ (២០០៨) | ដើរតាមផ្លូវត្រូវ (សម្រេចបាន) |
| | អត្រាស្លាប់ដោយសារករណីគ្រុនចាញ់ធ្ងន់ធ្ងរ | - | - | ០,១០ ភាគរយ | ០,២៥ ភាគរយ | ០,៣៥ ភាគរយ (២០០៩) | ដើរខុសផ្លូវ |

*ប្រភព ៖* CDHS, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, UNDP ប្រព័ន្ធព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាល
*កំណត់សំគាល់ ៖* ទិន្នន័យបឋមរបស់ CDHS ឆ្នាំ ២០១០

**អត្រាខ្ពស់នៃកង្វះអាហារូបត្ថម្ភកុមារចោទជាហានិភ័យចំពោះការអភិវឌ្ឍសេដ្ឋកិច្ចរយៈពេលវែងរបស់កម្ពុជា។** កង្វះអាហារូបត្ថម្ភនៅតែកើតមាន ដោយសាររបៀបផ្តល់អាហារដល់កូន ខ្វះទឹកប្រើប្រាស់ និងមិនសូវមានអនាម័យ អសន្តិសុខស្បៀង និងខ្វះលទ្ធភាពក្នុងការទទួលបានការថែទាំ និងព្យាបាលចំពោះកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។ ជំងឺក្រេះចំពោះកុមារអាយុតិចជាង ៥ ឆ្នាំ បានធ្លាក់ចុះពី ៤៩ ភាគរយនៅឆ្នាំ ២០០០ ដល់ ៤០ ភាគរយនៅ ឆ្នាំ ២០១០ ប៉ុន្តែភាគរយនៃកុមារដែលមានទម្ងន់មិនគ្រប់មានការប្រែប្រួលតិចតួចក្នុងអំឡុងឆ្នាំ ២០០៥-២០១០ ក្នុងកម្រិត ២៨ ភាគរយ ខណៈដែលការលូតលាស់យឺតបានកើនពី ៨ ទៅ ១១ ភាគរយ (រូបលេខ ២៦)។ កង្វះអាហារូបត្ថម្ភមានកម្រិតខ្ពស់ក្នុងចំណោមបញ្ចភាគប្រាក់ចំណូលនានា ចំណែកឯសភាពស្គមស្គាំងមានកម្រិតខ្ពស់ជាងគេក្នុងចំណោមពលរដ្ឋក្រីក្រនៅទីប្រជុំជន។ កង្វះអាហារូបត្ថម្ភចំពោះកុមារ កាត់បន្ថយការរីកចម្រើន សមត្ថភាពយល់ដឹង និងកាត់បន្ថយផលិតភាពរបស់មនុស្សពេញវ័យ។ មូលហេតុ និងផលវិបាកនៃកង្វះអាហារូបត្ថម្ភ មានចរិតពហុវិស័យ ហេតុនេះតម្រូវឱ្យមានការឆ្លើយតបរបស់រដ្ឋាភិបាលដែលមានការសម្របសម្រួល (ក្រសួងសុខាភិបាល ឆ្នាំ ២០០៨)។

**ការស្លាប់របស់មាតាបានចុះថយ និងស្ថិតលើផ្លូវត្រូវក្នុងការឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្ស មួយផ្នែក គឺដោយសារការកើនឡើងយ៉ាងខ្លាំងនូវការគ្របដណ្តប់ និងការប្រើប្រាស់សេវាសុខភាពមាតា ប៉ុន្តែការស្លាប់នៅមានកម្រិតខ្ពស់នៅឡើយ។** អត្រាស្លាប់របស់មាតាត្រូវបានប៉ាន់ស្មានថាចំនួន ៤៧២ នាក់ ក្នុង ១០០.០០០ កំណើតរស់ នៅឆ្នាំ ២០០៥ និងបានធ្លាក់ចុះមកប្រមាណជា ២០៦ នាក់ ក្នុង ១០០.០០០ កំណើតរស់ នៅឆ្នាំ ២០១០ (CDHS ឆ្នាំ ២០១០)។ អត្រាមានកូនបានធ្លាក់ចុះពី ៤,៩ នៅឆ្នាំ ១៩៩៥ មកត្រឹម ២,៩ នៅឆ្នាំ ២០០៩ ខណៈពេលដែលការប្រើវិធីការពារកុំឱ្យមានកូនបានកើនឡើងជាបណ្តើរៗដល់ ៣៥ ភាគរយ នៅឆ្នាំ ២០១០ ទាបជាងផែនការ ផយអជ ដែលបានកំណត់ ៤០ ភាគរយសម្រាប់ឆ្នាំ ២០១០។ ការសម្រាលកូននៅតាមមន្ទីរពេទ្យរដ្ឋបានកើនឡើងជាខ្លាំងពី ២២ ភាគរយ នៃចំនួនសម្រាលកូនសរុបនៅឆ្នាំ ២០០៥ ដល់ ៥៤ ភាគរយ នៅឆ្នាំ ២០១០ (រូបលេខ ២៧)។ ទោះជាយ៉ាងណាក្តី គុណភាពនៃការថែទាំសុខភាពមាតានៅតែជាកង្វល់មួយទាំងក្នុងវិស័យសាធារណៈ និងក្នុងផ្នែកឯកជន។ លទ្ធភាពបានទទួលការថែទាំសង្គ្រោះបន្ទាន់ផ្នែកសម្រាលកូនក៏មានកម្រិតទាប ជាពិសេសនៅតំបន់ជនបទ ដោយសារខ្វះបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាល និងខ្វះបរិក្ខារសម្រាប់ដោះស្រាយចំពោះករណីសម្រាលកូនដែលមានការលំបាក ឬសម្រាប់ការវះយកកូនចេញ។

**រូបលេខ ២៥. ការស្លាប់របស់ទារក និងកុមារបានធ្លាក់ចុះជាខ្លាំង ប៉ុន្តែការស្លាប់របស់ទារកទើបកើតធ្លាក់ចុះតិចតួចប៉ុណ្ណោះ**
(ស្លាប់ក្នុងមួយពាន់កំណើត)




*ប្រភព* : អង្កេត CDHS ឆ្នាំ ២០០០-២០០៥-២០១០

**រូបលេខ ២៦. កង្វះអាហារូបត្ថម្ភនៅតែមានកម្រិតខ្ពស់**
(ជាភាគរយ)




*ប្រភព* : អង្កេត CDHS ឆ្នាំ ២០០៥

រូបលេខ ២៧. ចំនួនមន្ទីរសម្ភពបានកើនឡើងយ៉ាងច្រើនជាមួយនឹងកំណើនយឺតចំពោះការបង្ការការមានកូន

(ជាភាគរយ)




*ប្រភព :* អង្កេត CDHS ឆ្នាំ ២០០០-២០០៥-២០១០

រូបលេខ ២៨. អ្នកផ្តល់សេវាឯកជនត្រូវបានពិគ្រោះជំងឺញឹកញាប់ចំពោះការថែទាំព្យាបាល

(គិតជា ភាគរយ)




*ប្រភព :* អង្កេត CSES ឆ្នាំ ២០០៧

**ទោះបីជាមានការរីកចម្រើនជាបណ្តើរៗក្នុងការកាត់បន្ថយអត្រារាំងស៊ីងដំនែជំងឺ និងអត្រាស្លាប់ក្តី កម្ពុជាប្រឈមមុខនឹងបន្ទុកពីរ ទាំងជំងឺឆ្លង និងជំងឺមិនឆ្លង។** កម្ពុជា គឺជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសនានា ដែលរងគ្រោះធ្ងន់ធ្ងរបំផុតពីការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍នៅក្នុងតំបន់ដែលមនុស្សពេញវ័យ ០,៧ ភាគរយ បានរងគ្រោះ។ បន្ទុកនៃជំងឺមិនឆ្លងមានទំហំធំជាងជំងឺឆ្លងរួចទៅហើយ។ យោងតាមអង្គការសុខភាពពិភពលោកនៅកម្ពុជានាឆ្នាំ ២០០៤ មានមនុស្សស្លាប់ចំនួន ៨៣២ នាក់ ក្នុងចំណោមប្រជាជន ១០០.០០០ នាក់ ដោយសារជំងឺមិនឆ្លង និង ៦៦០ នាក់ ចំពោះជំងឺឆ្លង។ មនុស្សពេញវ័យម្ភៃភាគរយនៅក្នុងបញ្ចភាគបីដែលក្រីក្របំផុតនិយាយថា ពួកគេជក់បារីប្រចាំថ្ងៃ ធៀបនឹងមនុស្សពេញវ័យនៅក្នុងបញ្ចភាគដែលមានជីវភាពធូរធារបំផុត ដែលមានមនុស្សជក់បារីត្រឹមតែ ១១ ភាគរយប៉ុណ្ណោះ (CSES ២០០៧)។ ការបង្កើនពន្ធលើថ្នាំជក់យ៉ាងខ្ពស់ នឹងអាចជួយកាត់បន្ថយមនុស្សជក់បារី ជាពិសេសគឺពលរដ្ឋក្រីក្រដែលការជក់បារីកើតមានជាទូទៅ-និងបង្កើនចំណូលបន្ថែម។

**ការប្រើប្រាស់ការថែទាំព្យាបាលបានកើនឡើងទាំងក្នុងវិស័យសាធារណៈ និងទាំងក្នុងផ្នែកឯកជន ប៉ុន្តែប្រជាជនកម្ពុជាចូលចិត្តទៅរកសេវាឯកជន។** ប្រមាណជាពីរភាគបីនៃសេវាថែទាំចាំបាច់ (រាប់ទាំងការថែទាំដោយខ្លួនឯងផងដែរ) ប្រព្រឹត្តិទៅនៅក្នុងផ្នែកឯកជន។ ខណៈដែលអត្រាពិគ្រោះជំងឺអ្នកជំងឺក្រៅក្នុងវិស័យសាធារណៈបានកើនឡើង ការប្រើប្រាស់ផ្នែកឯកជន ទាំងមាន និងគ្មានលិខិតអនុញ្ញាត បានកើនឡើងលឿនជាង។ នៅតំបន់ទីក្រុង ប្រភពចម្បងនៃការថែទាំ គឺឱសថស្ថានឯកជន គ្លីនិកឯកជន ផ្ទះលក់ថ្នាំពេទ្យដែលគ្មានលិខិតអនុញ្ញាត និងមន្ទីរពេទ្យជាតិ។ ការទៅពិនិត្យជំងឺដល់ផ្ទះអ្នកផ្តល់សេវា និងការប្រើប្រាស់ផ្ទះលក់ថ្នាំ ពេទ្យដែលគ្មានលិខិតអនុញ្ញាត បានធ្លាក់ចុះក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។ នៅតំបន់ជនបទ ផ្ទះលក់ថ្នាំពេទ្យដែលគ្មានលិខិតអនុញ្ញាត ការទៅពិនិត្យជំងឺដល់ផ្ទះបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាល និងឱសថស្ថានឯកជន គឺជាប្រភពដែលគេនិយមទៅទទួលសេវាថែទាំ (CSES ឆ្នាំ ២០០៤ និង ២០០៩)។

**ការផ្តល់ការថែទាំសុខភាពផ្នែកឯកជនបានរីកចម្រើនយ៉ាងឆាប់រហ័សចាប់តាំងពីត្រូវបានទទួលស្គាល់ដោយច្បាប់នៅឆ្នាំ ១៩៩៣ មក។** ការផ្តល់សេវាសុខភាពឯកជន រួមមាន មន្ទីរពេទ្យ និងគ្លីនិកឯកជន អ្នកប្រកបវិជ្ជាជីវៈបុគ្គល (មាន និងគ្មានលិខិតអនុញ្ញាត) និងអ្នកលក់ថ្នាំពេទ្យ ព្រមទាំងឱសថស្ថាននានា (មាន និងគ្មានលិខិតអនុញ្ញាត)។ ទិន្នន័យផ្លូវការទំនងជាប៉ាន់ស្មានមន្ទីរពេទ្យ និងអ្នកប្រកបវិជ្ជាជីវៈពេទ្យជាក់ស្តែង មិនគ្រប់ចំនួន។ ក្រសួងសុខាភិបាលបានរាប់ឃើញមន្ទីរពេទ្យ គ្លីនិក និងពហុគ្លីនិកឯកជនចំនួន ១៦៩ កន្លែង នៅឆ្នាំ ២០០៩ មានគ្រែសម្រាប់អ្នកជំងឺសម្រាកព្យាបាលចំនួន ៧៥៨។ មានរបាយការណ៍ដែលបានឱ្យដឹងថាមាន "បន្ទប់ពិនិត្យជំងឺ" ឯកជនចំនួន ២.៣០០ ក្នុងនោះ ៨០ ភាគរយបានចុះបញ្ជី។ នៅភ្នំពេញមានមន្ទីរពេទ្យស្វែងរកប្រាក់ចំណេញធំៗ ចំនួនពីរ និងមួយទៀតនៅខេត្តសៀមរាប។ ការបណ្តុះបណ្តាលសុខភាពចំពោះផ្នែកឯកជន បានរីកចម្រើនចាប់តាំងពីការបង្កើតសាកលវិទ្យាល័យអន្តរជាតិនៅភ្នំពេញ នៅឆ្នាំ ២០០២។ ក្រសួងសុខាភិបាលកំពុងបង្កើតនីតិវិធីផ្តល់អាជ្ញាប័ណ្ណសម្រាប់អ្នកប្រកបវិជ្ជាជីវៈពេទ្យលក្ខណៈបុគ្គលដោយធ្វើការជាមួយក្រុមប្រឹក្សាវិជ្ជាជីវៈនានានៅកម្ពុជា។

**ក្រសួងសុខាភិបាលកំពុងចាត់វិធានការដើម្បីពង្រឹងការគ្រប់គ្រងផ្នែកឯកជន ប៉ុន្តែទំនាស់ផលប្រយោជន៍ដែលបណ្តាលមកពីការធ្វើការរដ្ឋផង និងផ្តល់សេវាសុខភាពឯកជនផងនៅតែជាបញ្ហាប្រឈមមួយ ហើយការគ្រប់គ្រងឱសថស្ថានឯកជន ចាំបាច់ត្រូវពង្រឹងបន្ថែមទៀត។ ក្រសួងសុខាភិបាលផ្តោតការយកចិត្តទុកដាក់លើការកែលំអស្ថិតិសុខភាពក្នុងផ្នែកឯកជន។** គេនៅតែពុំឃើញមានបទប្បញ្ញត្តិអំពីថ្លៃ ឬគុណភាពនៃការថែទាំសុខភាពក្នុងផ្នែកឯកជននៅឡើយទេ។ ការបម្រើការរដ្ឋផង និងការផ្តល់សេវាសុខភាពឯកជនផង ត្រូវបានអនុគ្រោះ ប៉ុន្តែមិនត្រូវបានគ្រប់គ្រងឡើយ ឬមិនតម្រូវឱ្យអនុវត្តតាមក្រមសីលធម៌ច្បាស់លាស់ឡើយ។ ទីផ្សារឱសថបានរីកចម្រើនយ៉ាងឆាប់រហ័សចាប់តាំងពីការនាំចូលត្រូវបានទទួលស្គាល់ស្របច្បាប់នៅឆ្នាំ ១៩៩៣ មក។ យោងតាមក្រសួងសុខាភិបាល ឱសថស្ថានចំនួន ៧៩៧ និងហាងលក់ថ្នាំពេទ្យ ១.១១១ កន្លែងគ្មានលិខិតអនុញ្ញាតនៅកម្ពុជា នៅឆ្នាំ ២០០៩។ ចំនួនអ្នកលក់រាយថ្នាំពេទ្យដែលគ្មានលិខិតអនុញ្ញាតត្រូវបានកាត់បន្ថយតាមរយៈការលើកកម្ពស់ការគ្រប់គ្រង ប៉ុន្តែនៅតែមានចំនួនច្រើន។ ការិយាល័យឱសថសាវន្តជាការិយាល័យទទួលបន្ទុកគ្រប់គ្រងផ្នែកឯកជន រាប់ទាំងការដោះស្រាយបញ្ហាការក្លែងថ្នាំពេទ្យ។ ទោះជាយ៉ាងណាក្តី ការិយាល័យនេះគ្មានបុគ្គលិកគ្រប់គ្រាន់ ដើម្បីធ្វើតេស្តថ្នាំពេទ្យ និងគ្មានអំណាចដកហូតទំនិញក្លែងក្លាយ ឬដាក់ទោសជនជួញដូរថ្នាំពេទ្យដោយខុសច្បាប់ឡើយ។

# គ. និន្នាការ និងសមាសភាគនៃចំណាយសុខាភិបាល

**ចំណាយសុខាភិបាលមានចំនួនត្រឹមតែមួយភាគប្រាំនៃចំណាយសុខាភិបាលសរុបរួមនៅកម្ពុជាតែប៉ុណ្ណោះ ប៉ុន្តែគិតជាភាគរយនៃ ផសស មានលក្ខណៈដូចគ្នាជាទូទៅជាមួយបណ្តាប្រទេស ដែលមានប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់ៗប្រហាក់ប្រហែលគ្នា។** ចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាលបានកើនឡើងប្រហែល ០,៨ ភាគរយ នៃ ផសស នៅឆ្នាំ ២០០០ ដល់ ១,១ ភាគរយ នៅឆ្នាំ ២០០៩ និងបានកើនឡើងថែមទៀតដល់ ១,៤ ភាគរយ នៃ ផសស នៅឆ្នាំ ២០១០។ ការគាំទ្រពីបរទេសចំពោះវិស័យសុខាភិបាល ក៏កើនឡើងឆាប់រហ័សក្នុងទសវត្សរ៍កន្លងទៅ និងនៅតែច្រើនជាងចំណាយរបស់រដ្ឋាភិបាល (រូបលេខ ២៩ និង ៣០)[២៣]។ ជាចំណែកមួយនៃចំណាយរួមរបស់រដ្ឋាភិបាលចំណាយលើវិស័យសុខាភិបាលបានកើនឡើងលើស ១១ ភាគរយ នៅឆ្នាំ ២០០៩ លើសកម្រិតមធ្យមក្នុងតំបន់ ប៉ុន្តែទាបជាងផែនការរបស់ ផយអជ ដែលបានកំណត់ ១៣ ភាគរយ។

**ចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាលនៅតែមានលក្ខណៈប្រមូលផ្តុំ។** ក្រសួងសុខាភិបាលគ្រប់គ្រងប្រហែល ៧០ ភាគរយ នៃចំណាយ ទោះបីជារដ្ឋាភិបាលមានចេតនាធ្វើវិមជ្ឈការចំណាយក្តី។ ចំណាយភាគច្រើនក្រៅពីនេះលើវិស័យសុខាភិបាល ត្រូវបានប្រគល់ឱ្យអភិបាលខេត្តដែលគ្រប់គ្រងការចំណាយ និងបុរេប្រទានសាច់ប្រាក់ក្នុងនាមមន្ទីរពេទ្យ-ថវិកាសុខាភិបាលខេត្តប្រមាណជា ៧០ ភាគរយ ចំណាយលើទឹក-ភ្លើង ប្រេងឥន្ធនៈ និងការចំណាយផ្សេងទៀតរបស់មន្ទីរពេទ្យ។ នៅក្រោមថ្នាក់ខេត្ត ព័ត៌មានស្តីពីមុខចំណាយ ឬអំពីតម្លៃជាក់ស្តែងនៃទំនិញ ដែលបានបែងចែកទៅកាន់មណ្ឌលសុខភាពមានតិចតួចប៉ុណ្ណោះ។ ហេតុនេះអង្កេតតាមដានចំណាយសាធារណៈលើវិស័យសុខាភិបាល បានលើកឡើងនូវកង្វល់អំពីសមាមាត្រនៃចំណាយសុខាភិបាលក្នុងការសម្រេចបាននូវកម្រិតនៃការផ្តល់សេវា (ធនាគារពិភពលោកឆ្នាំ ២០០៨)។ ក្រសួងសុខាភិបាលបានព្យាយាមកែលំអការរាយការណ៍អំពីចំណាយ ហើយកាលពីពេលថ្មីៗកន្លងទៅបានប៉ាន់ស្មានថា ការិយាល័យមន្ទីរសុខាភិបាលខេត្ត (PHDO) មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកខេត្ត និងស្រុកនីមួយៗទទួលវិភាជន៍ខេត្តប្រហែលមួយភាគបី។ គេពុំឃើញមានទិន្នន័យស្តីពីចំណាយវិនិយោគនៅឡើយទេ។

---

*២៣ តួលេខប៉ាន់ស្មានអំពីចំណាយសុខាភិបាលសរុប និងភាគរយនៃចំណាយប្រាក់ចេញពីហោប៉ៅផ្ទាល់ខ្លួនប្រែប្រួល ដោយសារការប៉ាន់ស្មានខុសៗគ្នាអំពីតួលេខចំណាយប្រាក់ចេញពីហោប៉ៅផ្ទាល់ខ្លួន (ភាគច្រើនផ្អែកលើទិន្នន័យ CDHS ឆ្នាំ ២០០៥) និងប្រភពទិន្នន័យផ្សេងគ្នាចំពោះហិរញ្ញប្បទានបរទេស។ នៅពេលដែលមានទិន្នន័យ CDHS ឆ្នាំ ២០១០ នោះនឹងអាចធ្វើបច្ចុប្បន្នកម្មតួលេខប៉ាន់ស្មានទាំងនេះ។*

**រូបលេខ ២៩. ចំណាយរដ្ឋាភិបាលបានកើនឡើងយ៉ាងខ្ពស់លើទឹកប្រាក់ចំណាយជាក់ស្តែង...**
(គិតជា ពាន់ដុល្លារអាមេរិក-ឆ្នាំ ២០០០-២០០៩)




*ប្រភព :* របាយការណ៍ប្រសិទ្ធភាពជំនួយរបស់ កអក និង កហវ ឆ្នាំ ២០១០

**រូបលេខ ៣០. ...និងកើនឡើងគិតជាភាគរយនៃ ផសស និងចំណាយសរុបរបស់រដ្ឋាភិបាល**
(គិតជា ភាគរយ និងភាគរយនៃ ផសស)




*ប្រភព :* កហវ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**រដ្ឋាភិបាលចំណាយខ្ពស់លើឱសថ និងបរិក្ខារពេទ្យ និងច្រើនជាងចំណាយប្រាក់ខែពីរដង។** ចំណាយសាធារណៈលើឱសថបានកើនលើសចំណាយមធ្យមអន្តរជាតិជាខ្លាំង។ ចំណាយលើឱសថមានចំនួនលើសបីដងធៀបនឹងទឹកប្រាក់ចំណាយដែលត្រូវចំណាយចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩ គឺកើនពី ៤០ ភាគរយ នៃថវិកាសុខាភិបាលនៅឆ្នាំ ២០០៤ ដល់ ៤៦ ភាគរយ នៅឆ្នាំ ២០០៩ (Pharmaceutical spending more than tripled in nominal terms from 2004 to 2009) (រូបលេខ ៣១)។ ចំណាយប្រតិបត្តិការថវិកាភាគច្រើន គឺសម្រាប់ទិញបរិក្ខារ និងសម្ភារៈមិនមែនវេជ្ជសាស្ត្រនៅថ្នាក់កណ្តាល និងនៅថ្នាក់ក្រោមជាតិ ដែលជិត ៦០ ភាគរយនៃថវិកាសុខាភិបាលសរុបត្រូវបានចំណាយលើលទ្ធកម្ម។ ប្រាក់កម្រៃ និងបៀវត្ស រាប់ទាំងប្រាក់ឧបត្ថម្ភផងដែរ បានកើនឡើងយ៉ាងឆាប់រហ័សពីកម្រិតទាបចំនួន ១៣ ភាគរយ នៃចំណាយសុខាភិបាលនៅឆ្នាំ ២០០៤ ដល់ ២០ ភាគរយ នៅឆ្នាំ ២០០៩។

**រូបលេខ ៣១. ចំណាយលើឱសថ និងបរិក្ខារពេទ្យមានចំនួនច្រើនជាងពីរដងនៃចំណាយលើប្រាក់កម្រៃ**
(គិតជា លានដុល្លារអាមេរិក)




*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**រូបលេខ ៣២. ថវិកាភាគច្រើនពុំមែនជាថវិកាកម្មវិធី**
(គិតជាភាគរយចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាល)




*ប្រភព :* ផែនការប្រតិបត្តិការប្រចាំឆ្នាំ (ផែនការប្រតិបត្តិប្រចាំឆ្នាំ) ក្រសួងសុខាភិបាល ២០០៩។

**ប្រហែលមួយភាគបីនៃចំណាយសរុបរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាល ត្រូវបានវិភាជន៍ទៅកាន់កម្មវិធីជាក់លាក់ ហើយបន្តមានភាពមិនស៊ីគ្នារវាងអាទិភាពជាតិ និងវិភាជន៍កម្មវិធីដែលបានកំណត់។** គោលដៅសុខាភិបាលទាំងបី និងយុទ្ធសាស្ត្រទូទាំងវិស័យចំនួនប្រាំនៃ HSP2 ត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការនៃការកសាងផែនការ និងរៀបចំថវិកាប្រចាំឆ្នាំ ប៉ុន្តែវិភាជន៍ទាំងនោះនៅមានកម្រិត

(រូបលេខ ៣២)។ សកម្មភាពដទៃទៀតដែលបានគ្រោងថវិកា ត្រូវបានបូកបញ្ចូលគ្នាជា "សកម្មភាពមិនមែនកម្មវិធី" និងរួមមានមុខចំណាយ ដែលត្រូវបានគ្រប់គ្រងនៅថ្នាក់កណ្ដាល ដូចជា ប្រាក់កម្រៃ លទ្ធកម្ម ថ្នាំពេទ្យ និងបរិក្ខារពេទ្យ និងសកម្មភាពទ្រទ្រង់ដទៃទៀត។ នៅឆ្នាំ ២០០៩ មានត្រឹមតែ ១ ភាគរយ នៃចំណាយហិរញ្ញប្បទានក្នុងស្រុកប៉ុណ្ណោះ ដែលត្រូវបានរៀបចំជាកម្មវិធីសម្រាប់ជំងឺមិនឆ្លង និងត្រឹមតែ ១០ ភាគរយប៉ុណ្ណោះ សម្រាប់សុខភាពបន្តពូជ សុខភាពមាតា សុខភាពទារក និងសុខភាពកុមារ។ ទោះជាយ៉ាងណាក្ដី តួលេខទាំងនេះមិនបង្ហាញពេញលេញនូវវិភាជន៍ធនធានថវិកាជាក់ស្ដែងទៅកាន់ជំងឺមិនឆ្លង និងសុខភាពមាតា និងកុមារឡើយ ដែលភាគច្រើនត្រូវបានដាក់បញ្ចូលក្នុងបន្ទាត់ថវិកា មិនមែនកម្មវិធីសម្រាប់ការថែទាំសុខភាពនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យនានា។

**ចំណាយមួយផ្នែកធំរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាល ត្រូវបានហិរញ្ញប្បទានពីជំនួយពីបរទេសជាជាងពីចំណូលផ្ទាល់ ធ្វើឱ្យមានកង្វល់អំពីចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាល និងសុខុដុមភាពរូបនីយកម្មនៃគោលដៅនានារវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ។** ហិរញ្ញប្បទានម្ចាស់ជំនួយបានកើនឡើងពីប្រមាណជា ៦៧ លានដុល្លារក្នុងមួយឆ្នាំ ពីឆ្នាំ ២០០០ ដល់ ២០០២ ទៅដល់ ២១០ លាន នៅឆ្នាំ ២០០៩[២៤]។ ម្ចាស់ជំនួយទ្វេភាគីបានផ្ដល់មូលនិធិប្រហែល ៤០ ភាគរយ នៃមូលនិធិពីបរទេសទៅកាន់វិស័យសុខាភិបាលនាឆ្នាំ ២០០៩ ចំណែកឯទីភ្នាក់ងារពហុភាគី មូលនិធិសាកលសម្រាប់ជំងឺគ្រុនចាញ់ របេង និងអេដស៍ និងអង្គការមិនស្វែងរកប្រាក់ចំណេញ អង្គការនីមួយៗផ្ដល់ប្រហែល ២០ ភាគរយ។ចំណាយលើផ្នែកសុខភាពមាតា និងកុមារមួយផ្នែកធំ បានមកពីហិរញ្ញប្បទានជាអំណោយមិនផ្លូវការ តាមរយៈមន្ទីរពេទ្យកុមាររបស់អង្គការក្រៅរដ្ឋាភិបាល (នៅកម្ពុជាមានកុមារភាគច្រើនជាអ្នកជំងឺក្នុង និងអ្នកជំងឺក្រៅ) ហើយមិនត្រូវបានកត់ត្រានៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំឡើយ។ ម្ចាស់ជំនួយបានបង្កើនកិច្ចប្រឹងប្រែង ដើម្បីសម្របសម្រួលជំនួយរបស់ខ្លួនក្រោយពេលដែលអង្កេតមូលដ្ឋានមួយរបស់ OECD នៅឆ្នាំ ២០០៦ បានបង្ហាញឱ្យឃើញនូវថាការសម្របសម្រួលគ្មានប្រសិទ្ធភាព។ ឧទាហរណ៍សព្វថ្ងៃ ម្ចាស់ជំនួយចំនួនប្រាំពីរផ្ដល់ការទ្រទ្រង់ចំពោះក្រសួងសុខាភិបាលក្រោមគម្រោងទ្រទ្រង់វិស័យសុខាភិបាលលើកទីពីរតាមរយៈកញ្ចប់មូលនិធិ ឬតាមរយៈយន្តការផ្ដល់មូលនិធិច្បាស់លាស់ដែលប្រើប្រាស់នីតិវិធីរួម ស្របជាមួយយុទ្ធសាស្ត្រវិស័យសុខាភិបាលលើកទីពីររបស់ក្រសួងសុខាភិបាល។

**ក្រៅពីចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាល ចំណាយសុខាភិបាលសរុប រួមមានចំណាយប្រាក់ពីហោប៉ៅផ្ទាល់ខ្លួន រាប់ទាំងថ្លៃសេវាផ្លូវការ - ចំណាយតាមរយៈមូលនិធិសមធម៌សុខភាព និងចំណាយដែលហិរញ្ញប្បទានដោយការធានារ៉ាប់រងដោយស្ម័គ្រចិត្ត។** សូមពិចារណាប្រភពនីមួយៗទាំងនេះ។

### រូបលេខ ៣៣. គ្រួសារមានជីវភាពធូរធារចំណាយច្រើនលើការថែទាំសុខភាព-ឆ្នាំ២០០៧
(គិតជា ដុល្លារអាមេរិក)




*ប្រភព :* អង្កេត CSES ឆ្នាំ ២០០៧

### រូបលេខ ៣៤. ថ្លៃសេវា គឺជាប្រភពសំខាន់មួយនៃការផ្ដល់មូលនិធិ-ឆ្នាំ២០០៩
(គិតជា ពាន់ដុល្លារអាមេរិក)




*ប្រភព :* របាយការណ៍ហិរញ្ញប្បទានសុខាភិបាលឆ្នាំ ២០០៩ ក្រសួងសុខាភិបាល

---

*២៤ តួលេខចំណាយទាំងនេះ ត្រូវបានបំពេញបន្ថែមដោយផ្ទាល់ពីអង្គការក្រៅរដ្ឋាភិបាល-ហិរញ្ញប្បទានពីបរទេសទៅកាន់មន្ទីរពេទ្យ និងអ្នកផ្ដល់សេវាសុខភាព ដែលមិនត្រូវបានដាក់បញ្ចូលទៅក្នុងថវិកា និងចំណាយសាធារណៈ។ ចំពោះព័ត៌មានបន្ថែម សូមអានជំពូក ២។*

**ការចំណាយប្រាក់ពីហោប៉ៅផ្ទាល់ខ្លួនមានចំនួនច្រើននៃចំណាយសរុបលើផ្នែកសុខភាព។** បីភាគបួននៃចំណាយឯកជនលើសុខភាព គឺសម្រាប់ការព្យាបាល និងថ្នាំពេទ្យផ្នែកឯកជន។ ទោះបីជាចំណាយប្រាក់ពីហោប៉ៅផ្ទាល់ខ្លួន ជាចំណាយរបស់បញ្ចូភាគអ្នកមានបំផុតក្តី ចំណាយប្រាក់ពីហោប៉ៅផ្ទាល់ខ្លួន គឺជាបន្ទុកធ្ងន់មួយមកលើពលរដ្ឋក្រីក្រ (រូបលេខ ៣៣)។ ពលរដ្ឋក្រីក្រចំណាយប្រាក់ចំណូលលើសុខភាពរបស់ខ្លួន ដោយអត្រាទាបជាងអ្នកមាន ជារឿយៗ ដោយសារខ្វះប្រាក់ធ្ងន់ធ្ងរ ពួកគេសុខចិត្តមិនធ្វើការថែទាំសុខភាព ឬរកការថែទាំសុខភាពបែបផ្សេងដែលចំណាយតិច ប៉ុន្តែចំណាយច្រើនហួសធ្វើឱ្យប៉ះពាល់ដល់អ្នកមានចំណូលគ្រប់ប្រភេទ។ ទោះជាយ៉ាងណាក្តី ចំណាយនេះនៅកម្ពុជាមានកម្រិតទាបជាងនៅប្រទេសមួយចំនួននៅក្នុងតំបន់ រាប់ទាំងប្រទេសវៀតណាមផងដែរ ប្រទេសទាំងនោះពឹងផ្អែកយ៉ាងច្រើនលើថ្លៃសេវា (Wagstaff និងអ្នកឯទៀត ១៩៩៥ GiZ ២០១១)។

**ថ្លៃសេវា-គ្រាន់តែជាផ្នែកមួយការចំណាយប្រាក់ពីហោប៉ៅផ្ទាល់ខ្លួន - ជាប្រភពសំខាន់មួយនៃការផ្តល់មូលនិធិចំពោះមន្ទីរពេទ្យរដ្ឋ ប៉ុន្តែជារបាំងក្នុងការទទួលបានសេវាចំពោះពលរដ្ឋក្រីក្រ និងស្ទើរក្រីក្រ។** នៅឆ្នាំ១៩៩៦ ធម្មនុញ្ញហិរញ្ញប្បទានសុខាភិបាល បានកំណត់ថ្លៃសេវានៅមន្ទីរពេទ្យរដ្ឋ។ បច្ចុប្បន្ន ៦០ ភាគរយនៃថ្លៃសេវា ត្រូវបានរក្សាទុកដោយមន្ទីរពេទ្យសម្រាប់ផ្តល់ការលើកទឹកចិត្តចំពោះបុគ្គលិក ៣៩ ភាគរយ ត្រូវរក្សាទុកសម្រាប់ចំណាយប្រតិបត្តិការរបស់មន្ទីរពេទ្យ និង ១ ភាគរយ ត្រូវបង្វែរទៅឱ្យរដ្ឋាភិបាល។ ចំណូលដែលបានរាយការណ៍ថាបានមកពីថ្លៃសេវា[២៥] បានកើនឡើងពី ១.៣ លានដុល្លារ នៅឆ្នាំ២០០១ ដល់ ១៥.៩ លានដុល្លារ នៅឆ្នាំ២០០៩ ដែលមន្ទីរពេទ្យជាតិរកបានពីរភាគបីនៃទឹកប្រាក់សរុប (រូបលេខ ៣៤)។ ថ្លៃសេវាមានចំនួន ៤៥ ភាគរយ នៃចំណូលរបស់មន្ទីរពេទ្យជាតិ ប៉ុន្តែមានត្រឹមតែ ៥.៨ ភាគរយ នៃចំណាយសរុបនៅថ្នាក់ខេត្តប៉ុណ្ណោះ។

**រូបលេខ ៣៥. ថ្លៃសេវាបង្កើតបានជាចំណូលយ៉ាងច្រើន**

(គិតជា ភាគរយនៃចំណូលសរុប)




*ប្រភព :* របាយការណ៍ហិរញ្ញប្បទានសុខាភិបាលរបស់ក្រសួងសុខាភិបាល ឆ្នាំ ២០០៨

**រូបលេខ ៣៦. ប្រភពផ្តល់មូលនិធិសម្រាប់មន្ទីរពេទ្យជាតិ ឆ្នាំ ២០០៨-២០០៩**

(គិតជា ពាន់ដុល្លារអាមេរិក)




*ប្រភព :* របាយការណ៍ហិរញ្ញប្បទានសុខាភិបាលរបស់ក្រសួងសុខាភិបាល ឆ្នាំ២០០៩, ទិន្នន័យចែកចាយរបស់ឃ្លាំងឱសថកណ្តាលចាប់ពីឆ្នាំ ២០០៨។

*សំគាល់ :* KBH = មន្ទីរពេទ្យ (កុមារ) គន្ធបុប្ផា- KOH = មន្ទីរពេទ្យកុសុមៈ- ADH = មន្ទីរពេទ្យអង្គឌួង- NPH = មន្ទីរពេទ្យកុមារជាតិ- KSFH = មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

*២៥ ថ្លៃសេវាមិនត្រូវបានដាក់បញ្ចូលក្នុងគណនីជាតិឡើយ ហើយមន្ទីរសុខាភិបាលខេត្ត និងក្រសួងសុខាភិបាលប្រមូលព័ត៌មាននេះដោយផ្ទាល់ពីមន្ទីរពេទ្យពាក់ព័ន្ធ ប៉ុន្តែការរាយការណ៍បានកែលំអយ៉ាងច្រើនក្នុងរយៈពេលពីរឆ្នាំចុងក្រោមនេះ (របាយការណ៍ហិរញ្ញប្បទានសុខាភិបាល ក្រសួងសុខាភិបាល ឆ្នាំ ២០០៩)។ ការប្រៀបធៀបអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ ២០០៤ និង ២០០៧ ផ្ទុយទៅវិញ បង្ហាញនូវការចុះថយនូវចំណាយចេញពីហោប៉ៅផ្ទាល់ខ្លួនបន្តិច ដែលបង់ឱ្យវិស័យសាធារណៈ ដោយសារចំណាយធ្លាក់ចុះនៅមន្ទីពេទ្យរដ្ឋ និងមណ្ឌលសុខភាពនៃបញ្ចូភាគទាំងពីរនៃអ្នកមានចំណូលខ្ពស់ជាងគេ ប៉ុន្តែគប្បីប្រយ័ត្នប្រយែងក្នុងការប្រើទិន្នន័យទាំងនេះ។*

**ពលរដ្ឋក្រីក្រត្រូវបានលើកលែងពីការយកថ្លៃសេវា (ផ្លូវការ) ប៉ុន្តែពួកគេចំណាយប្រាក់ពីហោប៉ៅផ្ទាល់ខ្លួនផ្សេងទៀត។** នៅឆ្នាំ ២០០៩ ការលើកលែងមិនយកថ្លៃសេវាមានចំនួន ១.៥ លានករណី ក្នុងនោះ ភាគច្រើនជាការលើកលែងនៅកម្រិតមណ្ឌលសុខភាព។ មន្ទីរពេទ្យជាតិកាន់តែច្រើនកំពុងក្លាយជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ ដែលមានស្វ័យភាពក្នុងការបង្កើនចំណូលពីថ្លៃសេវា។ ជាលទ្ធផល មន្ទីរពេទ្យទាំងនោះមិនចង់ផ្តល់ការលើកលែងមិនយកថ្លៃសេវាឡើយ វៀរលែងតែរដ្ឋាភិបាលធ្វើការបើកប្រាក់សងច្បាស់លាស់ចំពោះចំណូលដែលបានបាត់បង់ពីការលើកលែងនោះ។ ផ្ទុយមកវិញ មន្ទីរពេទ្យកុមារអង្គការក្រៅរដ្ឋាភិបាលគន្ធបុប្ផា ដែលបានទទួលថវិកាបង្វែរចំនួន ៣,៥ លានដុល្លារ និងមូលនិធិបរទេស ៣០ លានដុល្លារ នៅឆ្នាំ ២០០៩ ផ្តល់សេវាដោយមិនយកថ្លៃសេវាពីពលរដ្ឋក្រីក្រ (រូបលេខ ៣៦)។

**មូលនិធិសមធម៌សុខភាពបានក្លាយជាប្រភពប្រាក់ចំណូលដ៏សំខាន់សម្រាប់មន្ទីរពេទ្យរដ្ឋ ក្នុងការព្យាបាលអ្នកដែលមានលទ្ធភាពតិចតួចបំផុតក្នុងការរ៉ាប់រងថ្លៃចំណាយ។** នៅឆ្នាំ ២០០៩ មូលនិធិសមធម៌សុខភាពគ្របដណ្តប់ស្រុកប្រតិបត្តិ ប្រហែលបីភាគបួនលើស្រុកប្រតិបត្តិចំនួន ៥០ នៃស្រុកប្រតិបត្តិចំនួន ៧៧ មូលនិធិសមធម៌សុខភាពភាគច្រើន ត្រូវបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលជាមួយនឹងការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយចំណែកឯកគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលវិញ គ្របដណ្តប់មន្ទីរពេទ្យជាតិ និងស្រុកប្រតិបត្តិមួយចំនួន។ នៅឆ្នាំ ២០០៨ មន្ទីរពេទ្យខេត្តដែលមានមូលនិធិសមធម៌សុខភាពបានទទួលប្រាក់ ២៥ ភាគរយ នៃចំណូលសរុបរបស់ខ្លួនពីមូលនិធិសមធម៌សុខភាព (រូបលេខ ៣៥)។ ភស្តុតាងបង្ហាញថា មូលនិធិសមធម៌សុខភាពកាត់បន្ថយបំណុលទាក់ទងនឹងសុខភាព និងជាមធ្យោបាយដែលមានប្រសិទ្ធភាពច្រើនក្នុងការធានាសេវាមិនបង់ប្រាក់ចំពោះពលរដ្ឋក្រីក្រ ជាជាងការលើកលែងមិនយកថ្លៃសេវា ដែលគ្រប់គ្រងដោយមន្ទីរពេទ្យ (Bigdeli និង Annear ឆ្នាំ ២០០៩)។

**រដ្ឋាភិបាលកំពុងដាក់ឱ្យប្រើការរ៉ាប់រងសុខភាពចំពោះបុគ្គលិកឯកជនដែលបានទទួលប្រាក់ខែ និងគ្រោងដាក់ឱ្យប្រើកាតព្វកិច្ចធានារ៉ាប់រងសុខភាពចំពោះមន្ត្រីរាជការ។** តាមច្បាប់ស្តីពីសន្តិសុខសង្គម ឆ្នាំ ២០០២ អនុក្រឹត្យមួយចេញឆ្នាំ ២០០៧ បានបង្កើតក្របខ័ណ្ឌសម្រាប់បេឡាជាតិសន្តិសុខសង្គម។ គម្រោងគ្រោះថ្នាក់ការងារមួយ ដែលផ្តល់ហិរញ្ញប្បទានតាមរយៈពន្ធលើប្រាក់ខែសរុបស្មើនឹង ០,៨ ភាគរយ ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៨។ គម្រោងនេះគ្របដណ្តប់លើក្រុមហ៊ុនទាំងឡាយណាដែលមានកម្មករចាប់ពី ៨ នាក់ឡើងទៅ ហើយសហគ្រាស ១.២០០ បានចុះបញ្ជីចំនួន នៅឆ្នាំ ២០០៩ មានកម្មករចំនួន ៤០០.០០០ នាក់។ រដ្ឋាភិបាលគ្រោងដាក់ឱ្យដំណើរការជាផ្លូវការនូវគម្រោងធានារ៉ាប់សុខភាពឯកជននៅឆ្នាំ ២០១១ ប៉ុន្តែបានពន្យារពេលការចាប់ផ្តើមគម្រោងសម្រាប់មន្ត្រីរាជការ។ ចំណុចលម្អិតជាច្រើននៃគម្រោងទាំងនោះ រួមមាន កញ្ចប់ អត្ថប្រយោជន៍ និងកម្រិតភាគទានប្រាក់ខែសរុប នៅមិនទាន់បានកំណត់នៅឡើយ។ ទោះជាយ៉ាងណាក្តី សក្តានុពល និងលទ្ធភាពក្នុងការបង្កើនប្រាក់ចំណូល តាមរយៈភាគទានប្រាក់ខែសរុបបម្រុងទុកជួបការលំបាកដោយសារវិស័យក្នុងប្រព័ន្ធមានទំហំតូច ក៏ដូចជាលទ្ធភាពក្នុងការគេចវេះដែលមានចំនួនច្រើន និងភស្តុតាងពីប្រទេសនានា ដែលបង្ហាញថាពន្ធលើប្រាក់ខែ អាចប៉ះពាល់ធ្ងន់ធ្ងរដល់ការរីកចម្រើននៃវិស័យក្នុងប្រព័ន្ធ ពិសេសនៅបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប។ ជាងនេះទៅទៀត គម្រោងធានារ៉ាប់រងបែបនេះ អាចទទួលហិរញ្ញប្បទានពីចំណូលទូទៅរបស់រដ្ឋាភិបាលជាជាងពីពន្ធលើប្រាក់ខែ (Savedoff ២០០៤)។

**គម្រោងធានារ៉ាប់រងនៅក្នុងសហគមន៍ដោយស្ម័គ្រចិត្ត (CBHI) ត្រូវបានដាក់ឱ្យប្រើប្រាស់នៅផ្នែកនានានៃប្រទេសកម្ពុជាក្នុងទសវត្សរ៍កន្លងទៅ ប៉ុន្តែការគ្របដណ្តប់នៅមានទំហំតូចនៅឡើយ។** គម្រោងធានារ៉ាប់រងសុខភាពនៅក្នុងសហគមន៍ផ្តោត មុខសញ្ញាទៅកពលរដ្ឋមិនក្រីក្រ ឬស្ទើរក្រីក្រ និងបានរួមចំណែកក្នុងការបង្កើនការប្រើប្រាស់សេវាសុខភាព ទោះបីជាអ្នកចូលរួមនៅក្នុងគម្រោងនេះទំនងជាអ្នកដែលរស់នៅក្បែរមន្ទីរពេទ្យ ឬទំនងជាអ្នកដែលឧស្សាហ៍មានជំងឺក្តី។ ប្រមាណជាមានប្រជាជន ១០០.០០០ នាក់ ដែលបានទទួលការគ្របដណ្តប់ ហើយប្រាក់ចំណូលមានកម្រិតខ្ពស់ ទោះជាបុព្វលាភធានារ៉ាប់រងមានតម្លៃថោក នៅតែជាបន្ទុកធ្ងន់សម្រាប់ពួកគេក្តី។ បទពិសោធន៍អន្តរជាតិបង្ហាញថា ការធានារ៉ាប់រងសុខភាពនៅក្នុងសហគមន៍ និងគម្រោងដូចគ្នាដទៃទៀត សម្រាប់វិស័យក្រៅប្រព័ន្ធកម្រមានលទ្ធភាពសម្រេចបានការគ្របដណ្តប់ទូលំទូលាយ ដោយគ្មានឧបត្ថម្ភធនច្រើនពីរដ្ឋាភិបាល ដើម្បីលើកទឹកចិត្តក្នុងការចុះឈ្មោះ ឬតាមរយៈការធ្វើឱ្យគម្រោងមានលក្ខណៈជាកាតព្វកិច្ចណាស់ (ធនាគារពិភពលោក ឆ្នាំ ២០១០)។

**ឱកាសសម្រាប់បង្កើនកម្រិតចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាលធៀបនឹង ផសស អាស្រ័យលើកត្តាច្រើនយ៉ាង។** កត្តាសំខាន់បំផុតគឺអត្ថិភាពផ្នែកសារពើពន្ធ។ ក្នុងស្ថានភាពនៃកម្រិតប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ និងកម្រិតនៃភាពក្រៅប្រព័ន្ធនៅកម្ពុជា ការយកពន្ធដោយអត្រាខ្ពស់ និងការបង្កើតពន្ធថ្មី មិនទំនងជាជម្រើសដែលអាចយកមកអនុវត្តក្នុងពេលនេះឡើយ។ ហើយខណៈដែលអត្រាពន្ធខ្ពស់លើថ្នាំជក់ អាចជាឧបករណ៍មានប្រយោជន៍ដើម្បីកាត់បន្ថយការជក់បារី ប្រាក់ចំណូលថ្មីបានមកពីពន្ធទាំងនោះ មិនចាំបាច់យកមក

ចំណាយលើវិស័យសុខាភិបាលឡើយ ។ ការលើកកម្ពស់ការប្រមូលពន្ធ និងការកំណត់អាទិភាពជាថ្មីចំពោះចំណាយផ្សេងទៀតរបស់រដ្ឋាភិបាល គឺជាជម្រើសដែលអាចប្រើប្រាស់បាន ដើម្បីបង្កើនប្រាក់ចំណូលទូទៅសម្រាប់វិស័យសុខាភិបាល (សូមអានជំពូក ២) ។ ដូចគ្នាដែរ ការពិនិត្យដោយហ្មត់ចត់អំពីសមាសភាគនៃចំណាយមិនមែនកម្មវិធី និងការបង្កើនតម្លាភាពនៃចំណាយនៅថ្នាក់ក្រោមខេត្ត នឹងបង្កើតឱកាសសារពើពន្ធតាមរយៈការទទួលបាននូវប្រសិទ្ធភាព ។ ការធ្វើការជាមួយម្ចាស់ជំនួយដើម្បីបន្សុីការគាំទ្ររបស់ពួកគេឱ្យបានកាន់តែប្រសើរជាមួយអាទិភាពនានារបស់រដ្ឋាភិបាលមានសារៈសំខាន់ណាស់ ។

# ឃ. ប្រសិទ្ធភាព និងសមធម៌នៃចំណាយសុខាភិបាលនៅកម្ពុជា

**លទ្ធផលរយៈពេលមធ្យមសុខាភិបាលដែលបានកែសម្រួលទៅតាមប្រាក់លចំណូល និងកម្រិតនៃការចំណាយនៅកម្ពុជា មានកម្រិតប្រហាក់ប្រហែលមធ្យមភាគនៅលើពិភពលោក។** ទោះជាយ៉ាងណាក្តី លទ្ធផលរយៈពេលមធ្យមមានកម្រិតទាបជាងយ៉ាងច្រើន ធៀបនឹងប្រទេសភាគច្រើនកំពុងអភិវឌ្ឍន៍នៅអាស៊ីបូព៌ា ដែលទំនងជាមានចំណូលក្នុងម្នាក់ៗខ្ពស់ជាង (ធនាគារពិភពលោក ឆ្នាំ ២០១០) ។

## ប្រសិទ្ធភាព និងសមធម៌នៃការផ្តល់សេវាសុខាភិបាល

**ការគ្របដណ្តប់ និងលទ្ធភាពបានទទួលសេវាថែទាំសុខភាពបានកើនឡើង។** ក្រសួងសុខាភិបាលបានរៀបចំផែនការគ្របដណ្តប់សុខាភិបាល (HCP) នៅដើមទសវត្សរ៍ ១៩៩០ ឈានទៅកាន់ប្រព័ន្ធស្រុកប្រតិបត្តិសុខាភិបាលបច្ចុប្បន្ន ដែលគ្របដណ្តប់ប្រជាជនពី ១៥០.០០០ ដល់ ២៥០.០០០ នាក់ ជាមួយមន្ទីរពេទ្យស្រុក ឬមន្ទីរពេទ្យខេត្តមួយ និងមានមណ្ឌលសុខភាពពី ៨ ដល់ ១៥ ។ ចំនួននៃមណ្ឌលសុខភាពដំណើរការមានចំនួនដល់ ៩៨៤ នៅឆ្នាំ ២០០៩ ។ លទ្ធភាពក្នុងការបានទទួលសេវានៅតាមមន្ទីរពេទ្យសាធារណៈបានកើនឡើងយ៉ាងច្រើន ។ ចំណាយរដ្ឋាភិបាលលើការថែទាំសុខភាពបឋម ទំនងជាផ្តល់អត្ថប្រយោជន៍ចំពោះពលរដ្ឋក្រីក្រ និងប្រជាជនជនបទ ចំណែកឯចំណាយលើមន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យជាតិ ទំនងជាផ្តល់អត្ថប្រយោជន៍ដល់អ្នកមានជីវភាពធូរធារ (រូបលេខ ៣៧) ។ ចម្ងាយមធ្យមដែលអ្នកស្ថិតក្នុងបញ្ចភាគក្រីក្របំផុត ត្រូវធ្វើដំណើរទៅទទួលសេវានៅមណ្ឌលសុខភាពជិតបំផុតបានធ្លាក់ចុះ ៣៦ ភាគរយ នៅចន្លោះឆ្នាំ ២០០៤ និង ២០០៧ មកត្រឹម ៤,៥ គ.ម. ប៉ុន្តែចម្ងាយផ្លូវនៅតែជាឧបសគ្គក្នុងការទៅទទួលសេវានៅមន្ទីរពេទ្យបង្អែក (រូបលេខ ៣៨) ។

**សូចនាកររង្វាស់ស្តង់ប្រសិទ្ធភាព មន្ទីរពេទ្យទំនងជាមានភាពប្រសើរឡើង ប៉ុន្តែវិភាជន៍នៅតែផ្អែកជាមូលដ្ឋានលើចំនួនគ្រែ គេមិនសូវគិតគូរដល់ចំនួនអ្នកជំងឺសរុបឡើយ** (រូបលេខ ៣៩) ។ អត្រាប្រើប្រាស់គ្រែ (BOR) ចំពោះមន្ទីរពេទ្យបង្អែកខេត្តនៅឆ្នាំ២០០៨ ជាមធ្យមស្មើនឹង ៦៤ ភាគរយ នៅឆ្នាំ ២០០៨ ពីអត្រាប្រើប្រាស់គ្រែ ២៤ ភាគរយ នៅមន្ទីរពេទ្យបង្អែកខេត្តកែបដល់ ១០០ ភាគរយ នៅមន្ទីរពេទ្យដទៃ (ដូចជានៅគីរីវង្ស សៀមរាប ជាដើម) ។ នៅមន្ទីរពេទ្យជាតិអត្រាប្រើប្រាស់គ្រែជាមធ្យមស្មើនឹង ៨៤ ភាគរយ ។ រយៈពេលស្នាក់នៅមធ្យមមានចំនួនប្រហែលប្រាំមួយថ្ងៃ ទាំងនៅមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យខេត្ត ហើយគេឃើញមានភស្តុតាងមួយចំនួនអំពីការស្នាក់នៅយូរចំពោះអ្នកជំងឺ ដែលរ៉ាប់រងដោយមូលនិធិសមធម៌សុខភាព ។ ការប្តូរទៅកាន់ការបង់ថ្លៃតាមករណី ជាជាងការយកថ្លៃចំពោះសេវា អាចកាត់បន្ថយការលើកទឹកចិត្តចំពោះការព្យាបាលច្រើនលើសការចាំបាច់ និងជួយគ្រប់គ្រងចំណាយ ។ ការបង់ថ្លៃក៏អាចត្រូវបានកែសម្រួល ដើម្បីជំរុញការលើកទឹកចិត្តចំពោះការលើកកម្ពស់គុណភាពផងដែរ ។

**វិភាជន៍ទៅកាន់បណ្តាខេត្តទំនងដូចជាដឹកនាំដោយ ចំណាយពីពេលមុនៗ និងការចរចារដោយផ្ទាល់ ចំណែកឯការរៀបចំថវិកាផ្អែកលើតម្រូវការ ឬផ្អែកលើលទ្ធផល នៅពុំទាន់ត្រូវបានដាក់ឱ្យប្រើប្រាស់នៅឡើយ។** ហើយមានការប្រែប្រួលជាច្រើនលើវិភាជន៍ ជារួមចំពោះពលរដ្ឋម្នាក់ៗ (រូបលេខ ៤០) ។ ជាមួយគ្នានេះ វិភាជន៍នៃហិរញ្ញប្បទានបរទេសទៅកាន់បណ្តាខេត្ត ឆ្លុះបញ្ចាំងអាទិភាពនានារបស់ម្ចាស់ជំនួយ ។ ទោះបីជាឃ្លាំងឱសថកណ្តាលបានបង្កើតប្រព័ន្ធផ្គត់ផ្គង់សម្រាប់ការព្យាករណ៍ និងបែងចែកឱសថទៅតាមតម្រូវការក្តី ក៏វិភាជន៍សម្រាប់ពលរដ្ឋម្នាក់ៗនៅឆ្នាំ ២០០៨ មានភាពខុសគ្នាយ៉ាងច្រើនរវាងបណ្តាខេត្តនានា គឺប្រែប្រួលពី ១.២៨ ដុល្លារ នៅភ្នំពេញដល់ ១២.៤០ ដុល្លារ នៅប៉ៃលិន ។ ដូចគ្នាដែរ ការប្រៀបធៀបអំពីការគ្របដណ្តប់ការចាក់វ៉ាក់សាំង និងអត្រាប្រើប្រាស់អ្នកជំងឺក្រៅលើវិភាជន៍ថវិកាសម្រាប់ពលរដ្ឋម្នាក់ៗនៅថ្នាក់ខេត្ត បង្ហាញនូវភាពខុសគ្នាយ៉ាងច្រើនរវាងបណ្តាខេត្តនានា ។

**ការបែងចែកគ្រូពេទ្យវេជ្ជបណ្ឌិត និងគិលានុបដ្ឋាកយិកាសម្រាប់ពលរដ្ឋម្នាក់ៗនៅតាមបណ្តាខេត្តនានា ក៏មិនដូចគ្នាដែរ។** កម្ពុជាមានគ្រូពេទ្យវេជ្ជបណ្ឌិត ០,២ នាក់ និងគិលានុបដ្ឋាកយិកា និងឆ្មប ១,១ នាក់ ក្នុងចំនួនប្រជាជន ១.០០០ នាក់ ប៉ុន្តែចំនួននេះប្រែប្រួលជាខ្លាំងរវាងបណ្តាខេត្តនានា (រូបលេខ ៤១) ។ ខណៈដែលក្រសួងសុខាភិបាលបានធ្វើឱ្យមានវឌ្ឍនភាពក្នុងការដាក់ឱ្យមានឆ្មបបឋមទៅកាន់

មណ្ឌលសុខភាពស្ទើរតែទាំងអស់ ចំនួនបុគ្គលិកមធ្យមដែលបានបណ្តុះបណ្តាលកាលពីទសវត្សរ៍កន្លងមកបានធ្លាក់ចុះ។ ប្រព័ន្ធសុខាភិបាលបឋមនៅកម្ពុជាពឹងផ្អែកលើគិលានុប្បដ្ឋាកយិកា ដើម្បីផ្តល់ការថែទាំសុខភាពបឋម ហើយអនុបាតនៃគិលានុប្បដ្ឋាកយិកា និងឆ្មបក្នុងគ្រូពេទ្យវេជ្ជបណ្ឌិតម្នាក់ គឺ ៥,៤ ដែលចំនួននេះមានកម្រិតខ្ពស់ជាងមធ្យមភាគទាំងនៅអាស៊ាន (៤.៧) និងនៅលើពិភពលោក (២.១) (Kanchanachitra និងអ្នកឯទៀត ឆ្នាំ ២០១១)។

**រូបលេខ ៣៧. ចំណាយលើការថែទាំសុខភាពបឋមមានលក្ខណៈអំណោយផលចំពោះពលរដ្ឋក្រីក្រជាជាងចំណាយមន្ទីរពេទ្យ**
(គិតជា ភាគរយ)




*ប្រភព:* អង្កេត CSES ឆ្នាំ ២០០៧ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**រូបលេខ ៣៨. ពលរដ្ឋក្រីក្រស្ថិតនៅកៀកមណ្ឌលសុខភាពជាងមន្ទីរពេទ្យ**
(គិតជា គីឡូម៉ែត្រ)




*ប្រភព:* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០៩), ឃ្លាំងឱសថកណ្តាល (២០០៨) : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (២០០៩)

## ការលើកកម្ពស់លទ្ធកម្មនៃការផ្គត់ផ្គង់ឱសថ និងបរិក្ខារពេទ្យ

**ការទិញឱសថ និងបរិក្ខារពេទ្យកាន់តែមានប្រសិទ្ធភាព អាចធ្វើឱ្យមានការសន្សំប្រាក់ស្មើនឹងមួយភាគបីនៃថវិកាសុខាភិបាលឆ្នាំ ២០១០ ឬជិតស្មើនឹង ០,៤ ភាគរយ នៃ ផសស។** ចំណាយរដ្ឋាភិបាលលើការទិញឱសថបានកើនឡើងជាខ្លាំង ចាប់តាំងពីឆ្នាំ ២០០៥ មក ប៉ុន្តែនៅតែមានការដាច់ស្តុកថ្នាំពេទ្យនៅតាមមន្ទីរពេទ្យនានា (រូបលេខ ៤២)។ ការពិនិត្យឡើងវិញនូវវិក្កយបត្រមួយរបស់ឃ្លាំងឱសថកណ្តាលបង្ហាញថា ក្រសួងសុខាភិបាលកំពុងចំណាយជាមធ្យមចំនួនប្រាំមួយដងធៀបនឹងថ្លៃអន្តរជាតិគោលនៃថ្នាំពេទ្យសំខាន់ៗ។ នៅឆ្នាំ ២០១០ រដ្ឋាភិបាលបានចំណាយប្រមាណជា ៦៥ លានដុល្លារ លើឱសថ និង ១៤ លានដុល្លារ លើបរិក្ខារពេទ្យពីថវិកាសុខាភិបាលសរុបចំនួន ១៥០ លានដុល្លារ[២៦]។ ការទិញដែលមានប្រសិទ្ធភាពជាងនេះ អាចរកបានប្រាក់ ៥០ លានដុល្លារ-ជាប្រាក់សន្សំ-ក្នុងមួយឆ្នាំ (០.៤ ភាគរយនៃ ផសស) ដែលគេអាចយកទៅប្រើសម្រាប់បង្កើនអត្ថិភាពថ្នាំពេទ្យ និងដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់អាទិភាពសុខាភិបាលសំខាន់ៗដទៃទៀត។ ប្រមាណជា ៩៦ ភាគរយ នៃថ្នាំពេទ្យដែលប្រើប្រាស់នៅថ្នាក់ខេត្ត ត្រូវបានក្រសួងសុខាភិបាលទិញ។ មានថ្នាំពេទ្យតែ ៣,៥ ភាគរយប៉ុណ្ណោះ ដែលត្រូវបានទិញដោយវិភាជន៍ថវិកាខេត្ត ចំណែកឯក្រៅពីនេះ គឺទិញដោយប្រាក់ចំណូលពីថ្លៃប្រើប្រាស់សេវា។

---

*២៦ គ្មានទិន្នន័យអំពីចំណាយបរិក្ខារពេទ្យ និងសម្ភារៈក្រៅពីបរិក្ខារពេទ្យដែលបានទិញនៅថ្នាក់កណ្តាល និងនៅថ្នាក់ខេត្តឡើយ។ ចំណាយទាំងនេះមានទឹកប្រាក់ចំនួន ២០ លានដុល្លារ បន្ថែមលើចំណាយនៅឆ្នាំ ២០១០ ប៉ុន្តែគេទំនងជាអាចកាត់បន្ថយចំណាយឱ្យនៅទាបជាងនេះ។*

### រូបលេខ ៣៩. វិភាជន៍ថវិកាមានទំនាក់ទំនងជាមួយចំនួនគ្រែ ប៉ុន្តែមិនទាក់ទងនឹងលទ្ធផលរបស់មន្ទីរពេទ្យឡើយ
(គិតជា ដុល្លារអាមេរិក)




*ប្រភព :* ទិន្នន័យថវិកាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០៩)
*ទិន្នន័យចែកចាយរបស់ឃ្លាំងឱសថកណ្ដាល (២០០៨)*
*ទិន្នន័យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (២០០៩)*

### រូបលេខ ៤០. វិភាជន៍ថវិកានៅថ្នាក់ខេត្តមិនដូចគ្នាឡើយ
(គិតជា ដុល្លារអាមេរិក)




*ប្រភព :* អង្កេតសេដ្ឋកិច្ច-សង្គម ឆ្នាំ ២០០៧

**ឱសថ និងបរិក្ខារពេទ្យត្រូវបានទិញដោយក្រសួងសុខាភិបាល និងបែងចែកដោយឃ្លាំងឱសថកណ្ដាល ដែលនាយកដ្ឋានឱសថ ម្ហូបអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងនៃក្រសួងសុខាភិបាល (DDF) ទទួលខុសត្រូវលើគុណភាព។** នាយកដ្ឋាននេះកំណត់បញ្ជីឱសថសារវន្តក្នុងភាពជាដៃគូជាមួយកម្មវិធីជាតិនានា និងទទួលខុសត្រូវចំពោះការតាមដានគុណភាព។ ជាមួយគ្នានេះ សេចក្ដីសម្រេចចិត្តអំពីលទ្ធកម្ម អាស្រ័យលើគណៈកម្មាធិការវាយតម្លៃបុរេលក្ខណៈសម្បត្តិ និងផ្ដល់កិច្ចសន្យា (PREAC) ដែលត្រូវមានការឯកភាពពីនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បច្ចុប្បន្ន អង្គភាពលទ្ធកម្មនៅក្រសួងសុខាភិបាលរាយការណ៍ដោយផ្ទាល់ទៅរដ្ឋមន្ត្រីសុខាភិបាល។

**លទ្ធកម្មរបស់គណៈកម្មាធិការវាយតំលៃបុរេលក្ខណៈសម្បត្តិ និងផ្ដល់កិច្ចសន្យានៅមិនទាន់បានធ្វើសុខដុមភាវូបនីយកម្មជាមួយកិច្ចប្រតិបត្តិល្អអន្តរជាតិនៅឡើយ។** ឱសថ និងបរិក្ខារដែលផ្គត់ផ្គង់តាមរយៈគម្រោងទ្រទ្រង់សុខាភិបាលលើកទី ២ និងមូលនិធិសាកលចំពោះជំងឺអេដស៍ និងរបេង ត្រូវបានធ្វើលទ្ធកម្មតាមរយៈការដេញថ្លៃជាអន្តរជាតិ ដោយប្រើនីតិវិធីជាក់លាក់របស់ម្ចាស់ជំនួយ។ ការពិនិត្យវិក្កយបត្រសំណាករបស់ឃ្លាំងឱសថកណ្ដាលបង្ហាញថា ថ្នាំពេទ្យ និងវ៉ាក់សាំង ដែលបានទិញតាមរយៈនីតិវិធីរបស់ទីភ្នាក់ងារអន្តរជាតិនានា មានតម្លៃប្រហាក់ប្រហែលថ្លៃគោលអន្តរជាតិដែរ។

### រូបលេខ ៤១. របាយគ្រូពេទ្យវេជ្ជបណ្ឌិត និងឆ្មបបឋមប្រែប្រួលជាខ្លាំង

(ក្នុងចំនួនប្រជាជន ១០០.០០០ នាក់)




*ប្រភព :* អង្កេត CSES ឆ្នាំ ២០០៧

### រូបលេខ ៤២. នៅតែមានការដាច់ស្តុក ទោះបីជាចំណាយសម្រាប់ទិញឱសថកើនឡើងយ៉ាងឆាប់រហ័សក្តី

(គិតជា លានដុល្លារអាមេរិក និងជាភាគរយ)




*ប្រភព :* ទិន្នន័យថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - MOH HIS

## ការបង្កើនប្រសិទ្ធភាព និងការសម្របសម្រួលដំណើរការរៀបចំថវិកា និងការកសាងផែនការ

**ផែនការយុទ្ធសាស្ត្រថវិកា គឺជាធាតុចូលរបស់ក្រសួងសុខាភិបាលទៅក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម។** ផែនការយុទ្ធសាស្ត្រថវិកា កំណត់គោលដៅរយៈពេលមធ្យម និងកំណត់សូចនាករនានាសម្រាប់អាទិភាពវិស័យសុខាភិបាល ។ លើមូលដ្ឋាននៃក្របខ័ណ្ឌរយៈពេលមធ្យមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញសារាចរអំពីថវិកា ដែលណែនាំការរៀបចំសំណើថវិកាប្រចាំឆ្នាំដោយក្រសួងពាក់ព័ន្ធ ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ផែនការយុទ្ធសាស្ត្រថវិកាក្រសួងសុខាភិបាលបច្ចុប្បន្នមិនដាក់បញ្ចូលនូវចំណាយសុខាភិបាលនៅថ្នាក់ក្រោមជាតិទេ ហើយមានព័ត៌មានតិចតួចអំពីហិរញ្ញប្បទានបរទេស ។

**ស្រុកប្រតិបត្តិ មន្ទីរសុខាភិបាលខេត្ត និងក្រសួងសុខាភិបាលរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំជាឧបករណ៍សម្រាប់អនុវត្តថវិកាប្រចាំឆ្នាំ។** ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាលត្រូវបានប្រមូលពីផែនការបូកសរុប ដែលរៀបចំឡើងដោយនាយកដ្ឋាននានារបស់ក្រសួងសុខាភិបាល រៀបចំដោយខេត្ត កម្មវិធីជាតិ និងមន្ទីរពេទ្យនានា ។ មន្ទីរសុខាភិបាលទទួលខុសត្រូវចំពោះការបូកសរុបផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលរៀបចំដោយស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែក ដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិខេត្ត ។ ផែនការប្រតិបត្តិប្រចាំឆ្នាំនេះមានលក្ខណៈពេញលេញជាងថវិការដ្ឋាភិបាល ការគួបផ្សំចំណាយមូលធន និងចំណាយ ចរន្តចំណូលផ្ទាល់ខ្លួន និងហិរញ្ញប្បទានពីដៃគូបរទេស និងការប្រើចំណាត់ថ្នាក់សកម្មភាពកម្មវិធី/អនុកម្មវិធី ។ ផ្ទុយទៅវិញ ដំណើរការរៀបចំថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្សារភ្ជាប់ជាមួយចំណាយបច្ចុប្បន្នរបស់រដ្ឋាភិបាលមួយផ្នែកធំជាការផ្តល់មូលនិធិពីបរទេស និងមានមូលដ្ឋានលើប្រភេទចំណាយផ្នែកសេដ្ឋកិច្ច ។

**ផែនការយុទ្ធសាស្ត្រថវិកា ផែនការប្រចាំឆ្នាំ និងផែនការប្រតិបត្តិការប្រចាំឆ្នាំ គប្បីដូចគ្នាអំពីការគ្របដណ្តប់ប្រភេទនៃការចំណាយ និងប្រភពនៃហិរញ្ញប្បទាន តាមរយៈការបន្តអនុវត្តផែនការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។** ក្រសួងសុខាភិបាលបានរៀបចំផែនការលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលរួមមានធាតុសំខាន់ៗនៃកំណែទម្រង់ថវិកាពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណត់សកម្មភាពសំខាន់ៗ និងការទទួលខុសត្រូវនានាដែលបានគ្រោង ។

## ការពង្រឹងគំនិតផ្តួចផ្តើមអំពីហិរញ្ញប្បទានសុខាភិបាលលើផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់

**ភស្តុតាងបង្ហាញថាមូលនិធិសមធម៌សុខភាពបានជួយបង្កើនការប្រើប្រាស់សេវាសុខាភិបាល កាត់បន្ថយបំណុលទាក់ទងនឹងសុខភាព និងកំពុងមានប្រសិទ្ធភាពបន្ថែមលើមុខងារទាំងនេះ ជាជាងការលើកលែងមិនយកថ្លៃសេវា (Tangchanroensanthien និងអ្នកឯទៀត ឆ្នាំ ២០១១-Annear ឆ្នាំ ២០១០)។** ការពង្រីកមូលនិធិសមធម៌សុខភាពនៅទូទាំងប្រទេសនៅឆ្នាំ២០១៥ ជាមួយនឹងកញ្ចប់អត្ថប្រយោជន៍បច្ចុប្បន្ន

នឹងតម្រូវឱ្យមានប្រាក់លើសពី ១៦ លានដុល្លារក្នុងមួយឆ្នាំ គិតទាំងប្រាក់ ២,៣ លានដុល្លារ សម្រាប់កំណត់អត្តសញ្ញាណពលរដ្ឋក្រីក្រពេញលេញ (USAID និង URC ឆ្នាំ ២០១០)។ កញ្ចប់នៃអត្ថប្រយោជន៍ ក៏អាចត្រូវបានពង្រីកបន្ថែមដើម្បីដាក់បញ្ចូលនូវសេវាសារវន្តសម្រាប់អ្នកមានជីវភាពមិនក្រីក្រផងដែរ : ឧទាហរណ៍ ការសម្រាលកូនដោយផ្តល់ឧបត្ថម្ភធន និងការថែទាំសម្រាលកូនដោយសង្គ្រោះបន្ទាន់ ដែលត្រូវចំណាយទឹកប្រាក់ត្រឹមជាង ១ លានដុល្លារប៉ុណ្ណោះ។ គេអាចទទួលបាននូវកិច្ចប្រឹងប្រែងយ៉ាងច្រើនតាមរយៈការសម្របសម្រួលមូលនិធិសមធម៌សុខភាពជាមួយនឹងគម្រោងធានារ៉ាប់រងចំពោះកម្មករ និងមន្ត្រីរាជការក្នុងវិស័យក្នុងប្រព័ន្ធ។ សេចក្តីព្រាងផែនការមេចំពោះការការពារសុខភាពសង្គម តម្រូវឱ្យបង្កើតគណៈកម្មាធិការសម្របសម្រួលនៅក្រុមប្រឹក្សារដ្ឋមន្ត្រី និងបង្កើតទីភ្នាក់ងារគាំពារសុខភាពសង្គមមួយ។ យុទ្ធសាស្ត្រអន្តរកាលអាចត្រូវបង្កើតទីភ្នាក់ងារពាក់កណ្តាលស្វយ័តមួយក្រោមក្រសួងសុខាភិបាល ដើម្បីគ្រប់គ្រងគម្រោងមូលនិធិសមធម៌សុខភាព/ធានារ៉ាប់រងសុខភាពនៅក្នុងសហគមន៍ និងគម្រោងធានារ៉ាប់រងសុខភាពសង្គម ដោយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ។

**នៅឆ្នាំ ២០០៩ រដ្ឋាភិបាលបានចាត់អតីតស្រុកចុះកិច្ចសន្យាជាមួយអង្គការមិនមែនរដ្ឋាភិបាលជាទីភ្នាក់ងារប្រតិបត្តិការពិសេស (SOAs) ធ្វើឱ្យស្រុកទាំងនោះមានស្វ័យភាពតិចតួច និងបានទទួលកញ្ចប់ថវិកាសម្រាប់ផ្តល់សេវាផ្អែកលើលទ្ធផលការងារ។** ស្រុកប្រតិបត្តិដែលបានចុះកិច្ចសន្យាជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួនដប់ និងមន្ទីរពេទ្យបង្អែកខេត្តចំនួនប្រាំ ត្រូវបានផ្តួចផ្តើមធ្វើជាភ្នាក់ងារប្រតិបត្តិការពិសេសនៅឆ្នាំ ២០០៩ ដែលបន្តដោយរលកទីពីរនៃភ្នាក់ងារប្រតិបត្តិការពិសេសថ្មីចំនួន ១៥ នៅឆ្នាំ ២០១០។ គម្រោងទ្រទ្រង់វិស័យសុខាភិបាលលើកទីពីរ ផ្តល់កញ្ចប់ថវិកាសម្រាប់ផ្តល់សេវាលើមូលដ្ឋាននៃកិច្ចសន្យាលទ្ធផលការងាររវាងក្រសួងសុខាភិបាល និងភ្នាក់ងារប្រតិបត្តិការពិសេស។ បន្ទាប់មក ភ្នាក់ងារប្រតិបត្តិការពិសេសចុះកិច្ចសន្យាលទ្ធផលការងារជាមួយមន្ទីរពេទ្យនានា។ កម្រិត-ពិតាន រួមសម្រាប់ជំនួយផ្តល់សេវាមានមូលដ្ឋានផ្អែកលើរូបមន្តកែសម្រួលសម្រាប់ម្នាក់ៗ ដែល ៨០ ភាគរយ ត្រូវបានផ្តល់ជាវិភាជន៍មូលដ្ឋាន ១៥ ភាគរយ ត្រូវបានវិភាជន៍លើមូលដ្ឋាននៃលទ្ធផលការងាររបស់ទីភ្នាក់ងារ និង ៥ ភាគរយ លើមូលដ្ឋាននៃកិច្ចសន្យាលទ្ធផលការងាររបស់ទីភ្នាក់ងារ និង ៥ ភាគរយ លើមូលដ្ឋាននៃការចរចាកិច្ចសន្យា។ បច្ចុប្បន្ននេះ ៨០ ភាគរយ ឬច្រើនជាងនេះនៃ "វិភាជន៍មូលដ្ឋាន" របស់ជំនួយសម្រាប់ផ្តល់សេវា និងការបែងចែកលទ្ធផលការងារ អាចយកទៅចំណាយលើការលើកទឹកចិត្តបុគ្គលិកបន្ថែមលើ ៦០ ភាគរយនៃ ចំណែកប្រាក់ចំណូលពីថ្លៃសេវា និងមូលនិធិសមធម៌ សុខភាព។ បន្ថែមលើការផ្តល់មូលនិធិបដិភាគចំពោះកម្មវិធីកញ្ចប់ថវិកាសម្រាប់ផ្តល់សេវា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឯកភាពផ្តល់ថវិកាផ្អែកលើកម្មវិធី ដែលមានលក្ខណៈងាយបត់បែនដោយផ្ទាល់ទៅកាន់ភ្នាក់ងារប្រតិបត្តិការពិសេស។ ចាប់ពីឆ្នាំ ២០១១ មក វិភាជន៍ថវិកាតាមកម្មវិធីត្រូវបានផ្តល់ឱ្យភ្នាក់ងារប្រតិបត្តិការពិសេស តាមរយៈរតនាគារខេត្តជាជាងផ្តល់តាមរយៈក្រសួងសុខាភិបាលដូចដែលបានអនុវត្តកន្លងមក។

**ទីភ្នាក់ងារប្រតិបត្តិការពិសេស និងកញ្ចប់ថវិកាសម្រាប់ផ្តល់សេវាជួបបញ្ហាប្រឈមជាច្រើន ហើយមិនទាន់ត្រូវបានតម្រឹមឱ្យបានពេញលេញជាមួយគោលនយោបាយហិរញ្ញប្បទានរដ្ឋាភិបាល និងគោលនយោបាយមុខងារសាធារណៈនៅឡើយ។** បញ្ហាប្រឈមនានា រួមមាន ការចាត់ចែងមិនគ្រប់គ្រាន់ចំពោះការតាមដានលទ្ធផលអនុវត្តពីសំណាក់ក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលខេត្ត កង្វះភាពច្បាស់លាស់អំពីវិធានសម្រាប់ប្រើប្រាស់ជំនួយសម្រាប់ផ្តល់សេវា និងការផ្តល់មូលនិធិយឺតយ៉ាវរបស់រដ្ឋាភិបាលចំពោះចំណាយប្រតិបត្តិការ។ ខណៈដែលលទ្ធផលអនុវត្តមានការខុសគ្នាយ៉ាងច្រើនរវាងភ្នាក់ងារប្រតិបត្តិការពិសេសនានា ទិន្នន័យស្តីពីការតាមដានបង្ហាញថា ដោយមានករណីលើកលែងតិចតួច ទីភ្នាក់ងារប្រតិបត្តិការពិសេសបានរក្សាលទ្ធផល និងក្នុងករណីមួយចំនួន បានលើកកម្ពស់លទ្ធផលអនុវត្តរបស់ខ្លួនចំពោះសូចនាករសំខាន់ៗ។ ការទូទាត់ប្រាក់លើកទឹកចិត្តនៃកញ្ចប់ថវិកាសម្រាប់ផ្តល់សេវាចំពោះបុគ្គលិក អាស្រ័យលើហិរញ្ញប្បទានរបស់ម្ចាស់ជំនួយ ហើយគេនៅតែមិនដឹងច្បាស់ថា តើរាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈ ឬមានលទ្ធភាពក្នុងការផ្តល់ហិរញ្ញប្បទានកញ្ចប់ថវិកាសម្រាប់ផ្តល់សេវាក្នុងទម្រង់បច្ចុប្បន្នតាមរយៈថវិកា ឬយ៉ាងណា។ សកម្មភាពវាយតម្លៃជាច្រើនត្រូវបានគ្រោងសម្រាប់ទីភ្នាក់ងារប្រតិបត្តិការពិសេស និងសម្រាប់កញ្ចប់ថវិកាសម្រាប់ផ្តល់សេវានៅឆ្នាំ ២០១១ ដែលគប្បីជួយកែលំអអភិក្រមនេះបន្ថែមទៀត។ ជំហានសំខាន់នាពេលបន្ទាប់ គឺត្រូវធ្វើសមាហរណកម្មការតាមដានលទ្ធផលអនុវត្ត ការទូទាត់របស់អ្នកផ្តល់សេវា និងយន្តការត្រួតពិនិត្យនៃកញ្ចប់ថវិកាសម្រាប់ផ្តល់សេវាជាមួយនឹងយន្តការនៃមូលនិធិសមធម៌សុខភាព។

**នៅឆ្នាំ ២០០៧ ប្រាក់លើកទឹកចិត្តចំនួន ១៥ ដុល្លារ ត្រូវបានប្រកាសផ្ដល់ដល់ឆ្មបសម្រាប់ការសម្រាលកូននីមួយៗនៅមណ្ឌលសុខភាព (១០ ដុល្លារ នៅមន្ទីរពេទ្យរដ្ឋ) ដែលហាក់ដូចជាបានរួមចំណែកចំពោះការកើនឡើងនូវការសម្រាលកូនបែបនេះ។** ការចំណាយទៅឱ្យបុគ្គលិកនៅស្ថាប័នថ្នាក់កណ្ដាល និងនៅមន្ទីរពេទ្យជាតិមានទឹកប្រាក់ចំនួន ០,៣ លានដុល្លារ (ទិន្នន័យឆ្នាំ ២០០៥) និងចំណាយចំពោះឆ្មបនៅថ្នាក់ខេត្តមានចំនួន ១,៦ លានដុល្លារ (ឆ្នាំ ២០០៨) ។ ចំណាយចុងក្រោយនេះស្មើនឹង ១០ ភាគរយ នៃប្រាក់កម្រៃមូលដ្ឋានសម្រាប់បុគ្គលិកសុខាភិបាលនៅថ្នាក់ខេត្ត ។ រាជរដ្ឋាភិបាលកម្ពុជាបានប្ដេជ្ញាចិត្តរក្សាទុកនូវប្រាក់ឧបត្ថម្ភចំពោះឆ្មបរហូតដល់ឆ្នាំ ២០១៥ ហើយបន្ទាប់មកអាចនឹងដាក់បញ្ចូលទៅក្នុងគម្រោងហិរញ្ញប្បទានផ្នែកតម្រូវការ ឬផ្នែកផ្គត់ផ្គង់ដទៃទៀត ។

**គំនិតផ្តួចផ្តើមនានា និងប្រាក់លើកទឹកចិត្តដែលបានពិភាក្សាខាងលើផ្តល់នូវការឧបត្ថម្ភគាំទ្រ និងការជំរុញទឹកចិត្តបន្ថែមចំពោះបុគ្គលិកសុខាភិបាល ប៉ុន្តែចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងកំណែទម្រង់បៀវត្សរយៈពេលមធ្យម និងដាក់បញ្ចូលយុទ្ធសាស្ត្រហិរញ្ញប្បទានសុខាភិបាលដែលបានធ្វើបច្ចុប្បន្នកម្ម។** គំនិតផ្តួចផ្តើមនីមួយៗ ប្រើប្រាស់វិធានផ្សេងគ្នាក្នុងការបែងចែកប្រាក់ចំណូលដល់បុគ្គលិក ដោយគ្មានគោលការណ៍ណែនាំអំពីប្រាក់ចំណូលបន្ថែមចំនួនប៉ុន្មាន ដែលបុគ្គលិកអាចទទួល ឬគប្បីបានទទួល ។ ការណ៍នេះបង្កើតឱ្យមានហានិភ័យមួយ ដែលមន្ទីរពេទ្យនឹងបង្កើនថ្លៃសេវា ឬរិះរកវិធីបង្កើនប្រាក់ចំណូលឱ្យបានច្រើនពីសេវាដែលដោយតម្លៃខ្ពស់ ធ្វើឱ្យសេវាមិនសូវមានប្រសិទ្ធភាព ហើយអ្នកមានជីវភាពស្ទើរក្រីក្រ និងអ្នកនៅក្នុងផ្នែកក្រៅប្រព័ន្ធ ពុំសូវមានលទ្ធភាពទទួលសេវាពីមន្ទីរពេទ្យឡើយ ។ កំណែទម្រង់ហិរញ្ញប្បទានសុខាភិបាល និងកំណែទម្រង់ប្រាក់កម្រៃ គប្បីមានទំនាក់ទំនងជាមួយការបង្កើតយន្តការទូទាត់ ដែលបង្កើតប្រាក់លើកទឹកចិត្តសមស្រប ដើម្បីឱ្យមានគុណភាព ប្រសិទ្ធភាព និងសមធម៌សម្រាប់មន្ទីរពេទ្យនានា ហើយនៅតែធានាដល់ការផ្តល់ប្រាក់ឧបត្ថម្ភ និងប្រាក់លើកទឹកចិត្តសមស្របដល់បុគ្គលិកសុខាភិបាល ។ គម្រោងលើកទឹកចិត្តចំពោះចំណាយប្រតិបត្តិការអាទិភាពសម្រាប់បុគ្គលិកផ្តល់សេវា អាចត្រូវបានបូកសរុបនៅក្នុងគម្រោងលើកទឹកចិត្តនៃមូលនិធិសមធម៌សុខភាព ដែលត្រូវបានធ្វើសមាហរណកម្មបន្ថែម ។ ដើម្បីឱ្យមានប្រសិទ្ធភាពប្រាក់បៀវត្សខ្ពស់ និងច្រើនជាមុន តម្រូវឱ្យការតាមដាន និងការវាយតម្លៃលទ្ធផលការងាររបស់បុគ្គលិកមានប្រសិទ្ធភាព ។

# ខ. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ

**គោលដៅរយៈពេលវែងរបស់រដ្ឋាភិបាល គឺសម្រេចឱ្យបាននូវការគ្របដណ្តប់ជាសាកលជាមួយនឹងការថែទាំសុខភាព ប្រកបដោយគុណភាពក្នុងកម្រិតលំហសារពើពន្ធដែលមាន។** ការសម្រេចឱ្យបាននូវគោលដៅបែបនេះ តម្រូវឱ្យមានការកែលំអបន្ថែមនូវប្រសិទ្ធភាពចំណាយផ្នែកសុខាភិបាល ការគ្របដណ្តប់សុខាភិបាល និងគុណភាពនៃការផ្តល់សេវា។ សារៈសំខាន់នៃជំពូកនេះ គឺរដ្ឋាភិបាលអាចធ្វើឱ្យមានវឌ្ឍនភាពច្រើនឆ្ពោះទៅកាន់គោលដៅសុខាភិបាលរយៈពេលវែងរបស់ខ្លួន តាមរយៈការគួបផ្សំរវាងការទិញទំនិញសុខភាពដែលកាន់តែមានប្រសិទ្ធភាព ការប្រគល់ធនធានបន្ថែមទៅកាន់កម្រិតផ្តល់សេវា ការពង្រឹងគំនិតផ្តួចផ្តើមស្តីពីហិរញ្ញប្បទានសុខាភិបាលដើម្បីបង្កើតការលើកទឹកចិត្តសមស្រប ដើម្បីឱ្យសេវាមានគុណភាព និងសមធម៌ ការពង្រឹងការតាមដាន និងការវាយតម្លៃសេវាសាធារណៈ និងការកែលំអការគ្រប់គ្រងផ្នែកឯកជន ។

**មាគ៌ាទៅកាន់ការគ្របដណ្តប់ជាសាកលនឹងត្រូវណែនាំដោយសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយសំខាន់ៗ។** ទីមួយ រដ្ឋាភិបាលត្រូវបញ្ជាក់ចក្ខុវិស័យរយៈពេលវែងរបស់ខ្លួនចំពោះ "ភាពចម្រុះបែប" ដែលប្រាថ្នាចង់បានរវាងវិស័យសាធារណៈ និងផ្នែកឯកជនចំពោះការថែទាំសុខភាពបឋម និងវិស័យមន្ទីរពេទ្យ ។ ទីពីរ ត្រូវធ្វើសេចក្តីសម្រេចចិត្តអំពីតុល្យភាពរវាងហិរញ្ញប្បទាន ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ (រួមមាន ថាតើត្រូវរក្សាតម្លៃសេវាឱ្យនៅទាប ដោយបន្តផ្តល់ឧបត្ថម្ភធនផ្នែកផ្គត់ផ្គង់ ឬផ្ទេរធនធាន ច្រើនទៅកាន់ការផ្តល់ហិរញ្ញប្បទានលើផ្នែកតម្រូវការ) ។ ទីបី សមត្ថកិច្ចនានាត្រូវបញ្ជាក់ទំហំនៃស្វ័យភាពដែលត្រូវផ្តល់ឱ្យមន្ទីរពេទ្យ និងសេវាសុខភាពដទៃទៀត និងវិធីបង្កើតយន្តការហិរញ្ញប្បទាន និងបទប្បញ្ញត្តិនានាចាំបាច់នានា ដើម្បីធានាឱ្យប្រាកដថាអង្គភាពស្វយ័តនានាបំពេញអាណត្តិសង្គមរបស់ខ្លួន ។ ទីបួន រដ្ឋាភិបាលចាំបាច់ត្រូវដោះស្រាយបញ្ហាប្រឈម អំពីការផ្តល់ប្រាក់ឧបត្ថម្ភ និងការជំរុញទឹកចិត្តរបស់បុគ្គលិកសុខាភិបាល ដោយការបង្កើតគោលការណ៍ណែនាំច្បាស់លាស់ចំពោះការធ្វើការរដ្ឋផង និងឯកជនផង ព្រមទាំងបន្សី និងដាក់បញ្ចូលនូវគំនិតផ្តួចផ្តើមនានា ដែលព្យាយាមលើកទឹកចិត្តបុគ្គលិកសុខាភិបាលជាមួយនឹងរបៀបវារៈកំណែទម្រង់បៀវត្សដែលកំពុងវិវឌ្ឍ ។

ការសម្រេចឱ្យបាននូវគោលដៅរយៈពេលវែងតម្រូវឱ្យមានវិធានការរយៈពេលខ្លី និងរយៈពេលមធ្យម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការចំណាយសុខាភិបាល និងដំណើរការថវិកា។ គេអាចសន្សំប្រាក់បានយ៉ាងច្រើនពីអនុសាសន៍ជាក់លាក់ដូចតទៅ។

**ក្នុងរយៈពេលខ្លីបង្កើនប្រសិទ្ធភាពនៃការទិញឱសថ និងបរិក្ខារពេទ្យ :**

- **លើកកម្ពស់ប្រសិទ្ធភាពចំណាយលើឱសថ បរិក្ខារ និងសំភារៈពេទ្យ តាមរយៈលទ្ធកម្មដែលមានលក្ខណៈប្រកួតប្រជែងបន្ថែមទៀត និងតាមរយៈការកំណត់មូលដ្ឋានប្រៀបធៀបថ្លៃអន្តរជាតិ។** គេអាចសន្សំបាន ៥០ លានដុល្លារក្នុងមួយឆ្នាំ ឬមួយភាគបីនៃចំណាយសុខាភិបាលរបស់រដ្ឋាភិបាល ត្រូវជា ០,៤ ភាគរយ នៃ ផសស ។ ប្រើប្រាក់សន្សំដើម្បីបង្កើនអត្ថិភាពថ្នាំពេទ្យ និងដើម្បីផ្តល់ហិរញ្ញប្បទានចំពោះកម្មវិធីអាទិភាពដទៃនានា រួមមាន ជំហាននានាឆ្ពោះទៅកាន់ការគ្របដណ្តប់សុខាភិបាលសាកល ។

- **ការប្រែក្លាយឃ្លាំងឱសថកណ្តាលទៅជាគ្រឹះស្ថានរដ្ឋបាលសាធារណៈស្វយ័ត ទទួលខុសត្រូវទាំងការងារលទ្ធកម្ម និងការចែកចាយឱសថ និងបរិក្ខារពេទ្យ។** អង្គភាពដែលបានកែទម្រង់នឹងដំណើរការតាមគោលការណ៍ពាណិជ្ជកម្ម ដោយមានអាណត្តិសង្គមស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល ដែលរួមមានតំណាងមកពីក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ថវិកាផ្នែកឱសថនឹងត្រូវផ្ទេរទៅកាន់អង្គភាពសេវាដែលត្រូវទិញពីទីភ្នាក់ងារថ្មី លើកលែងតែក្នុងកាលៈទេសៈពិសេស (ដូចជា ដាច់ស្តុក ឬមុខទំនិញពិសេសសម្រាប់មន្ទីរពេទ្យជាតិ) ។

**រដ្ឋាភិបាលក៏ត្រូវបានស្នើឱ្យចូលរួមក្នុងការពិចារណាវិធានការរយៈពេលខ្លី ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសុខភាពផងដែរ :**

- **ធ្វើសមាហរណកម្ម និងបង្កើតឱ្យមានជំនួយផ្អែកលើលទ្ធផលអនុវត្តបញ្ចូលទៅក្នុងហិរញ្ញប្បទានផ្អែកតម្រូវការ ដើម្បីបង្កើនលទ្ធផលអនុវត្តរបស់មន្ទីរពេទ្យ ពង្រឹងគម្រោងផ្តល់ប្រាក់លើកទឹកចិត្តបច្ចុប្បន្ន ដើម្បីជំរុញទឹកចិត្តបុគ្គលិកសុខាភិបាល និងផ្សារភ្ជាប់កំណែទម្រង់ទាំងអស់នេះជាមួយកំណែទម្រង់ប្រាក់ខែរយៈពេលមធ្យម។** ធ្វើបច្ចុប្បន្នកម្មជំពូកស្តីពីហិរញ្ញប្បទានសុខាភិបាល រួមមាន ការធ្វើបច្ចុប្បន្នកម្មវិធានសម្រាប់បែងចែកប្រាក់ចំណូលជាមួយបុគ្គលិកសុខាភិបាល ។

- **ពង្រឹងការតាមដាន និងការវាយតម្លៃរបស់ទីភ្នាក់ងារប្រតិបត្តិការពិសេស និងកញ្ចប់ថវិកាសម្រាប់ផ្តល់សេវា និងដាក់បញ្ចូលជាមួយប្រព័ន្ធទូទាត់ដទៃទៀតសម្រាប់មូលនិធិសមធម៌សុខភាព និងការធានារ៉ាប់រងសុខភាពនៅក្នុងសហគមន៍។** ពិចារណាថា តើកញ្ចប់ថវិកាសម្រាប់ផ្តល់សេវាអាច : (i) ដាក់បញ្ចូលទៅក្នុងយន្តការផ្ទេរថវិកាតាមកម្មវិធីនៅក្នុងប្រព័ន្ធជាតិដែរ ឬយ៉ាងណា និង/ឬ (ii) ដាក់បញ្ចូលជាមួយមូលនិធិសមធម៌សុខភាព និងបញ្ចូលជាមួយប្រាក់ចំណាយផ្អែកតម្រូវការដទៃទៀត ធ្វើជាប្រាក់បង្វែរចម្រុះផ្អែកលើលទ្ធផលអនុវត្តទៅកាន់អង្គភាពផ្តល់សេវាសុខភាព ។

- **ការបង្កើនពន្ធច្រើនចំពោះថ្នាំជក់អាចជួយកាត់បន្ថយអត្រាជក់ និងកាត់បន្ថយបន្ទុកនៃជំងឺរ៉ាំរ៉ៃក្នុងពេលអនាគត ជាពិសេសសម្រាប់ប្រពលរដ្ឋក្រីក្រ។**

**ជាផ្នែកមួយនៃរបៀបវារៈកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការបង្កើនសមធម៌ និងប្រសិទ្ធភាពវិភាជន៍ធនធានរបស់ក្រសួងសុខាភិបាល :**

- **ប្រគល់ថវិកាប្រតិបត្តិការមួយចំណែកធំទៅកាន់ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យក្រោមថ្នាក់ខេត្ត។** បង្កើតអង្គភាពថវិកានៅមន្ទីរសុខាភិបាលខេត្ត និងប្រសិនបើអាច បង្កើតអង្គភាពថវិកានៅស្រុកប្រតិបត្តិ និងកម្រិតមន្ទីរពេទ្យ និង/ឬយកស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកខេត្តធ្វើជា "មណ្ឌលថវិកា" ដើម្បីបង្កលក្ខណៈចំពោះវិភាជន៍ថវិកា និងការតាមដានចំណាយ ។

- **លើកកម្ពស់ និងពង្រីកការរៀបចំថវិកាតាមកម្មវិធីទៅកាន់បណ្តាខេត្ត និងពិចារណាវិធីរកវិធី ដើម្បីវិភាជថវិកាបន្ថែមពីការផ្តល់មូលនិធិមិនមែនកម្មវិធីទៅកាន់ការផ្តល់មូលនិធិតាមកម្មវិធី។** ពិចារណាអំពីការយកលំនាំតាមអភិក្រមកម្រិតរដ្ឋបាល ក្រសួងអប់រំ យុវជន និងកីឡាប្រើប្រាស់ (ដូចជា ការថែទាំសុខភាពបឋម ការថែទាំសុខភាពមធ្យម) ហើយរក្សាលេខសំគាល់កម្មវិធីផ្សារភ្ជាប់ជាមួយ ផយអជ សម្រាប់ចំណាយនៅថ្នាក់កណ្តាល ។

- **កែលំអបន្ថែមនូវផែនការយុទ្ធសាស្ត្រថវិកា ដែលបំពេញបន្ថែមដោយដំណើរការផែនការប្រតិបត្តិប្រចាំឆ្នាំ។** ពង្រឹងការកសាងផែនការរយៈពេលមធ្យមនៅក្នុងក្រសួងសុខាភិបាលតាមរយៈដំណើរការផែនការបីឆ្នាំរំកិល ដោយផ្សារភ្ជាប់ជាមួយផែនការយុទ្ធសាស្ត្រថវិកា និងពង្រីកផែនការយុទ្ធសាស្ត្រថវិកា ដើម្បីដាក់បញ្ចូលហិរញ្ញប្បទានថ្នាក់ក្រោមជាតិ និងហិរញ្ញប្បទានបរទេស ។

- **បង្កើតលក្ខណៈវិនិច្ឆ័យដែលមានតម្លាភាព ដើម្បីវិភាជថវិកាទៅបណ្ដាខេត្ត។** រូបមន្តវិភាជន៍ យ៉ាងហោចណាស់គប្បីដាក់បញ្ចូលចំនួនប្រជាជន ចំនួនមន្ទីរពេទ្យ និងបើអាចធ្វើបាន បញ្ជាក់ស្ថានភាពនៃភាពក្រីក្រ ឬស្ថានភាពសុខភាពរបស់អ្នកដែលបានទទួលសេវា ។

**ពីរយៈពេលមធ្យមទៅរយៈពេលវែង សមត្ថកិច្ចនានាត្រូវបានអញ្ជើញឱ្យពិចារណាអំពីវិធានការនានា ដើម្បីធានាឱ្យមានការគាំពារសង្គមគ្រប់គ្រាន់ចំពោះពលរដ្ឋក្រីក្រ និងកាត់បន្ថយការចំណាយប្រាក់ពីហោប៉ៅផ្ទាល់ខ្លួន :**

- **ពង្រីក និងធ្វើសមាហរណកម្មមូលនិធិសមធម៌សុខភាព និងទម្រង់ផ្សេងៗ នៃការធានារ៉ាប់រងដោយស្ម័គ្រចិត្ត និងដោយកាតព្វកិច្ចទៅក្នុងរបបផ្ដល់ហិរញ្ញប្បទានពេញលេញខាងផ្នែកតម្រូវការ។** ការដាក់ឱ្យដំណើរការនូវការធានារ៉ាប់រងសុខភាពសង្គមចំពោះបុគ្គលិកផ្នែកឯកជន និងមន្ត្រីរាជការ គប្បីប្រព្រឹត្តិទៅតាមបែបសម្របសម្រួល ។ ការបង្កើត ការរៀបចំស្ថាប័នជាតិសមស្របសម្រាប់មូលនិធិសមធម៌សុខភាព និងការធានារ៉ាប់រងសុខភាពនៅក្នុងសហគមន៍ គឺជាអាទិភាពមួយសំខាន់ណាស់ ។ ការធានារ៉ាប់រងចំពោះបុគ្គលិកក្នុងវិស័យក្រៅប្រព័ន្ធ ចាំបាច់ត្រូវតែផ្ដល់ឧបត្ថម្ភធនដើម្បីពង្រីកការគ្របដណ្ដប់ ។ វិធានការនេះ ត្រូវបានប៉ាន់ស្មានថាត្រូវចំណាយ ១៦ លានដុល្លារក្នុងមួយឆ្នាំ ។

- **ធានាឱ្យពលរដ្ឋក្រីក្រ និងស្ទើរក្រីក្រមានលទ្ធភាពបានទទួលសេវាមន្ទីរពេទ្យ។** ការប្ដូរឆ្ពោះទៅកាន់ការរៀបចំផ្ដល់សេវាពាក់កណ្ដាលស្វយ័តចំពោះមន្ទីរពេទ្យនានា គប្បីអមដោយវិធានការ ដើម្បីដាក់កំហិតការបង្កើនថ្លៃសេវា និងដើម្បីបង្កើតការរៀបចំហិរញ្ញប្បទានសមស្រប ដើម្បីធានាគុណភាព និងធ្វើយ៉ាងណាដើម្បីឱ្យពលរដ្ឋក្រីក្រ និងស្ទើរក្រីក្របានទទួលសេវា ។

- **ពង្រឹងបទប្បញ្ញត្តិស្ដីពីការគ្រប់គ្រងថ្លៃសេវា និងធ្វើបច្ចុប្បន្នកម្មធម្មនុញ្ញហិរញ្ញប្បទានសុខាភិបាល។**

- **ពន្ធលើប្រាក់កម្រៃទំនងជាធ្វើឱ្យបាក់ទឹកចិត្តដល់ការចូលក្នុងវិស័យក្នុងប្រព័ន្ធនៃសកម្មភាពសេដ្ឋកិច្ច ហើយធ្វើឱ្យមានការគេចវេសពន្ធយ៉ាងច្រើន ពិសេសនៅបណ្ដាប្រទេសដែលមានកម្រិត ផសស ទាប ក្នុងពលរដ្ឋម្នាក់ៗ ហើយដែលមានសកម្មភាពក្រៅប្រព័ន្ធពាសពេញហើយនោះ។** សមត្ថកិច្ចនានា គប្បីជៀសវាងបង្កើនបន្ថែមនូវអត្រាពន្ធលើប្រាក់ខែ ។

# រចនាសម្ព័ន្ធ និងគុណភាពនៃចំណាយអប់រំ ៥

## ក. សេចក្តីផ្តើម

**កម្ពុជាសម្រេចបានវឌ្ឍនភាពជាខ្លាំងក្នុងការលើកកម្ពស់លទ្ធភាពបានទទួលការអប់រំបឋមសិក្សា និងឧត្តមសិក្សា។** ចំណុចផ្តោតការយកចិត្តទុកដាក់ឥឡូវនេះ ត្រូវពិនិត្យមើលលទ្ធភាពបានទទួលការអប់រំរបស់កុមារតូច និងការអប់រំនៅមធ្យមសិក្សា ហើយសំខាន់ជាងនេះទៅទៀតនោះ ត្រូវបង្កើនគុណភាពនៃលទ្ធផលនៃការអប់រំ និងដោះស្រាយបញ្ហាសមធមមិនទៅទូទាំងតំបន់នានានៅក្នុងប្រទេស។ ដូចនៅក្នុងផ្នែកដទៃទៀតដែរ ការអប់រំនៅកម្ពុជានៅតែពឹងផ្អែកជាខ្លាំងលើការគាំទ្ររបស់ម្ចាស់ជំនួយបរទេស ហើយសម្រេចបានវឌ្ឍនភាពជាខ្លាំងក្នុងការបន្សុីការគាំទ្រនេះជាមួយអាទិភាពនានារបស់រដ្ឋាភិបាល។ ប៉ុន្តែក្នុងកម្រិត ២,៣ ភាគរយ នៃ ផសស ចំណាយរួមរបស់រដ្ឋាភិបាលលើវិស័យអប់រំ "ទាំងធនធានផ្ទាល់ និងការគាំទ្ររបស់ម្ចាស់ជំនួយ" មានកម្រិតទាបជាងនៅបណ្តាប្រទេសដែលមានកម្រិតប្រាក់ចំណូលក្នុងម្នាក់ៗប្រហាក់ប្រហែលគ្នា និងទាបជាងប្រទេសភាគច្រើននៅអាស៊ីបូព៌ា។ ហេតុនេះ ចំណាយឯកជនលើវិស័យអប់រំមានទំហំធំប្រហាក់ប្រហែលនឹងទំហំចំណាយរួមរបស់រដ្ឋាភិបាលដែរ។ ខណៈដែលការចូលរួមរបស់គ្រួសារបែបនេះជួយពង្រឹងគណនេយ្យភាព វាក៏ធ្វើឱ្យមានសម្ពាធហិរញ្ញវត្ថុដល់គ្រួសារផងដែរ។ អត្ថិភាពនៃវិទ្យាស្ថានអប់រំជាន់ខ្ពស់របស់ឯកជន តម្រូវឱ្យមានការគ្រប់គ្រងកាន់តែហ្មត់ចត់ ដើម្បីធានាឱ្យមានស្តង់ដារអប់រំដែលមានសង្គតិភាព។

**ដូចនៅក្នុងវិស័យដទៃទៀតមួយចំនួនដែរ វិភាជន៍កាន់តែច្រើនចំពោះវិស័យអប់រំ អាចជួយលើកកម្ពស់គុណភាពនៃលទ្ធផល។** ទោះជាយ៉ាងណាក្តី ក្នុងស្ថានភាពដែលលំហសារពើពន្ធរួមជួបការលំបាក ជំហានដំបូង ចាំបាច់ត្រូវផ្តោតលើការរកចន្លោះប្រហោងនៅក្នុងវិស័យនេះ។ ការធ្លាក់ចុះជាខ្លាំងក្នុងការចុះឈ្មោះចូលរៀនក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗ ផ្តល់លទ្ធភាពសម្រាប់ការសន្សំយ៉ាងច្រើន ប្រសិនបើសមត្ថកិច្ចនានាបែងចែងធនធានសាឡើងវិញពីសាលារៀន និងបណ្តាស្រុកនានា ដែលការចុះឈ្មោះចូលរៀនធ្លាក់ចុះ។ ប្រសិនបើអាចមានលទ្ធភាពផ្នែកលំហសារពើពន្ធ ធនធានបន្ថែមអាចត្រូវបានប្រើ ដើម្បីធ្វើវិចារណកម្មប្រាក់កម្រៃគ្រូបង្រៀន ហើយផ្តល់ប្រាក់លើកទឹកចិត្តកាន់តែប្រសើរចំពោះគ្រូបង្រៀនដែលមានស្នាដៃល្អ ពង្រីកការអប់រំកុមារតូច និងទ្រទ្រង់កម្មវិធីអាហារូបករណ៍សម្រាប់ការអប់រំនៅមធ្យមសិក្សា ដែលធ្លាប់មានលទ្ធផលវិជ្ជមានច្រើនកាលពីពេលមុន។

**ជាទូទៅ ក្របខ័ណ្ឌនៃការកសាងផែនការ និងការរៀបចំថវិកាដំណើរការបានល្អប្រសើរ។** មានចង្កោមគោលដៅដែលត្រូវបានកំណត់ច្បាស់លាស់ អាចគ្រប់គ្រងបាន និងមានប្រព័ន្ធដំណើរការកម្មវិធីដែលតម្រឹមតម្រង់ធនធានថវិកា និងធនធានម្ចាស់ជំនួយ ឆ្ពោះទៅរកការឆ្លើយតបនឹងគោលដៅទាំងនោះ។ "សូចនាករញែកសំខាន់ៗ" តូចមួយ ត្រូវបានតាមដានយ៉ាងជិតស្និទ្ធជាមួយសូចនាករដទៃទៀត ដែលប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវិស័យអប់រំ (EMIS) ប្រមូល និងផ្តល់ទិន្នន័យដែលមានគុណភាពបានទាន់ពេលវេលា។ គេឃើញមានលទ្ធភាពលើកកម្ពស់អនុកម្មវិធីថវិកាតាមកម្មវិធី ដែលផ្តល់ថវិកាដំណើរការសាលារៀន តាមរយៈការរៀបចំនីតិវិធីនានាឱ្យមានប្រសិទ្ធភាព និងផ្តល់ស្វ័យភាពកាន់តែច្រើនចំពោះសាលារៀនលើមុខចំណាយថវិកាដែលបានឯកភាព និងការពិនិត្យឡើងវិញនូវទំនុកចិត្តហិរញ្ញវត្ថុលើមូលដ្ឋានសំណាកជាក្រោយ។ ចាំបាច់ត្រូវពង្រឹងសមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើប្រព្រឹត្តិកម្មទិន្នន័យសម្រាប់សេចក្តីសម្រេចចិត្ត ដែលទាក់ទងនឹងការរៀបចំ និងការអនុវត្តគោលនយោបាយ។ ជាពិសេសផែនការយុទ្ធសាស្ត្រអប់រំ (ESP) ចាំបាច់ត្រូវមានយន្តការមួយ ដើម្បីកែសម្រួលសកម្មភាពគោលនយោបាយលើមូលដ្ឋាននៃកម្រិតសមិទ្ធផល។ ចំណុចនេះមានសារៈសំខាន់ជាពិសេសតាមទស្សនវិស័យប្រចាំតំបន់ ព្រោះថាមានការប្រែប្រួលជាខ្លាំងចំពោះសូចនាករ និងធនធានមួយចំនួន ហើយការយកចិត្តទុកដាក់ផ្នែកគោលនយោបាយចាំបាច់ ត្រូវឆ្លើយតបចំពោះការប្រែប្រួលប្រចាំតំបន់ទាំងនោះ។

**ផ្នែកផ្សេងទៀតនៃជំពូកនេះ ត្រូវបានរៀបចំដូចតទៅ។ ផ្នែក ខ ពណ៌នាអំពីការរៀបចំវិស័យអប់រំនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល និងបង្ហាញសមិទ្ធផលក្នុងអំឡុងឆ្នាំ ២០០៦-២០១០ លើមូលដ្ឋាននៃលទ្ធភាពបានទទួលការអប់រំ គុណភាពអប់រំ និងការអភិវឌ្ឍស្ថាប័ន។** ផ្នែក គ វិភាគចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ ដោយផ្តោតលើការរៀបចំថវិកាតាមកម្មវិធី។ ផ្នែក ឃ ពិនិត្យមើលបញ្ហាគ្រូបង្រៀន និងប្រាក់កម្រៃរបស់គ្រូបង្រៀន និងផ្នែក ង ផ្តោតលើសៀវភៅសិក្សា។ ហិរញ្ញប្បទានគ្រួសារលើការអប់រំនៅកម្ពុជា ត្រូវបានស្វែងយល់ក្នុងផ្នែក ច។ ផ្នែក ឆ ពិភាក្សាចំណាយរបស់រដ្ឋាភិបាលមកលើឧត្តមសិក្សា។ ផ្នែក ជ បង្ហាញអនុសាសន៍គោលនយោបាយ។

## ២. សមិទ្ធផល និងបញ្ហាប្រឈមនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ

**ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) សម្រាប់ឆ្នាំ ២០០៦-២០១០ គ្របដណ្តប់ផ្នែកយុទ្ធសាស្ត្រចំនួនបី ដែលមានកន្សោមសូចនាករមួយតូច ដែលត្រូវបានកំណត់ច្បាស់លាស់។ ផ្នែកយុទ្ធសាស្ត្រនៃផែនការនេះគឺលទ្ធភាពបានទទួលការអប់រំ គុណភាពនៃការអប់រំ និងសមត្ថភាព។**

**គេឃើញមានវឌ្ឍនភាពរឹងមាំចំពោះផ្នែកយុទ្ធសាស្ត្រអំពីលទ្ធភាពបានទទួលការអប់រំនៅបឋមសិក្សា មធ្យមសិក្សា។** ការអប់រំកម្រិតមត្តេយ្យ និងកម្រិតមធ្យមសិក្សាបច្ចុប្បន្ន តម្រូវឱ្យបង្កើនការយកចិត្តទុកដាក់ផ្នែកគោលនយោបាយ ។ វឌ្ឍនភាព គួរជាទីចាប់អារម្មណ៍ខ្លាំងបំផុតក្នុងការលើកកម្ពស់លទ្ធភាពបានទទួលការអប់រំបឋមសិក្សា ដែលអត្រាចុះឈ្មោះចូលរៀនមានរហូតដល់ប្រមាណជា ៩៥ ភាគរយ នៅឆ្នាំ ២០១០ ពីអត្រាខ្ពស់រួចទៅហើយស្មើនឹង ៩១,៣ ភាគរយ នៅពេលចាប់ផ្តើមមានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០។ ការចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិត្រូវបានអនុវត្តលើសផែនការ រីឯឧត្តមសិក្សា ការចុះឈ្មោះចូលរៀនមានចំនួនជិតស្មើផែនការ (តារាងលេខ ១៥) ។ វឌ្ឍនភាពតិចតួចចំពោះការអប់រំកុមារតូច (អាយុ ៥ ឆ្នាំ) និងការអប់រំនៅមធ្យមសិក្សាបឋមភូមិ ។ វិធានការផ្នែកគោលនយោបាយនានា ទំនងជាតម្រូវឱ្យមានការយកចិត្តទុកដាក់ទាំងចំពោះការផ្តល់ទីតាំងសាលារៀន និងលទ្ធភាពរ៉ាប់រងចំណាយចំពោះមាតាបិតា ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំជាច្រើនសម្រាប់អនាគត គប្បីផ្តល់ការវិភាគអំពីមូលហេតុថា ហេតុអ្វីបានជាសូចនាករមួយចំនួន ដូចជាអត្រាចុះឈ្មោះចូលរៀននៅមធ្យមសិក្សាមិនបានអនុវត្តតាមផែនការ ហើយកំណត់វិធានការកែតម្រូវ ។

**ខណៈដែលអត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សាបានកើនឡើង ចំនួនសិស្សដែលបានចុះឈ្មោះចូលរៀនបានធ្លាក់ចុះប្រហែល ១២,៥ ភាគរយ ចាប់ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០១០។** ជាមួយគ្នានេះ ការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាទុតិយភូមិបានកើនឡើងប្រមាណជា ៥០ ភាគរយ ប៉ុន្តែការគ្របដណ្តប់នៅមានកម្រិតទាបជាង ២០ ភាគរយ នៃចំនួនប្រជាជន ។ កម្ពុជាអាចទាញយកអត្ថប្រយោជន៍នៃ "ភាគផលប្រជាសាស្ត្រ" អំពីថ្នាក់ដែលមានចំនួនសិស្សតិចជាងនេះចំពោះកម្រិតបឋមសិក្សា ប៉ុន្តែរក្សាទុលគ្រូបឋម និងកែតម្រូវទ្រង់ទ្រាយរូបវន្តនៃសាលារៀនឱ្យមានមតេយ្យសាលា ឬកម្រិតមធ្យមសិក្សា គឺជាការចាំបាច់ ។

**តារាងលេខ ១៥. លទ្ធភាពបានទទួលសេវាអប់រំកម្រិតបឋម និងមធ្យមសិក្សា**
(គិតជា ភាគរយ វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ)

| | ជាក់ស្តែងឆ្នាំ ២០០៥-០៦ | | ផែនការ ២០០៩-១០ | | ជាក់ស្តែង ២០០៩-១០ | | ផែនការ ២០១៣-១៤ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ចុះឈ្មោះចូលរៀនអាយុ ៥ ឆ្នាំ | ២៧,៣ | ២៧,៩ | ៥០ | ៥០ | ៣៩,៨ | ៤០,៥ | ៦០ | ៦០ |
| អត្រាទទួលសិស្សចូលរៀនពិត | ៨២,៦ | ៨១,៨ | ៩៥ | ៩៥ | ៩២,៤ | ៩២,៧ | ១០០ | ១០០ |
| អត្រាទទួលសិស្សចូលរៀនពិតនៅបឋមសិក្សា | ៩១,៣ | ៨៩,៧ | ៩៦ | ៩៦ | ៩៤,៨ | ៩៤,៦ | ៩៨ | ៩៨ |
| អត្រាទទួលសិស្សចូលរៀនពិតនៅមធ្យមសិក្សាបឋមភូមិ | ៣១,៣ | ៣០,៤ | ៥០ | ៥០ | ៣២,៦ | ៣៤,៦ | ៥២ | ៥២ |
| អត្រាទទួលសិស្សចូលរៀនពិតនៅមធ្យមសិក្សាទុតិយភូមិ | ១១,៣ | ៩,៩ | ១៨ | ១៧ | ១៩,៤ | ១៩,៤ | ២៤ | ២៤ |
| និស្សិតនៅឧត្តមសិក្សា | ៩១.០០០ | ២៩.០០០ | ១៦២.០០០ | ៥៨.០០០ | ១៤៥.០០០ | ៥២.០០០ | ២០៦.០០០ | ៩៦.០០០ |

*ប្រភព :* ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៩-២០១៣ ក្រសួងអប់រំ យុវជន និងកីឡា

**ការអប់រំកុមារតូចតម្រូវឱ្យមានការយកចិត្តទុកដាក់លើការរៀបចំគោលនយោបាយជាថ្មី ព្រោះមានអត្ថប្រយោជន៍សេដ្ឋកិច្ច សមធម៌ និងប្រសិទ្ធភាពជាច្រើនក្នុងការវិនិយោគក្នុងកម្រិតនេះ។** ការរៀបចំការថែទាំកុមារប្រកបដោយគុណភាពផ្តល់ អត្ថប្រយោជន៍ដល់ស្ត្រី ជាពិសេសស្ត្រីដែលមានប្រាក់ចំណូលទាប បង្កលក្ខណៈឱ្យពួកគេធ្វើការនៅក្រៅផ្ទះ។ កុមារដែលបានទទួលអត្ថប្រយោជន៍ពីការអប់រំកុមារតូច ក៏ទំនងជារៀនសូត្របានកាន់តែប្រសើរនៅកម្រិតឧត្តមសិក្សាផងដែរ។ ភស្តុតាងពីប្រទេសកម្ពុជាអំពីការធ្លាក់ចុះនូវសមត្ថភាពយល់ដឹងរបស់កុមារ ដោយសារគ្មានកម្មវិធីថែទាំកុមារប្រកបដោយគុណភាពមានលក្ខណៈធ្ងន់ធ្ងរ និងគួរឱ្យព្រួយបារម្ភ (រូបលេខ ៤៣)។ ក្រាហ្វិកបង្ហាញការធ្លាក់ចុះទៅតាមអាយុនូវពិន្ទុនៃការធ្វើតេស្តវាស់ស្ទង់សមត្ថភាព ដោយប្រើរូបភាព និងពាក្យសំដី (TVIP) និងការធ្លាក់ចុះនៃពិន្ទុក្នុងការធ្វើតេស្ត សមត្ថភាពគណនា សមត្ថភាពស្គាល់ពាក្យ និងសមត្ថភាពយល់កថាខណ្ឌខ្លីៗ (WJ) ពិសេសចំពោះកុមារដែលមកពីក្រុមគ្រួសារដែលមានប្រាក់ចំណូលទាប។

### រូបលេខ ៤៣. សមត្ថភាពយល់ដឹងរបស់កុមារកម្ពុជាវ័យក្មេងបានធ្លាក់ចុះ




*ប្រភព :* Naudeau, Martinez and Filmer, 2010

**ឧបសគ្គផ្នែកតម្រូវការ គឺជារបាំងចម្បងមួយចំពោះការចូលរៀននៅមធ្យមសិក្សា។** តម្លៃឱកាសនៃពេលវេលាចំណាយនៅសាលារៀន ទំនងជាកើនខ្ពស់ជាខ្លាំងចំពោះសិស្សនៅមធ្យមសិក្សាបឋមភូមិ។ ឧបករណ៍គោលនយោបាយមួយសម្រាប់ដោះស្រាយបញ្ហានេះ គឺកម្មវិធីអាហារូបករណ៍របស់រដ្ឋាភិបាល ដែលទទួលបានជោគជ័យជាខ្លាំងក្នុងការរក្សាកុមារឱ្យនៅរៀនក្នុងសាលា។ ការវាយតម្លៃហ្មត់ចត់មួយអំពីឥទ្ធិពលដែលប្រព្រឹត្តទៅក្រោមការឧបត្ថម្ភគាំទ្ររបស់ធនាគារពិភពលោក បង្ហាញថាមានឥទ្ធិពលយ៉ាងធំនៃកម្មវិធីអាហារូបករណ៍ ដែលបានផ្តល់អាហារូបករណ៍ (៤៥-៦០ ដុល្លារក្នុងមួយឆ្នាំ) ចំពោះសិស្សនៅមធ្យមសិក្សាបឋមភូមិ។ សិស្សដែលបានទទួលអាហារូបករណ៍ទំនងជាត្រូវបានចុះឈ្មោះចូលរៀន ២០ ភាគរយ ច្រើនជាងសិស្សដែលមិនបានទទួលអាហារូបករណ៍ (រូបលេខ ៤៤)។ ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ផ្នែកគោលនយោបាយក្នុងការរក្សាកម្រិតនៃការផ្តល់មូលនិធិចំពោះកម្មវិធីអាហារូបករណ៍ ហើយរក្សាផលដែលមិនងាយទទួលបានសម្រាប់កុមារមកពីគ្រួសារក្រីក្រ ពិសេសក្មេងស្រី។

### រូបលេខ ៤៤. ប្រូបាប៊ីលីតេបាន់ស្មានអំពីការចូលរៀន និងចុះឈ្មោះចូលរៀន ជាអនុគមន៍នៃចំណាត់ថ្នាក់




*ប្រភព :* Filmer and Schady, ធនាគារពិភពលោក ឆ្នាំ ២០០៩

**ការបង្កើនវឌ្ឍនភាពនៃគុណភាព - ជាផ្នែកទីពីរនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ - មានភាពយឺតយ៉ាវក្នុងការកែលំអលទ្ធភាពបានទទួលសេវាអប់រំ ដោយអត្រាសិស្សរៀនត្រួតថ្នាក់ និងអត្រាបោះបង់នៅតែមានកម្រិតខ្ពស់។** មានកុមារត្រឹមតែ ៣៨ ភាគរយ ដែលចុះឈ្មោះចូលរៀននៅថ្នាក់ទី ១ បន្តរៀនរហូតដល់ថ្នាក់ទី ៩។ អនុបាតសិស្ស-គ្រូមិនប្រែប្រួលច្រើនឡើយ ហើយគ្រូម្នាក់បង្រៀនសិស្សប្រហែល ៥០ នាក់ក្នុងថ្នាក់រៀនចង្អៀត មិនស្របតាមវិធីបង្រៀន និងរៀនសូត្រដែលមានប្រសិទ្ធភាពឡើយ។ គេឃើញមានភាពល្អប្រសើរខ្លះអំពីអត្រាត្រួតថ្នាក់ ប៉ុន្តែការរៀនត្រួតថ្នាក់នៅតែមានកម្រិតខ្ពស់ជាខ្លាំង ជាពិសេសនៅថ្នាក់ទី ១។ ជាងនេះទៅទៀត នៅកម្ពុជាការវាយតម្លៃសិស្សនៅមិនទាន់ដំណើរការបានរឹងមាំនៅឡើយ។ កន្លងមកប្រទេសកម្ពុជានៅមិនទាន់ចូលរួមជាមួយការវាយតម្លៃអន្តរជាតិ ដូចជា PISA ឬ TIMSS ជាដើម ទោះបីជាកម្ពុជាអាចចូលរួមក្នុងផ្នែកមួយនៃអាស៊ីអាគ្នេយ៍ ក្នុងការវាយតម្លៃទ្វីបអាហ្វ្រិកដែលនិយាយភាសាបារាំងក្តី។

**តារាងលេខ ១៦. ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ**

| | ជាក់ស្តែង ២០០៥-០៦ | | ផែនការ ២០០៩-១០ | | ជាក់ស្តែង ២០០៩-១០ | | ផែនការ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| **បឋមសិក្សា** | | | | | | | | |
| អនុបាតរវាងសិស្ស និងគ្រូ | ៥០,៨ | | ៤៥ | | ៤៩,២ | | ៤៥ | |
| អត្រាត្រួតថ្នាក់ | ១១ | ៩,៨ | ២ | ២ | ៨,៩ | ៧,៨ | ៥ | ៥ |
| អត្រាបោះបង់ | ១១,៦ | ១១,៩ | ៦ | ៥ | ៨,៣ | ៧,៩ | ៥ | ៥ |
| បន្តរៀនពីថ្នាក់ទី ១ ដល់ទី ៦ | ៤៩,៣ | ៤៨,៩ | ៧៥ | ៧៦ | ៦១,៧ | ៦៣,៨ | គ្មាន | គ្មាន |
| **មធ្យមសិក្សាបឋមភូមិ** | | | | | | | | |
| អនុបាតរវាងសិស្ស និងគ្រូ | ៣១,៧ | | ២៨,៥ | | ៣២,២ | | គ្មាន | |
| អត្រាត្រួតថ្នាក់ | ២,៥ | ១,៧ | ១ | ១ | ២,៣ | ១,៥ | ១ | ១ |
| អត្រាបោះបង់ | ២២,៨ | ២៤,៩ | ១៣ | ១៤ | ១៨,៨ | ១៩,៤ | ១២ | ១៤ |
| បន្តរៀនពីថ្នាក់ទី ១ ដល់ទី ៦ | ២៦,៣ | ២៤,៣ | ៥៤ | ៥៤ | ៣៧,២ | ៣៧,៩ | គ្មាន | គ្មាន |

*ប្រភព :* ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៩-២០១៣ ក្រសួងអប់រំ យុវជន និងកីឡា

**ការវាយតម្លៃសិស្សត្រូវបានអនុវត្តជាផ្នែកមួយនៃគម្រោង CESSP បង្ហាញលទ្ធផលល្អប្រសើរ ប៉ុន្តែចាំបាច់ត្រូវប្រឹងប្រែងបន្ថែមទៀតដើម្បីដាក់បញ្ចូលការវាយតម្លៃសិស្សទៅក្នុងទស្សនៈទូទៅ។** មានលទ្ធផលចំនួនពីរបែបពីការវាយតម្លៃថ្នាក់ជាតិលើមូលដ្ឋានសំណាក ដែលបង្កើតបានជាគម្រោង CESSP (សំណាកមានទំហំពី ៦.០០០ ទៅ ៧.០០០ និងមានលក្ខណៈតំណាងនៅថ្នាក់ជាតិ)។ លទ្ធផលបង្ហាញថា លទ្ធផលរៀនសូត្រនៅមានកម្រិតយ៉ាងទាបនៅថ្នាក់ទី ៣ ចំពោះការធ្វើតេស្តភាសាខ្មែរ និងគណិតវិទ្យា ប៉ុន្តែលទ្ធផលរៀនសូត្រត្រូវបានលើកកម្ពស់ជាខ្លាំងចាប់ពីឆ្នាំ ២០០៥-០៦ រហូតដល់ ២០០៨-០៩។ (ពិន្ទុភាសាខ្មែរជាមធ្យមបានកើនឡើងពី ៤០,៤ ភាគរយ ដល់ ៥៤,១ ភាគរយ)។ ចំពោះថ្នាក់ទី ៩ ពិន្ទុនៅមានកម្រិតស្ទេរស្មើ ៦៨ ភាគរយ ចំពោះភាសាខ្មែរ និងកើនឡើងពី ៤១,២ ភាគរយ ដល់ ៤៣,៨ ភាគរយ ចំពោះគណិតវិទ្យា។ ការវិភាគលម្អិតអំពីការប្រែប្រួលពិន្ទុនឹងជួយឱ្យដឹងថា តើការកែលំអបណ្តាលមកពីឥទ្ធិពលនៃការវាស់ស្ទង់ ឬដោយសារសមត្ថភាពសិស្សកើនឡើង។ ប្រសិនបើសមត្ថភាពសិស្សកើនឡើងសំខាន់ត្រូវព្យាយាមវិភាគទិន្នន័យដើម្បីយល់អំពីកត្តាធ្វើឱ្យមានការប្រែប្រួលបែបនេះ។

**ការវាយតម្លៃសិស្ស គឺជាវិធីល្អមួយសម្រាប់បង្កើនគុណភាពនៃប្រព័ន្ធអប់រំ ជាជាងការពឹងផ្អែកលើការវាស់ស្ទង់ធាតុចូល និងសូចនាករ ដូចជាអត្រាត្រួតថ្នាក់ជាដើម។** ពិន្ទុធ្វើតេស្តត្រូវបានបង្ហាញបានល្អនូវពិន្ទុអំពីការយល់ដឹង ដូចជាក្នុងករណីនៃ PISA ដែលសំណួរត្រូវបានថ្លឹងថ្លែងទៅតាមកម្រិតនៃការលំបាក ដើម្បីឱ្យទទួលបានព័ត៌មានពីរបាយពិន្ទុតេស្តទាំងមូល។ គេក៏អាចធ្វើតេស្តដើម្បីបង្កើនគណនេយ្យភាព និងផ្តល់យោបល់ត្រឡប់ទៅកាន់គ្រូ និងគណៈគ្រប់គ្រងសាលារៀនផងដែរ។ ដើម្បីសម្រេចបានបែបនេះ រដ្ឋាភិបាលចាំបាច់ត្រូវបង្កើនគុណភាពនៃការធ្វើតេស្ត និងរៀបចំធ្វើតេស្តសាកលទៀងទាត់ជាជាងការធ្វើតេស្តផ្អែកលើមូលដ្ឋានសំណាក។

**ការត្រួតពិនិត្យបឋមនូវស្ទង់នាករបរិមាណចំពោះការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាព - ជាផ្នែកទីបីនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ - បង្ហាញថាខ្វះវឌ្ឍនភាពចាប់ពីឆ្នាំ ២០០៦ រហូតដល់ឆ្នាំ ២០១០។** ចំណាយអប់រំបានធ្លាក់ចុះ ពី ១៨,៥ ភាគរយ នៃចំណាយចរន្តសរុបរបស់រដ្ឋាភិបាលនៅឆ្នាំ ២០០៦ មកត្រឹម ១៧ ភាគរយ នៅឆ្នាំ ២០០៩ និងត្រូវជា ២,៥ ភាគរយ នៃ ផសស នៅឆ្នាំ ២០០៩ (តារាងលេខ ១៧)។ កម្រិតចំណាយលើវិស័យអប់រំ ទុកឱ្យកម្ពុជាស្ថិតនៅក្រោយបណ្តាប្រទេសភាគច្រើន ដែលមានកម្រិតនៃប្រាក់ចំណូលក្នុងម្នាក់ៗប្រហាក់ប្រហែលគ្នា និងទាបជាងប្រទេសភាគច្រើននៅអាស៊ីបូព៌ា។ កម្មវិធីសកម្មភាពអាទិភាពលើកមុន ត្រូវបានជំនួសក្នុងអំឡុងផែនការយុទ្ធសាស្ត្រវិស័យអប់រំពីឆ្នាំ ២០០៦-២០១០ ដែលថវិកាកម្មវិធីជាផ្នែកមួយនៃកំណែទម្រង់ទូទៅរបស់រដ្ឋាភិបាលអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ចំពោះព័ត៌មានលម្អិត សូមមើលជំពូក ៦)។ អត្រាអនុវត្តថវិកាកម្មវិធីបានកើនឡើងពី ៦២,១ ភាគរយ នៅឆ្នាំ ២០០៧ ដល់ ៩០ ភាគរយ នៅឆ្នាំ ២០០៩។ ភាពពឹងផ្អែកលើជំនួយបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍បានធ្លាក់ចុះតិចជាងផែនការដែលបានគ្រោងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៦-១០ ដែលវាស់ស្ទង់ដោយ នាក់-ខែសរុប។ ទោះជាយ៉ាងណាក្តីគេមិនដឹងច្បាស់ទេថា នេះជាខ្នាតវាស់សមស្របក្នុងការកំណត់ភាពពឹងផ្អែកលើជំនួយបច្ចេកទេសរបស់ក្រសួង អប់រំ យុវជន និងកីឡា។

**តារាងលេខ ១៧. ការអភិវឌ្ឍស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពចំពោះបុគ្គលិកអប់រំចំពោះវិមជ្ឈការ**
(គិតជា ភាគរយ និង នាក់-ខែ)

| | ជាក់ស្តែង ២០០៦ | ផែនការ ២០០៩ | ជាក់ស្តែង ២០០៩ | ផែនការ ២០១៣ |
|---|---|---|---|---|
| អប់រំ (គិតជាភាគរយ នៃថវិកាចរន្តរបស់រដ្ឋាភិបាល) | ១៨,៥ | ២០,០ | ១៧,០ | ២១,០ |
| ចំណាយថវិកាកម្មវិធី (គិតជាភាគរយ នៃថវិកាកម្មវិធីសរុប ២០០៧) | ៦២,១ | ១០០ | ៨៩,៩ | ៩៥ |
| អង្គភាពអនុវត្តថវិកាកម្មវិធីត្រូវបានធ្វើសវនកម្មផ្ទៃក្នុង (គិតជាភាគរយ) | ៤២,៤ | ៤៥,០ | ១៦,៧ | គ្មាន |
| សាលារៀនដែលត្រូវធ្វើសវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ (គិតជាភាគរយ) | ៩ | ៥ | ១,១ | គ្មាន |
| ការគាំទ្របច្ចេកទេស (នាក់-ខែ) | ៥៧៦ | ៣៨២,៥ | ៥១៦ | ៣៣៩ |

*ប្រភព* : ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ក្រសួងអប់រំ យុវជន និងកីឡា

**សមត្ថកិច្ចនានាបានរៀបចំមូលដ្ឋានសម្រាប់ធ្វើការវាយតម្លៃកម្មវិធីអាហារូបករណ៍ចំពោះសិស្សមធ្យមសិក្សាបឋមភូមិ ហើយរបកគំហើញបឋមបង្ហាញអំពីឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំងពីអាហារូបករណ៍ចំពោះការចុះឈ្មោះចូលរៀន។** ប៉ុន្តែលទ្ធផលមិនទំនងជាត្រូវបានប្រើប្រាស់សម្រាប់គាំទ្រការបង្កើនចំណាយចំពោះអាហារូបករណ៍ឡើយ។ កម្មវិធីនេះ គឺជាឧទាហរណ៍មួយ ដែលការផ្តល់ហិរញ្ញប្បទានបានប្តូរពីធនធានរបស់ដៃគូបរទេសទៅកាន់ធនធានរបស់រដ្ឋាភិបាល។ សមត្ថកិច្ចគប្បីពិចារណាជាថ្មីឡើងវិញក្នុងការពង្រីកកម្មវិធីនេះ និងពង្រីកដែនសកម្មភាព ទោះជាមានជំនួយជាបន្តពីដៃគូអភិវឌ្ឍន៍ក្តី។

# គ. ចំណាយលើវិស័យអប់រំ លំនាំ និងនិន្នាការ

**ចំណាយលើវិស័យអប់រំបានកើនឡើងជាចំនួនដាច់ខាត ប៉ុន្តែបានធ្លាក់ចុះធៀបនឹង ផសស ស្របជាមួយការកាត់បន្ថយការគាំទ្ររបស់ម្ចាស់ជំនួយ។** ចំណាយទូទៅរបស់រដ្ឋាភិបាលលើវិស័យអប់រំ - រួមមាន ធនធានផ្ទាល់ខ្លួន (រដ្ឋាភិបាល) និងការគាំទ្ររបស់ម្ចាស់ជំនួយ - បានធ្លាក់ចុះពី ៣ ភាគរយ នៃ ផសស នៅឆ្នាំ ២០០៣ មកត្រឹម ២,៤ ភាគរយ នៅឆ្នាំ ២០០៩ (រូបលេខ ៤៥- តារាងលេខ ១៨ តារាងលេខ ១៩)។ ចំណាយលើវិស័យអប់រំដែលផ្តល់ហិរញ្ញប្បទានពីធនធានផ្ទាល់ (រដ្ឋាភិបាល) បានកើនឡើង ០,២ ភាគរយ នៃ ផសស ក្នុងរយៈពេលដូចគ្នា។ ចំណាយរដ្ឋាភិបាលមានកម្រិតទាបជាងកម្រិតចំណាយ ៣,៨ ភាគរយ នៃ ផសស នៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីបូព៌ា ៤,៦ ភាគរយ ជាមធ្យមនៅបណ្តាប្រទេស IDA និង ៤,៨ ភាគរយ មធ្យមភាគនៅលើពិភពលោក។ រួមជាមួយចំណាយគ្រួសារលើការអប់រំ ចំណាយអប់រំជារួមនៅកម្ពុជាបានធ្លាក់ចុះពីរង្វង់ ៦ ភាគរយ នៃ ផសស នៅឆ្នាំ ២០០៤ មកត្រឹមរង្វង់ ៥ ភាគរយ នៅឆ្នាំ ២០០៩ (ចំពោះការពិភាក្សាអំពីចំណាយគ្រួសារលើការអប់រំ សូមមើលចំណុចខាងក្រោម)។

**រដ្ឋាភិបាលបានដាក់ឱ្យដំណើរការថវិកាតាមកម្មវិធី នៅឆ្នាំ ២០០៧ បន្ទាប់ពីកម្មវិធីសកម្មភាពអាទិភាពក្រោមការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទូទៅរបស់រដ្ឋាភិបាល។** អប់រំ គឺជាវិស័យអាទិភាពមួយសម្រាប់រដ្ឋាភិបាល ដែលដំណើរការរៀបចំវិកា កំពុងត្រូវបានធ្វើឱ្យទំនើបដោយជោគជ័យដែលថវិកាកម្មវិធី ត្រូវបានគ្រោងសម្រាប់ការបង្កើនសមាមាត្រចំណាយក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំបច្ចុប្បន្ន។

**វិភាជន៍ថវិកាកម្មវិធីធំបំផុតក្នុងរយៈពេលបីឆ្នាំកន្លងទេ គឺសម្រាប់បង្កើនគុណភាពបឋមសិក្សា ហើយគ្រោងបន្តអនុវត្តនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-១៣។** ថវិកាប្រហែលពាក់កណ្ដាលនៅក្នុងអនុកម្មវិធី ១.២ គឺសម្រាប់ថវិកាប្រតិបត្តិការសាលារៀន ដែលត្រូវបានប្រើប្រាស់ដោយសាលារៀន ដើម្បីបានទទួលសម្ភារៈឧបទេស។ កម្មវិធីថវិកាកម្មវិធីជាច្រើនស្ថិតនៅក្នុងថវិកាមូលធន ដែលភាគច្រើនត្រូវបានដៃគូអភិវឌ្ឍន៍ផ្ដល់ហិរញ្ញប្បទាន។ ចំពោះអនុកម្មវិធី ១.២ អនុកម្មវិធីនេះ មានធនធានសម្រាប់ការសាងសង់សាលារៀន និងបន្ទប់អនាម័យ។

**រូបលេខ ៤៥. ចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំបានធ្លាក់ចុះធៀបនឹង ផសស ឆ្នាំ ២០០៣-២០០៩**
(គិតជា ភាគរយនៃ ផសស)




*ប្រភព :* ចំណាយអប់រំ ពី ECORYS ឆ្នាំ ២០១១ និង WDI

**តារាងលេខ ១៨. ចំណាយលើវិស័យអប់រំនៅកម្ពុជាមានកម្រិតទាបជាងគូប្រៀបធៀប**
(គិតជា ភាគរយនៃ ផសស វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ)

| | EAP | ECA | LAC | MNA | SAS | SSA | IDA | FTI | ពិភពលោក |
|---|---|---|---|---|---|---|---|---|---|
| មធ្យមភាគ | ៣,៨ | ៥,០ | ៥,០ | ៥,២ | ៤,៦ | ៤,៨ | ៤,៦ | ៤,៨ | ៤,៨ |
| មេដ្យាន | ៣,៥ | ៥,១ | ៤,៩ | ៥,៥ | ៣,៨ | ៤,៦ | ៤,២ | ៤,៦ | ៤,៨ |
| ខ្ពស់បំផុត | ៦,៣ | ៨,៣ | ១៣,៣ | ៨,៦ | ៧,៩ | ១៣,៣ | ១៣,៣ | ១៣,៣ | ១៣,៣ |
| តិចបំផុត | ១,៦ | ២,៦ | ២,៤ | ២,៧ | ២,៦ | ១,៤ | ១,៤ | ១,៤ | ១,២ |
| ប្រទេសដែលមានទិន្នន័យ/ ប្រទេសទាំងអស់ | ១២/៣៥ | ៣៣/៥៨ | ១៩/៣៦ | ៩/២១ | ៥/៨ | ២៤/៤៨ | ៣៨/៧៨ | ២៤/៣៧ | ១០៤/២០៩ |

*ប្រភព :* ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៩-២០១៣ ក្រសួងអប់រំ យុវជន និងកីឡា
*សំគាល់ :* EAP = អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក- ECA = អឺរ៉ុប និងអាស៊ីកណ្ដាល- LAC = អាមេរិកឡាទីន និងការ៉ាអ៊ីប - MNA = មជ្ឈឹមបូព៌ា និងអាហ្វ្រិកខាងជើង- SAS = អាស៊ីអាគ្នេយ៍- SSA = អាហ្វ្រិកខាងត្បូងវាលខ្សាច់សាហារ៉ា

**វិភាជន៍ថវិកាកម្មវិធីដទៃទៀត និងញ្ហាលេខធ្លោ។** ឧទាហរណ៍ កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ (អនុកម្មវិធី ១.៤) មុននេះត្រូវបានផ្ដល់ហិរញ្ញប្បទានដោយការគាំទ្រពីបរទេស ប៉ុន្តែសព្វថ្ងៃបានក្លាយជាផ្នែកមួយនៃថវិកាចរន្តរបស់រដ្ឋាភិបាល។ ថវិកាត្រឹមតែពាក់កណ្ដាលប៉ុណ្ណោះនៃថវិកាកម្មវិធីសម្រាប់អភិវឌ្ឍសៀវភៅសិក្សា (អនុកម្មវិធី៥.៣) ត្រូវបានចំណាយដោយសារមានបញ្ហាលទ្ធកម្មសៀវភៅសិក្សាសម្រាប់កម្រិតមធ្យមសិក្សានៅឆ្នាំ ២០០៨។ ការអភិវឌ្ឍធនធានមនុស្ស (អនុកម្មវិធី ៥.៤) ចំណាយមួយផ្នែកធំដោយកម្មវិធីមួយដែលផ្ដល់ប្រាក់រង្វាន់ចំពោះគ្រូបង្រៀននៅតំបន់ឆ្ងាយ ឬតំបន់ក្រីក្រ។ គប្បីពិចារណាដាក់បញ្ចូលនូវកម្មវិធីពិសេសមួយដើម្បីពង្រឹងអភិបាលកិច្ច (អនុកម្មវិធី ៥.៥) ទោះបីជាការអនុវត្តមិនបានល្អក្ដី។

**ការលើកកម្ពស់អាទិភាពក្នុងការពង្រីកការអប់រំកុមារតូច និងឧត្តមសិក្សា មានលក្ខណៈស្របគ្នាជាមួយកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការពង្រីកទំហំគ្របដណ្តប់។** ការពង្រីកថវិកាមូលធន មួយផ្នែកធំ គឺដោយសារការបង្កើនល្បឿនអនុវត្តកម្មវិធី EFA FTI-CF បន្ទាប់ពីបញ្ហាទាក់ទងនឹងលទ្ធកម្មកាលពីមុនត្រូវបានដោះស្រាយ។ កម្មវិធីទី ៣ សម្រាប់យុវជន និងកីឡា ត្រូវបានគ្រោងបង្កើនក្នុងទ្រង់ទ្រាយធំ ដោយសារកម្មវិធីនេះចាប់ផ្តើមពីកម្រិតទាបជាខ្លាំង។ ជាចុងក្រោយ ថវិកាសម្រាប់អនុកម្មវិធី ៥.៥ (ការកសាងប្រអប់សុវត្ថិភាព) ត្រូវបានគ្រោងបង្កើនពី ១,២ ពាន់លានរៀល នៅឆ្នាំ ២០០៩ ដល់ ១៨ ពាន់លានរៀល នៅឆ្នាំ ២០១១។ សំខាន់ រដ្ឋាភិបាលត្រូវពិនិត្យមើលកម្រិតនៃការអនុវត្តជាក់ស្តែងកន្លងមកនៅក្នុងកម្មវិធីចុងក្រោយ ដើម្បីធានាឱ្យមានការបន្សីគ្នាជាមួយអាទិភាពនានានៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ក្រៅពីចំណុចនេះ វិភាជន៍ថវិកាកម្មវិធីផ្សេងទៀត ព្រមទាំងឯកសារអមនិងវិចារណកម្មមានគុណភាពខ្ពស់ និងឆ្លុះបញ្ចាំងបានល្អអំពីសមត្ថភាពកសាងផែនការ និងកសាងថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ដំណើរការសម្រាប់កសាងផែនការ និងកសាងថវិកាចំពោះចំណាយអប់រំមានមូលដ្ឋានរឹងមាំ ដោយមានការធ្វើសមាហរណកម្មជិតស្និទ្ធរវាងតួលេខផែនការ វិធានការគោលនយោបាយ និងចំណាយ។** ឧបករណ៍ ថវិកាកម្មវិធីទំនងដូចជាមានដំណើរការល្អក្នុងវិស័យអប់រំ ថ្វីត្បិតតែមានផ្នែកថវិកាកម្មវិធីនីមួយៗ ដែលត្រូវធ្វើឱ្យមានប្រសិទ្ធភាពបន្ថែម។ បញ្ហាមួយនៃបញ្ហានានាអំពីការអនុវត្តថវិកាកម្មវិធី គឺកង្វះភាពបត់បែន និងស្វ័យភាព ដែលផ្តល់ទៅឱ្យអង្គភាពចំណាយនីមួយៗ ដែលធ្វើឱ្យការអនុវត្តថវិកាមានកម្រិតទាប និងមានការកាត់បន្ថយថវិកាជាបន្តបន្ទាប់។ ពិសេសជាមួយថវិកាប្រតិបត្តិការសាលារៀន ការបង្កើនស្វ័យភាពចំពោះសាលារៀន តាមរយៈប្រាក់លើកទឹកចិត្ត ដើម្បីជំរុញការអនុវត្តបានទាន់ពេលវេលា ដែលនឹងបង្កើនប្រសិទ្ធភាពកាន់តែខ្ពស់។ សមធម៌នឹងកើនឡើង ព្រោះភាពពឹងផ្អែកលើវិភាគទានមាតាបិតាសិស្សនឹងត្រូវបានកាត់បន្ថយ។

**តារាងលេខ ១៩. ចំណាយវិស័យអប់រំឆ្នាំ ២០០៩-១៣**
(គិតជា លានរៀល វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ)

| | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|
| (ក) ថវិកា រដ្ឋាភិបាល | ៥០៦.៦៤៤ | ៦៥៩.៩៧១ | ៧៥៤.៦៦៦ | ៨២៤.៨៧៩ | ៩៥០.១៨៥ | ១.០៤៦.៤១៩ | ១.១៦៥.៤១៥ |
| ប្រាក់កម្រៃ | ៣៧២.០៨៨ | ៤៣៥.៣៨៤ | ៥០៥.៧៤៩ | ៦០៩.៩៦០ | ៦៨៦.៨១៥ | ៧៥៦.៤៤៩ | ៨៤២.៣៨៨ |
| មិនមែនប្រាក់កម្រៃ | ១៣៤.៥៥៦ | ២២៤.៥៨៧ | ២៤៨.៩១៧ | ២១៤.៩១៩ | ២១៤.៩១៩ | ២៦៣.៣៧០ | ៣២៣.០២៦ |
| (ខ) ការគាំទ្ររបស់ម្ចាស់ជំនួយ | ៣៥៥.១៩៣ | ២៧៤.៣៨៤ | ២៦០.៥៣៥ | ៣១៤.៤៦២ | ៤០៨.៥៨៥ | ៤១២.៦៧២ | ៤១៧.២៥២ |
| ចំណាយសរុបរបស់រដ្ឋាភិបាល (ក + ខ) | ៨៦១.៨៣៧ | ៩៣៤.៣៥៥ | ១.០១៥.២០១ | ១.១៣៩.៣៤១ | ១.៣៤៤.៣២២ | ១.៤៧៦.៧១១ | ១.៦២៥.២៤១ |
| (គិតជាភាគរយនៃ ផសស) | ២,៥ | ២,២ | ២,៤ | ២,៤ | ២,៦ | ២,៦ | |
| ថវិកាកម្មវិធី | ៧៨.២៧២ | ៩២.៥៨៧ | ១១១.៧៤៥ | ១៦២.២៧២ | ២២៦.៥៥០ | ២៦៥.៦០១ | ៣០៤.១៣២ |
| គិតជាភាគរយនៃចំណាយចរន្ត | ១៥,៥ | ១៤,០ | ១៤.៨១ | ១៩,៧ | ២៤,២ | ២៥.០ | ២៥,២ |
| ***មុខចំណាយមួយពីថវិកាកម្មវិធី*** | | | | | | | |
| អប់រំទូទៅ | ៤៨.៥២៦ | ៦៤.០១១ | ៧៤.៣៩៤ | ១១១.៥៣៨ | ១៣៥.៨៩៦ | ១៥៤.១៣៨ | ១៧០.១៨៤ |
| អប់រំកុមារតូច | ៤៣៤ | ៦៤១ | ៦៨៦ | ៦.៥៥៣ | ៧.១៣០ | ៧.៧០០ | ៨.២៦៧ |
| គុណភាពអប់រំនៅបឋមសិក្សា | ៣០.០៤៦ | ៣៨.៤២៧ | ៤៣.៧៩៤ | ៤៣.៧៧៥ | ៤៤.៣៣១ | ៥៤.២៧០ | ៦០.៤៥៦ |
| អប់រំនៅមធ្យមសិក្សា | ១២.១៩៥ | ១៦.៩៨៣ | ១៨.៩៤៩ | ៣៦.៣៦០ | ៥០.១៣១ | ៥៥.៦៧២ | ៦២.១៩៣ |
| អាហារូបករណ៍សម្រាប់សិស្សក្រីក្រ | ៣.៤០៩ | ៤.០០១ | ៦.៤៣៨ | ៨.២៣០ | ៩.២៨០ | ១០.៣៤២ | ១១.៤៩៧ |
| ការពង្រីកការអប់រំក្រៅប្រព័ន្ធ | ២.៤៤១ | ៣.៩៥៩ | ៤.៥២៧ | ៦.៨៦០ | ៧.៧២៤ | ៨.៥០៥ | ៩.៤៧១ |
| ឧត្តមសិក្សា | ១.៦៧៧ | ២.៥០១ | ៣.០៦២ | ៣.៤៩៣ | ១៥.៤៣៩ | ២៧.៩០៨ | ៤១.៣៣៥ |
| អភិវឌ្ឍយុវជន និងកីឡា | ៥៣១ | ១.២៣៧ | ១.៤៩៦ | ២.៤១៧ | ២.៩៩៦ | ៣.៣៩០ | ៣.៨៨៤ |
| ការពង្រឹងអភិបាលកិច្ច | ៣០៩ | ៤៤១ | ៤៣៩ | ៧០៧ | ៩១៤ | ១៣២៧ | ១៤៩២ |

*ប្រភព :* ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣; ECORYS, ២០១១ សម្រាប់តួលេខសរុប ២០០៧-២០០៩; ក្រសួងអប់រំ យុវជន និងកីឡា និងថវិកា ២០០៧-២០០៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឃ. គ្រូបង្រៀន និងប្រាក់កម្រៃគ្រូបង្រៀន

**ទំហំប្រាក់កម្រៃសម្រាប់វិស័យអប់រំ បានកើនឡើងបួនដងគិតលើទំហំទឹកប្រាក់ជាក់ស្តែង ចាប់ពីដើមទសវត្សរ៍ ហើយបច្ចុប្បន្នស្មើនឹងបីភាគបួននៃចំណាយវិស័យអប់រំ។** គិតជាអត្រានៃ ផសស ទំហំប្រាក់កម្រៃបានកើនឡើងពី ០,៨ ភាគរយ នៃ ផសស កាលពីដើមទសវត្សរ៍ ដល់ ១,១ ភាគរយ នៅឆ្នាំ ២០០៩ ជាល្បឿនកំណើនខ្ពស់ជាងកំណើននៃចំណាយសរុបលើវិស័យអប់រំ ។ បួនភាគប្រាំនៃការកើនឡើង គឺដោយសារកំណើនប្រាក់កម្រៃ ដែលការដំឡើងប្រាក់កម្រៃប្រមូលផ្តុំក្នុងឆ្នាំ ២០០៦-២០០៨ ។ ទោះជាយ៉ាងណាក្តី បៀវត្សមធ្យមប្រចាំខែរបស់គ្រូបង្រៀនស្មើប្រមាណជា ១១៥ ដុល្លារ ដែលជាទូទៅមានកម្រិតស្មើគ្នាទៅនឹងអ្វី ដែលការសិក្សាថ្មីមួយមានចំណងជើងថា "ប្រាក់ឈ្នួលដែលអាចរស់បានសម្រាប់កម្មករកាត់ដេរ- the living wage for garment workers"[២៧] ។ គ្រូបឋមសិក្សាប្រហែល ៦៨ ភាគរយ និងគ្រូមធ្យមសិក្សា ៥០ ភាគរយ មានការងារទីពីរបន្ទាប់ពីម៉ោងធ្វើការធម្មតា ដើម្បីបំពេញបន្ថែមលើប្រាក់ចំណូលរបស់ខ្លួន[២៨] ។ មុខរបរទីពីរ គឺការបង្រៀនឯកជនមាន ៤២ ភាគរយ នៃគ្រូបង្រៀននៅកម្រិតបឋមសិក្សានៅតំបន់ទីក្រុង ( ៨៧ ភាគរយ នៃគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិនៅទីប្រជុំជន និងនៅទីជនបទ) ។ ការបង្រៀនឯកជនដោយគ្រូបង្រៀននៅសាលារដ្ឋ មានផលប៉ះពាល់ផ្នែកសមធម៌ និងគប្បីលុះបង់មុខរបរទីពីរនេះ ។

**កំណើនមួយភាគប្រាំលើបញ្ជីប្រាក់កម្រៃ គឺបណ្តាលមកពីការបង្កើនចំនួនគ្រូបង្រៀន។** ចំនួនគ្រូបង្រៀនបានកើនឡើងពី ៧១.០០០ នាក់ នៅឆ្នាំ ២០០១-០២ ដល់ ៨៣.០០០ នៅឆ្នាំ ២០០៩-១០ ប៉ុន្តែកំណើននៃការចុះឈ្មោះចូលរៀន មានន័យថា អនុបាតរវាងសិស្ស និងគ្រូនៅតែមានកម្រិតខ្ពស់ ( តារាងលេខ ២០) ។ ទោះជាយ៉ាងណាក្តី គេឃើញមានការលើកកម្ពស់គួរឱ្យកត់សំគាល់អំពីគុណវុឌ្ឍិរបស់គ្រូបង្រៀន ។ អត្រាគ្រូបង្រៀនដែលមានគុណវុឌ្ឍិត្រឹមតែមធ្យមសិក្សាបឋមភូមិ បានធ្លាក់ចុះ ៦៦ ភាគរយ នៅឆ្នាំ ២០០១-០២ មកត្រឹម ៤៥ ភាគរយ នៅឆ្នាំ ២០០៩ ។ យ៉ាងណាក៏ដោយ អត្រាគ្រូបង្រៀននៅកម្រិតឧត្តមសិក្សាមានការផ្លាស់ប្តូរតិចតួចប្រហែល ៧ ភាគរយ ។

**តារាងលេខ ២០. ស្ថានភាពគ្រូ និងទំហំប្រាក់កម្រៃរបស់គ្រូ ឆ្នាំ ២០០១/០២ ដល់ ២០០៩/១០**
( គិតជា ភាគរយ និងជាដុល្លារអាមេរិក)

| | ២០០១-០២ | ២០០២-០៣ | ២០០៣-០៤ | ២០០៤-០៥ | ២០០៥-០៦ | ២០០៦-០៧ | ២០០៧-០៨ | ២០០៨-០៩ | ២០០៩-១០ |
|---|---|---|---|---|---|---|---|---|---|
| បុគ្គលិកមិនបង្រៀន | ១១.១៤១ | ១១.៨៨៤ | ១៣.២៦៦ | ១៤.៥៩១ | ១៥.៦៤៣ | ១៦.៦៦៧ | ១៧.១៨០ | ១៧.៣៤០ | ១៧.១៣៥ |
| បុគ្គលិកបង្រៀន | ៧០.៦០៨ | ៧៣.៦៤២ | ៧៦.៣៥០ | ៧៧.៨៩៧ | ៧៨.៦០៦ | ៧៧.៩៧៤ | ៧៩.៨២៣ | ៨១.៣៥០ | ៨២.៨២០ |
| **របាយអាយុរបស់គ្រូបង្រៀន (គិតជា % នៃចំនួនសរុប)** | | | | | | | | | |
| អាយុយ៉ាងតិច ៣០ ឆ្នាំ | ៥,២ | ៥,៣ | ៥,១ | ៤,៨ | ៤,៧ | ៤,៤ | ៤,៦ | ៤,១ | ៣,៩ |
| ៣០-៣៩ ឆ្នាំ | ៦៥,៦ | ៦៣,១ | ៦០,៤ | ៥៩,២ | ៥៧,៩ | ៥៦,៦ | ៥៣,៧ | ៥០,១ | ៤៥,៦ |
| ៤០-៤៩ឆ្នាំ | ២៣,៣ | ២៥,៨ | ២៨,៦ | ៣០,២ | ៣២,០ | ៣៣,១ | ៣៥,៧ | ៣៨,៩ | ៤៣,១ |
| អាយុ ៥០ យ៉ាងតិច | ៥,៩ | ៥,៨ | ៥,៩ | ៥,៨ | ៥,៤ | ៥,៩ | ៦,១ | ៦,៩ | ៧,៣ |
| **របាយគ្រូបង្រៀនទៅតាមគុណវុឌ្ឍិអប់រំ (គិតជា % នៃចំនួនសរុប)** | | | | | | | | | |
| បឋមសិក្សា | ៤១ | ៣៨ | ៣៧ | ៣៧ | ៣៧ | ៣៦ | ៣៨ | ៣៩ | ៣៩ |
| មធ្យមសិក្សាបឋមភូមិ | ៣១ | ៣៦ | ៣៩ | ៤១ | ៤០ | ៤០ | ៣៩ | ៣៧ | ៣៤ |
| មធ្យមសិក្សាទុតិយភូមិ | ១៧ | ១៤ | ១២ | ១០ | ១០ | ៩ | ៩ | ១១ | ១៤ |
| ឧត្តមសិក្សា | ១០ | ១១ | ១១ | ១១ | ១២ | ១២ | ១២ | ១២ | ១១ |
| **ប្រាក់កម្រៃគ្រូបង្រៀនប្រចាំឆ្នាំ (គិតជាដុល្លារ)** | | | | | | | | | |
| ប្រាក់កម្រៃជាក់ស្តែង | ៤៥៥ | ៥៥១ | ៥៦៤ | ៥៧៧ | ៦២៩ | ៧៨៦ | ១១២១ | ១២៨៥ | ១៣៧៨ |
| PPP កែសម្រួល | ១៤៤៣ | ១៧៥៩ | ១៨៣៧ | ១៨៦៣ | ២០១៤ | ២៤៩០ | ៣៤១២ | ៣៥៥៦ | ៣៨៩៥ |

*ប្រភព : កម្រងទិន្នន័យ HRMIS រាយការណ៍ដោយ ECORYS ឆ្នាំ ២០១១*

---

*២៧ កងចាន់ដារាវត្តី និង លីវ ដាណែត ឆ្នាំ ២០០៩ "អង្កេតប្រាក់ឈ្នួល ដែលអាចរស់បានចំពោះឧស្សាហកម្មកាត់ដេរនៅកម្ពុជា- Living Wage Survey for Cambodia's Garment Industry" វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍កម្ពុជា-ប្រទេសកម្ពុជា*

*២៨ លទ្ធផលពីអង្កេត PETS ដូចបានពណ៌នាក្នុងរបាយការណ៍ធនាគារពិភពលោកឆ្នាំ ២០០៥*

**ប្រាក់លើកទឹកចិត្តសម្រាប់គ្រូបង្រៀនទៅធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាលទំនងជាមានប្រសិទ្ធភាព។** ចំនួនគ្រូបង្រៀននៅតំបន់ឆ្ងាយដាច់ស្រយាលបានកើនឡើងពី ៩៨៦ នាក់ នៅឆ្នាំ ២០០១-០២ ដល់ ១.៧៥០ នាក់ នៅឆ្នាំ ២០០៨-០៩ កំណើនបួនដង ស្មើនឹងទំហំកំណើននៃចំនួនគ្រូបង្រៀនសរុបនៅក្នុងប្រទេស។ អនុកម្មវិធីនៃថវិកាកម្មវិធី ៥.៤ បានបញ្ជូនប្រាក់ប្រហែល ២១ លានដុល្លារ ក្នុងរយៈពេល ៥ ឆ្នាំ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្នុងការផ្តល់ប្រាក់លើកទឹកចិត្តដល់គ្រូបង្រៀនឱ្យទៅធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាល។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំដាក់ផែនការពង្រាយ ៩៥ ភាគរយ នៃគរុសិស្សទើបចេញពីសាលាថ្មីៗទៅកាន់សាលារៀនដែលខ្វះបុគ្គលិកសាលា ដែលមានការខ្វះខាត និងសាលានៅតំបន់ឆ្ងាយដាច់ស្រយាល។

**គេលំបាករំពឹងថានឹងទទួលបានលទ្ធផលខ្ពស់ ខណៈដែលគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតទាប និងទទួលប្រាក់ខែតិច។** ប្រាក់ឈ្នួលខ្ពស់នៅផ្នែកផ្សេងទៀត ពិសេសក្នុងផ្នែកឯកជន កាត់បន្ថយចំនួនអ្នកដែលមានឆន្ទៈចង់ក្លាយជាគ្រូបង្រៀន។ ប្រាក់ខែទាបបានបង្ហាញឱ្យឃើញថាមានទំនាក់ទំនងជាមួយអវត្តមានរបស់គ្រូបង្រៀន។ ឧទាហរណ៍ ក្នុងអំឡុងពេលទស្សនកិច្ចមិនផ្តល់ដំណឹងជាមុន នៅឆ្នាំ ២០០៦ គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិប្រហែល ១៥,៦ ភាគរយ និងគ្រូបង្រៀនបឋមសិក្សា ៧ ភាគរយ អវត្តមាន [២៩]។ ករណីមានគ្រូជំនួសជាករណីកម្រ ហើយកង្វះគ្រូបង្រៀន មានន័យថា នៅសាលារៀនមានការរៀនសូត្រតិចតួច ឬគ្មានការរៀនសូត្រ។ ចាំបាច់ត្រូវបង្កើនប្រាក់ខែគ្រូបង្រៀនបន្ថែមទៀតក្នុងក្របខ័ណ្ឌនៃវិធានច្បាស់លាស់អំពីគុណវុឌ្ឍិ និងលទ្ធផលបង្រៀន។ ពិសេសបំផុតនោះ គឺការបង្កើនគុណភាពគ្រូបង្រៀន គឺជាកូនសោចំពោះវិបុលភាពនៅពេលអនាគត។ ការបណ្តោយឱ្យបាត់បង់គុណភាពគ្រូបង្រៀននឹងធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានរយៈពេលវែងមកលើប្រទេសកម្ពុជា។

## ខ. ការផ្តល់សៀវភៅសិក្សា

**សៀវភៅសិក្សា គឺជាធាតុចូលដ៏សំខាន់ដើម្បីឱ្យមានការអប់រំល្អ។ ចំណុចនេះពិត ជាពិសេសចំពោះចំនួនសិស្ស ៥០ នាក់ ឬច្រើនជាងនេះនៅក្នុងថ្នាក់រៀន។** ទោះជាយ៉ាងណាក្តី ការផ្តល់សៀវភៅសិក្សាជួបបញ្ហាបីយ៉ាង : មានថវិកាមិនគ្រប់គ្រាន់ បញ្ហាទាក់ទងនឹងកិច្ចលទ្ធកម្ម និងការចែកចាយសៀវភៅសិក្សា និងការរៀបចំមាតិកានៃសៀវភៅសិក្សា។ ខណៈដែលអនុបាតរវាងសិស្ស និងគ្រូបង្រៀនមានចំនួនប្រហែល ៥០ ការប្រាស្រ័យទាក់ទងបុគ្គលរវាងគ្រូ និងសិស្សមានតិចតួច ហើយសៀវភៅកាន់តែមានសារៈសំខាន់បន្ថែមទៀត ដើម្បីជួយសិស្សឱ្យរៀនតាមមេរៀន និងរៀនបន្ថែមក្រៅម៉ោងសិក្សា។ យកល្អ សិស្សម្នាក់ៗគប្បីមានសៀវភៅសិក្សាមួយចំនួនសម្រាប់មុខវិជ្ជានីមួយៗដែលសិស្សអាចយកទៅផ្ទះបាន ហើយត្រូវប្តូរសៀវភៅសិក្សារៀងរាល់បួនឆ្នាំម្តង។ សៀវភៅសិក្សាទាំងនេះត្រូវបន្ថែមលើសៀវភៅលំហាត់នានា។ មានកិច្ចការច្រើនណាស់ដែលត្រូវធ្វើ ដើម្បីឱ្យចំណុចនេះក្លាយជាការពិតនៅកម្ពុជា។

**ធនធានថវិកាសម្រាប់សៀវភៅសិក្សាមានមិនគ្រប់គ្រាន់។** ក្នុងអំឡុងឆ្នាំ ១៩៧៩-១៩៩៥ សៀវភៅសិក្សាដែលបានចែកចាយមានចំនួនមិនគ្រប់គ្រាន់ជាមួយនឹងការកើនឡើងនូវចំនួនសិស្ស ហើយកង្វះសៀវភៅសិក្សានេះមានសភាពធ្ងន់ធ្ងរ។ គម្រោងសៀវភៅសិក្សាសម្រាប់ការអប់រំមូលដ្ឋាន (BETP) ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី និងយូនីសេហ្វបានផ្តល់ ២៨ លានដុល្លារ ក្នុងអំឡុងឆ្នាំ ១០០៦-២០០២ (ប្រហែល ១៦ ពាន់លានរៀលក្នុងមួយឆ្នាំ)។ ចាប់តាំងពីឆ្នាំ ២០០២ មក ការផ្តល់សៀវភៅសិក្សាត្រូវបានដាក់បញ្ចូលទៅក្នុងថវិកាកម្មវិធីសកម្មភាពអាទិភាព។ អំឡុងឆ្នាំ ២០០២-២០០៦ ថវិកាកម្មវិធីសកម្មភាពអាទិភាពបានវិភាជន៍ប្រហែល ១៣ ពាន់លានរៀលក្នុងមួយឆ្នាំ។ មានប្រាក់តែមួយចំនួនប៉ុណ្ណោះ ដែលត្រូវបានចំណាយចាប់ពី ៧ ពាន់លានរៀល នៅឆ្នាំ ២០០៣ ដល់ ១២ ពាន់លានរៀល នៅឆ្នាំ ២០០៦។ ចាប់តាំងពីឆ្នាំ ២០០៧ មក សៀវភៅសិក្សា គឺជាផ្នែកនៃថវិកាកម្មវិធី ហើយវិភាជន៍បានកើនដល់ ១៩ ពាន់លានរៀល នៅឆ្នាំ ២០១១។

**មានលទ្ធភាពច្រើនក្នុងការកែលំអកិច្ចលទ្ធកម្ម និងការអភិវឌ្ឍសៀវភៅសិក្សា។** កម្មវិធីសិក្សាថ្មីត្រូវបានដាក់ឱ្យប្រើនៅឆ្នាំ ២០០៦ ប៉ុន្តែសព្វថ្ងៃមានសិស្សត្រឹមតែពាក់កណ្តាលប៉ុណ្ណោះដែលមានសៀវភៅសិក្សាថ្មី ហើយមានគ្រូបង្រៀនតិចតួចប៉ុណ្ណោះដែលបានទទួលសៀវភៅសម្រាប់គ្រូ។ រហូតមកទល់ពេលថ្មីៗនេះ ទីផ្សារសៀវភៅសិក្សាត្រូវបានផ្តាច់មុខដោយអង្គភាពរោងពុម្ពពាក់កណ្តាលសាធារណៈ។ ដើម្បីធានាឱ្យកុមារទាំងអស់មានសៀវភៅសិក្សា ហើយគ្រូបង្រៀនមានសៀវភៅសម្រាប់គ្រូ ចាំបាច់ត្រូវបង្កើនថវិកា

---

២៩ ធនាគារពិភពលោក ឆ្នាំ ២០០៨ - ការបង្រៀននៅកម្ពុជា- *Teaching in Cambodia*

ប្រហែល ២៥ ភាគរយ លើថវិកាបច្ចុប្បន្ន[៣០] ។ ដើម្បីបង្កើនគុណភាពនៃការផ្តល់ និងការអនុវត្តថវិកាសកម្មភាពកាលពីពេលថ្មីៗឆ្ពោះទៅរកការបើកទីផ្សារសៀវភៅសិក្សា ដើម្បីឱ្យមានការប្រកួតប្រជែងដោយមិនចំណុះរោងពុម្ពរដ្ឋ គឺជាប្រការត្រឹមត្រូវ ហើយត្រូវមាននិរន្តរភាព។ ទោះជាយ៉ាងណាក្តី មានបញ្ហាស្តីពីការរៀបចំសៀវភៅសិក្សា និងមានភាពមិនប្រាកដប្រជា ដែលកន្លងមកធ្វើឱ្យរាំងស្ទះដល់ការរីកចម្រើននៃក្រុមហ៊ុនរឹងមាំ រដ្ឋាភិបាលគប្បីពិនិត្យរកជម្រើសគោលនយោបាយដើម្បីអភិវឌ្ឍទីផ្សារ ដោយការញែកភារកិច្ចនៃការអភិវឌ្ឍសៀវភៅសិក្សាចេញពីការបោះពុម្ព និងការចែកចាយ។ ជម្រើសមួយដែលបានដំណើរការល្អនៅប្រទេសមួយចំនួន គឺការផ្តល់ចំណេងជើងខុសគ្នាចំពោះមុខវិជ្ជា និងថ្នាក់នីមួយៗ ហើយគ្រូបង្រៀន និងសហគមន៍សាលារៀន កំណត់ការជ្រើសរើសចំណេងជើងសមស្រប។

# ច. ចំណាយគ្រួសារចំពោះការអប់រំមូលដ្ឋាន

**ចំណាយផ្ទាល់របស់គ្រួសារចំពោះការអប់រំមានទំហំធំ។** គ្រួសារនៅកម្ពុជាបានចំណាយប្រមាណជា ១,១ ពាន់លានរៀល ក្នុងមួយឆ្នាំចំពោះការអប់រំ ឬប្រហែល ២,៥ ភាគរយ នៃ ផសស មានចំនួនដូចគ្នានៃចំណាយរបស់រដ្ឋាភិបាល ទាំងចំណាយពីធនធានផ្ទាល់ និងពីការគាំទ្ររបស់ម្ចាស់ជំនួយ (តារាងលេខ ២១)[៣១] ។

**ទំហំនៃការរួមវិភាគទានរបស់គ្រួសារបង្ហាញថា មាតាបិតាសិស្សមានចំណែកដ៏ធំអំពីគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំ។ ជាមួយគ្នានេះ ចំណាយដ៏ច្រើនទាំងនេះធ្វើឱ្យមានបន្ទុកធ្ងន់មកលើគ្រួសារ។** វិសមភាពដ៏ធំនៃចំណាយពីសំណាក់បញ្ចូភាគចំណូលផ្សេងគ្នា មានន័យថាមានសមភាពយ៉ាងច្រើនក្នុងការទទួលបានលទ្ធផល។ ការវិភាគដែលមានមូលដ្ឋានផ្អែកលើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ ២០០៨ បង្ហាញថា បញ្ចូភាគទាបបំផុតរួមចំណែក ៦ ភាគរយនៃចំណាយ ចំណែកឯបញ្ចូភាគខ្ពស់បំផុតរួមចំណែកច្រើនជាងពាក់កណ្តាល[៣២] ។ អាស្រ័យហេតុនេះ នៅក្នុងប្រព័ន្ធសាលារដ្ឋដូចគ្នា សិស្សមួយចំនួនមានបទពិសោធន៍ដែលមានលក្ខណៈផ្សេងគ្នា ព្រោះថាឪពុកម្តាយរបស់ពួកគេបំពេញបន្ថែមលើធនធានសាធារណៈដោយធនធានផ្ទាល់ខ្លួន ដូចជាតាមរយៈការទិញសៀវភៅសិក្សា ដែលរដ្ឋាភិបាលមិនផ្តល់ឱ្យ ឬតាមរយៈការទទួលបាននូវបង្រៀនពិឯកជន។ ករណីនេះនាំមកនូវចំណុចឃ្លាតគ្នាចំពោះលទ្ធផលនៃការអប់រំ ដែលហាក់ដូចជាធ្វើឱ្យវិសមធម៌សង្គមក្នុងជំនាន់កាន់តែមានសភាពធ្ងន់ធ្ងរ មានន័យថា កូនចៅរបស់គ្រួសារធូរធារបានទទួលការអប់រំល្អជាង ហើយពួកគេទំនងជាអាចរកការងារធ្វើក្នុងទីផ្សារពលកម្មបានប្រសើរជាង។ ជាលទ្ធផល ការអប់រំនៅសាលារដ្ឋពង្រីកវិសមធម៌សង្គមជាជាងកាត់បន្ថយវិសមធម៌សង្គម។

**តារាងលេខ ២១. ចំណាយគ្រួសារនៅតាមបញ្ចូភាគមិនដូចគ្នាឡើយ ឆ្នាំ២០០៩**
(គិតជា ពាន់លានរៀល)

| | បញ្ចូភាគទី ១ | បញ្ចូភាគទី ២ | បញ្ចូភាគទី ៣ | បញ្ចូភាគទី ៤ | បញ្ចូភាគទី ៥ | សរុប |
|---|---|---|---|---|---|---|
| ថ្លៃសាលា | ១៩,២២ | ១៥,៨៤ | ២៧,៩៥ | ៧៥,៣៤ | ២៥០,៨៦ | ៣៨៩,២៦ |
| ថ្លៃសិក្សា | ១១,៩០ | ១៣,២៩ | ២៥,០៤ | ៣៥,៤៧ | ៧៤,៧៨ | ១៦០,៤៩ |
| សៀវភៅសិក្សា | ១១,៦៣ | ១១,១៨ | ១៣,៩៥ | ២២,៣៤ | ៤០,៥១ | ៩៩,៦១ |
| សម្ភារៈដទៃទៀត | ១២,៧២ | ១១,០៩ | ១៥,០៨ | ២៣,៣៣ | ៣៧,៧៧ | ៩៩,៩៩ |
| ប្រាក់ឧបត្ថម្ភ | ២៦,៨៦ | ២៥,៤៦ | ២៦,៩៧ | ៤៤,៦៤ | ១០១,៣៦ | ២២៥,២៩ |
| ការធ្វើដំណើរ | ១១,៧០ | ១១,១៨ | ១១,៨៨ | ៣១,០២ | ៧៤,៦១ | ១៤០,៤០ |
| អំណោយសម្រាប់គ្រូ | ០,៨០ | ០,៧៦ | ១,៣៧ | ២,៤៨ | ៤,៥៩ | ១០,០០ |
| សរុប | ៩៤,៧០ | ៨៨,៨៣ | ១២១,៩៩ | ២៣៤,១៤ | ៥៨៣,២៩ | ១.១២២,៩៦ |

*ប្រភព* : អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ២០០៩។

*៣០ Fukao (2011a) ផ្តល់ព័ត៌មានលម្អិតអំពីការវិភាគតម្រូវការថវិកាប៉ាន់ស្មាន*
*៣១ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ ២០០៩*
*៣២ Fukao (2011b) ផ្តល់ការវិភាគខ្សែកោង Lorenz លើមូលដ្ឋានជាប្រភពនៃអំណះអំណាងនេះ*

## ឆ. ភាពជាដៃគូរវាងសាធារណៈ និងឯកជននៅឧត្តមសិក្សា

**ការចុះឈ្មោះចូលរៀនទាំងនៅវិទ្យាស្ថានរដ្ឋ និងឯកជននៅកម្រិតឧត្តមសិក្សាបានកើនឡើងជាខ្លាំងនៅទសវត្សរ៍ចុងក្រោយនេះ។** ការចុះឈ្មោះចូលរៀនបានកើនឡើងពីនិស្សិត ៨.៩០២ នាក់ នៅឆ្នាំ ១៩៩៨ ដល់ ១២៤.៩៤៧ នាក់ នៅឆ្នាំ ២០០៨ នៅតាមស្ថាប័នឧត្តមសិក្សារដ្ឋចំនួន ៣៤ (ភាគច្រើនជាស្ថាប័នស្វយ័ត) និងសាលាឯកជនចំនួន ៥៥ នៅលើបរិវេណសាលារៀនចំនួន ១១១ កន្លែង។ ស្ថានភាពនេះបានពង្រីកឱកាសឧត្តមសិក្សាទៅកាន់ប្រជាជនជាច្រើនផ្នែក។

**លក្ខណៈដោយឡែកនៃឧត្តមសិក្សានៅកម្ពុជា គឺហិរញ្ញប្បទានឯកជនដែលមានទំហំធំ។** ការចំណាយឯកជនបង់ថ្លៃសិក្សានៅសាកលវិទ្យាល័យឯកជន និងថ្លៃសាលារដ្ឋ។ ផ្ទុយទៅវិញ ចំណាយសាធារណៈនៅឧត្តមសិក្សាមានចំនួនតិចតួច ភាគច្រើនក្នុងទម្រង់ជាបៀវត្សនិងអាហារូបករណ៍មានចំនួន ៣,៣ ភាគរយ នៃចំណាយសាធារណៈសរុបលើវិស័យអប់រំនៅឆ្នាំ ២០០៧ ធ្វើឱ្យកម្ពុជាដើរយឺតជាប្រទេសជិតខាងរបស់ខ្លួន (តារាងលេខ ២២)។

**តារាងលេខ ២២. ចំណាយសរុបនៅឧត្តមសិក្សាគិតតាមប្រភពនៃការផ្តល់មូលនិធិ**
(គិតជា ពាន់ដុល្លារអាមេរិក វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ)

| | ឧត្តមសិក្សារដ្ឋ | ឧត្តមសិក្សាឯកជន | សរុប | គិតជា % នៃ ផសស |
|---|---|---|---|---|
| ការផ្តល់មូលនិធិសាធារណៈ | ៨.១៥០ | -- | ៨.១៥០ | ០,១ |
| ការផ្តល់មូលនិធិឯកជន | ១៤.៩៩៣ | ២៧.៣៦៤ | ៤២.៣៥៧ | ០,៥ |
| **សរុប** | **២៣.១៤៣** | **២៧.៣៦៤** | **៥០.៥០៧** | **០,៦** |

*ប្រភព :* Orivel (២០០៩)

**ចំណាយពិតនៅឧត្តមសិក្សាកំពុងធ្លាក់ចុះធៀបនឹង ផសស ក្នុងពលរដ្ឋម្នាក់ៗ មួយផ្នែកធំបណ្តាលមកពីការប្រកួតប្រជែងរវាងស្ថាប័នឧត្តមសិក្សានានាក្នុងការទាក់ទាញនិស្សិត។** ចំណាយបានធ្លាក់ចុះត្រឹម ៦៩ ភាគរយ នៃ ផសស នៅឆ្នាំ២០០៧ ពី ១៣០-១៦០ ភាគរយ នៅឆ្នាំ ២០០០។

**ការកើនឡើងយ៉ាងឆាប់រហ័សនូវលទ្ធភាព បានទទួលការអប់រំនៅឧត្តមសិក្សាដោយសារការផ្តល់សញ្ញាល្អពីផ្នែកឯកជនចំពោះកម្ពុជា ដោយសារកំណើននេះបង្ហាញតម្រូវការខ្ពស់ចំពោះការអប់រំ។** ដើម្បីប្រើប្រាស់ធនធានឯកជនទាំងនេះឱ្យមានប្រសិទ្ធភាពបំផុត រដ្ឋាភិបាលគប្បីពិចារណាការគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍន៍បន្ថែមនៅក្នុងផ្នែកអាទិភាពនានា ដែលមានភស្តុតាងសេដ្ឋកិច្ចគ្រប់គ្រាន់អំពីតម្រូវការអន្តរាគមន៍របស់រដ្ឋដោយសារមានកត្តាវិជ្ជមានពីខាងក្រៅ។ ផ្នែកឯកជន គឺជាដៃគូសំខាន់នៅក្នុងផ្នែកនេះ។ រដ្ឋាភិបាលក៏គប្បីផ្តោតការយកចិត្តទុកដាក់លើការកែលំអបទប្បញ្ញត្តិអំពីការបង្រៀនមុខវិជ្ជាពីសំណាក់សាលាឯកជនផងដែរ ដើម្បីធានាឱ្យមានគុណភាពអប់រំដូចគ្នា។ ការចូលរួមកាន់តែច្រើនពីសំណាក់ពលរដ្ឋ ក៏នឹងជួយទ្រទ្រង់តម្លាភាពក្នុងករណីនេះដែរ។

## ជ. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ

**នៅកម្ពុជាមានវឌ្ឍនភាពយ៉ាងច្រើនក្នុងការផ្តល់លទ្ធភាពឱ្យសិស្សបានទទួលការអប់រំនៅមធ្យមសិក្សា ប៉ុន្តែនៅមានកិច្ចការជាច្រើនដែលត្រូវធ្វើដើម្បីលើកកម្ពស់គុណភាពនៅបឋមសិក្សា ព្រមទាំងផ្តល់លទ្ធភាពឱ្យបានទទួលការអប់រំនៅកម្រិតសិក្សាដទៃទៀតប្រកបដោយគុណភាព។**

**បច្ចុប្បន្ន កម្ពុជាចំណាយ ២,៤ ភាគរយ នៃ ផសស លើវិស័យអប់រំស្របតាមគោលដៅនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។** ការចំណាយនេះមានកម្រិតទាបជាងជាខ្លាំងធៀបនឹងប្រទេសដទៃទៀត ដែលជាទូទៅមានចំណូលក្នុងពលរដ្ឋម្នាក់ប្រហាក់ប្រហែលគ្នា ប៉ុន្តែការបង្កើនចំណាយក្នុងកម្រិតនេះ អាចប្រព្រឹត្តិទៅបានត្រឹមកម្រិតដែលសមត្ថកិច្ចវិភាជន៍សាជាថ្មីនូវចំណាយក្នុងថវិកា ឬដោយធានាឱ្យមានជំនួយពីការគាំទ្ររបស់ម្ចាស់ជំនួយក្នុងកម្រិតនៃចំណាយរួមរបស់រដ្ឋាភិបាល និងឯកជន លើទំនិញសាធារណៈ។

**អាជ្ញាធរមានសមត្ថកិច្ចនានា ក៏ត្រូវបានស្នើឱ្យពិចារណាកន្លែងដែលនឹងត្រូវទំនេរ ដោយសារការធ្លាក់ចុះ ១២,៥ ភាគរយ នៃចំនួនសិស្សបឋមសិក្សាក្នុងរយៈពេលប្រាំឆ្នាំកន្លងមក។** កន្លែងនេះអាចត្រូវបានបន្ថែមដោយការកើនឡើងនូវការគាំទ្ររបស់ម្ចាស់ជំនួយ ប្រសិនបើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងជំនួយរបស់ម្ចាស់ជំនួយត្រូវបានតម្រឹមតម្រង់ ដូចបានពិភាក្សានៅក្នុងជំពូក ១ និង ២។ អាជ្ញាធរមានសមត្ថកិច្ចត្រូវពិចារណាធ្វើវិភាជន៍សាជាថ្មីនូវប្រាក់សន្សំពីការរៀបចំសាលារៀន និងបុគ្គលិក ដែលបណ្តាលមកពីការធ្លាក់ចុះនេះ និងសក្តានុពលនៃការបង្កើនជំនួយរបស់ម្ចាស់ជំនួយចំពោះផ្នែកខាងក្រោម :

- **ការអប់រំកុមារតូច :** ធនធានដែលបានវិភាជន៍ដើម្បីបង្កើនលទ្ធភាពបានទទួលការអប់រំកុមារតូច ចាំបាច់ត្រូវចំណាយឱ្យបានទាន់ពេលវេលា និងឱ្យបានសមស្រប។ ប្រើសាលាមតេយ្យរបស់រដ្ឋ សាលាមតេយ្យសហគមន៍ និងកម្មវិធីតាមផ្ទះដើម្បីពង្រីកកម្រិតនៃការផ្តល់ធនធាន។

- **ថវិកាសម្រាប់សៀវភៅសិក្សា :** ត្រូវកែលំអវិភាជន៍ថវិកាចំពោះសៀវភៅសិក្សា។ ការសម្រេចបានតាមផែនការ សៀវភៅសិក្សាមួយចំពោះមុខវិជ្ជាមួយសម្រាប់សិស្សម្នាក់ៗ យ៉ាងហោចណាស់ត្រូវការកំណើនវិភាជន៍ថវិកា ២៥ ភាគរយ និងដើម្បីឱ្យមានប្រសិទ្ធភាព។ ចំណាយប៉ាន់ស្មានមានចំនួនប្រហែល ០,០២ ភាគរយនៃ ផសស ក្នុងមួយឆ្នាំ។

- **កម្មវិធីអាហារូបករណ៍ :** ដោយមានការឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍ ចូរផ្តល់ធនធានបន្ថែមចំពោះអាហារូបករណ៍សិស្ស។ ចំណាយប៉ាន់ស្មានមានចំនួនប្រហែល ០,០៣ ភាគរយ នៃ ផសស ក្នុងមួយឆ្នាំ។

**ក្នុងរយៈពេលមធ្យម អនុសាសន៍ខាងក្រោមនឹងជួយលើកកម្ពស់លទ្ធផលនៃវិស័យអប់រំ**

- **ការកសាងផែនការយុទ្ធសាស្ត្រ :** ESP ឬផែនការយុទ្ធសាស្ត្រវិស័យអប់រំ ចាំបាច់ត្រូវអមដោយដំណើរការនៃការផ្តល់យោបល់ ការសម្រេចបាន ឬមិនសម្រេចបានផែនការត្រូវបានវិភាគ ហើយវិធានការកែតម្រូវត្រូវបានប្រកាន់យក រួមជាមួយការដាក់ផែនការសមស្រប។

- **គុណភាពសាលារៀន :** គុណភាពអប់រំតាមការវាស់ស្ទង់តម្រូវការវាយតម្លៃសិស្ស ចាំបាច់ត្រូវបញ្ជ្រាប និងពង្រីកពីអភិក្រមបច្ចុប្បន្នដែលផ្អែកលើគម្រោង។

# ៦ ការធ្វើឱ្យជំនឿទុកចិត្តចំពោះថវិកាមាននិរន្តរភាព និងការឈានឆ្ពោះទៅកាន់គណនេយ្យភាពហិរញ្ញវត្ថុកាន់តែខ្ពស់

## ក. សេចក្តីផ្តើម

**កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពយ៉ាងច្រើនក្នុងការកែទម្រង់គោលនយោបាយចំណាយសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ បន្ទាប់ពីចាប់ផ្តើមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅឆ្នាំ ២០០៤ មក (PFMRP)។** សមិទ្ធផលក្នុងការលើកកម្ពស់ទំនុកចិត្តថវិកានៅក្នុងជំហានទីមួយ - ដំណាក់កាលទីមួយនៃកម្មវិធី - គួរឱ្យកត់សំគាល់ ប៉ុន្តែការធ្វើឱ្យវឌ្ឍនភាពមាននិរន្តរភាពនៅតែជាបញ្ហាប្រឈមចម្បងមួយ ។ ភាពជឿទុកចិត្តនៃថវិកាត្រូវបានទទួល ទោះបីជាមានការធ្លាក់ចុះ និងមានចំណុចខ្វះខាតក្តី ។ ជំហានទីពីរ ពង្រីកកំណែទម្រង់នានា និងគ្រោងផ្តល់ការទទួលខុសត្រូវផ្នែកថវិកាកាន់តែធំទៅកាន់អ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងការលើកកម្ពស់យន្តការត្រួតពិនិត្យផ្ទៃក្នុង និងយន្តការគណនេយ្យភាព ។ អភិក្រមប្រុងប្រយ័ត្ន និងអនុវត្តតាមលំដាប់លំដោយមានភាពចាំបាច់ ដើម្បីបង្កើនការគ្រប់គ្រងបរិយាកាសផ្ទៃក្នុង ទន្ទឹមនឹងការផ្តល់ការទទួលខុសត្រូវទៅឱ្យនាយកដ្ឋាននានានៃក្រសួងពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអង្គភាពនានា ។

**ជំពូកនេះពិនិត្យមើលវឌ្ឍនភាពដែលសម្រេចបានចាប់តាំងពីឆ្នាំ ២០០៤ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផ្តល់ទិដ្ឋភាពទូទៅនៃការអនុវត្តចំណាយសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។** ជំពូកនេះ ពិនិត្យឡើងវិញនូវស្នាដៃសំខាន់នានានៃជំហានទីមួយ (២០០៤-២០០៨) និងគូសបញ្ជាក់បញ្ហាប្រឈមដែលនៅសេសសល់ ។ ជំពូកនេះ វិភាគកំណែទម្រង់ដែលបានកំណត់នៅក្នុងជំហានទី ២ ដោយមានការយកចិត្តទុកដាក់ពិសេសលើការអនុវត្តការគ្រប់គ្រងប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ ។ ការវិភាគនេះគូសបញ្ជាក់បញ្ហា និងហានិភ័យសំខាន់ៗ ដែលប្រឈមមុខចំពោះរដ្ឋាភិបាល គួបផ្សំជាមួយបញ្ហាប្រឈមពីរអំពីការថែរក្សាផលដែលសម្រេចបានក្នុងបណ្តាឆ្នាំកន្លងទៅ និងការធ្វើឱ្យចលករកំណែទម្រង់មាននិរន្តរភាព ។

**ការប្រព្រឹត្តិទៅនៃដំណើរការនានារបស់កម្ពុជាដើម្បីគ្រប់គ្រង និងចំណាយថវិកាសាធារណៈចាំបាច់ត្រូវរៀបចំក្នុងបរិបទទូលាយ អំពីវិធីដែលវិស័យសាធារណៈទាំងមូលដំណើរការ។** កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពចម្បងក្នុងការរៀបចំមូលដ្ឋានគ្រឹះនានា ដើម្បីក្លាយជារដ្ឋមួយមានប្រសិទ្ធភាពក្រោយពេលមានជម្លោះ ។ ជាមួយគ្នានេះ មានបញ្ហាជាច្រើនដែលធ្វើឱ្យរដ្ឋាភិបាលពិបាកផ្តល់សេវាសំខាន់ៗ ហើយការសិក្សាទាំងអស់លើកឡើងអំពីពុករលួយកម្រិតខ្ពស់ដែលនៅស្ថិតស្ថេរក្នុងសង្គម ។ ការបង្កើតអភិបាលកិច្ចដែលកាន់តែមានប្រសិទ្ធភាពប្រកបដោយតម្លាភាព និងមានមូលដ្ឋានផ្អែកលើវិធាន នៅតែជាចំណុចសំខាន់នៃបញ្ហាប្រឈមនៃការអភិវឌ្ឍរបស់កម្ពុជា (និងជាចំណុចសំខាន់នៃការគាំទ្ររបស់ធនាគារពិភពលោកសម្រាប់អនាគតរបស់កម្ពុជា) ។ សំខាន់ត្រូវទទួលចាត់ទុកការវិភាគ និងអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍នេះ ជាការលើកសរសើរចំពោះការងារ ដែលកំពុងប្រព្រឹត្តិទៅក្នុងការបង្កើនតម្លាភាព គណនេយ្យភាព និងការចូលរួម ហើយការលើកកម្ពស់តម្លៃនេះមានប្រភពចេញពីហិរញ្ញប្បទានសាធារណៈ អាស្រ័យលើវឌ្ឍនភាពនៅក្នុងផ្នែកទាំងពីរ ។

**ជំពូកនេះគូសបញ្ជាក់ផ្នែកធំៗចំនួនបួន ដែលត្រូវយកចិត្តទុកដាក់បន្ថែម និងត្រូវមានវិធានការ។** ទីមួយ ត្រូវបង្កើនកិច្ចសហការរវាងម្ចាស់ជំនួយ ដើម្បីបន្តគាំទ្រ និងធានាឱ្យថវិការក្សាបាននូវភាពជឿទុកចិត្ត ហើយកំណែទម្រង់ដែលបានគ្រោងនៅក្នុងជំហានទីពីរត្រូវបានអនុវត្តជឿនលឿនទៅមុខ ។ ក្នុងកម្រិតអប្បបរមា ការពិភាក្សាអំពីការរៀបចំរបាយការណ៍ចំណាយសម្រាប់គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ ដោយប្រើប្លង់គណនីរបស់រដ្ឋាភិបាល (COA) គប្បីត្រូវបានដោះស្រាយ ។ ទីពីរ ត្រូវពង្រឹងជាចាំបាច់នូវរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាឱ្យការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុទទួលជោគជ័យ ។ ទីបី ផែនការអនុវត្តរយៈពេល ៣ ឆ្នាំ (IP3) និងរបៀបវារៈកំណែទម្រង់ហិរញ្ញវត្ថុនៅថ្នាក់ក្រោមជិត ចាំបាច់ត្រូវតម្រឹមជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាឱ្យមានអភិក្រមមួយដែលអាចអនុវត្តបាន និងមានលំដាប់លំដោយចំពោះកំណែទម្រង់វិសហមជ្ឈការ និងវិមជ្ឈការ ។ ទីបួន សំខាន់ត្រូវចេញដំណើរពីកំណែទម្រង់រដ្ឋបាលសាធារណៈ និងប្រាក់ឧបត្ថម្ភ ដើម្បីទ្រទ្រង់កំណែទម្រង់ទូទៅរបស់រដ្ឋាភិបាល និងពង្រឹងគុណភាពនៃសេវាសាធារណៈ ។

**ផ្នែកផ្សេងទៀតនៃជំពូកនេះត្រូវបានរៀបចំដូចតទៅ។** ផ្នែក ខ ពិនិត្យមើលស្ថានភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា។ ផ្នែក គ ពិភាក្សាអំពីតម្រូវការក្នុងការអនុវត្តស៊ីជម្រៅចំពោះកំណែទម្រង់ជំហានទីមួយ និងបន្តសកម្មភាពក្រោមជំហានទីពីរ។ ផ្នែក ឃ ពិភាក្សាអំពីការអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ។ ផ្នែក ង វិភាគអំពីកំណែទម្រង់រដ្ឋបាលសាធារណៈ និងវិសហមជ្ឈការ និងវិមជ្ឈការ។ ផ្នែក ច បង្ហាញអនុសាសន៍ផ្នែកគោលនយោបាយ។

## ខ. ស្ថានភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ឯកសារវាយតម្លៃចំរុះលើទំនុកចិត្ត និងការពិនិត្យសើរើឡើងវិញលើចំណាយសាធារណៈឆ្នាំ ២០០៣ (IFAPER) បានសន្និដ្ឋានថាប្រព័ន្ធចំណាយសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុមិនបានល្អធ្វើឱ្យមានចំណាយខ្ពស់អំពីប្រសិទ្ធភាពវិភាជន៍ និងប្រតិបត្តិការ ហើយបានបង្កើតហានិភ័យយ៉ាងខ្ពស់លើទំនុកចិត្តចំពោះមូលនិធិសាធារណៈ។** ការអនុវត្តថវិការងនូវការអូសបន្លាយពេលវេលា និងការផ្តល់មូលនិធិដែលមិនអាចប៉ាន់ស្មានបាន ដោយសារកង្វះសាច់ប្រាក់ដែលបណ្តាលមកពីការគ្រប់គ្រងសាច់ប្រាក់មិនបានល្អ។ ការណ៍នេះធ្វើឱ្យមានបំណុលកកស្ទះ។ ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធរាយការណ៍មិនគ្រប់គ្រាន់ជាមួយនឹងបរិយាកាសគ្រប់គ្រងមិនបានល្អបង្កឱកាសឱ្យមានអំពើពុករលួយ។

**ភាពខ្វះចន្លោះក្នុងការរៀបចំ និងការអនុវត្តថវិកាធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពវិភាជន៍ និងប្រសិទ្ធផល ដែលធ្វើឱ្យការវិភាជន៍ធនធានមិនបានត្រឹមត្រូវនៅតាមវិស័យ និងតំបន់។** កិច្ចប្រឹងប្រែងពីមុនក្នុងការកែតម្រូវបញ្ហាទាំងនេះ បានប្រព្រឹត្តិទៅតាមរយៈគំនិតផ្តួចផ្តើមសាកល្បង រាប់ទាំងកម្មវិធីបង្កើនល្បឿនអភិវឌ្ឍន៍ស្រុក និងកម្មវិធីផែនការសកម្មភាព រួមជាមួយអភិក្រម "ទូទាំងវិស័យ" (Swap)។ អភិក្រមទាំងនេះបានលើកកម្ពស់ការតម្រឹមធនធានជាមួយគោលដៅផ្នែកគោលនយោបាយ ប៉ុន្តែត្រូវបានរាំងស្ទះដោយកង្វល់បច្ចុប្បន្នជុំវិញបរិយាកាសគ្រប់គ្រង និងសមត្ថភាពស្ថាប័នទន់ខ្សោយ បង្ហាញអលទ្ធភាពជារួមក្នុងការផ្តល់ប្រតិបត្តិការគាំទ្ររតនាគាររឹងមាំ។

**ដើម្បីដោះស្រាយរបៀបវារៈកំណែទម្រង់រួម និងមានលក្ខណៈជាប្រព័ន្ធ រដ្ឋាភិបាលបានបង្កើតកម្មវិធីផ្អែកលើអភិក្រមតាមជំហាន ដែលចែកជាដំណាក់កាលរយៈពេលវែងក្នុងខែធ្នូ ឆ្នាំ២០០៤។** "កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ : ការពង្រឹងអភិបាលកិច្ចតាមរយៈការលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុ" បានបង្ហាញផែនការសកម្មភាពលម្អិត និងចែកតាមលំដាប់លំដោយសម្រាប់កំណែទម្រង់។ ដោយសារការធ្វើឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្លាស់ប្តូរទៅតាមចក្ខុវិស័យ ជាកិច្ចការមួយដែលមានរយៈពេលវែង រដ្ឋាភិបាលបានកំណត់ដំណាក់កាលនានាក្នុងដំណើរការកំណែទម្រង់ ដែលត្រូវមានការប្តេជ្ញាចិត្តមុនពេលឈានទៅដំណាក់កាលបន្ទាប់។ ដំណាក់កាលនីមួយៗ ត្រូវបានរៀបចំដើម្បីផ្លាស់ប្តូរលទ្ធផលអនុវត្តនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផ្តល់មូលដ្ឋានសម្រាប់អនុវត្តជំហាននានាជាបន្ត។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ជំហានទីមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានគោលបំណងធ្វើឱ្យថវិកាក្លាយជាឧបករណ៍មួយ ដែលមានជំនឿទុកចិត្តសម្រាប់ការគ្រប់គ្រងដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងប្រតិបត្តិការនៃធនធានសាធារណៈ។** សកម្មភាពនានានៅក្នុងជំហានទីមួយផ្តោតលើការលើកកម្ពស់ការកៀរគរធនធាន (ការធ្វើឱ្យមាន និងប្រមូលចំណូលរដ្ឋាភិបាល) បង្កើនភាពពេញលេញ និងភាពត្រឹមត្រូវនៃថវិកា និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តថវិកា។ ភាពពេញលេញនៃថវិកាត្រូវបានលើកកម្ពស់ដោយការអនុម័តច្បាប់ថវិកាឆ្នាំ ២០០៨ និងការដាក់បញ្ចូលនូវមូលនិធិរបស់ម្ចាស់ជំនួយ ព្រមទាំងរួមបញ្ចូលមួយផ្នែកនូវចំណាយមូលនិធិផ្លូវផ្ទាល់។ ការដាក់ឱ្យប្រើផែនការយុទ្ធសាស្ត្រថវិកាចំពោះការចំណាយដែលផ្តល់មូលនិធិពីក្នុងស្រុក និងពីបរទេសជាមួយនឹងយុទ្ធសាស្ត្រវិស័យអាទិភាពដែលបានគណនាចំណាយបានជួយតម្រឹមថវិកាជាមួយវិស័យអាទិភាពនានា។

**ភាពជឿទុកចិត្តនៃថវិកាត្រូវបានលើកកម្ពស់ ដោយសារវិធានការជាច្រើន។** ទាំងនេះរួមមាន ការពង្រឹងដំណើរការរៀបចំថវិកា និងដំណើរការអនុវត្តថវិកា ការលើកកម្ពស់លទ្ធផលនៃការប្រមូលចំណូល និងការព្យាករណ៍ចំណូល ការធ្វើសុខុដុមភាវូបនីយកម្ម ចំណាត់ថ្នាក់ថវិកា និងប្លង់គណនី ការគ្រប់គ្រងសាច់ប្រាក់បានល្អ និងការដាក់ឱ្យមានដំណើរការពិនិត្យថវិកាឡើងវិញនៅពាក់កណ្តាលឆ្នាំ។ ក្របខ័ណ្ឌម៉ាក្រូ និងសារពើពន្ធរយៈពេលមធ្យមដែលមានលក្ខណៈប្រាកដនិយម (MTMFF) ត្រូវបានបង្កើត។ សម្រេចបាននូវវឌ្ឍនភាពក្នុងការប្រមូលផ្តុំគណនីធនាគាររបស់រដ្ឋាភិបាល ការពង្រឹងគណនីទោលនៅរតនាគារ (TSA) និងការពង្រីកការប្រើប្រាស់ធនាគារពាណិជ្ជចំពោះប្រតិបត្តិការនានារបស់រដ្ឋាភិបាល។ កិច្ចការនេះ រួមជាមួយការប្តូរទីតាំងសាជាថ្មីនៃអង្គភាពគ្រប់គ្រងសាច់ប្រាក់ទៅកាន់អគ្គនាយកដ្ឋានរតនាគារជាតិ បានជួយកែលំអការគ្រប់គ្រងសាច់ប្រាក់ ហេតុនេះធានាឱ្យមានលទ្ធភាពព្យាករណ៍ ភាពជឿទុកចិត្ត និង

ធានាឱ្យមានធនធានហិរញ្ញវត្ថុបានកាន់តែល្អប្រសើរ[៣៣]។ បំណុលកកស្ទះចំពោះការទូទាត់ ត្រូវបានលុបបំបាត់ដោយជោគជ័យនៅឆ្នាំ ២០០៧ ហើយគ្មានបំណុលកកស្ទះកើតឡើងសាជាថ្មីឡើងវិញឡើយចាប់តាំងពីឆ្នាំនោះមក (រូបលេខ ៤៦)[៣៤]។ ការអនុវត្តថវិកាក្រោមការតាមដានប្រចាំត្រីមាស ត្រូវបានកែលំអជាបណ្តើរៗពីអត្រាបើកផ្តល់ថវិកា ៦៤-៦៨ ភាគរយ ក្នុងអំឡុងឆ្នាំ ២០០៤-២០០៥ ដល់ ៩៣-៩៦ ភាគរយជាមធ្យម ក្នុងអំឡុងឆ្នាំ ២០០៦-២០១០ បង្ហាញឱ្យឃើញនូវការកែលំអដំណើរការកសាងផែនការលទ្ធកម្ម និងដំណើរការទូទាត់ដែលបានរៀបចំត្រឹមត្រូវ (រូបលេខ ៤៧) (សូមមើលសូចនាករលទ្ធផលអនុវត្តលម្អិតនៅត្រង់ចំណុចលេខ ១៤ នៃឧបសម្ព័ន្ធក្នុងអំឡុងឆ្នាំ ២០០៤-២០១០)។

**បានប្រកាន់យកនូវជំហានវិជ្ជមានសម្រាប់ពង្រឹងក្របខ័ណ្ឌលទ្ធកម្មសាធារណៈ និងបង្កើនបរិយាកាសលទ្ធកម្មជារួមនៅក្នុងប្រទេស។** ទាំងនេះរួមមាន ការអនុម័តអនុក្រឹត្យលេខ ១០៥ ស្តីពីលទ្ធកម្មនៅថ្នាក់ជាតិកាលពីខែ តុលា ឆ្នាំ ២០០៦ និងការបោះពុម្ព និងចេញផ្សាយវិធានទ្រទ្រង់ការអនុវត្ត និងបទប្បញ្ញត្តិសម្រាប់លទ្ធកម្មសាធារណៈ (IRRPP) រាប់ទាំងឯកសារស្តង់ដារសម្រាប់ដេញថ្លៃ (SBDs) កាលពីខែ កក្កដា ឆ្នាំ ២០១០ ផងដែរ។ ទាំងអស់នេះចាំបាច់ត្រូវអនុវត្តដោយអង្គភាពទាំងអស់របស់រដ្ឋាភិបាលក្នុងការធ្វើលទ្ធកម្មដោយប្រើប្រាស់ថវិកា។

**រូបលេខ ៤៦. បំណុលកកស្ទះចំពោះការទូទាត់បានធ្លាក់ចុះយ៉ាងលឿន និងត្រូវបានលុបបំបាត់ទាំងស្រុងនៅឆ្នាំ ២០០៧...**
(គិតជា ពាន់លានរៀល)




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**រូបលេខ ៤៧. ...ខណៈដែលការបើកផ្តល់ថវិកានៅចុងត្រីមាស ត្រូវបានកែលំអយ៉ាងឆាប់រហ័ស**
(គិតជា ភាគរយនៃថវិកាប្រចាំឆ្នាំ)




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្ម ដែលធ្វើសមាហរណកម្មប្រព័ន្ធលទ្ធកម្ម ដែលផ្តល់ហិរញ្ញប្បទានពីក្នុងស្រុក និងពីម្ចាស់ជំនួយ គ្រោងបញ្ជូនទៅកាន់សភាចុងឆ្នាំនេះ។** ទន្ទឹមនឹងនេះ ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំកិច្ចលទ្ធកម្មចំពោះគម្រោងដែលទទួលហិរញ្ញប្បទានពីបរទេសជិតត្រូវបានបញ្ចប់។ សៀវភៅណែនាំនេះដាក់បញ្ចូលមតិយោបល់ ដែលបានទទួលក្នុងអំឡុងប្រាំឆ្នាំចុងក្រោយ អំពីការប្រើ និងផ្តល់ការណែនាំ និងនីតិវិធីបន្ថែម ដើម្បីបង្កលក្ខណៈឱ្យការអនុវត្តរបស់អង្គភាពអនុវត្តគម្រោងមានប្រសិទ្ធភាព។ សំណើជាច្រើនសម្រាប់ពង្រឹងសមត្ថភាពលទ្ធកម្មរបស់រដ្ឋាភិបាល ក៏កំពុងត្រូវបានពិចារណាផងដែរ។

**ការវាយតម្លៃមួយចំពោះប្រព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងលទ្ធផលអនុវត្តន៍ជារួមរបស់រដ្ឋាភិបាល ដោយប្រើប្រាស់ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) បានប្រព្រឹត្តិទៅនៅឆ្នាំ ២០០៩[៣៥]។** ការវាយតម្លៃនោះបានបង្ហាញអំពីការពង្រឹងជំនឿទុកចិត្តថវិកា ដែលថាថវិកាសព្វថ្ងៃផ្តល់នូវសញ្ញាណត្រឹមត្រូវនៃធនធានហិរញ្ញវត្ថុជាក់ស្តែងចំពោះអង្គភាពចំណាយសម្រាប់ផ្តល់សេវានានា តាមរយៈលទ្ធភាពព្យាករណ៍ចំណូលបានកាន់តែប្រសើរ និងការគ្រប់គ្រងចំណាយបានល្អប្រសើរ។

---

៣៣ *Cambodia PFMR – Review by the External Advisory Panel, ខែ កុម្ភៈ ឆ្នាំ ២០១០*

៣៤ *បំណុលកកស្ទះចំពោះការទូទាត់ត្រូវបានកំណត់ថាជាការកកស្ទះបញ្ជេចំណាយរយៈពេល ៩០ ថ្ងៃ ឬយូរជាងនេះ។*

៣៥ *ការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា៖ លើមូលដ្ឋាននៃក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ របាយការណ៍ស្ថាពរ ខែ កុម្ភៈ ឆ្នាំ ២០១០។*

**ការប្រៀបធៀបក្នុងតំបន់បង្ហាញថា ពិន្ទុកម្ពុជាចំពោះក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុមានកម្រិតខ្ពស់ជាង ឬប្រហាក់ប្រហែលប្រទេសឡាវផងដែរ ប៉ុន្តែទាបជាងប្រទេសថៃ**[៣៦]។ ពិន្ទុកម្ពុជាមានកម្រិតខ្ពស់បំផុតលើទិដ្ឋភាពកសាងផែនការដែលផ្អែកលើគោលនយោបាយក្នុងចំណោមប្រទេសទាំងបី (សូមមើលចំណុចទី ១៦ នៃឧបសម្ព័ន្ធ)។

**គម្រោងផ្តល់លាភការបន្ថែមដោយផ្អែកទៅតាមគុណសម្បត្តិការងារ (MBPI) ដែលបានដាក់ឱ្យដំណើរការក្នុងអំឡុងដំណាក់កាលទី ១ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានសារៈសំខាន់ក្នុងការជំរុញឱ្យបុគ្គលិកចូលរួមនៅក្នុងកម្មវិធីកំណែទម្រង់។** ទោះបីជាមានការលំបាកនានាក្នុងពេលបច្ចុប្បន្នក្នុងការសម្របសម្រួល និងសហប្រតិបត្តិការរវាងនាយកដ្ឋាននឹងនាយកដ្ឋានក្តី គេឃើញមានផ្លាស់ប្តូរជាច្រើន។ ប្រធានគ្រប់គ្រងមួយចំនួនបានណែនាំគំនិតស្តីពីការគ្រប់គ្រងចំពោះការផ្លាស់ប្តូរ និងបានកែសម្រួលដំណើរការការងារ ហើយទទួលបានលទ្ធផលល្អ[៣៧]។

**ជំហានទីពីរ ពង្រីកកំណែទម្រង់នានា និងមានគោលបំណងប្រគល់ការទទួលខុសត្រូវកាន់តែធំចំពោះថវិកាដល់ប្រធានគ្រប់គ្រងកម្មវិធីតាមរយៈការបង្កើនយន្តការគ្រប់គ្រងផ្ទៃក្នុង និងយន្តការគណនេយ្យភាព។** យុទ្ធសាស្រ្តដែលមានគោលដៅពីរនេះ តម្រូវឱ្យមានវិធីសាស្រ្តថ្លឹងថ្លែងតុល្យភាព និងគិតគូរអំពីលំដាប់លំដោយឱ្យបានច្បាស់លាស់។ ការប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកាលពីខែ ធ្នូ ឆ្នាំ ២០០៨ សកម្មភាពកំណែទម្រង់ជំហានទីពីរ ត្រូវបានផ្តួចផ្តើមនៅក្នុងរដ្ឋាភិបាល និងនៅតាមក្រសួងពាក់ព័ន្ធ។ សេចក្តីសម្រេចក្នុងការគ្របដណ្តប់លើរដ្ឋាភិបាលទាំងមូល ធ្វើឱ្យមានការអនុវត្តមានភាពមិនស្មើគ្នា និងមានការអូសបន្លាយការអនុវត្តដែលមានល្បឿនយឺតស្រាប់។ ការចាត់ចែងផ្នែកស្ថាប័ន ដូចជាការបង្កើតឱ្យមានភ្នាក់ងារលទ្ធកម្មឯករាជ្យ (IPA) ធ្វើឱ្យរាំងស្ទះចំពោះវឌ្ឍនភាព។ ជាការឆ្លើយតប ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តោតកិច្ចប្រឹងប្រែងសាជាថ្មីលើសកម្មភាពយុទ្ធសាស្រ្តមួយចំនួន - ជាពិសេសជុំវិញការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ - នៅតាមក្រសួងពាក់ព័ន្ធសំខាន់ៗ។ វិធានការជំរុញដើម្បីពន្លឿនការអនុវត្តយុទ្ធសាស្រ្តនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានរៀបចំនៅក្នុងត្រីមាសទីមួយ ឆ្នាំ ២០១០ ហើយត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅខែ មេសា ឆ្នាំដដែល បានកំណត់លទ្ធផលចំពោះមុខជាច្រើន ដែលត្រូវសម្រេចឱ្យបាននៅចុងឆ្នាំ ២០១០។

**រូបលេខ ៤៨. ចំណាយអាទិភាពត្រូវបានលើកកម្ពស់ជាបណ្តើរៗ ទន្ទឹមនឹងកំណើនខ្ពស់នៃចំណាយវិនិយោគ...**




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**រូបលេខ ៤៩. ...ហើយការបើកផ្តល់ថវិកាប្រចាំឆ្នាំជារួម គិតតាមប្រភេទចំណាយបានកើនឡើងយ៉ាងច្បាស់**
(គិតជា ភាគរយនៃថវិកាប្រចាំឆ្នាំ)




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

---

*៣៦ ការប្រៀបធៀបក្នុងតំបន់ចាំបាច់ត្រូវពិនិត្យដោយប្រយ័ត្នប្រយែង ព្រោះថាការផ្តល់ពិន្ទុរបស់ប្រទេសមួយ មិនអាចប្រៀបធៀបដូចគ្នាទាំងស្រុងទៅនឹងការដាក់ពិន្ទុរបស់បណ្តាប្រទេសដទៃទៀយ។*

*៣៧ របាយការណ៍វាយតម្លៃឯករាជ្យស្តាពរមានចំណងជើងថា "ការវាយតម្លៃគម្រោងផ្តល់លាភការបន្ថែម ដោយផ្អែកទៅតាមគុណសម្បត្តិការងារ" ខែ តុលា ឆ្នាំ ២០០៩។*

**សកម្មភាពនានាក្នុងជំហានទីពីរ ដែលជាជំហានជំរុញ និងសកម្មភាពនានា ដែលនៅសេសសល់ក្នុងជំហានទីមួយមានវឌ្ឍនភាពល្អ។** គោលនយោបាយចំណូល និងគ្រប់គ្រងចំណូលបន្តវិវឌ្ឍស៊ីជម្រៅ និងមានភាពល្អប្រសើរ។ ការប្រើប្រាស់ប្រព័ន្ធធនាគារ បានពង្រីក និងការពង្រឹងប្រព័ន្ធលទ្ធកម្មរបស់រដ្ឋាភិបាល នឹងដំណើរការទៅមុខជាមួយនឹងផែនការអនុម័តច្បាប់លទ្ធកម្មនៅឆ្នាំ ២០១១។ សព្វថ្ងៃថវិកាផ្តល់សញ្ញាណកាន់តែប្រសើរអំពីធនធានជាក់ស្តែងដែលមាន សម្រាប់អង្គភាពចំណាយ ហេតុនេះបន្តលើកកម្ពស់ភាពជឿទុកចិត្តនៃថវិកាជាឯកសារគោលនយោបាយ និងជាឧបករណ៍អនុវត្ត។ ចំណាយអាទិភាព និងចំណាយវិនិយោគបន្តកើនឡើង សឱ្យឃើញគោលនយោបាយចំណាយសមស្រប (រូបលេខ ៤៨)។ ការបើកផ្តល់ថវិកាត្រូវបានកែលំអយ៉ាងច្រើន ជាពិសេស គឺចំណាយមូលធនចង្អុលបង្ហាញដល់ក្របខ័ណ្ឌដែលបានអភិវឌ្ឍបន្ថែមសម្រាប់អនុវត្តថវិកា (រូបលេខ ៤៩)[៣៨]។

**កិច្ចប្រឹងប្រែងដែលបានធ្វើឆ្ពោះទៅបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ក្រោមជំហានទីពីរមានទំហំធំធេង។** កិច្ចការភាគច្រើនស្ថិតនៅជុំវិញកត្តាជំរុញចំនួនប្រាំ ដែលមានទំនាក់ទំនងទៅវិញទៅមកជុំវិញការអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ។ គោលនយោបាយសម្រាប់អភិវឌ្ឍអង្គភាពថវិកានៅក្រោមកម្រិតក្រសួងមានដំណើរការទៅមុខ។ សវនកម្មផ្ទៃក្នុងត្រូវបានពង្រឹង ហើយនាយកដ្ឋានសវនកម្មផ្ទៃក្នុងជាច្រើននៅតាមក្រសួងពាក់ព័ន្ធនានាជាច្រើន ត្រូវបានបង្កើត។ រចនាសម្ព័ន្ធលេខកូដគណនីឯកភាពចម្រុះ កំពុងត្រូវបានរៀបចំ។ រចនាសម្ព័ន្ធនេះនឹងធ្វើឱ្យមុខងារថវិកា និងគណនេយ្យ ចូលទៅក្នុងរចនាសម្ព័ន្ធតែមួយ។

### ប្រអប់លេខ ៣. តើប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុចម្រុះធ្វើអ្វី?

ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ធ្វើឱ្យប្រតិបត្តិការហិរញ្ញវត្ថុនៃអង្គភាពថវិកា និងរតនាគារ ត្រូវបានកសាងជាធម្មតានៅជុំវិញប្រព័ន្ធរតនាគារស្នូល គាំទ្រមុខងារអនុវត្តថវិកាសំខាន់ៗ។ ប្រព័ន្ធនេះ

- បង្កើនភាពត្រឹមត្រូវនៃប្រតិបត្តិការថវិកា ការអនុវត្តថវិកា និងការរាយការណ៍ឆ្លងស្ថាប័នអង្គការ និងអង្គភាពថវិកា
- បង្កើនប្រសិទ្ធភាព និងតម្លាភាព តាមរយៈការទូទាត់ដោយផ្ទាល់ទៅកាន់អ្នកលក់ កាត់បន្ថយភាពមិនច្បាស់លាស់ជុំវិញការទូទាត់
- ទ្រទ្រង់ប្រតិបត្តិការមជ្ឈការតាមរយៈដំណោះស្រាយលើមូលដ្ឋានគេហទំព័រកណ្តាលក្នុងការផ្តល់លទ្ធភាពដល់អ្នកប្រើថវិកា ដែលមានការអនុញ្ញាតនៅគ្រប់កម្រិត (ខេត្ត ស្រុក)។

**ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ** (FMIS) **បង្កលក្ខណៈឱ្យរដ្ឋាភិបាលគ្រប់គ្រងចំណាយសរុប និងគ្រប់គ្រងឱនភាព ព្រមទាំងផ្តល់អាទិភាពចំណាយចំពោះគោលនយោបាយ កម្មវិធី និងគម្រោងនានា ដើម្បីឱ្យមានប្រសិទ្ធភាព និងសមធម៌។** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវនិយមន័យ និងចក្ខុវិស័យចំពោះការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុចម្រុះពេញលេញនៅក្នុងរដ្ឋាភិបាលទាំងមូល។ ស្របជាមួយការអនុវត្តជាបន្តបន្ទាប់ និងស្របតាមផែនការយុទ្ធសាស្ត្រជុំវិញផ្នែកសំខាន់ៗ (រួមមាន ការរៀបចំឡើងវិញនូវការពិនិត្យមុខងារឡើងវិញ ការគ្រប់គ្រងចំពោះការផ្លាស់ប្តូរគមនាគមន៍ និងការរៀបចំឡើងវិញនូវដំណើរការការងារ និងការកសាងផែនការគម្រោង FMIS) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងណែនាំអំពីរចនាសម្ព័ន្ធនៃភាពជាអ្នកដឹកនាំ និងរចនាសម្ព័ន្ធគ្រប់គ្រងដែលតម្រូវឱ្យដឹកនាំ និងអនុវត្តកំណែទម្រង់ស្មុគស្មាញមានរយៈពេលច្រើនឆ្នាំ។

**ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានគ្រោងអនុវត្តជាពីរដំណាក់កាល។** ដំណាក់កាលទីមួយ ពិនិត្យសំណើអំពីលំដាប់លំដោយដែលរួមមានម៉ូឌុលសំខាន់អំពីរតនាគារ និងថវិកា ដែលត្រូវអនុវត្តក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ : នាយកដ្ឋាននានានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរតនាគារជាតិ និងរតនាគារខេត្តទាំងអស់ខណៈមាន Interface អេឡិចត្រូនិក (ទម្រង់អេឡិចត្រូនិកភ្ជាប់ជាមួយក្រសួង**ពាក់ព័ន្ធទាំងអស់។** ម៉ូឌុលដំណើរការផ្សេងទៀត គឺម៉ូឌុលស្តីពីការទិញ ការគ្រប់គ្រងទ្រព្យសកម្ម និង Interfaces (ការគ្រប់គ្រងប្រាក់ខែ-ចំណូលពន្ធ និងបំណុល) នឹងត្រូវបំពាក់នៅតាមក្រសួង និងបណ្តាខេត្តពាក់ព័ន្ធទាំងអស់ជាផ្នែកមួយនៃដំណាក់កាលទីពីរ។ ដំណាក់កាលទីមួយ គឺការផ្តោតទៅរតនាគារ ដែលនឹងជួយធានាការអនុវត្តមុខងារស្នូលនៅរតនាគារជាតិ និងរតនាគារខេត្ត។ បណ្តាក្រសួងចំណាយនៅថ្នាក់កណ្តាល និងមន្ទីរចំណាយនៅតាមបណ្តាខេត្ត នឹងដាក់ទិន្នន័យប្រតិបត្តិការមកកាន់រតនាគារកណ្តាល ឬរតនាគារខេត្ត ដើម្បីធ្វើប្រព្រឹត្តិកម្ម ដោយប្រើគេហទំព័របច្ចុប្បន្នកម្មទាន់សភាពការណ៍ (web-based portal) ប្រសិនបើអាចធ្វើបាន។ Web-based portal នេះនឹងផ្តល់លទ្ធភាពងាយស្រួលក្នុងការទទួលបានព័ត៌មានហិរញ្ញវត្ថុពីក្រសួង-មន្ទីរចំណាយនានា។ តាមអភិក្រមនេះ ការអនុវត្តប្រព័ន្ធថ្នាក់កណ្តាលនឹងមានភាពងាយស្រួល និងចំណាយតិចអនុញ្ញាតឱ្យរដ្ឋាភិបាលក្តាប់បាននូវរាល់ប្រតិបត្តិការទូទាត់ទាំងឡាយបានឆាប់រហ័ស បង្កលក្ខណៈងាយស្រួលចំពោះការគ្រប់គ្រងសារពើពន្ធកាន់តែប្រសើរ និងក្តាប់ព័ត៌មានហិរញ្ញវត្ថុកាន់តែបានទាន់ពេលវេលា។

---

*៣៨ ក្រសួងអាទិភាព រួមមាន សុខាភិបាល អប់រំ កសិកម្ម អភិវឌ្ឍន៍ជនបទ កិច្ចការនារី យុត្តិធម៌ រៀបចំដែនដី និងការងារ។*

### ប្រអប់លេខ៤. ចំណាត់ថ្នាក់ថ្មីជំរុញការប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល

ចំណាត់ថ្នាក់ថវិកាថ្មី (និងប្លង់គណនី) ត្រូវបានចាត់ទុកថាជារចនាសម្ព័ន្ធលេខកូដគណនីឯកភាព ដែលនឹងបង្កលក្ខណៈងាយស្រួលដល់សមាហរណកម្មថវិកា និងជំរុញការប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាលតាមរយៈការគាំទ្រថវិកា ព្រោះម្ចាស់ជំនួយនឹងអាចយល់បានកាន់តែច្បាស់អំពីវិធីកត់ត្រាមូលនិធិ និងមុខចំណាយ ។

កិច្ចការនេះអាចធ្វើបានទៅតាមការដាក់លេខកូដចំណាត់ថ្នាក់តាម "ប្រភពមូលនិធិ" និង "តាមភូមិសាស្ត្រ" ។ ចំណាត់ថ្នាក់ "ប្រភពមូលនិធិ "គាំទ្រសមាហរណកម្មនៃគម្រោង ដែលផ្តល់ហិរញ្ញប្បទានពីបរទេសទៅក្នុងថវិកា និងការរាយការណ៍ហិរញ្ញវត្ថុ និងក្តោបប្រភពផ្ទាល់របស់រដ្ឋាភិបាល និងប្រភពពីបរទេស (ផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ) ។ ចំណាត់ថ្នាក់ "តាមភូមិសាស្ត្រ" កំណត់ទីតាំងដែលចំណាយបានកើតឡើង ដោយញែកចេញពីគ្នានូវកម្រិតរដ្ឋបាលថ្នាក់កណ្តាល ថ្នាក់ខេត្ត ថ្នាក់ក្រុង ថ្នាក់ស្រុក និងថ្នាក់ឃុំ ។

**អង្គភាពថវិកា គឺជាទស្សនាទានសំខាន់មួយសម្រាប់ដាក់ឱ្យមានគណនេយ្យភាពហិរញ្ញវត្ថុ និងគណនេយ្យភាព តាមកម្មវិធីកាន់តែប្រសើរនៅគ្រប់លំដាប់ថ្នាក់របស់រដ្ឋាភិបាល។** អង្គភាពថវិកា គឺជាស្ថាប័នមួយដែលប្រើប្រាស់ ឬដែលទទួលធនធានសាធារណៈ ដើម្បីបំពេញមុខងារក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាល[៣៩] ។ ស្ថាប័នសាធារណៈស្វយ័ត និងអាជ្ញាធរថ្នាក់ក្រោមជាតិ ពីដំបូងឡើយត្រូវបានចាត់ទុកថាជាអង្គភាពថវិកា ឬមណ្ឌលចំណាយ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រោងសេនីឱ្យក្រសួងសាកល្បងរៀបចំបញ្ជូនថវិការបស់ខ្លួនសម្រាប់ឆ្នាំ ២០១៣ តាមរចនាសម្ព័ន្ធថ្មីនេះ ។ អង្គភាពថវិកានឹងត្រូវបានអនុវត្តសាកល្បងក្នុងក្រសួងពាក់ព័ន្ធសំខាន់ៗជាផ្នែកមួយនៃអភិក្រមតាមដំណាក់កាលទូទៅ ដើម្បីដាក់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុដំណើរការ ដែលតម្រូវឱ្យមានការរៀបចំដំណើរការការងារជាថ្មីឡើងវិញផងដែរ រួមមាន ការចាត់ថ្នាក់ថវិកាពេញលេញ និងរចនាសម្ព័ន្ធលេខកូដគណនីឯកភាព ការពង្រឹងសវនកម្ម និងការត្រួតពិនិត្យ និងការកត់ត្រា និងរាយការណ៍ពេញលេញ[៤០] ។

**ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុនឹងជួយសម្រួលការដាក់ឱ្យដំណើរការរចនាសម្ព័ន្ធគណនីឯកភាពចម្រុះ។** ប្រព័ន្ធចំណាត់ថ្នាក់ប្រាំមួយផ្នែកដែលលើកសំណើដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើសមាហរណកកម្មមុខងារថវិកា និងគណនេយ្យ ចូលទៅក្នុងរចនាសម្ព័ន្ធទោលឯកភាពមួយ ។ រចនាសម្ព័ន្ធកំណត់លេខកូដថ្មីឆ្លុះបញ្ចាំងមុខងារផ្នែករដ្ឋបាល សេដ្ឋកិច្ច កម្មវិធី ប្រភពធនធានសេដ្ឋកិច្ច និងភូមិសាស្ត្រ និងក្របខ័ណ្ឌមួយ ដែលនឹងគ្របដណ្តប់សេចក្តីត្រូវការរបស់អ្នកប្រើប្រាស់គ្រប់រូប អំពីទិន្នន័យហិរញ្ញវត្ថុទាំងអស់រដ្ឋាភិបាល ទាំងសភា អាជ្ញាធរជាតិ សវនកម្ម ក្រសួងពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ រហូតដល់ប្រជាពលរដ្ឋ និងទីភ្នាក់ងារម្ចាស់ជំនួយនានា ។

**ជាមណ្ឌលផ្ទុកព័ត៌មាន និងជាប្រភពគ្រប់គ្រងថវិកាសមាហរណកម្មនៅថ្នាក់កណ្តាល ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុនឹងផ្តល់ព័ត៌មានសរុប ដែលកាន់តែអាចជឿទុកចិត្ត និងទាន់ពេលវេលាដល់ប្រធានគ្រប់គ្រង។** ការរាយការណ៍នឹងក្លាយជាលទ្ធផលនៃប្រព័ន្ធនេះ ហើយពុំមែនជាដំណើរការឡើយ ។ នៅពេលណាដែលប្រតិបត្តិការនានាត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធនេះរួចហើយ របាយការណ៍នឹងត្រូវបានបង្កើត ។ ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុផ្តល់ឱកាស ដើម្បីកែលំអប្រព័ន្ធដែលមានស្រាប់ តាមរយៈស្វ័យប្រវត្តិកម្មដែលមានទ្រង់ទ្រាយធំ សមាហរណកម្ម និងការរៀបចំប្រតិបត្តិការនានា ។ ទាំងអស់នេះអាចនឹងអនុវត្តទៅបាន ប្រសិនបើដំណើរការការងារសមស្របត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ។ អាស្រ័យហេតុនេះ ការប្តូរពីប្រព័ន្ធចុះដោយដៃ និងប្រព័ន្ធដែលដាច់ៗគ្នាទៅកាន់ប្រព័ន្ធមួយ ដែលមានកម្រិតស្វ័យប្រវត្តិ និងសមាហរណកម្មខ្ពស់ តម្រូវឱ្យមានការពិនិត្យឡើងវិញនូវដំណើរការការងារដែលគាំទ្រដោយវិធានការគ្រប់គ្រងការផ្លាស់ប្តូររឹងមាំ ។

**ដំណើរការងារថ្មីនឹងលុបបំបាត់វិយាបថស្វែងរកប្រាក់ចំណេញផ្ទាល់ខ្លួន។** នៅពេលដែលប្រើកុំព្យូទ័រដំណើរការការងារថ្មីនឹងធ្វើឱ្យលំហូរការងារមានលក្ខណៈស្វ័យប្រវត្តិ លុបបំបាត់ការធ្វើការជាន់គ្នា លុបបំបាត់ស្រទាប់ និងជំហានការងារសំពោងសំពាយ និងកាត់បន្ថយតម្រូវការក្នុងការប្រើប្រាស់លិខិតស្នាមនានា ។ សេចក្តីជូនដំណឹងអេឡិចត្រូនិកទៅកាន់ប្រធានគ្រប់គ្រងនានា នឹងជំនួសការចូលរួមរបស់គណៈគ្រប់គ្រងក្នុងប្រតិបត្តិការនានា និងកាត់បន្ថយដំណើរការឯកភាពមិនចាំបាច់ ដែលការណ៍នេះលុបបំបាត់ឱកាសសម្រាប់ការស៊ីគ្រលំគ្នា និងលុបបំបាត់អំពើពុករលួយ ។

---

*៣៩ ក្របខ័ណ្ឌសម្រាប់កំណត់អត្តសញ្ញាណអង្គភាពថវិកា - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០១០*

*៤០ ក្រសួងដែលបានគ្រោងអនុវត្តសាកល្បងនូវប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ រួមមាន ក្រសួងសុខាភិបាល អប់រំ យុវជន និងកីឡា កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិវឌ្ឍន៍ជនបទ និងសាធារណៈការ និងដឹកជញ្ជូន ។*

**ប្លង់គណនី (COA) ឯកភាពត្រូវបានបង្កើតតាមរយៈការប្រកាន់យកជំហាននានាសម្រាប់ឱ្យគ្រប់លំដាប់ថ្នាក់នៃរដ្ឋាភិបាលប្រើ។** នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន និងនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ (DIC) កំពុងធ្វើរៀបចំបញ្ចប់នូវការបង្កើតរចនាសម្ព័ន្ធគណនីឯកភាព ដោយច្របាច់បញ្ចូលគ្នានូវប្លង់គណនីដោយឡែក ដែលត្រូវបានប្រើប្រាស់នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំរបស់រដ្ឋាភិបាល ។

**ការបង្កើតទស្សនៈមួយរលូនអំពីគំរូ និងស្តង់ដារគណនេយ្យដំណើរការដោយយឺតៗ មួយផ្នែក គឺដោយសារការការប្រឹក្សាផ្នែកគោលនយោបាយរបស់ម្ចាស់ជំនួយមិនស៊ីសង្វាក់គ្នា។** ថ្មីៗនេះ ការមូលមតិផ្ទៃក្នុងរដ្ឋាភិបាលបានបង្កើតឡើងជុំវិញការអនុវត្តស្តង់ដារគណនេយ្យអន្តរជាតិវិស័យសាធារណៈ (IPSAS) និងការព្យាយាមយល់ដឹងស្តង់ដារទាំងនេះ កំពុងស្ថិតនៅក្នុងដំណាក់កាលដំបូង ។ ជំហានសំខាន់ទីមួយ អគ្គនាយកដ្ឋានរតនាគារបានធ្វើការវិភាគអំពីចំណុចខ្វះចន្លោះរវាងប្រព័ន្ធបច្ចុប្បន្ន និងស្តង់ដារ IPSAS ដើម្បីបង្កើតផែនទីចង្អុលផ្លូវ និងរៀបចំយុទ្ធសាស្ត្រឆ្ពោះទៅអនុវត្តស្តង់ដារ IPSAS និងស្តង់ដាររាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ។ កម្មវិធីមួយកំពុងត្រូវបានពិចារណា ដើម្បីគាំទ្រការអនុវត្តផែនទីចង្អុលផ្លូវនោះ ។ កម្មវិធីបែបនេះនឹងពង្រឹងបន្ថែមនូវប្រតិបត្តិការរតនាគារ និងពង្រឹងមុខងារដែលមានសារៈសំខាន់សម្រាប់អនុវត្តដោយជោគជ័យនូវប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ ។

**ការធ្វើសវនកម្មផ្ទៃក្នុងត្រូវបានដាក់ឱ្យដំណើរការ។** នាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតនៅតាមក្រសួងពាក់ព័ន្ធ និងស្ថាប័ននានា ទោះបីជានាយកដ្ឋានផ្ទៃក្នុងជាច្រើនមិនបានដំណើរការដោយពេញលេញក្តី ។ ក្របខ័ណ្ឌសវនកម្មផ្ទៃក្នុង ដែលរួមមានស្តង់ដារសវនកម្មអន្តរជាតិ និងលក្ខន្តិកៈសម្រាប់ដំណើរការសវនកម្មផ្ទៃក្នុង គឺជាផ្នែកសំខាន់មួយនៃបរិយាកាសត្រួតពិនិត្យផ្ទៃក្នុងរឹងមាំមួយ ដែលតម្រូវឱ្យពង្រឹងបន្ថែម ។ ជាមួយនឹងវត្តមាននៃក្របខ័ណ្ឌនេះ សៀវភៅណែនាំ ផែនការ និងនីតិវិធីនានា អាចត្រូវបានបង្កើតដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅក្រសួងពាក់ព័ន្ធ ។ ស្តង់ដារឯកភាព និងមានសង្គតិភាព ដែលកំពុងស្ថិតនៅក្នុងដំណាក់កាលរៀបចំចុងក្រោយសម្រាប់ឱ្យក្រសួងទាំងអស់អនុវត្តតាម មានសារៈសំខាន់ក្នុងការធានាឱ្យមានការត្រួតពិនិត្យសមស្រប និងនីតិវិធីនានានៅក្នុងរដ្ឋាភិបាល ។

# គ. ការធ្វើកំណែទម្រង់ជ្រាលជ្រៅចំពោះជំហានទីមួយ ពន្លឿនសកម្មភាពជំហានទីពីរ

**ជំហានទីមួយ និងទីពីរសម្រេចបានវឌ្ឍនភាពយ៉ាងច្រើន ប៉ុន្តែនៅមានបញ្ហាប្រឈមមួយចំនួន។** ការវាយតម្លៃក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ បានប្រៀបធៀបវឌ្ឍនភាពចាប់តាំងពីឆ្នាំ ២០០២ និងបានសន្និដ្ឋានថា ភាពជឿទុកចិត្តនៃថវិកាតម្រូវឱ្យពង្រឹងបន្ថែមលើផ្នែកនានានៃគោលនយោបាយ និងរដ្ឋបាលចំណូល ការគ្រប់គ្រងសាច់ប្រាក់ ការគ្រប់គ្រងបំណុល និងលទ្ធកម្ម ។

**ការពង្រីកលំហសារពើពន្ធនៅតែជាបញ្ហាប្រឈមទ្វេទិស ដោយសារអត្រាទាបនៃចំណូលធៀបនឹង ផសស និងការពឹងផ្អែកជ្រុលហួសលើពន្ធពាណិជ្ជកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។** ការប្រមូលចំណូលធ្លាក់ចុះនៅឆ្នាំ ២០០៩ ដោយសារផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសាកល (សម្រាប់ព័ត៌មានបន្ថែម សូមមើលរូបលេខ ៥០ និងជំពូក ១) ។ តាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (AFTA) រដ្ឋាភិបាលមានកាតព្វកិច្ចកាត់បន្ថយពន្ធពាណិជ្ជកម្ម ប៉ុន្តែប្រព័ន្ធយកពន្ធត្រូវបានរាំងស្ទះ ដោយប្រាក់លើកទឹកចិត្តចំពោះការវិនិយោគដែលចោទជាបញ្ហា និងភាពកម្សោយនៃអនុលោមភាព (រូបលេខ ៥១) ។ ការប្រមូលពន្ធផ្ទាល់នៅមានកម្រិតទាបជាងយ៉ាងច្រើនធៀបជាមួយកម្រិតនៃការប្រមូលពន្ធនៅបណ្តាប្រទេសអាស៊ីបូព៌ាកំពុងអភិវឌ្ឍន៍ ហើយរដ្ឋបាលពន្ធជារួមនៅមិនទាន់គ្រប់គ្រាន់ ។ នៅឆ្នាំ ២០១០ រដ្ឋាភិបាលបានឯកភាពលើយុទ្ធសាស្ត្រ កៀរគរចំណូលដែលកំណត់វិធានការសក្តានុពលផ្សេងៗ ដើម្បីដោះស្រាយចំណុចខ្វះខាតនានា ។ ការដាក់ឱ្យដំណើរការនូវវិក្កយបត្រចំណូលជាតិ ចំពោះចំណូលមិនមែនពន្ធមានបំណងលើកកម្ពស់ការគ្រប់គ្រងចំណូល ។ ការបញ្ជាក់ច្បាស់អំពីពន្ធប្រេងកាត និងការដាក់ឱ្យអនុវត្តគម្រោងយកពន្ធលើអចលនវត្ថុ និងពន្ធលើចំណេញមូលធននឹងបង្កើនការប្រមូល និងពង្រីកលំហសារពើពន្ធ ។ ការលើកកម្ពស់ការគ្រប់គ្រងចំណូល និងការពង្រីកមូលដ្ឋានគិតពន្ធមានសារៈសំខាន់ជាពិសេស ។ កិច្ចប្រឹងប្រែងបែបនេះ ត្រូវអមដោយវិធានការនានា ដើម្បីពង្រឹងគណនេយ្យភាពចំពោះការប្រើប្រាស់មូលនិធិសាធារណៈ ។

**រូបលេខ ៥០. ការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចធ្វើឱ្យប្រាក់ចំណូលធ្លាក់ចុះ នៅឆ្នាំ ២០០៩...**

(ការប្រែប្រួលគិតជាភាគរយធៀបនឹងថវិកា)




*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**រូបលេខ ៥១. ...នៅពេលដែលអត្រាកំណើនពន្ធផ្ទាល់ នៅតែប្រែប្រួល**

(ការប្រែប្រួលគិតជាភាគរយ ពីមួយឆ្នាំទៅមួយឆ្នាំ)




*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ចំណែកនៃចំណាយអាទិភាពដែលផ្តល់ហិរញ្ញប្បទានក្នុងស្រុកបានធ្លាក់ចុះជាបណ្តើរៗ។** ចំណុចនេះបង្ហាញថាលំហពន្ធបន្ថែមដែលត្រូវបានបង្កើត ត្រូវបានប្រើប្រាស់សម្រាប់វិស័យមិនមែនអាទិភាព (រូបលេខ ៥២)។ ខណៈដែលការភ្ជាប់អាទិភាពនានានៃកម្មវិធី និងថវិកាត្រូវដោះស្រាយឱ្យបានពេញលេញបន្ថែមក្នុងដំណាក់កាលទីបីនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បណ្តាជំហានកាលពីដំបូង អាចត្រូវបានប្រកាន់យកក្នុងពេលបច្ចុប្បន្ន រាប់ទាំងការធ្វើសមាហរណកម្មចំណាយដែលផ្តល់ហិរញ្ញប្បទានពីធនធានផ្ទាល់ និងពីការគាំទ្រពីបរទេស ការអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងការតម្រឹមផែនការយុទ្ធសាស្ត្រថវិកាជាមួយអាទិភាពនានារបស់វិស័យ។

**ឯកសារក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុបានកត់សំគាល់ថា លទ្ធភាពព្យាករណ៍ថវិកាសម្រាប់ស្ថាប័នចំណាយមានកម្រិតទាប ហើយការប្រែប្រួលសមាសភាគចំណាយបានកើនលើសពីកម្រិតល្អៀងសរុប ១០ ភាគរយ ក្នុងរយៈពេលពីរឆ្នាំនៃរយៈពេលបីឆ្នាំចុងក្រោយនាដំណាច់ឆ្នាំ ២០០៨។** ការប្រែប្រួលនេះ មួយចំណែកបណ្តាលមកពីវិភាជន៍មិនទៀងទាត់ពីថវិកាបម្រុងធំមួយ (យថាភាព) ថវិកា។ ថវិកាបម្រុងមានចំនួនប្រហែល ១០ ភាគរយនៃចំណាយដែលបានគ្រោង ហើយវិធីដែលមិនអាចព្យាករណ៍ដែលថវិកានេះត្រូវបានវិភាជន៍ទូទាំងឆ្នាំ រួមចំណែកធ្វើឱ្យការគ្រប់គ្រងថវិកាគ្មានតម្លាភាព។ លទ្ធភាពព្យាករណ៍មានភាពប្រសើរខ្លះៗក្នុងវិស័យអប់រំ សុខាភិបាល និងកសិកម្ម[៤១]។

**ទោះបីជាមានការកែលំអច្រើនចំពោះការគ្រប់គ្រងសាច់ប្រាក់ក្តី ជាពិសេសក្នុងការពង្រឹងគណនីទោលនៅរតនាគារ ការគ្រប់គ្រងលំហូរសាច់ប្រាក់មិនទាន់វិវត្តគ្រប់គ្រាន់នៅឡើយ។** បញ្ហាមួយចំនួនទាក់ទងនឹងការប្រមូល និងការផ្សព្វផ្សាយ ទិន្នន័យព្យាករណ៍លំហូរសាច់ប្រាក់នៅតែមានផលប៉ះពាល់ធ្ងន់ធ្ងរក្នុងការធានាឱ្យមានធនធានដ៏ច្រើននៅក្នុងដៃ ដើម្បីឆ្លើយតបនឹងតម្រូវការលំហូរសាច់ប្រាក់របស់រដ្ឋាភិបាល។ ស្ថានភាពស្ទើរខ្វះសាច់ប្រាក់បានកើតជាថ្មីឡើងវិញចាប់តាំងពីឆ្នាំ ២០១០ ជាការគំរាមកំហែងដល់សមិទ្ធផលដែលបានមកដោយពិបាកលើបំណុលកកស្ទះចំពោះការទូទាត់ (រូបលេខ ៥៣)។ អង្គភាពគ្រប់គ្រងសាច់ប្រាក់ (CMU) បានកំណត់ថា តម្រូវការឱ្យមានព័ត៌មានស្តីពីការកសាងផែនការចំណាយ និងសហប្រតិបត្តិការពេញលេញជាមួយក្រសួងពាក់ព័ន្ធ និងជាមួយនាយកដ្ឋាននានានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាទិភាព ប៉ុន្តែអង្គភាពគ្រប់គ្រងសាច់ប្រាក់គ្មានសមត្ថកិច្ចតម្រូវឱ្យនាយកដ្ឋាននានា ផ្ញើតួលេខព្យាករណ៍លំហូរសាច់ប្រាក់ឡើយ។

*៤១ ខណៈដែលការពង្រឹងគណនីទោលរតនាគារបានជួយបង្កើនភាពគ្រប់ជ្រុងជ្រោយនៃថវិកា ដោយប្រមូលផ្តុំគណនីធនាគារនានារបស់រដ្ឋាភិបាល ការវាយតម្លៃ PEFA កាលពីពេលកន្លងទៅថ្មីៗបង្ហាញថា មានការមិនរាយការណ៍អំពីប្រតិបត្តិការលើសថវិកា ដោយប្រើប្រាស់ចំណូលមិនមែនពន្ធមិនបានប្រកាស ដែលអាចមិនត្រូវគ្នាជាមួយគោលដៅនៃគោលនយោបាយសាធារណៈ។*

## រូបលេខ ៥២. ចំណាយវិស័យអាទិភាពគិតជាភាគរយនៃថវិកាក្នុងស្រុកកំពុងធ្លាក់ចុះ
(គិតជា ភាគរយ នៃចំណាយហិរញ្ញប្បទានក្នុងស្រុក)




*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបលេខ ៥៣. សមតុល្យសាច់ប្រាក់គណនីទោលរតនាគារបាន និងកំពុងធ្លាក់ចុះចាប់តាំងពីពាក់កណ្ដាលឆ្នាំ ២០០៩
(គិតជា ពាន់លានរៀល)




*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ការអនុវត្តប្រព័ន្ធគ្រប់គ្រងបំណុល និងវិភាគហិរញ្ញវត្ថុ ព្រមទាំងការរៀបចំក្របខ័ណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងបំណុលមានការរីកចម្រើនខ្លាំងគួរ** (DMFAS)។ ផ្ទុយទៅវិញ សមាហរណកម្មទិន្នន័យបំណុលមិនទទួលបានជោគជ័យឡើយ ។ អគ្គនាយកដ្ឋានរតនាគារជាតិមិនអាចក្ដាប់ទិន្នន័យបំណុលបាន ដោយសារការរាយការណ៍ហិរញ្ញវត្ថុមិនពេញលេញរបស់រដ្ឋាភិបាល ។ នៅតែមានភាពដាច់គ្នាផ្នែកស្ថាប័នអំពីមុខងារគ្រប់គ្រងបំណុល និងសាច់ប្រាក់ ។ ប្រតិបត្តិការគ្រប់គ្រងបំណុល និងសាច់ប្រាក់ដែលដំណើរការល្អ និងបានធ្វើសមាហរណកម្មពេញលេញនឹងជួយធានាដល់ការលើកកម្ពស់ការគ្រប់គ្រងសាច់ប្រាក់ និងកសាងផែនការសាច់ប្រាក់ ។

**បច្ចុប្បន្ន ប្រព័ន្ធលទ្ធកម្មសាធារណៈនៅតែមានលក្ខណៈដាច់ពីគ្នា ដោយសារក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពីរដាច់ចេញពីគ្នា អនុវត្តចំពោះលទ្ធកម្មដែលផ្ដល់ហិរញ្ញប្បទានពីថវិកាជាតិ និងពីម្ចាស់ជំនួយបរទេស។** ប្រព័ន្ធនីមួយៗគ្រប់គ្រងដោយអនុក្រឹត្យ ដោយឡែកវិធានអនុវត្តផ្សេងគ្នា បទប្បញ្ញត្តិ និងដំណើរការនានា ស្ថិតក្រោមការត្រួតពិនិត្យរបស់នាយកដ្ឋានពីរផ្សេងគ្នានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អត្ថប្រយោជន៍សេដ្ឋកិច្ច និងប្រសិទ្ធភាពយ៉ាងច្រើនអាចទទួលបានតាមរយៈការបញ្ចូលប្រព័ន្ធទាំងពីរនេះ ទៅជាប្រព័ន្ធលទ្ធកម្មសាធារណៈទោលឯកភាពថ្នាក់ជាតិ ។ គ្មានបញ្ញត្តិ ឬនីតិវិធីជាក់ច្បាស់ណាអំពីវិធានការកែតម្រូវ ដែលត្រូវប្រកាន់យកប្រឆាំងនឹងអ្នកពាក់ព័ន្ធនឹងការក្លែងបន្លំ និងអំពើពុករលួយក្នុងដំណើរការលទ្ធកម្ម ឬក្នុងពេលអនុវត្តកិច្ចសន្យាឡើយ (រាប់ទាំងការឃុបឃិត ការបង្ខាប់បញ្ជា និងការធ្វើឱ្យរាំងស្ទះ) ។ សមត្ថភាពរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធនានាក្នុងការអនុវត្តកិច្ចលទ្ធកម្មនៅតែខ្សោយ ហើយទីផ្សារក្នុងស្រុកនៃក្រុមហ៊ុនផ្គត់ផ្គង់ និងអ្នកម៉ៅការរីកចម្រើនតិចតួច ហើយជួបការលំបាកដោយសារបញ្ហាអភិបាលកិច្ច ។ គ្មានប្រព័ន្ធណាមួយ ដើម្បីឱ្យក្រសួង ស្ថាប័ននានាតាមដានការអនុវត្ត និងលទ្ធផលនៃលទ្ធកម្មឡើយ ។

**ចំណុចខ្សោយចម្បងនៃទម្រង់រៀបចំថវិកាផ្អែកលើគោលនយោបាយ គឺសមាហរណកម្មមិនល្អជាបន្តនៃចំណាយមូលធន និងចំណាយចរន្ត។** ចំណុចនេះកាន់តែធ្ងន់ធ្ងរបន្ថែមទៀត ដោយសារការមានអង្គភាពដាច់ដោយឡែក (the DIC) នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពអនុវត្តគម្រោង (PIUs) នៅក្នុងក្រសួងពាក់ព័ន្ធនានា ដែលគ្រប់គ្រងគ្រប់ទិដ្ឋភាពនៃគម្រោង ដែលផ្ដល់មូលនិធិដោយម្ចាស់ជំនួយ ។ ខណៈដែលមានការកសាងទំនាក់ទំនងកាន់តែរឹងមាំរវាងការរៀបចំថវិកាប្រចាំឆ្នាំ និងការកសាងផែនការរយៈពេលមធ្យមតាមរយៈផែនការយុទ្ធសាស្ត្រថវិកា គេអាចធ្វើកិច្ចបន្ថែមទៀត ដើម្បីក្ដាប់គម្រោងហិរញ្ញប្បទានពីបរទេស ដើម្បីធានាអត្ថិភាពនៃការផ្ដល់មូលនិធិចំពោះចំណាយនៃគម្រោងទាំងអស់ និងពង្រឹងទំនាក់ទំនងនៃគម្រោង ដែលផ្ដល់ហិរញ្ញប្បទានពីម្ចាស់ជំនួយជាមួយអាទិភាពធនធាននានារបស់រដ្ឋាភិបាល ។ ព័ត៌មានចំណាយច្បាស់លាស់អំពីកាតព្វកិច្ចធនធានក្នុងស្រុក និងធនធានបរទេសជាមួយនឹងការកំណត់គោលដៅ និងផែនការច្បាស់លាស់ ផ្សារភ្ជាប់ជាមួយអាទិភាពនានាតាមវិស័យ នឹងបង្កើនភាពជឿទុកចិត្តលើផែនការយុទ្ធសាស្ត្រថវិកាថាជាឧបករណ៍គោលនយោបាយ ។

**ការអនុវត្តរបស់ម្ចាស់ជំនួយក្នុងផ្នែកជាច្រើនបន្តវាស់ស្ទង់សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការជំរុញកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ។** ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ បានចាត់ថ្នាក់ការអនុវត្តរបស់ម្ចាស់ជំនួយក្នុងកម្រិតទាប និងស៊ីសង្វាក់គ្នាលើ (i) លទ្ធភាពព្យាករណ៍ការទ្រទ្រង់ថវិកាដោយផ្ទាល់ (ii) ការប្រើប្រាស់ប្រព័ន្ធរបស់ប្រទេស (iii) ភាពពេញលេញ និងភាពទាន់ពេលវេលានៃការប៉ាន់ស្មានថវិកាសម្រាប់គាំទ្រគម្រោង និង (iv) ចំនួន និងការគ្របដណ្តប់ការរាយការណ៍លំហូរជាក់ស្តែងរបស់ម្ចាស់ជំនួយសម្រាប់គាំទ្រគម្រោង[៤២] ។ ការសម្រេចឱ្យបាននូវភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពនៃថវិកា នៅតែជាបញ្ហាប្រឈមចម្បងមួយចំពោះរដ្ឋាភិបាល សំខាន់ដោយសារការផាត់ចេញនូវផ្នែកសំខាន់មួយនៃចំណាយសាធារណៈ ដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ[៤៣] ។ចំណុចនេះមានបញ្ហាជាពិសេស នៅពេលដែលហិរញ្ញប្បទានពីបរទេសចំពោះការចំណាយ នៅតែស្ថិតនៅខាងក្រៅគោលដៅនៃគោលនយោបាយដែលបានកំណត់របស់រដ្ឋាភិបាល ។

**ការងាកឆ្ពោះទៅប្រើប្រាស់ប្រព័ន្ធនានារបស់រដ្ឋាភិបាល ក៏មានសារៈសំខាន់ផងដែរ។** ជំហានដំបូង គម្រោងរបស់ម្ចាស់ជំនួយអាចប្រើប្លង់គណនីរបស់រដ្ឋាភិបាលដើម្បីរាយការណ៍ទិន្នន័យបង្កលក្ខណៈឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្តាប់បានទិន្នន័យនេះ ក្នុងគោលបំណងពង្រីកការកសាងផែនការកសាងថវិកា និងដើម្បីរាយការណ៍ ។ ភាពជឿទុកចិត្តនៃថវិកាកម្រិតខ្ពស់ក្រោម PEFA ជាការយល់ខុសនៅពេលណាដែលអង្គភាពអនុវត្តគម្រោង បន្តគ្រប់គ្រងគម្រោង ដែលឧបត្ថម្ភគាំទ្រដោយម្ចាស់ជំនួយនៅក្នុងក្រសួងនានា ក្រៅយន្តការថវិកា យន្តការគណនេយ្យ និងយន្តការរាយការណ៍របស់រដ្ឋាភិបាល ។ កង្វះតម្លាភាពនៅក្នុងគម្រោងដែលផ្តល់ជំនួយឥតសំណងជាច្រើនរបស់ម្ចាស់ជំនួយ ដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលធ្វើឱ្យប៉ះពាល់ដល់ភាពជឿទុកចិត្តនៃថវិកា ។ បន្ថែមពីលើនេះ ការបន្ថែមមូលនិធិរបស់ម្ចាស់ជំនួយលើថវិកា ជំរុញឱ្យប្រព័ន្ធផ្លូវការនានារបស់រដ្ឋាភិបាលដំណើរការភ្លាមៗ សម្រួលឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវ និងត្រួតពិនិត្យកាន់តែខ្ពស់ និងដើរតួជាកាតាលីករ ដើម្បីជំរុញអនុវត្តការផ្លាស់ប្តូរ ។ បញ្ហាទាំងនេះមានសារៈសំខាន់ក្នុងបរិបទទូលាយក្នុងការតម្រឹមការគាំទ្ររបស់ម្ចាស់ជំនួយជាមួយការកសាងផែនការយុទ្ធសាស្ត្រ និងថវិការបស់រដ្ឋាភិបាល ។ គំនិតផ្តួចផ្តើមកាលពីពេលថ្មីៗ អនុញ្ញាតឱ្យដាក់បញ្ចូលលក្ខខណ្ឌ ដើម្បីចាត់ថ្នាក់ធនធាន និងចំណាយដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ ប្រើប្លង់គណនីរបស់រដ្ឋាភិបាល ដូចមានចែងនៅក្នុងសេចក្តីព្រាង <u>សៀវភៅណែនាំអំពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោងដែលផ្តល់ហិរញ្ញប្បទានពីម្ចាស់ជំនួយ</u> ។ បញ្ញត្តិនេះរក្សាភាពបត់បែនក្នុងការបំពេញកិច្ចតម្រូវក្នុងការរាយការណ៍ អំពីការកសាងថវិកា និងហិរញ្ញវត្ថុ រហូតទាល់តែការលើកកម្ពស់សុខុដុមភាវូបនីយកម្ម និងការតម្រឹមតម្រង់ទទួលការឯកភាព និងត្រូវបានអនុវត្ត ។ កិច្ចព្រមព្រៀងក្នុងចំណោមម្ចាស់ជំនួយ គប្បីជាអាទិភាព និងគប្បីពន្លឿន ។

### ប្រអប់លេខ ៥. វិធានការលើកទឹកចិត្តដើម្បីអនុវត្តកម្មវិធីកំណែទម្រង់

ក្នុងខែ សីហា ឆ្នាំ ២០០៥ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានសាកល្បងអនុវត្ត និងផ្តល់ហិរញ្ញប្បទានរួមគ្នានូវគម្រោងផ្តល់លាភការបន្ថែម ដោយផ្អែកទៅតាមគុណសម្បត្តិការងារ ផ្តល់ប្រាក់លើកទឹកចិត្តកាន់តែប្រសើរ ដើម្បីអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ មួយផ្នែកធំ គឺដោយសារការពិចារណាអំពីសមធម៌ រដ្ឋាភិបាលបានលុបគម្រោងផ្តល់លាភការបន្ថែម ដោយផ្អែកតាមគុណសម្បត្តិការងារកាលពីថ្ងៃ ទី ១ ខែ មករា ឆ្នាំ ២០១០ ហើយជំនួសគម្រោងនេះរយៈពេលប្រាំពីរខែក្រោយមក ដោយផែនការផ្តល់ការលើកទឹកចិត្តថ្មី ហៅថា ចំណាយប្រតិបត្តិការអាទិភាព ។

គម្រោងចំណាយប្រតិបត្តិការអាទិភាពនេះ គឺជាផ្នែកមួយនៃអភិក្រមពីរផ្លូវសម្រាប់កំណែទម្រង់លាភការទូទៅ រួមមាន (១) យុទ្ធសាស្ត្ររយៈពេលវែង ដូចបានកំណត់ដោយកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល និង (២) ការរៀបចំចំណាយប្រតិបត្តិការអាទិភាពបណ្តោះអាសន្ន ដើម្បីដោះស្រាយបញ្ហាស្តីពីការផ្តល់សេវា និងបញ្ហាស្តីពីការអនុវត្តកំណែទម្រង់ ។ផ្លូវទាំងពីរនេះត្រូវបានរំពឹងថារីកចម្រើនស្របគ្នា ដោយមានការត្រួតពិនិត្យជាទៀងទាត់ ដើម្បី (១) ប៉ាន់ស្មានវឌ្ឍនភាពឆ្ពោះទៅកំណែទម្រង់លាភការ និង (២) បញ្ចូលមេរៀនពីចំណាយប្រតិបត្តិការអាទិភាព ដើម្បីកែទម្រង់លាភការ និងទី (៣) សម្រេចចិត្តលើគុណសម្បត្តិនៃការកែតម្រូវ ការបន្ត ការដោះស្រាយបញ្ហាលាភការទាំងមូល គឺជាកត្តាមួយសំខាន់ ដើម្បីធ្វើឱ្យមាននិរន្តរភាព និងជំរុញបន្ថែមនូវលើការតែទម្រង់វឌ្ឍនភាពនៅទូទាំងរដ្ឋាភិបាល ។

---

*៤២ លើកលែងសូចនាករទីមួយទាក់ទងនឹងលទ្ធភាពព្យាករណ៍នៃការគាំទ្រថវិកាដោយផ្ទាល់ ដែលបានទទួលចំណាត់ថ្នាក់ "គ" គ្រប់សូចនាករទាំងអស់ដែលទាក់ទងជាមួយការអនុវត្តរបស់ម្ចាស់ជំនួយបានទទួលចំណាត់ថ្នាក់ ឃ ។*

*៤៣ ផលប៉ះពាល់លើចំណាយចរន្តភាគច្រើននៃគម្រោង ដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយលើថវិកាជាតិ មិនត្រូវបានកំណត់អត្តសញ្ញាណ ឬមិនត្រូវបានពិចារណាពេញលេញ និងតំណាងការផ្តល់មូលនិធិអនាគតយ៉ាងច្រើន និងកាតព្វកិច្ចផ្តល់សេវាកម្មវិធី ។ PEFA កត់សំគាល់ថា ការមានចំណងទាក់ទងកាន់តែរឹងមាំរវាងថវិកាចរន្ត និងថវិកាមូលធន នឹងពង្រឹងទំនុកចិត្តថវិកាក្នុងរយៈពេលមធ្យមតាមរយៈការបង្កើនប្រូបាប៊ីតេនៃធនធានហិរញ្ញវត្ថុពេញលេញ ដែលកំពុងត្រូវបានគ្រោងថវិកា ដើម្បីផ្តល់សេវាទៅតាមតួលេខដែលបានព្យាករណ៍ ។*

**វឌ្ឍនភាពចំពោះកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតែជួបបញ្ហាខ្វះជំនាញបច្ចេកទេស និងកង្វះសមត្ថភាព ទោះជាកំពុងមានកិច្ចប្រឹងប្រែងកសាងសមត្ថភាពជាបន្តក្តី។** សំណើកម្មវិធីសហការនឹងផ្តល់ការបណ្តុះបណ្តាលគណនេយ្យ ការកសាងថវិកាសវនកម្ម និងការគ្រប់គ្រងជាមូលដ្ឋានដោយប្រើអង្គភាពបណ្តុះបណ្តាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុការបណ្តុះបណ្តាលនេះចាំបាច់ត្រូវបំពេញបន្ថែមដោយកិច្ចប្រឹងប្រែងអភិវឌ្ឍសមត្ថភាពដឹកនាំ ដោយរចនាសម្ព័ន្ធ និងនាយកដ្ឋានពាក់ព័ន្ធ ។ ការណ៍នេះអាចជួយឱ្យវឌ្ឍនភាពចំពោះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់ដទៃទៀតឱ្យមានចីរភាពដូចជា វិមជ្ឈការ និងវិសហមជ្ឈការកំណែទម្រង់រដ្ឋបាលសាធារណៈ និងអភិបាលកិច្ចល្អ (សូមមើលប្រអប់លេខ ៥ អំពីមុខងារសំខាន់នៃការអភិវឌ្ឍធនធានមនុស្សក្នុងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុនៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត) ។

### ប្រអប់លេខ ៦. បទពិសោធន៍ធនាគារពិភពលោកជាមួយប្រព័ន្ធរតនាគារ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ

ចាប់តាំងពីឆ្នាំ ១៩៨៨ មក ធនាគារពិភពលោកបានផ្តល់ហិរញ្ញប្បទានគម្រោងរតនាគារ និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុចំនួន ៨៧ នៅ ៥១ ប្រទេស ។ កត្តាសំខាន់បួនដែលរួមចំណែកចំពោះជោគជ័យនៃគម្រោងរតនាគារ និងគម្រោងប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ គឺ :

- ការផ្តោតលើការអភិវឌ្ឍសមត្ថភាពធនធានមនុស្សចាំបាច់ ដើម្បីអនុវត្ត និងដំណើរការប្រព័ន្ធពេញលេញ
- វត្តមាននៃការប្តេជ្ញាចិត្តដែលនយោបាយ និងភាពជាម្ចាស់របស់អ្នកខ្ចី
- ស្ថិតនៅក្បែរការត្រួតពិនិត្យរបស់ធនាគារពិភពលោក
- ការគ្រប់គ្រងគម្រោងមានភាពបត់បែន

**ការលើកកម្ពស់គណនេយ្យភាព តាមរយៈមុខងារសវនកម្មផ្ទៃក្នុង និងផ្ទៃក្រៅ ដែលទ្រទ្រង់ដោយការពង្រឹងការត្រួតពិនិត្យរបស់សភានៅតែមានបញ្ហា។** ទោះបីជាការងារស្តីពីសវនកម្មផ្ទៃក្នុង បាន និងកំពុងដំណើរការចាប់តាំងពីឆ្នាំ ២០០៦ ក្តី ការវាយតម្លៃរបស់ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុកាលពីពេលថ្មីៗ បានកត់សំគាល់ថា ការត្រួតពិនិត្យផ្ទៃក្នុងនៅខ្សោយនៅឡើយ ។ ខណៈដែលគំរូសម្រាប់របាយការណ៍សវនកម្មត្រូវបានបង្កើតឡើងដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ដោយ ក៏គំរូរបាយការណ៍ទាំងនោះមិនត្រូវបានអនុវត្ត ឬប្រើប្រាស់ដូចៗគ្នាដោយក្រសួងពាក់ព័ន្ធឡើយ ។ ដោយមានការគាំទ្ររបស់ម្ចាស់ជំនួយ សវនកម្មផ្ទៃក្នុងត្រូវបានលើកកម្ពស់នៅក្រសួងពាក់ព័ន្ធសំខាន់ៗ រួមមាន ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ ទោះជាទាំងអស់នេះត្រូវបានអនុវត្តមួយផ្នែកធំ ដើម្បីបំពេញកាតព្វកិច្ចរាយការណ៍ដែលតម្រូវដោយម្ចាស់ជំនួយ ជាជាងតម្រូវដោយរដ្ឋាភិបាលក្តី។ នៅពេលដែលរដ្ឋាភិបាលប្តូរការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យភាពទៅកាន់ក្រសួងពាក់ព័ន្ធ និងទៅកាន់អាជ្ញាធរថ្នាក់ក្រោមជាតិ ផែនការសវនកម្ម ចាំបាច់ត្រូវដាក់បញ្ចូលនូវអភិក្រមផ្អែកលើហានិភ័យ ដែលកំពុងស្ថិតនៅក្រោមការទ្រទ្រង់ និងណែនាំរបស់បុគ្គលិក នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយប្រមូលផ្តុំលើក្រសួងពាក់ព័ន្ធ ។

**អាជ្ញាធរសវនកម្មជាតិរឹងមាំ នឹងពង្រឹងតម្លាភាពសារពើពន្ធ និងជំរុញឱ្យម្ចាស់ជំនួយប្រើប្រព័ន្ធនានារបស់ប្រទេសកាន់តែច្រើន។** បញ្ហាពីរមានសារៈសំខាន់ជាពិសេស គឺការធ្វើសវនកម្មរបស់អាជ្ញាធរជាតិសវនកម្មអំពីអនុលោមភាព និងហិរញ្ញវត្ថុ និងការបោះផ្សាយបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយនូវលទ្ធផល ដែលឆ្លើយតបនឹងស្តង់ដារសវនកម្មអន្តរជាតិ ។ ការពិនិត្យឡើងវិញកាលពីពេលថ្មីៗដោយការិយាល័យសវនកម្មនូវែលហ្សេឡង់ បានសន្និដ្ឋានដោយផ្តល់អនុសាសន៍ចំនួនបី ។ អនុសាសន៍ទាំងនោះ គឺ (i) កសាងប្រព័ន្ធ និងវិធីសាស្ត្រនានាដែលមានស្រាប់របស់អាជ្ញាធរជាតិសវនកម្មសម្រាប់សកម្មភាពសវនកម្មរបស់ខ្លួន (ii) ត្រៀមលក្ខណៈអាជ្ញាធរជាតិសវនកម្មចំពោះការរួមចំណែកកាន់តែទូលាយ ក្រោមកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (iii) បន្តអនុវត្តយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រាប់ទាំងកម្លាំងពលកម្ម និងប្រព័ន្ធ ICT ពេញលេញ និងមានចីរភាព[៤៤] ។

---

*៤៤ ការពិនិត្យឡើងវិញនេះប្រព្រឹត្តិទៅឆ្នាំ ២០១០ ។ អនុសាសន៍ភាគច្រើនត្រូវបានបំភ្លេច ឬមិនសូវផ្តល់អាទិភាពនៅក្នុងផែនការការងាររបស់អាជ្ញាធរជាតិសវនកម្ម ។ ការវាយតម្លៃរបស់ ក៏បានសន្និដ្ឋានថា សវនកម្មផ្ទៃក្រៅមិនដើរតួសំខាន់ក្នុងការតម្រូវឱ្យនីតិប្រតិបត្តិរបស់រដ្ឋាភិបាលទទួលខុសត្រូវឡើយ ។ អាជ្ញាធរជាតិសវនកម្មមិនបានបោះផ្សាយរបាយការណ៍របស់ខ្លួនឱ្យបានទាន់ពេលវេលា (ខ្លឹមសារសង្ខេបនៅក្នុងរបាយការណ៍សវនកម្មឆ្នាំ ២០០៦ ត្រូវបានបោះពុម្ពផ្សាយនៅចុងឆ្នាំ ២០០៩) ដែលមិនអាចធ្វើឱ្យសាធារណជនដឹងថា តើមូលនិធិសាធារណៈត្រូវបានចំណាយស្របតាមគោលបំណងរបស់ខ្លួនមែន ឬយ៉ាងណា ។*

**ការត្រួតពិនិត្យរបស់សភានៅខ្សោយ។ ការពង្រឹងសមត្ថភាពរបស់សភា និងជាពិសេសការពង្រឹងសមត្ថភាពរបស់គណៈកម្មការទទួលបន្ទុកហិរញ្ញវត្ថុ និងធនាគារនឹងបង្កើនសមត្ថភាពត្រួតពិនិត្យបន្ថែមទៀត។** ដៃគូអភិវឌ្ឍន៍បន្តចូលរួមជាមួយសភា ជាពិសេសក្នុងអំឡុងពេលប្រជុំបែងចែកថវិកាប្រចាំឆ្នាំតាមរយៈសិក្ខាសាលា និងកម្មសិក្ខាសាលា និងផ្តល់ការគាំទ្រចំពោះការបោះផ្សាយ "ព័ត៌មានខ្លីអំពីថវិកា" ដល់ប្រជាពលរដ្ឋដើម្បីបង្កើនការយល់ដឹងអំពីថវិការបស់រដ្ឋាភិបាលពីពលរដ្ឋគ្រប់រូប ។ ការជំរុញកាលពីពេលថ្មីៗនៃស្ថាន័នរដ្ឋសភាព និងស្ថាប័នជាតិសវនកម្មក្នុងការចែករំលែកបទពិសោធន៍ជាសកម្មភាពដ៏គួរឱ្យលើកទឹកចិត្ត ។

## ឃ. ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ : បញ្ហាប្រឈម និងហានិភ័យ

**គម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ គឺជាបញ្ហាប្រឈមផ្នែកបច្ចេកទេស និងជាការប្រែក្លាយជាមូលដ្ឋាន អំពីវិធីធ្វើសេចក្តីសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងវិធីត្រួតពិនិត្យ និងគ្រប់គ្រងធនធាន។** ជម្រើសដែលត្រូវជ្រើសជុំវិញ សមត្ថកិច្ច គណនេយ្យភាព ការទទួលខុសត្រូវ និងបច្ចេកវិទ្យា នឹងរៀបចំព្រមទាំងកំណត់ការគ្រប់គ្រងហិរញ្ញវត្ថុរួម និងរចនាសម្ព័ន្ធផ្តល់សេវារបស់រដ្ឋាភិបាលសម្រាប់ច្រើនឆ្នាំតទៅមុខ ។ ភាពច្បាស់លាស់នៅក្នុងគោលនយោបាយអំពីចំនួនបញ្ហាបច្ចេកទេស និងមិនមែនបច្ចេកទេស នឹងជំរុញការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ និងជួយធានាថា ប្រព័ន្ធនេះដែលដាក់ឱ្យដំណើរការនៅទូទាំងប្រទេស ជាប្រព័ន្ធមានសារប្រយោជន៍ និងមានភាពពាក់ព័ន្ធ។ កិច្ចការកំពុងប្រព្រឹត្តិទៅក្នុងការរៀបចំកិច្ចសន្យា ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុបង្ហាញថា ការរៀបចំប្រព័ន្ធនេះឱ្យចប់សព្វគ្រប់ ត្រូវចំណាយពេលវេលាយូរ ហើយខណៈពេលដែលអាចមានការកែទម្រង់ផ្លាស់ប្តូរទ្រង់ទ្រាយជាច្រើនដែលលំបាកតម្រូវឱ្យមានការតាំងចិត្ត និងយល់ព្រមបាត់បង់គោលនយោបាយពិបាកយកឈ្នះ ឬផលប្រយោជន៍ផ្នែកនីតិវិធីនៅពេលដែលប្រព័ន្ធនេះត្រូវបានដាក់ពង្រាយឱ្យដំណើរការ ។

**សកម្មភាពជំរុញប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុបានរីកចម្រើន ប៉ុន្តែគប្បីផ្តោតការយកចិត្តទុកដាក់ និងតម្រឹមសកម្មភាពទាំងនេះជាថ្មី ដើម្បីពន្លឿនវឌ្ឍនភាព។** មានផ្នែកសំខាន់ៗចំនួនពីរ ដើម្បីជួយធានាឱ្យប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ចាប់ផ្តើមលើផ្លូវត្រឹមត្រូវ សម្រួលការអនុវត្តគម្រោង និងជៀសវាងការអូសបន្លាយពេលវេលា ដែលកាត់បន្ថយសក្តានុពលនៃការកែសម្រួលកិច្ចសន្យាក្នុងពេលអនាគតដែលត្រូវចំណាយខ្ពស់ ។ ទីមួយ ការពិនិត្យមុខងារឡើងវិញ និងការបង្កើតឱ្យមានរចនាសម្ព័ន្ធចាត់តាំងថ្មី ដើម្បីគាំទ្ររបៀបវារៈកំណែទម្រង់ គឺជាការចាំបាច់ ។ ការមានរចនាសម្ព័ន្ធ និងការគ្រប់គ្រងក្នុងពេលប្រគល់កិច្ចសន្យា នឹងជួយសម្រួលការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុឱ្យកាន់តែរលូន ។ ទីពីរ ប្លង់គណនីថ្មីមួយ ដែលច្របាច់បញ្ចូលថវិកា និងគណនេយ្យទៅក្នុងរចនាសម្ព័ន្ធលេខកូដគណនីឯកភាព គប្បីទទួលបានការយល់ព្រម និងអនុវត្ត ។ និងទីបី ដំណើរការការងារចាំបាច់ត្រូវមានដំណើរវិវឌ្ឍន៍ទៅមុខជាបណ្តើរៗ ដើម្បីធ្វើការអនុវត្តសាកល្បងកែតម្រូវ និងធ្វើការបណ្តុះបណ្តាលបុគ្គលិកជាបន្តបន្ទាប់ មុនពេលដែលប្រព័ន្ធស្នូលចាប់ផ្តើមដំណើរការនៅដើមឆ្នាំ ២០១៣ ។

**សកម្មភាពទាំងអស់នេះ គប្បីគាំទ្រផែនការសកម្មភាពប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុដែលកំណត់ និងធ្វើសមាហរណកម្មបានត្រឹមត្រូវដែលដាក់បញ្ចូលនូវធាតុទាំងអស់នៃការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុដោយជោគជ័យ។** ក្រុមចំនួនបី (ផ្នែកគណនេយ្យភាព ផ្នែកអនុវត្តថវិកា និងផ្នែកគណនេយ្យ និងស្តង់ដារនៃការរាយការណ៍) ដឹកនាំដោយរដ្ឋលេខាធិការពីររូប និងអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដើម្បីរៀបចំ និងអនុវត្តផែនការសកម្មភាពប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ។

**ដើម្បីបង្កើនល្បឿនអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើឱ្យកំណត់អាទិភាពបន្ថែមនូវផ្នែកជំរុញសំខាន់ចំនួនប្រាំ ជុំវិញការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ។** "សំណើ ៣ + ២ " ដែលបានបង្ហាញកាលពីខែ មីនា ឆ្នាំ ២០១០ ព្យាយាមផ្តល់អាទិភាព និងពន្លឿនបន្ថែមនូវការងាររបស់ក្រុមធ្វើការអំពីសំណុំកត្តាជំរុញទីមួយ (តារាងលេខ ២៣) ។ គេត្រូវការកិច្ចប្រឹងប្រែងបន្ថែម ដើម្បីដាក់បញ្ចូលការងាររបស់ក្រុមទាំងបីទៅក្នុងផែនការតែមួយ ដែលឯកភាពដោយដៃគូអភិវឌ្ឍន៍ ។

**នៅក្រោមសំណើនៃគំរូដែលផ្តោតលើរតនាគារ អគ្គនាយកដ្ឋានរតនាគារនឹងធ្វើប្រព្រឹត្តិកម្មប្រតិបត្តិការទាំងអស់ រីឯប្រព័ន្ធគណនេយ្យប្រមូលផ្តុំ និងប្រព័ន្ធទូទាត់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅតែស្ថិតនៅដដែល។** សំណើបែបនេះ មិននាំមកនូវគណនេយ្យភាពដែលបានគ្រោងនៅក្នុងជំហានទី ២ ឡើយ។ នៅក្រោមទិដ្ឋភាពនេះ សវនកម្មផ្ទៃក្នុងនៅក្នុងក្រសួងពាក់ព័ន្ធនានាក្លាយជាមិនសូវសំខាន់។ ទោះបីជាត្រូវបានចាត់ទុកថាជាដំណោះស្រាយបណ្តោះអាសន្នក្តី គប្បីពន្លឿនការរៀបចំគម្រោងស្មើចំពោះអំណាច និងការទទួលខុសត្រូវ ដែលត្រូវផ្តល់ឱ្យអង្គភាពថវិកានៅកម្រិតខុសៗគ្នា ដើម្បីជួយកំណត់រកវិធីពង្រឹងសមត្ថភាពអង្គភាពថវិកានៅក្នុងគម្រោងអនុវត្តសាកល្បង និងនៅទូទាំងរដ្ឋាភិបាល។

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើតយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយសម្រាប់គ្រប់គ្រងបុគ្គលិក ដើម្បីគាំទ្រការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ។** យុទ្ធសាស្ត្រនេះ មានគោលបំណងគ្រប់គ្រងការរឹងទទឹងរបស់បុគ្គលិក និងកសាងសមត្ថភាព ដើម្បីឱ្យមានការផ្លាស់ប្តូរនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាក់ព័ន្ធនានា និងនៅតាមរតនាគារខេត្ត។ ទោះបីជាការវាយតម្លៃដំណើរការការងារបានចាប់ផ្តើម ហើយកម្រិតមួយចំនួននៃការចូលរួម និងការយល់ដឹងរបស់នាយកដ្ឋានត្រូវបានសម្រេចក្តី ការទទួលយកនូវការផ្លាស់ប្តូរទាំងនេះនៅក្នុងជួររដ្ឋាភិបាលនៅតែជាបញ្ហាប្រឈមធំមួយ ជាស្ថានភាពមួយ ដែលកាត់បន្ថយលទ្ធភាពនៃការទទួលយកកាលពីពេលដំបូង។ ដោយសារការមកដល់នៃដំណើរការងារស្វ័យប្រវត្តិ នឹងកាត់បន្ថយឱកាសក្នុងការស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន ភាពជាអ្នកដឹកនាំរឹងមាំ និងមានចិរភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាក់ព័ន្ធ និងក្រុមអនុវត្តគម្រោងមានសារៈសំខាន់ណាស់ដើម្បីឱ្យប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុទទួលជោគជ័យ។

**តារាងលេខ ២៣. គម្រោងស្នើ ៣ + ២ : កត្តាជំរុញសំខាន់ដើម្បីឱ្យមានគណនេយ្យភាពហិរញ្ញវត្ថុ**

| **កត្តាជំរុញ ៣ សំខាន់ (ធាតុ)** | **ចំណុចគោលសំខាន់ៗ** |
|---|---|
| បន្ទាត់គណនេយ្យភាព | • អង្គភាពថវិកា |
| | • ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង |
| ស្តង់ដារគណនេយ្យ | • ចំណាត់ថ្នាក់ថវិកា |
| | • ប្លង់គណនី |
| | • ការកត់ត្រា/របាយការណ៍ |
| ប្រព័ន្ធអនុវត្តថវិកា | • ដំណើរការសន្យា |
| | • ដំណើរការលទ្ធកម្ម |
| | • ដំណើរការទូទាត់ |
| **កត្តាជំរុញ ២ សំខាន់** | **ចំណុចគោលសំខាន់ៗ** |
| ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធព័ត៌មាន (ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ) | • ផែនការអនុវត្តយុទ្ធសាស្ត្រ |
| | • ការផ្តល់កិច្ចសន្យា និង |
| | • ការគ្រប់គ្រងគម្រោង |
| ការអភិវឌ្ឍសមត្ថភាព | • ការបណ្តុះបណ្តាល |
| | • ការគ្រប់គ្រងធនធានមនុស្ស |
| | • រចនាសម្ព័ន្ធស្ថាប័ន |

*ប្រភព :* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**បទពិសោធន៍ជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបង្ហាញថា ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ នឹងមានល្បឿនយឺតជាងការប្រមើលទុកមុននេះ។** ទស្សនាទាន និងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុជារឿងមួយថ្មីនៅកម្ពុជា។ ក្នុងស្ថានភាពខ្វះបទពិសោធន៍ ភាពស្មុគស្មាញ និងវិសាលភាពនៃភារកិច្ចសំខាន់នេះ គប្បីពិចារណាបន្ថែមអំពីពេលវេលាចាំបាច់សម្រាប់អនុវត្តសាកល្បង និងសម្រាប់បន្តអនុវត្តដំណាក់កាលទីមួយនៃគម្រោង។ក្រោមផែនការបច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមើលឃើញការផ្តល់កិច្ចសន្យាទោលតែមួយសម្រាប់ដំណាក់កាលទីមួយ ដែលរួមមានដំណាក់កាលសាកល្បង និងការប្រគល់មុខងាររតនាគារ និងមុខងារថវិកាស្នូលទៅកាន់រតនាគារខេត្តទាំងអស់ក្នុងរយៈពេលបួនឆ្នាំ។ បទពិសោធន៍របស់ធនាគារពិភពលោកក្នុងការអនុវត្តគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុនៅជុំវិញពិភពលោកបង្ហាញថា គម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុគ្រប់ជ្រុងជ្រោយ ត្រូវចំណាយពេល ៦-៧ ឆ្នាំ ដើម្បីរៀបចំឱ្យរួចស្រេចបាច់ (រួមមាន ការតាក់តែងគម្រោងលទ្ធកម្ម ការបង្កើតប្រព័ន្ធព័ត៌មាន និងការកសាងសមត្ថភាព)។ ដោយសារដំណើរការកិច្ចលទ្ធកម្មសម្រាប់ប្រព័ន្ធ ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុបានចាប់ផ្តើមនៅឆ្នាំ ២០០៦ ការបង្កើនរយៈពេលសម្រាប់គម្រោងនេះ និងការផ្តល់កិច្ចសន្យាក្នុងដំណាក់ការច្រើន ទំនងជាវិធីដែលគប្បីអនុវត្តតទៅអនាគត។

## ខ. កំណែទម្រង់រដ្ឋបាលសាធារណៈ និងវិមជ្ឈការ និងវិសហមជ្ឈការ

**ការធ្វើសមាហរណកម្មកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ហិរញ្ញវត្ថុជាមួយកំណែទម្រង់វិស័យអប់រំ និងវិស័យដទៃទៀតនៅតែជាបញ្ហាប្រឈមមុខដ៏ជ្រាលជ្រៅ។** ការកំណត់ការទទួលខុសត្រូវចំពោះការផ្តល់សេវា និងការគ្រប់គ្រងធនធានមានទំនាក់ទំនងជាមួយការរៀបចំបុគ្គលិក និងវិធីរៀបចំមុខងារសាធារណៈទាំងមូល ។ ការពន្យារពេលកំណែទម្រង់មុខងារសាធារណៈ និងកំណែទម្រង់ស្ថាប័នគ្រប់ជ្រុងជ្រោយ មានឥទ្ធិពលដោយផ្ទាល់មកលើវឌ្ឍនភាពដែលសម្រេចបាន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយចីរភាពនៃផលប្រយោជន៍ដែលបានមកដោយលំបាកប្រឈមមុខនឹងហានិភ័យ ។ ការចាត់ និងការប្រគល់មុខងារ គឺជាទិដ្ឋភាពសំខាន់មួយដើម្បីសម្រេចបាននូវការបន្សីកាន់តែល្អប្រសើររវាងធនធាន ការទទួលខុសត្រូវ និងការផ្តល់រង្វាន់ ។ វឌ្ឍនភាពក្នុងពេលអនាគតលើកំណែទម្រង់នានាក្នុងជំហានទីពីរ រាប់ទាំងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុអាចប្រឈមមុខនឹងហានិភ័យ វៀរលែងតែបញ្ហារដ្ឋបាលសាធារណៈទូទៅទាំងនេះត្រូវបានដោះស្រាយ ។ នៅពេលដែលប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុដំណើរការមុខងារបច្ចុប្បន្នជាច្រើន សមត្ថកិច្ច និងការទទួលខុសត្រូវដែលបានប្រគល់ឱ្យ ព្រមទាំងការផ្លាស់ប្តូរដែលនាំមកដោយដំណើរការការងារដែលបានកែសម្រួល ចាំបាច់ត្រូវដោះស្រាយតាមរយៈការរៀបចំរចនាសម្ព័ន្ធចាត់តាំងសាឡើងវិញ និងការលើកកម្ពស់ជំនាញ និងសមត្ថភាពរបស់បុគ្គលិកបច្ចុប្បន្ន ។

**ការដាក់ឱ្យមានកិច្ចប្រឹងប្រែងរួមគ្នា ដើម្បីពង្រឹងដំណើរការ ដើម្បីធ្វើការជាមួយមន្ត្រីជាន់ខ្ពស់នៅក្នុងបណ្តាក្រសួងនានា ក្នុងការអនុវត្តកំណែទម្រង់គ្រប់គ្រងវិស័យសាធារណៈចំនួនបី ពោល គឺកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ អាចលើកកម្ពស់ការទទួលខុសត្រូវបុគ្គលសម្រាប់ជោគជ័យរបស់ពួកគេ។** យន្តការបែបនេះ អាចរួមមានការពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំនៃក្រសួងពាក់ព័ន្ធ និងស្ថាប័ននានាអំពីវិធីដែលកិច្ចប្រឹងប្រែងកែទម្រង់ពាក់ព័ន្ធទាំងបី អាចជួយពួកគេដោយប្រសិទ្ធភាពបំផុត ដើម្បីឆ្លើយតបនឹងអាណត្តិការងាររបស់ពួកគេ ក៏ដូចជាវិធីដែលអាចកែសម្រួលកិច្ចប្រឹងប្រែងកែទម្រង់ ដែលប្រទាំងប្រទើសគ្នាដើម្បីទ្រទ្រង់ក្រសួងពាក់ព័ន្ធក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការផ្តល់សេវា និងអនុវត្តកម្មវិធីនានា ។ ការមានមន្ត្រីជាន់ខ្ពស់តិចនៃក្រសួងពាក់ព័ន្ធធ្វើការរាយការណ៍ជាទៀងទាត់ទៅកាន់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ អំពីវិធីដែលគំនិតផ្តួចផ្តើមកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំពុងត្រូវបានអនុវត្តនៅតាមក្រសួងរបស់ពួកគេ អាចជំរុញទំនាក់ទំនង ការយល់ដឹង និងការទទួលយកកំណែទម្រង់នៅក្នុងជួររដ្ឋាភិបាល ។ បន្ថែមពីលើនេះ ការប្រាស្រ័យទាក់ទង និងការពិគ្រោះយោបល់កាន់តែច្រើនក្នុងចំណោមថ្នាក់ដឹកនាំបច្ចេកទេសធ្វើការលើកំណែទម្រង់ទាំងនេះ ពិសេសក្នុងការធ្វើសុខដុមភាវូបនីយកម្មនូវការរៀបចំគោលការណ៍ណែនាំគ្រប់គ្រង និងគោលការណ៍ណែនាំអនុវត្ត នឹងកាត់បន្ថយលទ្ធភាពមានទំនាស់ និងកាត់បន្ថយលទ្ធភាពមានដំណើរការវិសមភាព ហេតុនេះកាត់បន្ថយការពន្យារពេលមិនចាំបាច់ចំពោះការអនុវត្តកំណែទម្រង់ ។

**រដ្ឋបាលកំណែទម្រង់សាធារណៈ គប្បីត្រូវបានចាត់ទុកថាជាផ្នែកមួយនៃដំណើរការកំណែទម្រង់ទូលាយ ដើម្បីធ្វើឱ្យប្រាកដថា ការរៀបចំគោល-នយោបាយ ការរៀបចំថវិកា ការផ្តល់សេវា និងគណនេយ្យភាពត្រូវបានតម្រឹមតម្រង់ ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។** រដ្ឋាភិបាលមានបំណងប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជា "អ្នកផ្តល់សេវាសាធារណៈដែលមានប្រសិទ្ធភាព" ដោយធ្វើឱ្យសេវាសាធារណៈមានតម្លាភាពមានលក្ខណៈឆ្លើយតប និងមានប្រសិទ្ធភាពតាមរយៈការជំរុញទឹកចិត្ត ភក្តីភាព និងវិជ្ជាជីវៈនិយម ។ ដើម្បីធ្វើបែបនេះបាន ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលកំពុងរៀបចំគោលនយោបាយគន្លឹះ រួមមាន ការគ្រប់គ្រងធនធានមនុស្ស ការអភិវឌ្ឍធនធានមនុស្ស និងគោលនយោបាយសេវាសាធារណៈ ។ រដ្ឋាភិបាលមានគោលនយោបាយសម្រាប់បង្កើនប្រាក់បៀវត្សមូលដ្ឋាន ២០ ភាគរយក្នុងមួយឆ្នាំ ។ ទោះជាយ៉ាងណាក្តី បៀវត្សមន្ត្រីរាជការនៅតែមានកម្រិតទាបធៀបនឹងបៀវត្សក្នុងផ្នែកឯកជន ។ កម្រិតបៀវត្សទាបកំហិតលទ្ធភាពរបស់វិស័យសាធារណៈក្នុងការផ្តល់សេវានៅតាមផ្នែកនានា និងជាពិសេសចំពោះកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងភាពខុសគ្នានៃបៀវត្ស ។ គម្រោងផ្តល់លាភការបន្ថែមដោយផ្អែកទៅតាមគុណសម្បត្តិការងារ និងក្រោយមកទៀតគម្រោងចំណាយប្រតិបត្តិការអាទិភាពដោះស្រាយបញ្ហាទាំងនេះ ។ កម្មវិធីកំណែទម្រង់រដ្ឋបាលនៅថ្នាក់ជាតិ ដាក់ចេញនូវក្របខ័ណ្ឌរួមសម្រាប់ដោះស្រាយរចនាសម្ព័ន្ធនានារបស់រដ្ឋាភិបាល ក្នុងការលើកកម្ពស់ឧបករណ៍គ្រប់គ្រងធនធានមនុស្ស និងកំណែទម្រង់ប្រាក់លាភការ ។ រដ្ឋាភិបាលដែលដឹកនាំដោយក្រុមប្រឹក្សាកំណែទម្រង់ និងដៃគូអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌក្រុមការងារបច្ចេកទេស កំណែទម្រង់រដ្ឋបាលសាធារណៈ បានព្រមព្រៀងកំណត់អត្តសញ្ញាណសំណើដែលអាចអនុវត្តបាន ដើម្បីរៀបចំតាមលំដាប់លំដោយនូវប្រាក់លាភការ និងកំណែទម្រង់រដ្ឋបាលសាធារណៈទូលំទូលាយនៅចុងឆ្នាំ ២០១១ ដូចបានរំពឹងទុកដោយហេតុថា បញ្ហាប្រាក់លាភការជារួមនៅតែជាកត្តាដ៏សំខាន់សម្រាប់ធ្វើឱ្យកំណែទម្រង់នានារបស់រដ្ឋាភិបាល ជាពិសេសកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមាននិរន្តរភាព និងមានវឌ្ឍនភាពបន្ថែម ។

**ចំបាច់ត្រូវតម្រឹមរបៀបវារៈកំណែទម្រង់ថ្នាក់ក្រោមជាតិឱ្យបានជិតស្និទ្ធជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។** ប្រការនេះតម្រូវឱ្យមានការបន្ត និងពង្រីកពិភាក្សារយៈពេលវែងលើកំណែទម្រង់ទាំងនេះ តម្រូវឱ្យមានការបញ្ជាក់ច្បាស់អំពីមុខងារ និងភារកិច្ច និងកិច្ចប្រឹងប្រែងនានា ដើម្បីជៀសវាងការធ្វើកិច្ចការត្រួតជាន់គ្នា និងជៀសវាងការធ្វើកំណែទម្រង់ដែលមិនបានតម្រឹមតម្រង់។ ច្បាប់ថវិកាដែលបានអនុម័តនៅឆ្នាំ ២០០៨ ដាក់ចេញនូវក្របខ័ណ្ឌច្បាប់ និងគ្រប់គ្រងចំពោះរាល់ទិដ្ឋភាពនៃដំណើរការគ្រប់គ្រងថវិការដ្ឋាភិបាលនៅថ្នាក់ជាតិ និងក្រោមជាតិ។ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិកាលពីពេលកន្លងទៅថ្មីៗ ចែងអំពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ច្បាប់ទាំងនេះតម្រូវឱ្យមានពិនិត្យមើលឡើងវិញឱ្យបានហ្មត់ចត់ ដើម្បីធានាឱ្យច្បាប់ទាំងនោះមានលក្ខណៈបំពេញបន្ថែម មិនផ្ទុយគ្នា និងបង្កើតលទ្ធភាពគ្រប់គ្រាន់សម្រាប់បង្កើតយន្តការ និងច្បាប់ដទៃទៀតដែលគាំទ្រហិរញ្ញប្បទាននៅថ្នាក់ក្រោមជាតិ។

**សំណើគ្រប់គ្រងគណនីរដ្ឋបាលក្រោមច្បាប់ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិជាចំណុចចាប់អារម្មណ៍។** ច្បាប់ថវិកាតម្រូវឱ្យប្រើគណនីទោលនៅរតនាគារ ហើយវឌ្ឍនភាពយ៉ាងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំនេះក្រោមកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការបិទគណនី។ ការអនុញ្ញាតឱ្យអភិបាលគ្រប់គ្រង បើក និងបិទ "គណនីរដ្ឋបាល" ក្រោមច្បាប់ថវិកាថ្នាក់ក្រោមជាតិ នឹងធ្វើឱ្យប៉ះពាល់ដល់កិច្ចប្រឹងប្រែងនានារបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ ដែលពិបាកជាស្រេចរួចទៅហើយ និងរួមចំណែកធ្វើខ្ទះសាច់ប្រាក់ធ្វើឱ្យខូចខាតដល់និរន្តរភាពនៃកំណែទម្រង់នានានៅជំហានទីមួយ។គប្បីយកចិត្តទុកដាក់ឱ្យហ្មត់ចត់ថាតើក្នុងពេលនេះគេត្រូវការឱ្យមានគណនីរដ្ឋបាលសម្រាប់អភិបាលដែរ ឬយ៉ាងណា និងគប្បីគិតគូរដល់ហានិភ័យផ្នែកថវិកាដែលទាក់ទងនឹងគណនីបែបនេះ ខណៈដែលរចនាសម្ព័ន្ធគ្រប់គ្រងក្នុងពេលបច្ចុប្បន្ននៅទន់ខ្សោយ។

**ផែនការអនុវត្តរយៈពេលបីឆ្នាំសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពណ៌នាអំពីអនុលោមភាពស្មុគស្មាញ និងការរៀបចំអំពីអធិការកិច្ច។** គេអាចសម្រេចអនុលោមភាពមួយផ្នែកធំតាមរយៈសវនកម្មផ្ទៃក្រៅ និងផ្ទៃក្នុង។ ខណៈដែលបណ្តាក្រសួងនានា ចាំបាច់ត្រូវអនុវត្តមុខងារត្រួតពិនិត្យលើបទប្បញ្ញត្តិគ្រប់គ្រង ដើម្បីធានាឱ្យប្រាកដថាយុទ្ធសាស្ត្រជាតិ គោលនយោបាយ និងនីតិវិធីនានា ត្រូវបានអនុវត្តតាម ហើយរបៀបដែលកិច្ចការទាំងនេះ ត្រូវធ្វើតម្រូវឱ្យមានការយកចិត្តទុកដាក់ហ្មត់ចត់។ ផែនការអនុវត្ត (IP3) ប្រមើលឃើលនូវរចនាសម្ព័ន្ធការពារថវិកាជាមួយនឹងគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុង ព្រមជាមួយសវនកម្មឯករាជ្យចំពោះគណនីនានា។ ការទទួលខុសត្រូវក្នុងការធ្វើសវនកម្មឯករាជ្យនៅថ្នាក់ក្រោមជាតិមានលក្ខណៈមិនច្បាស់លាស់។ ប្រសិនបើកិច្ចការនេះត្រូវអនុវត្តដោយអាជ្ញាធរជាតិសវនកម្ម ស្ថាប័ននោះនឹងត្រូវការការអភិវឌ្ឍសមត្ថភាពយ៉ាងច្រើន ដើម្បីបំពេញមុខងារនេះ។

**ភាពច្បាស់លាស់ជុំវិញការរៀបចំរាយការណ៍ផ្នែកហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាការចាំបាច់។** ការផលិតរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដោយអង្គភាពនានានៅថ្នាក់ក្រោមជាតិ និងសវនកម្មប្រចាំឆ្នាំដោយអាជ្ញាធរជាតិសវនកម្ម គឺជាជំហានវិជ្ជមានមួយអំពីអភិបាលកិច្ច គណនេយ្យភាព និងតម្លាភាព។ រដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវងាកឆ្ពោះទៅរកស្តង់ដារគណនេយ្យអន្តរជាតិវិស័យសាធារណៈ (IPSAS) ដើម្បីឱ្យស៊ីគ្នាជាមួយការការអនុវត្ត និងស្តង់ដារគណនេយ្យរបស់រដ្ឋាភិបាល។ IP3 ចែងថាប្រព័ន្ធព័ត៌មានគ្រប់គ្រងតែមួយ ដែលត្រូវបានធ្វើសមាហរណកម្មសម្រាប់កសាងផែនការ រៀបចំថវិកា តាមដាន វាយតម្លៃ គ្រប់គ្រងហិរញ្ញវត្ថុ (និងគណនេយ្យ) ចុះកិច្ចសន្យា និងរាយការណ៍ នឹងត្រូវបានអនុវត្ត។ ចាំបាច់ត្រូវមានការពិចារណា និងកសាងផែនការដោយប្រុងប្រយ័ត្ន ដើម្បីធានាឱ្យមានចំណងទាក់ទងសមស្របជាមួយប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ដែលនឹងត្រូវបន្តអនុវត្តនៅថ្នាក់ខេត្ត និងត្រូវកំណត់ថា តើប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ខេត្ត ស្រុក និងក្រុង នឹងមានលទ្ធភាពផ្តល់អត្ថប្រយោជន៍ដែលបានពិនិត្យឃើញដែរ ឬយ៉ាងណា។

**ទិដ្ឋភាពគន្លឹះមួយនៃរបៀបវារៈវិមជ្ឈការផ្តោតលើការពិភាក្សា និងកិច្ចព្រមព្រៀងលើមុខងារ ហើយតើរដ្ឋាភិបាលកម្រិតណាដែលទទួលខុសត្រូវចំពោះការអនុវត្តរបស់ខ្លួន។** ការប្រគល់ការទទួលខុសត្រូវទៅឱ្យខេត្ត និងស្រុក មិនត្រឹមតែមានបច្ច័យផ្នែកហិរញ្ញប្បទាន និងធនធានប៉ុណ្ណោះទេ ប៉ុន្តែក៏មានបច្ច័យទៅដល់ការពិចារណាផ្នែកស្ថាប័ន អង្គការចាត់តាំង និងធនធានមនុស្ស ដែលតម្រូវឱ្យមានកិច្ចព្រមព្រៀងនៅក្នុងរដ្ឋាភិបាល។ ការមូលមតិវិវឌ្ឍលើបញ្ហាស្រួចស្រាល់ទាំងនេះ ដែលកំណត់ការគ្រប់គ្រងធនធានសមស្រប និងបញ្ហាវិភាជន៍កាន់តែមានលក្ខណៈច្បាស់លាស់បន្ថែមទៀត។

# ច. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ

**រដ្ឋាភិបាលនៅតែប្តេជ្ញាចិត្តអនុវត្តតាមផែនការសកម្មភាពពិស្តារ និងបានរៀបចំតាមលំដាប់លំដោយដើម្បី "ពង្រឹងអភិបាលកិច្ច" តាមរយៈការលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។** គប្បីបន្តប្រឹងប្រែងពង្រឹងសមិទ្ធកម្មនានានៅជំហានទីមួយ ។ជំហានទីពីរ ពង្រីកកំណែទម្រង់នានា និងសំដៅប្រគល់ការទទួលខុសត្រូវកាន់តែធំលើផ្នែកថវិកាទៅកាន់អ្នកគ្រប់គ្រងកម្មវិធី តាមរយៈការលើកកម្ពស់យន្តការត្រួតពិនិត្យផ្ទៃក្នុង និងយន្តការគណនេយ្យភាព។ ចាំបាច់ត្រូវមានអភិក្រមមួយដែលមានការថ្លឹងថ្លែង និងរៀបចំលំដាប់លំដោយហ្មត់ចត់ ដើម្បីកែលំអបរិយាកាសត្រួតពិនិត្យផ្ទៃក្នុង ហើយទន្ទឹមជាមួយនោះធ្វើវិសហមជ្ឈការការត្រួតពិនិត្យ និងការទទួលខុសត្រូវទៅឱ្យនាយកដ្ឋាននានា នៃក្រសួងពាក់ព័ន្ធ និងអាជ្ញាធរ ព្រមទាំងអង្គភាពនានានៅថ្នាក់ក្រោមជាតិ។ ការមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តសាកល្បង និងធ្វើតេស្តដំណើរការ និងនីតិវិធីនានា ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការកសាងសមត្ថភាព និងការចូលរួមជាមួយក្រសួងពាក់ព័ន្ធ នឹងជួយធានាឱ្យមានការទទួលយក និងទទួលជោគជ័យនៅគ្រប់កម្រិតនៃរដ្ឋាភិបាល។ "សំណើ ៣ + ២" គឺជាជំហានមួយក្នុងទិសដៅត្រឹមត្រូវ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តផ្តល់ភាពជាអ្នកដឹកនាំចាំបាច់ ដើម្បីធានាដល់ជោគជ័យរួមនៃគម្រោងប្រព័ន្ធព័ត៌មាន គ្រប់គ្រងហិរញ្ញវត្ថុ។ ការឈានចូលទៅជំហានទីបី សកម្មភាពគប្បីប្រព្រឹត្តិទៅតែក្នុងករណីណាដែលភាពជឿទុកចិត្តនៃថវិកា ត្រូវបានលើកកម្ពស់បន្ថែមទៀត និងមាននិរន្តរភាព ព្រមទាំងសម្រេចបានដោយជោគជ័យនូវការពង្រីកការអនុវត្តបន្តនូវការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុនេះ។

**រដ្ឋាភិបាលស្នើឱ្យពិចារណាអនុសាសន៍ខាងក្រោម ដើម្បីជួយសម្រេចឱ្យបាននូវគោលដៅកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានលើកឡើង។**

**ក្នុងរយៈពេលខ្លី វិធានការសម្រាប់ធ្វើឱ្យជំនឿទុកចិត្តចំពោះថវិកាមាននិរន្តរភាព ជាវិធានការដែលពាក់ព័ន្ធនឹងការពង្រឹងបន្ថែមនូវសកម្មភាពនានានៅក្នុងជំហានទីមួយ :**

- **បង្កើត និងអនុវត្តផែនការសកម្មភាពចំពោះយុទ្ធសាស្ត្រកៀរគរចំណូលដែលបានអនុម័តថ្មីៗ ដើម្បីពង្រីកលំហសារពើពន្ធ។** ណែនាំឱ្យស្គាល់ និងអនុវត្តរបបវិក្កយបត្រជាតិ ដែលគ្រោងប្រកាសដាក់ឱ្យដំណើរការនៅដើមឆ្នាំ ២០១១។
- **ពង្រឹងបន្ថែមនូវការគ្រប់គ្រងសាច់ប្រាក់ និងគណនីធនាគារ រាប់ទាំងការព្យាករណ៍លំហូរសាច់ប្រាក់ និងការកសាងផែនការសាច់ប្រាក់ផងដែរ។** ពង្រីកការប្រើប្រាស់ធនាគារចំពោះប្រតិបត្តិការរបស់រដ្ឋាភិបាលទៅកាន់បណ្តាខេត្តទាំងអស់។ ពិចារណាសាជាថ្មីនូវការប្រគល់អំណាចជុំវិញ "គណនីរដ្ឋបាល" នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ។
- **អនុម័ត និងអនុវត្តច្បាប់លទ្ធកម្មថ្មី។** ការឈានទៅរកសមាហរណកម្មប្រព័ន្ធលទ្ធកម្មសាធារណៈនៅថ្នាក់ជាតិ នៅក្រោមស្ថាប័ននិយ័តកម្ម ដើម្បីធានាឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**ជាមួយគ្នានេះ ការឈានឆ្ពោះទៅកាន់គណនេយ្យភាពហិរញ្ញវត្ថុ នឹងរួមមានការជំរុញសកម្មភាពសំខាន់ៗនៃជំហានទីពីរ :**

- **រៀបចំ និងអនុវត្តផែនការសកម្មភាពអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ដែលកំណត់បានច្បាស់លាស់ និងដែលត្រូវបានធ្វើសមាហរណកម្ម គួសបញ្ជាក់ដោយបន្ទាត់គណនេយ្យភាពដែលទើបបានបង្កើតថ្មី ការអនុវត្តថវិកា និងក្រុមស្តង់ដារហិរញ្ញវត្ថុ។** គប្បីមានផែនការបែបនេះ ដែលប្រមូលផ្តុំក្រុមការងារទាំងបីនេះជាមួយគ្នា (បន្ទាត់គណនេយ្យភាព ស្តង់ដារគណនេយ្យ និងការអនុវត្តថវិកា) នៃគណៈកម្មាធិការដឹកនាំប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ហើយវឌ្ឍនភាពខ្លាំងក្លានឹងកើតមាននៅពេលផ្តល់កិច្ចសន្យាដោយប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុនេះ។ ជាមួយគ្នានេះផងដែរ ផែនការនេះក៏គប្បីដាក់បញ្ចូលនូវផែនទីចង្អុលផ្លូវ ដែលបង្ហាញអន្តរកាលពីអភិក្រមផ្តោតលើរតនាគារ ទៅកាន់ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុអនុវត្តទូទៅ ដែលផ្តល់នូវការគ្រប់គ្រងហិរញ្ញវត្ថុបានកាន់តែប្រសើរ និងគណនេយ្យភាពចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងពាក់ព័ន្ធ។ កាលវេលាសម្រាប់អនុវត្តកម្មវិធីទាំងមូល គប្បីរៀបចំឡើងវិញ។

- **លើកកម្ពស់ការចូលរួម និងបង្កើនសមត្ថភាពរបស់អាជ្ញាធរជាតិសវនកម្មក្នុងការធ្វើសវនកម្មផ្ទៃក្រៅ និងលើកកម្ពស់ការត្រួតពិនិត្យ និងការចូលរួមរបស់នីតិបញ្ញត្តិ។** ដោយសារមានម្ចាស់ជំនួយមួយចំនួនកំពុងគាំទ្រ ឬគ្រោងផ្តល់ការគាំទ្រអាជ្ញាធរជាតិ សវនកម្ម ការឧបត្ថម្ភគាំទ្រ ត្រូវតែធ្វើការសម្របសម្រួល ហើយគប្បីមានកិច្ចព្រមព្រៀងលើប្រភេទនៃការឧបត្ថម្ភគាំទ្រ (ដោយផ្អែកលើអនុសាសន៍នៃការពិនិត្យឡើងវិញរបស់ស្ថាប័នក្នុងចង្កោមដូចគ្នា)។
- **រៀបចំ និងអនុវត្តកម្មវិធីគាំទ្ររតនាគារគ្រប់ជ្រុងជ្រោយ ដើម្បីសម្រួលការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ធ្វើឱ្យមាននិរន្តរភាព និងលើកកម្ពស់ការគ្រប់គ្រងសាច់ប្រាក់ និងចលនាឈានទៅសម្របតាមស្តង់ដារ ស្តង់ដារគណនេយ្យអន្តរជាតិវិស័យសាធារណៈ (IPSAS)។**
- **បន្តកសាងសមត្ថភាពចំពោះកម្មវិធីរយៈពេលខ្លី និងវែង រួមមាន តាមរយៈកម្មវិធីសហការ សហប្រតិបត្តិការទ្វេភាគី និងពហុភាគី។** បង្កើតឱ្យមានកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីផ្តល់វិញ្ញាបនបត្រចំពោះគណនេយ្យសវនកម្មផ្ទៃក្នុង និងលទ្ធកម្ម។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១. ចំណុចដៅនានានៃ ផយអជ ឆ្នាំ ២០០៦-២០១០ និងគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សកម្ពុជា

| | | ២០០៥ | ២០០៨ | ២០១០ | CMDG-២០១៥ |
|---|---|---|---|---|---|
| | **លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន (*)** | | | | |
| ១* | កម្រិតនៃភាពក្រីក្រ - ភាគរយនៃចំនួនប្រជាជន | ៣៤,៧ | ៣០,១ | ២៥ | ១៩,៥ |
| ២* | កម្រិតនៃភាពក្រីក្រ - ភាគរយនៃប្រជាជនជនបទ | ៣៩,២ | ៣៤,៧ | | |
| ៣* | អ្នកនៅក្រោមបន្ទាត់នៃភាពក្រីក្រផ្នែកស្បៀងអាហារ - ភាគរយនៃប្រជាជន | ១៩,៧ | ១៨ | ១៣ | ១០ |
| | **បង្កើនផលិតកម្ម និងផលិតភាពកសិកម្ម** | | | | |
| ៤ | ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | ១,៩៧ | ២,៧៤ | ២,៨ | ៣,០ |
| ៥ | តំបន់ចម្រុះ - រាប់ទាំងការស្រោចស្រពបន្ថែម (ភាគរយ នៃផ្ទៃដីធ្វើស្រែ) | ២០ | - | ៣៣,៥ | |
| ៦ | កំណែទម្រង់ដីធ្លី : បណ្ណកម្មសិទ្ធដីធ្លីផ្តល់ឱ្យកសិករ - ភាគរយនៃដីកសិកម្មសរុប | ១២ | ២០ | ២៤ | |
| | **ការលើកកម្ពស់សុខភាព (*)** | | | | |
| ៧* | អត្រាស្លាប់របស់ទារកក្នុង ១.០០០ កំណើតរស់ | ៦៦ | ៦៦ | ៦០ | ៥០ |
| ៨* | អត្រាស្លាប់កុមារអាយុលើស ៥ ឆ្នាំ ក្នុង ១.០០០ កំណើតរស់ | ៨២ | ៨២ | ៧៥ | ៦៥ |
| ៩* | ការស្លាប់របស់ម្តាយក្នុង ១០០.០០០ កំណើតរស់ | ៤៧៣** | ៤៦១*** | ៣៥០ | ២៥០ |
| ១០* | ការសម្រាលកូនដោយបុគ្គលិកជំនាញដែលបានទទួលការបណ្តុះបណ្តាល - ភាគរយ | ៤៤** | ៥៨ | ៧០ | ៨៧ |
| ១១* | ប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ ភាគរយនៃមនុស្សពេញវ័យ ១៥-៤៨ ឆ្នាំ | ១,០ | ០,៧ | ០,៧ | <០,៦ |
| ១២* | ករណីគ្រុនចាញ់ - ការស្លាប់ក្នុង ១០០.០០០ ករណី | ២,៧០ | ២,១០ | ១,២០ | ០,៧៨ |
| ១៣* | ករណីកំហាករបេងវិជ្ជមានក្នុង ១០០.០០០ កំហាក | ៦៧៦ | ៦១៧ | ៥៦៤ | ៤៦៤ |
| ១៤* | ស្ត្រីមានគ្រួសារដែលបានប្រើវិធីពន្យារកំណើតបែបទំនើប (ភាគរយ) | ២០,១ | ២៦ | ៤០ | ៦០ |
| | **ការលើកកម្ពស់អាហារូបត្ថម្ភ** | | | | |
| ១៥ | ភាគរយនៃទារកអាយុពី ០-៥៩ ខែ ដែលមិនសូវលូតលាស់ តិចតួច ឬក្រិនធ្ងន់ធ្ងរ (កម្ពស់ធៀបនឹងអាយុច្រើនជាងកម្រិតល្បៀង ២ ក្រោមកម្រិតធម្មតា) | ៣៧ | ៣៩,៥ | ២៨ | ២២ |
| ១៦ | ភាគរយនៃទារកមានអាយុពី ០-៥៩ ខែ ដែលស្គមតិចតួច ឬស្គមខ្លាំង (កម្ពស់ធៀបនឹងអាយុច្រើនជាងកម្រិតល្បៀង ២ ក្រោមកម្រិតធម្មតា) | ៧ | ៨,៩ | ១០ | ៩ |
| ១៧* | ភាគរយនៃស្ត្រីអាយុ ១៥-៤៩ ឆ្នាំ ដែលស្លេកស្លាំង | ៤៧ | គ្មាន | ៣២ | ១៩ |

| | | | | | |
|---|---|---|---|---|---|
| ១៨ | ភាគរយ នៃទារកមានអាយុពី ០-៥៩ ខែ ដែលស្លេកស្លាំង | ៦២ | គ្មាន | ៥២ | ៤២ |
| | **ការលើកកម្ពស់ការអប់រំ (*)** | | | | |
| ១៩* | ការចុះឈ្មោះចូលរៀនសុទ្ធ : សាលាបឋមសិក្សា - សរុប, សិស្សប្រុស, សិស្សស្រី - ភាគរយ | ៩១,៩-៩៣,០-៩០,៧ | ៩៤,៤-៩៤,៨-៩៤,០ | ៩៦,០-៩៥,៥-៩៦,០ | ១០០ សម្រាប់ទាំងអស់គ្នា |
| ២០* | ការចុះឈ្មោះចូលរៀនសុទ្ធ : មធ្យមសិក្សាបឋមភូមិ - សរុប, សិស្សប្រុស, សិស្សស្រី - ភាគរយ | ២៦,១-២៧,១-២៤,៨ | ៣៣,៩-៣២,០-៣៥,០ | ៤៣,០-៤១,០-៤៥,០ | ១០០ |
| ២១* | អត្រារៀនចប់ថ្នាក់ទី ៦ - ភាគរយ | ៥៣,១ | ៨៥,៦ | ៨៨ | ១០០ |
| ២២* | អត្រារៀនចប់ថ្នាក់ទី ៩ - ភាគរយ | ៣០,១៨ | ៤៩,១ | ៥៣ | ១០០ |
| ២៣* | អាយុ ៦-១៤ ឆ្នាំ នៅក្រៅសាលារៀន (ភាគរយ) | ១៨,៧ | ១៧ | ១៥ | ១០ |
| | **អភិវឌ្ឍន៍ជនបទ** | | | | |
| ២៤ | ផ្លូវជនបទដែលបានស្តារនីតិសម្បទា - Kames (គ.ម.?) (ធៀបនឹងប្រវែងសរុប ២៨.០០០ គ.ម.?) | ២២,៧០០ | ២៤.១៤០ | ២៦.៦៥៨ | ៣២.០០០ |
| ២៥* | មានទឹកសុវត្ថិភាពប្រើ - ភាគរយនៃប្រជាជនជនបទ | ៤១,៦ | ៤០,៤៩ | ៤៣,៤៩ | ៥០,០៩ |
| ២៦* | មានអនាម័យ - ភាគរយនៃប្រជាជនជនបទ | ១៦,៤ | ២៣,២៤ | ២៥ | ៣៣ |
| | **និរន្តរភាពបរិស្ថាន (*)** | | | | |
| ២៧* | គម្របព្រៃ - ភាគរយនៃផ្ទៃសរុប | ៦០ | ៥៩,០៩ | ៥៧,៩៩ | ៦០ |
| ២៨* | ភាពពឹងផ្អែកលើអុស : គ្រួសារ - ភាគរយ | ៨៣,៩ | ៧៣ | ៦១ | ៥២ |
| ២៩* | មានប្រភពទឹកសុវត្ថិភាព - ភាគរយនៃប្រជាជនទីក្រុង | ៣៥១ | ៥១ | ៧៥១ | ៨០ |
| ៣០* | មានអនាម័យប្រសើរជាងមុន - ភាគរយនៃប្រជាជនទីក្រុង | ៥៥ | - | ៦៧ | ៧៤ |
| | **សមធម៌យេនឌ័រ (*)** | | | | |
| ៣១* | បញ្ជ្រាបយេនឌ័រនៅគ្រប់វិស័យ | | | | |
| a | ចំនួនក្រសួង, ស្ថាប័នដែលបានបង្កើតផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ | ២ | ១៥ | ២០ | ២៧ |
| b | ចំនួនក្រសួង, ស្ថាប័នដែលបានអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ | ២ | ១០ | ១៥ | ២៧ |
| ៣២* | ចំណែកប្រាក់ខែការងារស្ត្រី - កសិកម្ម ឧស្សាហកម្ម សេវាកម្ម (ភាគរយ) | ៥២,៥-៥៣,៥-២៧,០ | ៥២,៥-៥៣,៥-២៧,០ | ៥០-៥០- ៣៧ | ៥០- ៥០- ៥០ |
| ៣៣* | កម្រិតនៃការយល់ដឹងថាអំពើហិង្សាប្រឆាំងស្ត្រី គឺជាឧក្រិដ្ឋកម្ម (ភាគរយ) | ៤,៥ | ៣០ | ៥០ | ៧០ |
| a | ចំនួនលិខិតបញ្ជាការពារដែលចេញដោយតុលាការផ្អែកលើច្បាប់ស្តីពីការបង្ការអំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ | ០ | គ្មាន | ៤០ | ១២០ |
| b | ចំនួនជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលបានទទួលការប្រឹក្សាពីបុគ្គលិកមានគុណវុឌ្ឍិ | ០ | ៦០០ | ៩០០ | ២០០០ |

| | | | | | |
|---|---|---|---|---|---|
| | **កំណែទម្រង់នានា** | | | | |
| ៣៤ | បង្កើនល្បឿនកំណែទម្រង់អភិបាលកិច្ច | ត្រូវរៀបចំ | | | |
| | **ធ្វើឱ្យកំណើនម៉ាក្រូសេដ្ឋកិច្ចមានកម្រិតខ្ពស់ (*)** | | | | |
| ៣៥ | កំណើន ផសស ប្រចាំឆ្នាំតាមថ្លៃថេរ - ភាគរយ | ១៣,៣ | ៦,៧ | ៣,០ | |
| ៣៦ | ផសស ក្នុងម្នាក់ៗតាមថ្លៃថេរ (០០០ រៀល) | ១.៤០០ | ២.៩៩៨ | ៣.២៨៤ | |
| ៣៧ | អត្រាអតិផរណា គិតជាភាគរយ | ៦,២ | ១៩,៧ | ៦,០ | |
| | **បង្កើនលទ្ធផលថវិកា** | | | | |
| ៣៨ | ថវិកាចំណូលថវិកាសរុបរបស់រដ្ឋាភិបាល - ភាគរយនៃ ផសស | ១១,៨០ | ១៣,៣ | ១២,៦ | |
| ៣៩ | ចំណាយថវិកាសរុបរបស់រដ្ឋាភិបាល - ភាគរយនៃ ផសស | ១៤,៩ | ១៥,៧ | ១៥,៤ | |
| | **ចំណុចដៅ សូចនាករ បង្កើនកំណើនឧស្សាហកម្ម និងឱកាសការងារ** | | | | |
| ៤០ | កំណើនប្រចាំឆ្នាំក្នុងផ្នែកកម្មន្តសាលតាមថ្លៃថេរ (ភាគរយ) | ១០,២ | ៣,១ | ១៤,២ | |
| ៤១* | កុមារធ្វើការអាយុពី ៥-១៧ ឆ្នាំ - ភាគរយ | ២២,៣ | - | ១០,៦ | ៨ |
| | **ទេសចរណ៍** | | | | |
| ៤២ | Annual ការមកដល់នៃភ្ញៀវទេសចរណ៍ប្រចាំឆ្នាំ (រយពាន់នាក់) | ១.៤២១ | ២.១២៥ | ២.២៧៦ | ៤.៤៥០ |
| | ការដោះមីន ការផ្តល់ជំនួយដល់ជនរងគ្រោះ (*) | | | | |
| ៤៣* | ចំនួនគ្រោះថ្នាក់ (ស្លាប់ និងរបួស) | ៧៩៧ | ២៧១ | ២១២ | ១២៥ |
| ៤៤* | ផ្ទៃដីមានគ្រាប់មីន និងកាកសំណល់ពីសង្គ្រាម ដែលបានបោសសំអាត - ភាគរយ | ៣០ | ៤៨ | ៥៨ | ៨៧ |
| | **ហេដ្ឋារចនាសម្ព័ន្ធ** | | | | |
| ៤៥ | ប្រវែងផ្លូវថ្នល់ដែលបានក្រាលថ្ម (ផ្លូវមេ និងផ្លូវលំ) ក្នុងប្រវែង ១១.៦១៨ គ.ម | ២.១០០ | ២.១៨៦ | ២.៩៨០ | ៤.១០០ |
| | **ថាមពល** | | | | |
| ៤៦ | ការប្រើថាមពលអគ្គិសនីក្នុងម្នាក់ៗ - គីឡូវ៉ាត់ម៉ោង | ៥៤ | ១៣៩ | ១៥៣ | ៣៥០ |

*ប្រភព :* អង្កេត CDHS ឆ្នាំ ២០០៥-ជំរឿនប្រជាជនឆ្នាំ ២០០៨-និងការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិឆ្នាំ ២០០៨
*សំគាល់ :* គោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សកម្ពុជាត្រូវបានសំគាល់ដោយ *

## ឧបសម្ព័ន្ធ ២. រដ្ឋាភិបាល ហិរញ្ញប្បទានទូទៅរបស់រដ្ឋាភិបាលតាមចំណាត់ថ្នាក់មុខងារ
(គិតជា លានដុល្លារអាមេរិក)

| | មុខងារ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩e |
|---|---|---|---|---|---|---|---|---|---|---|
| ១ | រដ្ឋាភិបាលស្នូល | ២១៥ | ២៣១ | ១៨៦ | ១៧១ | ២០១ | ២៨០ | ៣៥៥ | ៤១២ | ៧៦៨ |
| ១.១ | រដ្ឋបាលទូទៅ និងតុលាការ | ១០៩ | ១២៧ | ៨៣ | ៦៣ | ៩០ | ១៩៣ | ២០២ | ២១៦ | ៤២៣ |
| ១.២ | ការពារជាតិ | ៧១ | ៦៨ | ៦៨ | ៦៨ | ៧១ | ៨០ | ៩២ | ១២៣ | ២៣៤ |
| ១.៣ | សន្តិសុខជាតិ | ៣៦ | ៣៦ | ៣៦ | ៤១ | ៤០ | ៤៨ | ៦១ | ៧២ | ១១០ |
| ២ | សេវាសេដ្ឋកិច្ច | ៩៦ | ១៤២ | ១៤៨ | ១៥៩ | ១៨២ | ២៩០ | ២៦៤ | ៣៩៤ | ៤៩២ |
| ២.១ | កសិកម្ម | ២១ | ២២ | ១៨ | ២៤ | ១២ | ១០៨ | ៣៤ | ៤២ | ៦៧ |
| ២.២ | ដឹកជញ្ជូន | ៦៣ | ៧៩ | ៦៦ | ៩១ | ៨៩ | ៧៣ | ១២៧ | ១៨៧ | ២៤៨ |
| ២.៣ | សេវាសេដ្ឋកិច្ចដទៃទៀត | ១៣ | ២៩ | ៤៩ | ២៦ | ៧១ | ៩៩ | ១០៥ | ១៦៧ | ១៧០ |
| ២.៤ | បរិស្ថាន | ២ | ១៧ | ២០ | ២២ | ១៥ | ១៧ | ៧ | ៦ | ៧ |
| ៣ | អភិវឌ្ឍន៍ជនបទ | ៤៣ | ៣០ | ១១ | ៤៩ | ៣២ | ៣៩ | ៦០ | ៥៨ | ៦៣ |
| ៤ | សេវាសង្គម | ២២៨ | ២៤៦ | ២៧៦ | ២៦១ | ២៨២ | ៣៦០ | ៤១០ | ៤២៦ | ៤៩០ |
| ៤.១ | សុខាភិបាល | ៥៨ | ៦៥ | ៧៦ | ៩១ | ១៣៧ | ១៥៧ | ១៧៨ | ២០៤ | ២៥៧ |
| ៤.២ | អប់រំ | ៦៤ | ១០៥ | ១០៧ | ១១០ | ១០៨ | ១៤៥ | ១៦៥ | ១៦៤ | ២១៤ |
| ៤.៣ | សេវាសង្គមដទៃទៀត | ១០៦ | ៧៦ | ៩៣ | ៦០ | ៣៧ | ៥៨ | ៦៧ | ៥៨ | ១៩ |
| ៥ | ក្រៅពីនេះ | ១២១ | ១៣៦ | ២០៧ | ១៣១ | ១៤៧ | ១១៦ | ១៩៦ | ៤០៥ | ២១៧ |
| ៦ | ជំនួយសង្គ្រោះបន្ទាន់ឱ្យ និងស្បៀងអាហារ | - | - | - | - | ៣ | ០ | ០ | ០ | ១ |
| | **សរុប** | **៧០៣** | **៧៨៥** | **៨២៨** | **៧៧១** | **៨៤៦** | **១.០៨៥** | **១.២៨៥** | **១.៦៩៥** | **២.០៣២** |
